# ប្រទេសដាក់លក់

ស្វាគមន៍នៅប្រទេសកម្ពុជា

## របៀបដែលពួកវរជនកម្ពុជាបានចាប់ក្តាប់ ឧស្សាហកម្មដកស្រង់ធនធានរបស់ប្រទេស

global witness




## សទ្ទានុក្រមនៃពាក្យសំខាន់ៗ

**ឧស្សាហកម្មដកស្រង់** – សម្រាប់គោលបំណងនៃរបាយការណ៍នេះ ឧស្សាហកម្មដកស្រង់ ត្រូវបានកំណត់និយមន័យ ជាឧស្សាហកម្មប្រេង ឧស្ម័ន និងរ៉ែ។

**ចោរធិបតេយ្យ** – ប្រភេទនៃអភិបាលកិច្ច មានលក្ខណៈពុករលួយនៅថ្នាក់ខ្ពស់ ហើយនិងការប្លន់ថវិការបស់រដ្ឋ សម្រាប់គោលបំណងបង្កើនទ្រព្យសម្បត្តិផ្ទាល់ខ្លួន និងអំណាចនយោបាយ នៃវណ្ណៈកាន់អំណាច។

**រដ្ឋស្រមោល**[1] – រដ្ឋមួយ ដែលអំណាចត្រូវបានប្រើប្រាស់ជាមធ្យោបាយដើម្បីបង្កើនទ្រព្យសម្បត្តិផ្ទាល់ខ្លួន របស់បុគ្គលកាន់អំណាច ហើយស្ថាប័នរបស់រដ្ឋ ត្រូវបានធ្វើវិទ្ធង្សនា ដើម្បីគាំទ្រដល់សេចក្ដីត្រូវការទាំងនោះ។ នៅពីក្រោយច្បាប់ និងស្ថាប័នរដ្ឋាភិបាលរបស់រដ្ឋបែបនេះ មានប្រព័ន្ធស្របមួយ នៃការកាន់អំណាចផ្ទាល់ខ្លួន។ អ្នកដឹកនាំនៃរដ្ឋបែបនេះ ជាធម្មតាអាចធ្វើអាជីវកម្មលើធនធានសាធារណៈនៃប្រទេសខ្លួនឯង ជាពិសេសធនធានធម្មជាតិ តាមរយៈការធ្វើវិទ្ធង្សនានូវស្ថាប័នការិយាធិបតេយ្យ ហើយនិងអំណាចផ្ដាច់មុខលើការប្រើប្រាស់កម្លាំងហិង្សា។ តាមរបៀបនេះ ពួកគេអាចបង្កើនទ្រព្យសម្បត្តិខ្លួនឯង ហើយទិញមធ្យោបាយដើម្បីរក្សាអំណាចរបស់ខ្លួន។

សទ្ទានុក្រមនៃពាក្យសំខាន់ៗ

ផែនទី

មាតិកា

អនុសាសន៍

សេចក្ដីសង្ខេប

ជំពូកទី ១៖ ឧស្សាហកម្មដកស្រង់របស់ប្រទេសកម្ពុជា – មានរង្វាន់ថ្លៃ

ធនធានរ៉ែ – លំនាំដើម

ប្រេង និងឧស្ម័ន – លំនាំដើម

ប្រទេសកម្ពុជាសព្វថ្ងៃនេះ៖ ពីការពិសោធន៍ប្រជាធិបតេយ្យ ទៅជាចោរធិបតេយ្យគណបក្សតែមួយវិញ

ប្រអប់ទី១៖ ឈើខ្លះខ្លាយ – មេរៀននៃការកាប់ឈើខុសច្បាប់

ប្រអប់ទី ២៖ ការវិនិយោគលើដីធ្លី នៅក្នុងប្រទេសកម្ពុជា – ដូចជាការប្លន់អញ្ចឹង!

ដំណើរការ គឺជាការសំខាន់៖ ហេតុអ្វីបានជាការចែករំលែកសម្បទាន នៅក្នុងប្រទេសកម្ពុជា ជាការសំខាន់

ជំពូកទី ២៖ អាជីវកម្មរ៉ែ

ផែនទីបង្ហាញពីសកម្មភាពអាជីវកម្មរ៉ែ ដែលត្រូវបានគេដឹង នៅក្នុងប្រទេសកម្ពុជា

ការដាក់កម្រិតលើអាជីវកម្មរ៉ែ នៅក្នុងប្រទេសកម្ពុជា

អាជ្ញាប័ណ្ណដើម្បីខ្លួង?

អ្នកណាជាម្ចាស់ដី?

ការផ្ដល់ព័ត៌មាន

"តំបន់អភិរក្ស គឺមិនមែនបំពាន់អត់បាននោះទេ"

ប្រអប់ទី ៣៖ ការធ្វើអាជីវកម្មរ៉ែ នៅក្នុងឧទ្យានជាតិវីរៈជ័យ

ផ្សុរតនៈ–អណ្ដូងរ៉ែ ខិននីតិក

ប្រអប់ទី ៤៖ តើសិទ្ធិអាជីវកម្មរ៉ែ ថ្លៃប៉ុន្មាន?

អណ្ដូងរ៉ែ ហុងហ្វ៊ូ-ទ្រី ភាព

ប្រអប់ទី ៥៖ អាជីវកម្មនៃក្រុមហ៊ុនភាពីម៉ិច

ក្រុមហ៊ុនរ៉ែ សារធើន
ឧទ្យានុរក្ស ត្រូវបានឃាត់
ទាហានខ្មែរ ម្ចាស់វៀតណាម?
ប្រអប់ទី ៦៖ តួនាទីនៃកងយោធពលរបស់ប្រទេសកម្ពុជា នៅក្នុងការលួចប្លន់ធនធានសាធារណៈ
ក្រុមហ៊ុន Float Asia Friendly Mation
ប្រអប់ទី ៧៖ ការត្រលប់មកវិញ នៃលោក ឌី ចូច
ខ្សាច់កោះកុង
លោក លី យ៉ុងផាត់ និងឧស្សាហកម្មខ្សាច់
ប្រអប់ទី ៨៖ សិង្ហបុរី – ដីខ្សាច់ និងការចាក់ពង្រីកដី
ខ្សែរយៈ ចម បូរី
តារាងទី ១៖ ភាគីសំខាន់ៗ នៅក្នុងវិស័យឧស្សាហកម្មរ៉ែ របស់ប្រទេសកម្ពុជា

# ជំពូកទី ៣៖ ប្រេង និងឧស្ម័ន

ក្របខណ្ឌច្បាប់ និងនីតិវិធី
ការផ្ទេរអំណាច
ប្រអប់ទី ៩៖ ឯកឧត្តម សុខ អាន
ការគ្រប់គ្រងវិស័យប្រេង និងឧស្ម័នរបស់ប្រទេសកម្ពុជា៖ ករណីច្បាប់កិច្ចព្រមព្រៀង ឬ?
តារាងទី ២៖ ថ្លៃទារនៅក្នុងកិច្ចព្រមព្រៀងប្រេងកាតព្រាង របស់រដ្ឋាភិបាលកម្ពុជា
រចនាសម្ព័ន្ធនៃ CNPA៖ ការបាក់បែកផ្ទៃក្នុង...
តារាងទី ៣៖ រចនាសម្ព័ន្ធ នៃអាជ្ញាធរប្រេងកាតជាតិកម្ពុជា
ប្រអប់ទី ១០៖ នយោបាយថ្ងៃបើកប្រាក់ខែ
លំហូរព័ត៌មាន?
វគ្គដេញថ្លៃ ហើយនិងការចែកកិច្ចព្រមព្រៀងចែកចាយផលិតកម្ម
ប្រអប់ទី ១១៖ អ្នកថ្មីចូលប្លុក ឬ?
តើអ្នកណាឈរពីក្រោយឈ្មោះ? ការចែករំលែកសម្បទានប្រេង និងឧស្ម័ន នៅក្នុងប្រទេស កម្ពុជា
ផែនទីនៃសម្បទានប្រេង និងឧស្ម័ន ដែលត្រូវបានគេដឹង នៅក្នុងប្រទេសកម្ពុជា
ប្លុក A
ប្រអប់ទី ១២៖ ក្រុមហ៊ុន សេវរ៉ន់ – បញ្ហានៃតម្លាភាព
ប្លុក B
ប្លុក C
ប្លុក D
ប្លុក E
ប្លុក F

ប្លុក XII
ប្លុក X និង XV
ប្លុកផ្សេងៗទៀត
ប្រាក់រង្វាន់ចុះហត្ថលេខាក្នុងប្រទេសកម្ពុជា – 'អ្នកណាចុះហត្ថលេខា អ្នកនោះទទួលប្រាក់រង្វាន់'
ការស្វែងរុករកនៅលើដីគោក នៅក្នុងខេត្តបាត់ដំបង និងពោធិ៍សាត់

ជំពូកទី ៩៖ ទាយករបស់ប្រទេសកម្ពុជា – តើគេធ្វើការដើម្បីអ្នកណា?
ប្រអប់ទី ១៣៖ បាត់ខ្លួន – ច្បាប់ប្រឆាំងអំពើពុករលួយរបស់ប្រទេសកម្ពុជា
អនុម័ត ឬមិនអនុម័ត? គម្រោងជំរុញតម្លាភាពឧស្សាហកម្មដកស្រង់ (EITI)
តារាងទី ៤ ៖ របៀបដើម្បីចែកប្រាក់ ដោយនៅតែគ្មានអានុភាព
ការស្មុគស្មាញនៃភាពជាដៃគូ

សេចក្ដីសន្និដ្ឋាន

អក្សរកាត់

# អនុសាសន៍

## រាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា គួរតប្បីៈ

**ចាត់វិធានការជាបន្ទាន់ ដើម្បីអនុវត្ត ហើយប្រតិបត្តិ នូវការព្យួរទុកបណ្តោះអាសន្នមួយ លើការប្រគល់សម្បទានរ៉ែ ឬប្រេងកាតបន្ថែមទៀត រហូតដល់រដ្ឋាភិបាលបានបង្កើតនូវក្របខណ្ឌជាមូលដ្ឋាន ខាងផ្នែកច្បាប់ បរិស្ថាន និងសង្គម ដើម្បីគ្រប់គ្រងវិស័យប្រេង ឧស្ម័ន និងរ៉ែ ដោយសមល្មម។**

- ប្រមូលទិន្នន័យដ៏ល្អបំផុត ដែលអាចប្រមូលបាន ស្តីពីស្រទាប់ធនធាន ដើម្បីផ្តល់ឲ្យគ្រប់ក្រុមហ៊ុន នូវព័ត៌មានដដែលៗ ហើយធ្វើឲ្យប្រាកដថា មានការប្រកួតប្រជែងដ៏ស្មើគ្នា រវាងក្រុមហ៊ុនទាំងឡាយ។
- បង្កើតឲ្យហើយ នូវក្របខណ្ឌច្បាប់ជាតិ ដែលណែនាំការជីកស្រង់ធនធានរ៉ែ និងប្រេងកាត។
- បង្កើតហើយបោះពុម្ព នូវយុទ្ធសាស្ត្ររយៈពេលយូរ សម្រាប់ការធ្វើអាជីវកម្មលើមូលដ្ឋានធនធានរ៉ែរបស់ប្រទេស រួមទាំងផែនការណ៍ដើម្បីទប់ស្កាត់លទ្ធផលបន្ទាប់បន្សំដ៏មិនល្អ ខាងសង្គម ឬខាងបរិស្ថាន។
- បង្កើតទីភ្នាក់ងារសាធារណៈដ៏ឯករាជ ដើម្បីចែកសិទ្ធិប្រើធនធានទាំងនេះ។ ទីភ្នាក់ងារគួរតែមានជំនាញបច្ចេកទេសដ៏សមស្រប និងភាពស្របច្បាប់ ហើយត្រូវស្ថិតនៅក្រោមការវិភាគមើលរបស់សាធារណជន និងការត្រួតពិនិត្យពីរដ្ឋសភា។
- បង្កើយដំណើរការប្រគល់ប័ណ្ណកម្មសិទ្ធិដីសហគមន៍ជនជាតិដើមភាគតិច ជាការស្រេច។
- បង្ហើយដំណើរការបែងចែកកំណត់ព្រំដែន សម្រាប់តំបន់ការពាររបស់ប្រទេសកម្ពុជា ជាការស្រេច។

**ចាត់វិធានការជាបន្ទាន់ ដើម្បីពិនិត្យគ្រប់សម្បទាន ហើយលុបចោលកិច្ចព្រមព្រៀងសម្បទាន ប្រសិនបើសម្បទាននោះ មិនបំពេញតាមលក្ខខណ្ឌទាំងឡាយ ដែលចែងខាងក្រោមនេះ។ មានតែក្រុមហ៊ុនណា ដែលអាចឲ្យសាធារណជន ហើយនិងរដ្ឋាភិបាល នូវភស្តុតាងជាក់ស្តែង អំពីសមត្ថភាពរបស់ខ្លួនប៉ុណ្ណោះ ទើបគួរអនុញ្ញាតឲ្យចាប់ផ្តើម ឬបន្ត នូវការងារនៅក្នុងប្រទេសកម្ពុជា។ ភស្តុតាងនេះ គួរតែបញ្ជាក់ហេតុការណ៍ដូចតទៅនេះៈ**

- ឈ្មោះនៃគ្រប់អ្នកដែលកាន់ហ៊ុន នៅក្នុងក្រុមហ៊ុន ហើយដែលនឹងទទួលផលប្រយោជន៍ពីអាជីវកម្មនេះ ព្រមទាំងឈ្មោះនៃដៃគូគ្រប់រូប នៅក្នុងការដេញថ្លៃរបស់គេ។
- ប្រភពនៃថវិកា។
- បទពិសោធន៍នៅក្នុងវិស័យឧស្សាហកម្ម។
- សមត្ថភាពជាក់ស្តែង ខាងបច្ចេកទេស និងខាងហិរញ្ញវត្ថុ ដើម្បីធ្វើអាជីវកម្មជាមួយសិទ្ធិណាដែលត្រូវបានផ្តល់ឲ្យ ដោយស្របច្បាប់។
- សមត្ថភាពដើម្បីការពារបង្ការនូវថ្លៃខាងសង្គម ឬថ្លៃខាងបរិស្ថាន ហើយនិងការរៀបចំផែនការណ៍គ្រប់គ្រាន់ និងថវិកាគ្រប់គ្រាន់ ដើម្បីតបស្នងនិងការខូចខាតណា ដែលកើតមានឡើង។

**ចាត់វិធានការជាបន្ទាន់ ដើម្បីធ្វើឲ្យប្រាកដថា មានតម្លាភាព នៅក្នុងការចែករំលែកនូវធនធានប្រេង ឧស្ម័ន និងរ៉ែ**

- តម្រូវឲ្យមន្ត្រីរដ្ឋាភិបាលគ្រប់រូប សមាជិកសភាគ្រប់រូប និងអ្នកមានតំណែងយោធាខ្ពស់គ្រប់រូប បោះពុម្ពព័ត៌មានស្តីពីចំណែកហ៊ុនរបស់ខ្លួន និងរបស់សមាជិកគ្រួសារជិតស្និទ្ធ។
- ប្រគល់សិទ្ធិប្រើប្រាស់ប្រេង ឧស្ម័ន និងរ៉ែ ដោយដំណើរការដេញថ្លៃ ប្រកបដោយភាពបើកចំហ និងការប្រកួតប្រជែង ដើម្បីបញ្ជាក់ថា ប្រទេសកម្ពុជា ទទួលបានផលល្អបំផុត។ លក្ខខណ្ឌសម្រាប់ការផ្តល់សិទ្ធិដេញថ្លៃ ហើយសម្រាប់ការប្រគល់សម្បទាន និងអាជ្ញាប័ណ្ណ គួរតែផ្តល់ជូនឲ្យសាធារណជនមើលដោយសេរី។
- បោះពុម្ពគ្រប់កិច្ចព្រមព្រៀង សម្រាប់សិទ្ធិប្រើប្រាស់ប្រេង ឧស្ម័ន និងធនធានរ៉ែ ហើយនិងព័ត៌មានលំអិតស្តីពីការដេញថ្លៃដ៏បរាជ័យ នៅក្នុងរយៈពេលដ៏ឆាប់សមហេតុសមផល ក្រោយពីការដេញថ្លៃត្រូវបានបញ្ចប់ ហើយមុនកិច្ចព្រមព្រៀងចាប់ផ្តើមមានសុពលភាព។

**ចាត់វិធានការជាបន្ទាន់ ដើម្បីបង្កើនតម្លាភាព នៅក្នុងការគ្រប់គ្រងធនធានប្រេង ឧស្ម័ន និងរ៉ែ**

- ធ្វើឲ្យប្រាកដថា មានការបញ្ចេញឲ្យដឹងព័ត៌មាន ដោយពេញលេញ និងដោយបន្តបន្ទាប់ ស្ដីពីការគ្រប់គ្រងធនធានសាធារណៈ មានរួមទាំង ប៉ុន្តែមិនកំណត់ចំពោះព័ត៌មានអំពីស្រទាប់ប្រេង ឧស្ម័ន និងជាតុរ៉ែ។
- ធ្វើឲ្យប្រាកដថា ព័ត៌មាននេះមានរួមដូចតទៅនេះ៖ អ្នកប្រតិបត្តិ (ហើយនិងដៃគូគ្រប់រូប) នៃសម្បទាន ឬអាជ្ញាប័ណ្ណនីមួយៗ ព្រមទាំងទំហំ និងទីតាំងនៃសម្បទាន ហើយនិងព័ត៌មានលំអិតស្ដីការសន្យាដែលបានធ្វើឡើង សម្រាប់ការទទួលសិទ្ធិទាំងនោះ។
- តម្រូវឲ្យគ្រប់ក្រុមហ៊ុនដែលប្រតិបត្តិការ នៅក្នុងវិស័យសេដ្ឋកិច្ចធនធានធម្មជាតិរបស់ប្រទេសកម្ពុជា បោះពុម្ពព័ត៌មានដូចគ្នា។
- ហាមមិនសមាជិករដ្ឋាភិបាល ឬអ្នករាជការ ព្រមទាំងសមាជិកគ្រួសាររបស់អ្នកទាំងនោះ ជាម្ចាស់ហ៊ុននៃក្រុមហ៊ុនណាដែលចូលរួមនៅក្នុងវិស័យដកស្រង់ធនធាន ដោយមូលហេតុថា នេះជាទំនាស់ផលប្រយោជន៍មួយ។

## ធ្វើឲ្យប្រាកដថា មានការគ្រប់គ្រងលើផលចំណូលប្រេង ឧស្ម័ន និងជាតុរ៉ែ ដោយប្រើប្រាស់ក្បួនប្រតិបត្តិអន្តរជាតិដ៏ល្អបំផុត

- បោះពុម្ពព័ត៌មានអំពីប្រាក់រង្វាន់ចុះហត្ថលេខា និងការបង់ប្រាក់ផ្សេងទៀតទៅកាន់រដ្ឋាភិបាលកម្ពុជា ដោយក្រុមហ៊ុនដែលពាក់ព័ន្ធក្នុងវិស័យប្រេង ឧស្ម័ន និងរ៉ែ។
- អនុវត្ត Guide to Resource Revenue Transparency [*ក្បួនស្ដីពីតម្លាភាពផលចំណូលធនធាន*] របស់អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF)។
- អនុម័ត ហើយអនុវត្ត នូវ Extractive Industries Transparency Initiative [គម្រោងជំរុញតម្លាភាពឧស្សាហកម្មដកស្រង់] (EITI)។
- ការបង់ទឹកប្រាក់ទាំងអស់ ទាក់ទងនិងការដកស្រង់ធនធានគួរតែបង់ចូលក្នុងគណនីរដ្ឋាភិបាលតែមួយគណនី ដែលត្រូវបានត្រួតពិនិត្យជាទៀងទាត់ដោយភាគីឯករាជ ហើយដែលលទ្ធផលនៃការត្រួតពិនិត្យនេះ ត្រូវបានបើកឲ្យសាធារណជនមើល។

## សភាជាតិ នៃប្រទេសកម្ពុជា គួរតែ៖

**មានតួនាទីដ៏សកម្មឡើង នៅក្នុងអភិបាលកិច្ចលើធនធានធម្មជាតិរបស់ប្រទេស៖**

- ពិភាក្សា ហើយអនុម័ត ចំពោះគ្រប់លក្ខណៈនៃដំណើរការប្រគល់សិទ្ធិប្រេង រ៉ែ ដី និងព្រៃឈើ មុននឹងការប្រគល់សិទ្ធិនោះត្រូវបានធ្វើឡើងជាការស្រេច។ នៅពេលដែលដំណើរការនេះត្រូវបានពិភាក្សា និងអនុម័តហើយ ដំណើរការគួរតែអនុវត្តដោយស្មើគ្នា ចំពោះគ្រប់ក្រុមហ៊ុន ហើយមិនមែនប្រែប្រួលឡើយ លុះត្រាតែមានការអនុម័តបន្ថែមទៀត ដោយសភាជាតិសិន។
- ត្រួតពិនិត្យលើការបង្កើតច្បាប់ និងវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងធនធានធម្មជាតិរបស់ប្រទេសកម្ពុជា។

## ទាយកអន្តរជាតិរបស់ប្រទេសកម្ពុជា រួមទាំងប្រទេសចិន គួរតែ៖

**ទទួលស្គាល់ថា មានតំណភ្ជាប់ផ្ទាល់ រវាងអភិបាលកិច្ច និងលទ្ធផលអភិវឌ្ឍ ហើយប្រើប្រាស់ប្រាក់ជំនួយជាគំនាស់ដើម្បីកែលំអរដ្ឋាភិបាល**

- ចាត់វិធានការជាបន្ទាន់ ដើម្បីធ្វើឲ្យប្រាកដថា ការផ្ដល់ជំនួយក្រៅពីជំនួយមនុស្សធម៌ ត្រូវបានធ្វើឡើយ ក្រោយ មិនមែនមុនការរីកចម្រើនដ៏ជាក់ស្ដែង ក្នុងការអនុវត្តវិធានការចាំបាច់ ដើម្បីសម្រេចអភិបាលកិច្ចដ៏ល្អឡើង។

**ចាត់វិធានការជាបន្ទាន់ ដើម្បីរួមបញ្ចូល ហើយសម្របសម្រួល នូវផែនការជំនួយទាយក ជាមួយសេចក្ដីត្រូវការដ៏បន្ទាន់ ដើម្បីកែទម្រង់ ហើយពង្រឹងដល់អភិបាលកិច្ចវិស័យដកស្រង់ធនធានដ៏កំពុងលូតឡើង របស់ប្រទេសកម្ពុជា**

- ធ្វើឲ្យជំនួយនៅពេលអនាគត អាស្រ័យលើលក្ខខណ្ឌនៃការបំពេញអនុសាសន៍ទាំងឡាយដែលបានចែងខាងលើនេះ។
- បង្កើតក្រុមការងាររួម រវាងទាយក និងរដ្ឋាភិបាល ហើយបង្កើតសូចនាត្រួតពិនិត្យ អំពីឧស្សាហកម្មដកស្រង់របស់ប្រទេសកម្ពុជា នៅក្នុងដំណើរការ Cambodia Development Cooperation Forum [វេទិកាកិច្ចសហការអភិវឌ្ឍន៍កម្ពុជា] (CDCF)។
- ចំពោះវិស័យរ៉ែ ដៅបញ្ជាក់អំពីការកាប់ព្រៃឈើ និងការខូចខាតរយៈពេលយូរ ដែលកើតមកពីការធ្វើអាជីវកម្មរ៉ែ នៅក្នុងតំបន់

ការពារ និងតំបន់ជុំវិញព្រៃឡង់ ជាពិសេសនៅក្នុងគ្រានៃការផ្លាស់ប្ដូរអាកាសធាតុ។ ផ្ទុយវិញ សូមលើកស្ទួយការប្រើប្រាស់ដី និងធនធានបែបផ្សេង សំអាងលើជម្រើសខាងហិរញ្ញវត្ថុ ហើយនិងការអភិវឌ្ឍន៍ ដែលគាំទ្រជនក្រីក្រ។ ជម្រើសទាំងនេះ អាចមានរួមទាំងការអភិវឌ្ឍន៍សហគ្រាសប្រចាំសហគមន៍ ផលិតផលព្រៃក្រៅពីឈើ ការដកយកនិងទុកជាតុកាបូន ការបង់ប្រាក់សម្រាប់គុណភាពទឹក ហើយនិងការបង់ប្រាក់ផ្សេងទៀតសម្រាប់សេវាកម្មខាងបរិស្ថាន (PES) ប្រហែលនៅក្រោមក្របខណ្ឌនៃកម្មវិធីបន្ថយការបញ្ចេញជាតុកាបូន ពីប្រទេសមានការកាប់ និងការបង្ខូចព្រៃឈើ (REDD)។

**ធ្វើឲ្យប្រាកដថា កិច្ចប្រឹងប្រែងប្រឆាំងការពុករលួយ ត្រូវបានរួមបញ្ចូលជាមួយសកម្មភាពនៃគ្រប់កម្មវិធីផ្ដល់ជំនួយ ទាក់ទងនឹងប្រេងកាត និងជាតុរ៉ែ នៅក្នុងប្រទេសកម្ពុជា។**

- នេះគប្បីមានរួមនូវការគាំទ្រ ទាំងផ្លូវហិរញ្ញវត្ថុ និងផ្លូវនយោបាយ ឲ្យសង្គមស៊ីវិល បុគ្គលមានសមត្ថភាពនៅក្នុងស្ថាប័ន សមាជិករដ្ឋសភាព ប្រព័ន្ធផ្សព្វផ្សាយ ហើយនិងអ្នករួមចំណែក ឬដំណើរការពាក់ព័ន្ធណាផ្សេងទៀត។
- ការវិនិយោគជាបន្ថែម លើការយោគយល់ពីសេដ្ឋកិច្ចនយោបាយរបស់ប្រទេសកម្ពុជា។

**គាំទ្រសង្គមស៊ីវិលកម្ពុជា នៅ ក្នុងកិច្ចប្រឹងប្រែងដើម្បីបង្កើនតម្លាភាព និងការទទួលខុសត្រូវ នៅក្នុងការគ្រប់គ្រងធនធានសាធារណរបស់ប្រទេសកម្ពុជា**

- អនុម័ត ហើយអនុវត្ត ដោយសាធារណៈ នូវគោលនយោបាយមិនអធ្យាស្រ័យសោះ ចំពោះអំពើហិង្សាឧបត្ថម្ភដោយរដ្ឋ ឬការគំរាមកំហែងប្រឆាំងនឹងសកម្មជន ឬអង្គការសង្គមស៊ីវិល។
- បង្កើតប្រព័ន្ធឆ្លើយតប ដើម្បីគាំទ្រសមាជិកសង្គមស៊ីវិល ដែលត្រូវបានគំរាមកំហែងដល់ជីវិត ឬអង្គការដែលប្រឈមមុខនឹងការបង្ខំបិទ ដោយសារការងារទាក់ទងនឹងតម្លាភាព និងការទទួលខុសត្រូវ របស់រដ្ឋាភិបាល។
- ផ្ដល់ការគាំទ្រដល់សង្គមស៊ីវិល ដើម្បីកត់ទុកជាឯកសារ សង្កេត ហើយពិនិត្យពិច័យ នូវការគ្រប់គ្រងធនធានធម្មជាតិ។
- ផ្ដល់ការគាំទ្រ ដើម្បីជួយអភិវឌ្ឍន៍សមត្ថភាពនៃសង្គមស៊ីវិល ដើម្បីសង្កេត នឹងធ្វើឲ្យប្រាកដថា ការបង់ប្រាក់ក្នុងវិស័យសាធារណៈ មានតម្លាភាព។

**រដ្ឋាភិបាលនានាគួរតែះ**

- ធ្វើតាមការដឹកនាំរបស់ប្រទេសសហរដ្ឋអាមេរិក ដោយដាក់វិធានការហាមការធ្វើដំណើរចូលប្រទេស ចំពោះបុគ្គល ឬសមាជិកគ្រួសាររបស់បុគ្គលណា ដែលមានភស្តុតាងល្អ គួរឲ្យជឿថា បុគ្គលនោះពាក់ព័ន្ធក្នុងការពុករលួយ ទាក់ទងនឹងការដកស្រង់ធនធានធម្មជាតិ នៅក្នុងប្រទេសរបស់ខ្លួន។[i]
- ទាមទារ ហើយគាំទ្រ ចំពោះសកម្មភាពប្រឆាំងការពុករលួយ ដោយបុគ្គលនៅថ្នាក់ជាតិ។
- បង្កើតប្រព័ន្ធលើកទឹកចិត្ត ដែលមានគោលបំណងឲ្យងាកទៅបុគ្គលដែលចែករំលែកប្រាក់ថវិកា សំអាងលើកត្តាអភិបាលកិច្ច។

**ក្រុមហ៊ុនដែលប្រតិបត្តិនៅក្នុងប្រទេសកម្ពុជា គួរគប្បីះ**

- បោះពុម្ពព័ត៌មានអំពីទំហំ និងទីតាំងនៃសម្បទាន ព្រមទាំងព័ត៌មានលំអិត ស្ដីពីការសន្យា ឬការបង់ប្រាក់ដែលបានធ្វើឡើងជាការតបស្នងសម្រាប់ការប្រគល់សិទ្ធិនោះ។
- កុំធ្វើការបង់ប្រាក់ ឲ្យសមាជិកនៃកងយោធពលខេមរភូមិន្ទឡើយ លើកលែងតែបើកប្រាក់នោះ ត្រូវបានតម្រូវដោយច្បាប់ប៉ុណ្ណោះ។
- ប្រកាសប្រាប់ទាំងស្រុង អំពីការបង់ប្រាក់ណា ដែលបានបង់ឲ្យសមាជិកកងយោធពលខេមរភូមិន្ទ។ ការបង់ប្រាក់ទាំងអស់ គួរគប្បីត្រួតពិនិត្យដោយភាគីឯករាជ។

[i] ដើម្បីមើលច្បាប់ទាំងស្រុង សូមមើលច្បាប់បម្រុងប្រាក់រួមរបស់សហរដ្ឋអាមេរិកះ http://frwebgate.access.gpo.gov/cgi-bin/getdoc.cgi?dbname=110_cong_bills&docid=f:h2764enr.txt.pdf។ មាត្រាដែលទាក់ទងនឹងប្រទេសកម្ពុជា នៅក្នុងច្បាប់បម្រុងប្រាក់រួម មាននៅក្នុងរបាយការណ៍ផ្នែក J ដែលអមភ្ជាប់ជាមួយច្បាប់ ដែលផ្ដល់ព័ត៌មានបន្ថែម ស្ដីពីការអនុវត្តច្បាប់នោះ។ របាយការណ៍ផ្នែក J អនុម័តសំដីអំពីប្រទេសកម្ពុជា ដែលមាននៅក្នុងច្បាប់បម្រុងប្រាក់សម្រាប់កម្មវិធីរដ្ឋ ប្រតិបត្តិការបរទេស និងកម្មវិធីដែលទាក់ទងផ្សេងទៀត ឆ្នាំ ២០០៨។ ឯកសារនេះមានចែងដូចតទៅះ "គណៈកម្មការនេះ លើកទឹកចិត្តរដ្ឋាភិបាល ដើម្បីអនុវត្តសេចក្ដីប្រកាសរបស់ប្រធានាធិបតីលេខ ៧៧៥០ [គឺជាគម្រោងហាមឃាត់ការធ្វើដំណើរចូល ចំពោះរដ្ឋចោរធិបតេយ្យ] ដើម្បីហាមឃាត់មន្ត្រីពុករលួយរបស់ប្រទេសកម្ពុជា ដែលត្រូវបានសំគាល់អត្តសញ្ញាណនៅក្នុងរបាយការណ៍ខែមិថុនា ឆ្នាំ ២០០៧ របស់ Global Witness ឈ្មោះថា 'ខ្សែស្រឡាយ អ្នកលួចជាតិះ ការកាប់ឈើខុសច្បាប់ និងការពុះច្រៀកទ្រព្យសម្បត្តិសាធារណៈ ដោយអ្នកដឹកនាំរបស់ប្រទេសកម្ពុជា ' មិនឲ្យចូលប្រទេសសហរដ្ឋអាមេរិកទេ។ គណៈកម្មការលើកទឹកចិត្តប្រទេសអភិវឌ្ឍន៍ឯទៀត ជាពិសេសនៅក្នុងអឺរ៉ុប និងអាស៊ី ដើម្បីអនុវត្តការហាមឃាត់បែបស្រដៀងគ្នា។"

# សេចក្តីសង្ខេប

ប្រទេសកម្ពុជាសព្វថ្ងៃនេះ គឺជាប្រទេសលក់។ ដោយសារពួកវរជនរបស់ប្រទេសកម្ពុជាបានប្រមូលទ្រព្យសម្បត្តិសន្ធឹកសម្រាប់ខ្លួនហើយ ដោយកាប់ធនធានឈើជាច្រើនរបស់ប្រទេស ឥឡូវអ្នកទាំងនោះកំពុងពង្រីកវិស័យពាណិជ្ជកម្មរបស់ខ្លួន ឲ្យរួមមានធនធានរបស់រដ្ឋប្រភេទផ្សេងទៀតផងដែរ។ ធនធានទាំងនេះ មានរួមទាំងដី ធនធានជលផល កោះ និងឆ្នេរសមុទ្រទេសចរណ៍ ជាតុរ៉ែ និងប្រេងកាត ជាដើម។ ប្រទេសជាតិកំពុងត្រូវបានបែងចែក ហើយលក់ចេញ យ៉ាងឆាប់រហ័ស។ នៅក្នុងរយៈពេល ១៥ ឆ្នាំកន្លងមកនេះ ដីប្រទេសជាតិចំនួន ៤៥ ភាគរយ ត្រូវបានទិញដោយអ្នកវិនិយោគឯកជន។ ប្រាជ្ញានៃការលក់នេះ មិនទាន់បានបង្ហាញឲ្យឃើញច្បាស់នៅឡើយសោះ។ លទ្ធផលអាក្រក់ផ្លូវសង្គម និងផ្លូវបរិស្ថាន មានសភាពធ្ងន់ធ្ងររួចជាស្រេច។[ii]

របាយការណ៍នេះសំអាងលើការស៊ើបអង្កេតដែលបានធ្វើឡើងដោយអង្គការ Global Witness [សាក្សីពិភពលោក] នៅក្នុងឆ្នាំ ២០០៨ ហើយរបាយការណ៍នេះផ្តោតលើមួយផ្នែកនៃបាតុភូតដ៏ធំទូលាយនេះ – គឺវិស័យប្រេង ឧស្ម័ន និងជាតុរ៉ែ ដ៏កំពុងលូតឡើង។ របាយការណ៍នេះលើកហេតុផល ដើម្បីឲ្យរដ្ឋាភិបាលកម្ពុជា ហើយនិងទាយកអន្តរជាតិរបស់ប្រទេសកម្ពុជា ពង្រឹងអភិបាលកិច្ចលើធនធានទាំងនេះ។

## ១ ប្រទេសកម្ពុជាកំពុងមានលទ្ធភាពទទួលផលលាភយ៉ាងសន្ធឹកដោយសារប្រេងកាត និងជាតុរ៉ែ។

បើសិនផលចំណូលពីជាវិស័យឧស្សាហកម្មដកស្រង់ថ្មីទាំងនេះ ត្រូវបានគ្រប់គ្រងយ៉ាងល្អ វាអាចផ្តល់ឲ្យរដ្ឋាភិបាលកម្ពុជា នូវឱកាសដ៏ល្អប្រសើរបំផុត នៅក្នុងជំនាន់នេះ ដើម្បីកសាងហេដ្ឋារចនាសម្ព័ន្ធឡើងវិញ ហើយលើកប្រជារាស្ត្រឲ្យផុតពីភាពក្រីក្របាន។ បើសិនជាវិស័យឧស្សាហកម្មទាំងនេះ ត្រូវបានគ្រប់គ្រងដោយការពុករលួយ និងអសមត្ថភាពទៅវិញ ទឹកប្រាក់ដែលរកបានអាចពង្រីកចន្លោះរវាងអ្នកមាន និងអ្នកក្រ ហើយបន្ទន់ដល់លទ្ធិប្រជាធិបតេយ្យបន្ថែមទៅទៀត ដោយចាក់ឫសនៃជំហររបស់ពួកវរជន ដែលកំពុងតែកាន់អំណាច យ៉ាងជ្រៅ។

## ២ ឧស្សាហកម្មដកស្រង់របស់ប្រទេសកម្ពុជា កំពុងតែចេញសញ្ញាឲ្យដឹងមុន ពីការចាប់ដោយរដ្ឋចោរធិបតេយ្យ។



Global Witness បានស្ទង់មើលវិស័យឧស្សាហកម្មដកស្រង់ដ៏កំពុងលូតឡើង របស់ប្រទេសកម្ពុជា តាមរយៈការសម្ភាសអ្នកផ្ទៃក្នុងវិស័យឧស្សាហកម្ម ហើយនិងការស៊ើបអង្កេតនៅនឹងកន្លែងដកស្រង់តែម្តង។ លទ្ធផល គឺគួរឲ្យភ្ញាក់ផ្អើល។ គំរូនៃការពុករលួយ និងអំណាចបរិបាលកិច្ច ដែលបានឃើញនៅក្នុងវិស័យព្រៃឈើ ហើយដែលត្រូវបានកត់ទុកជាឯកសារដោយ Global Witness អស់រយៈពេលជាង ១៣ ឆ្នាំនេះ ត្រូវបានឃើញដូចគ្នា នៅក្នុងវិស័យឧស្សាហកម្មដកស្រង់ដែរ។ ពួកវរជននយោបាយដដែលៗ ដែលបានខ្ជះខ្ជាយធនធានព្រៃឈើរបស់ប្រទេសជាតិនោះ ឥឡូវនេះកំពុងតែមានភារកិច្ចលើការគ្រប់គ្រងទ្រព្យសម្បត្តិជាតុរ៉ែ និងប្រេងកាត របស់ប្រទេសជាតិដែរ។ ដូចជាឈើថ្លៃដែរ ធនធានទាំងនេះ ផ្តល់ជាឱកាសដ៏មានតែមួយគត់។ នៅពេលវាអស់ហើយ គឺគ្មានទៀតទេ ជានិច្ច។[២]

ជើងសារអំណាចដ៏ធំខ្ពស់ចំនួនតិច ដែលគ្រប់គ្រងរដ្ឋ បានលក់ចេញសម្បទានដែលអាចមានតម្លៃថ្លៃ ទៅក្រុមហ៊ុនផ្សេងៗ ដោយរបៀបដ៏គ្មានតម្លាភាព ហើយគួរឲ្យសង្ស័យណាស់។ តាមនិន្នាការបច្ចុប្បន្ន ពួកជើងសារអំណាចទាំងនេះ ប្រុងប្រៀបនឹងទទួលផលប្រយោជន៍ពីឧស្សាហកម្មដកស្រង់របស់ប្រទេសកម្ពុជាសម្រាប់ខ្លួន។ ប្រជារាស្ត្រមិនទទួលប្រយោជន៍ទាំងនេះទេ។ អ្នកទាំងនេះមានជំនួយក្នុងការធ្វើបែបនេះ ដោយសារខ្វះតម្លាភាពទាំងស្រុងនៅក្នុងវិស័យប្រេងកាត និងវិស័យអាជីវកម្មរ៉ែ។ ភាពស្របច្បាប់ និងសមត្ថភាពបច្ចេកទេស នៃក្រុមហ៊ុនខ្លះ ដែលបានទិញសម្បទានទាំងនេះ គឺមិនច្បាស់ឡើយ។ ទន្ទឹមនឹងពេលនេះ ការប្រថុយគ្រោះថ្នាក់ដល់បរិស្ថាន និងប្រជារាស្ត្រដែលរស់នៅលើដីនោះ គឺធំណាស់។

ii បទយោងសម្រាប់ចំណុចដែលបានលើកឡើងនៅក្នុងផ្នែកនេះ ត្រូវបានលើកឡើងនៅក្នុងតួរបាយការណ៍។



កម្មករសាកល្បងដីរកធាតុរ៉ែ នៅឯការដ្ឋានអណ្តូងរ៉ែមួយ នៅក្នុងខេត្តព្រះវិហារ

### ៣ ការបង់ប្រាក់មកពីក្រុមហ៊ុនដកស្រង់ ចំនួនសរុបរាប់លានដុល្លារ មើលទៅដូចជាបាត់ទៅណាអស់។

ថ្លៃចំណូលហិរញ្ញវត្ថុ ដែលត្រូវបានបង់ដើម្បីទទួលសម្បទាន – គឺមានចំនួនសរុបរាប់លានដុល្លារ – មិនបានលេចឡើង តាមការសង្កេតរបស់ Global Witness នៅក្នុងរបាយការណ៍ផលចំណូលឆ្នាំ ២០០៦ ឬ ឆ្នាំ ២០០៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឡើយ។

## នៅក្នុងករណីវិស័យរ៉ែ៖

### ៤ អាជ្ញាប័ណ្ណស្វែងរុករកធនធានរ៉ែ ត្រូវបានចែកដោយសម្ងាត់ទៅពួកវរជនកាន់អំណាច ឬញាតិសន្តានរបស់អ្នកទាំងនោះ។

ក្នុងចំណោមការដ្ឋានរ៉ែ ដែលត្រូវបាន Global Witness ស៊ើបអង្កេតនៅក្នុងឆ្នាំ ២០០៨ គ្រប់ការដ្ឋានទាំងអស់ ត្រូវបានកាន់កាប់ ឬគ្រប់គ្រងដោយសមាជិកនៃពួកវរជននយោបាយ ឬយោធា របស់ប្រទេសកម្ពុជា។ បញ្ជីឈ្មោះមានរួមដូចតទៅនេះ៖

- លោកនាយ ឧត្តមសេនីយ៍ត្រី អ៊ុក កោសា[3] អ្នកប្រមុខនៃយោធភូមិភាគអភិវឌ្ឍន៍ របស់កងយោធពលខេមរភូមិន្ទ (RCAF);
- លោក ចម បូរី[៤] ត្រូវជាបងប្អូនជាមួយរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មកម្ពុជា លោក ចម ប្រសិទ្ធ;[៥]
- លោក ឌី ចូច[៦] (ហៅថា ហ៊ុន ចូច ដែរ) ត្រូវជាប្អូនជីដូនមួយរបស់អគ្គនាយករដ្ឋមន្ត្រី ហ៊ុន សែន;
- ឧត្តមសេនីយ៍ មាស សុភា[៧] ជាអគ្គមេបញ្ជាការកងទ័ពថ្មើរជើងនៃ RCAF;
- សមាជិកព្រឹទ្ធសភា ឯកឧត្តម លី យ៉ុងផាត់[៨] សមាជិកព្រឹទ្ធសភារបស់បក្សប្រជាជនកម្ពុជា (CPP) ហើយជាមហាសេដ្ឋីមានទ្រព្យសម្បត្តិច្រើន;
- ឯកឧត្តម ឱម យ៉ិនទៀង[៩] ទីប្រឹក្សាខ្ពស់របស់សម្តេច ហ៊ុន សែន ហើយជាប្រធានគណៈកម្មាធិការសិទ្ធិមនុស្ស នៃរដ្ឋាភិបាលប្រទេសកម្ពុជា;
- សមាជិកព្រឹទ្ធសភា ឯកឧត្តម ឡៅ ម៉េងឃីន[១០] អ្នកជំនិតរបស់សម្តេច ហ៊ុន សែន ហើយជានាយកនៃក្រុមហ៊ុន ភាពីម៉ិច ដែលជាក្រុមហ៊ុនដ៏មានអំណាចខ្លាំងបំផុតមួយ នៅក្នុងប្រទេសកម្ពុជា;
- លោកនាយឧត្តមសេនីយ៍ ប៉ុល សារឿន[១១] ជាអគ្គមេបញ្ជាការនៃកងទ័ពភូមិន្ទកម្ពុជា;
- ឧកញ៉ា ទ្រី ភាព[១២] ជាមហាសេដ្ឋីគាំទ្រគណបក្ស CPP។

### ៥ មានការពាក់ព័ន្ធដ៏ជាក់ស្តែង និងច្រើនអនេក ដោយកងយោធពលខេមរភូមិន្ទ នៅក្នុងវិស័យរ៉ែដ៏កំពុងលូតឡើង។

អ្នកស៊ើបអង្កេតរបស់ Global Witness បានប្រទះឃើញកងកម្លាំង RCAF ធ្វើការយាមការដ្ឋានអាជីវកម្មរ៉ែ នៅក្នុងខេត្តស្ទឹងត្រែង ព្រះវិហារ និងពោធិ៍សាត់។ នៅការដ្ឋានខ្លះ ដីធ្លីត្រូវបានចាប់យកពីអ្នកស្រុក ហើយមានគេរាយការណ៍អំពីការគំរាមកំហែងដល់អ្នកស្រុក។ នៅក្នុងករណីទាំងអស់នេះ គ្មានការផ្តល់ការអនុញ្ញាតមុនដោយសេរី និងដោយដឹងខ្លួនឡើយ។

**៦ តំបន់ការពារ ឬតំបន់មានបញ្ហាបរិស្ថាន គឺគួរឲ្យព្រួយបារម្ភជាពិសេស។ តាមនិន្នាការបច្ចុប្បន្ន តំបន់ដែលពីមុនមិនទាន់មានអ្នកណាស្វែងរុករក នៅក្នុងជួរភ្នំក្រវាញ ព្រៃឡង់ និងដែនជម្រកសត្វព្រៃភ្នំក្រសោប នោះនឹងត្រូវបានខូចខាត ឬបំផ្លាញជាអចិន្ត្រៃយ៍វិញ។**

រាជរដ្ឋាភិបាលប្រទេសកម្ពុជា បានសម្រេចចិត្តថា អាជីវកម្មរ៉ែត្រូវមានអាទិភាពជាងសេចក្ដីត្រូវការនៃបរិស្ថាន ហើយនិងកិច្ចការពារបរិស្ថាន។ នេះបាននាំទៅរកសកម្មភាពស្វែងរុករកធនធានរ៉ែយ៉ាងសន្ធឹក។ នៅក្នុងចំណោមតំបន់ការពារទាំង ២៣ តំបន់របស់ប្រទេសកម្ពុជា មានយ៉ាងហោចណាស់ ៦ តំបន់ ដែលមានសកម្មភាពអាជីវកម្មរ៉ែប្រភេទណាមួយ កំពុងតែកើតឡើងនៅក្នុងខ្សែព្រំដែនតំបន់។

## នៅក្នុងករណីវិស័យប្រេង និងឧស្ម័នៈ

**៧ ស្ថាប័នដែលគ្រប់គ្រងឧស្សាហកម្មប្រេង និងឧស្ម័នរបស់ប្រទេសកម្ពុជា – អាជ្ញាធរប្រេងកាតជាតិកម្ពុជា (CNPA) – គឺជាស្ថាប័នដ៏ខ្វះភាពស្របច្បាប់ច្បាស់លាស់ នៅក្រោមរដ្ឋធម្មនុញ្ញ ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់ពីអគ្គនាយករដ្ឋមន្ត្រី ហ៊ុន សែន ហើយនិងឧបនាយករដ្ឋមន្ត្រីរបស់លោក ឯកឧត្ដម សុខ អាន។[១៣]**

CNPA ត្រូវបានបង្កើតដោយរាជក្រឹត្យ។ តាមយោបល់របស់អ្នកជំនាញច្បាប់ ដែល Global Witness បានពិគ្រោះជាមួយ ការផ្ទេរអំណាចដ៏ធំបែបនេះ ទៅកាន់ស្ថាប័នថ្មី តាមរយៈតែរាជក្រឹត្យប៉ុណ្ណោះ ដោយគ្មានច្បាប់អនុម័តដោយសភាជាតិ គឺមិនសមស្របនឹងដំណើរការធម្មតា ហើយខ្វះភាពស្របច្បាប់ច្បាស់លាស់ នៅក្រោមរដ្ឋធម្មនុញ្ញ។

ទន្ទឹមនឹងពេលនេះ វិសោធនកម្មសម្ងាត់មួយចំនួន ដែលបានធ្វើឡើងនៅក្នុងច្បាប់ប្រេងកាតឆ្នាំ ១៩៩១ មើលទៅបានដាក់អំណាចគ្រប់គ្រងស្ថាប័ននេះ ទៅក្នុងដៃផ្ទាល់របស់អគ្គនាយករដ្ឋមន្ត្រី ហើយនិងឧបនាយករដ្ឋមន្ត្រី សុខ អាន។

**៨ មជ្ឈការ និងនយោបាយកម្ម នៃអំណាចនៅក្នុង CNPA បានបង្កើតនូវអង្គការដ៏វិកល ដែលសភាជាតិកម្ពុជាគ្មានអំណាចត្រួតត្រាសោះ ហើយក្រសួងដទៃទៀត គ្មានសំឡេងឡើយ។**

ការគ្រប់គ្រង និងការត្រួតត្រាលើ CNPA ត្រូវបានក្លាយជារឿងនយោបាយជាអនេក។ អ្នកកាន់អំណាច សុទ្ធតែជាអ្នកនយោបាយ CPP ដែលគាំទ្រសម្ដេច ហ៊ុន សែន។ ការអនុវត្តអំណាចនេះ មិនរាប់បញ្ចូល ហើយក៏ដកហូតអំណាចចេញពីអ្នកណាដែលគាំទ្រប្រធានព្រឹទ្ធសភា សម្ដេច ជា ស៊ីម។[១៤] អគ្គនាយកនៃ CNPA លោក តែ ដួងតារា[១៥] ក្ដាប់ព័ត៌មានយ៉ាងជាប់ ដោយការជ្រើសរើសបុគ្គលិកផ្ទាល់ខ្លួនរបស់គាត់ ពីក្រសួងដទៃទៀត ទាំងរំលងចោលបុគ្គលិកដ៏មានការហ្មឹកហ្មឺននៅក្នុង CNPA ហើយដោយការរក្សាទុកឯកសារនៅក្នុងផ្ទះខ្លួនឯង មិនមែនក្នុងការិយាល័យអាជ្ញាធរទេ។

គ្មានការត្រួតត្រាលើ CNPA ដោយសភាជាតិឡើយ។ សមាជិកសភា មើលទៅ មិនដឹងអ្វីសោះអំពីកិច្ចការរបស់ CNPA។ បែបដូចគ្នា CNPA មិនសម្របសម្រួលជាមួយនឹងក្រសួងដទៃទៀតទេៈ ក្រសួងហិរញ្ញវត្ថុ – ដែលនឹងទទួលខុសត្រូវលើការប្រមូលផលចំណូល ពីប្រេង និងឧស្ម័ន នៅពេលវាចាប់ផ្ដើមដំណើរការ – មិនបានរួមបញ្ចូលនៅក្នុងការពិភាក្សារបស់ CNPA ស្ដីការគ្រប់គ្រងធនធាននេះ ហើយនិងអនាគតផលចំណូលឡើយ។

**៩ ការចែកចាយសម្បទាន បានកើតឡើងនៅក្នុងភាពសម្ងាត់។**

កិច្ចព្រមព្រៀងរបស់ក្រុមហ៊ុនប្រេង ហើយនិងព័ត៌មានអំពីការចែកចាយសម្បទាន គឺជារឿងសម្ងាត់ ដែល CNPA ការពារយ៉ាងជាប់។ ក៏ប៉ុន្តែ មានព័ត៌មានឲ្យដឹងថា CNPA បានចែកសម្បទានគ្រប់ប្លុកនៅក្នុងសមុទ្រ ដែលជារបស់កម្ពុជាពិតប្រាកដ ទៅឲ្យក្រុមហ៊ុនឯកជនអស់ហើយ។ ទន្ទឹមនឹងនេះ អាជ្ញាធរនៅតែបន្តចែកប្លុកដីគោកជុំវិញអាងទន្លេសាប ហើយចែកអាជ្ញាប័ណ្ណសារជាថ្មី សម្រាប់ប្លុកនៅក្នុងតំបន់សមុទ្រមានការទាមទារជាន់គ្នា – គឺជាតំបន់សមុទ្រដែលប្រទេសថៃ និងប្រទេសកម្ពុជាជជែកគ្នាទាមទារ។ ក្រុមហ៊ុនច្រើនផ្សេងៗគ្នា បានទទួលសម្បទាន។ ក្រុមហ៊ុនខ្លះ គឺជាក្រុមហ៊ុនប្រតិបត្តិ ដែលមានសមត្ថភាពសមស្រប។ ចំពោះក្រុមហ៊ុនមួយចំនួនទៀត គឺវាមិនសូវច្បាស់លាស់ថា ពួកគេមានបទពិសោធន៍អ្វី ឬថា តើគេមានខ្សែស្រឡាយជាមួយអ្នកណាខ្លះ។



សម្ដេច ហ៊ុន សែន (ខាងស្ដាំ) មានអំណាចកាន់កាប់ដោយផ្ទាល់ លើអាជ្ញាធរប្រេងកាតជាតិកម្ពុជា (CNPA) ដែលទទួលភារកិច្ច សម្របសម្រួល វិស័យប្រេងរបស់ប្រទេសកម្ពុជា

ទីប្រឹក្សាសេដ្ឋកិច្ចរបស់អគ្គនាយករដ្ឋមន្ត្រី គឺមហាសេដ្ឋី លោកបណ្ឌិត ឈិន លិប គឹង[១៦] គឺជាម្ចាស់នៃក្រុមហ៊ុន Resourceful Petroleum [ក្រុមហ៊ុនប្រេងកាត រីសូសហ្វ៊ុល][១៧] ក្រុមហ៊ុនមួយដែលកាន់ចំណែកហ៊ុន ៣០ ភាគរយ នៅក្នុងសម្បទានសមុទ្រ ប្លុក B។ មេធាវីរបស់លោកបណ្ឌិត ឆិន លិប គឹង បានប្រាប់ Global Witness ថាក្រុមហ៊ុនប្រេកកាត រីសូសហ្វុល ធ្វើអាជីវកម្មប្រេង និងឧស្ម័ន នៅកន្លែងផ្សេងទៀត នៅក្នុងពិភពលោកដែរ។[18] ក្រុមហ៊ុនផ្សេងទៀត ដូចជាក្រុមហ៊ុន China Zhen Rong Cambodia [ក្រុមហ៊ុន ឆាយណា ចេន រ៉ុង កម្ពុជា][១៩] មើលទៅ ត្រូវបានបង្កើតឡើយ ដើម្បីគោលបំណងប្រើប្រាស់ធនធានប្រេង និងឧស្ម័នរបស់ប្រទេសកម្ពុជា។

## ១០ ប្រាក់រាប់លានដុល្លារ ត្រូវបានបង់ឲ្យ CNPA ដោយក្រុមហ៊ុនដកស្រង់ ប៉ុន្តែប្រាក់នេះ មើលទៅមិនដែលចូលក្នុងរតនាគារជាតិឡើយ។

ក្រុមហ៊ុននីមួយៗ ត្រូវតែបង់ប្រាក់រង្វាន់ចុះហត្ថលេខា ដែលចំនួនអាចចរចាបាន ទៅឲ្យ CNPA។ ដល់បច្ចុប្បន្ននេះ ក្រុមហ៊ុនឥណ្ឌូណេស៊ី PT Medco Energi Internasional [ថាមពល PT ម៉ិដកូ អន្តរជាតិ] បានបង់ប្រាក់សរុបចំនួន US$៧,៥ លានឲ្យ CNPA។ ម្យ៉ាងទៀត គ្រប់ក្រុមហ៊ុននីមួយៗ ដែលមានកិច្ចព្រមព្រៀងចែកចាយផលិតកម្ម សម្រាប់ប្លុកសម្បទានមួយ ក៏ត្រូវតែបង់ថ្លៃយ៉ាងធ្ងន់រាល់ឆ្នាំ។ នៅក្នុងឆ្នាំទីមួយ ប្រាក់នេះគឺជិត US$៨០០.០០០ ក្នុងសម្បទានមួយ។ តាមការសង្កេតរបស់ Global Witness ប្រាក់នេះមិនដែលលេចឡើងនៅក្នុងរបាយការណ៍ផលចំណូលមិនមែនពន្ធដារ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ឆ្នាំ ២០០៦ ឬ ២០០៧ ឡើយ។

## ១១ តំបន់ដីគោកហៅថា អាងទន្លេសាប កំពុងត្រូវគេស្វែងរកធនធានឥឡូវនេះ។

អាងនេះ មានរួមផ្នែកមួយនៃបឹងទន្លេសាប ជាឋបនីយជីវមណ្ឌល UNESCOមួយ ដែលទឹកផ្គត់ផ្គង់ត្រីប្រមាណជា ២៣០.០០០ តោនក្នុងមួយឆ្នាំ។ ត្រីទាំងនេះ ផ្ដល់ប្រមាណជា ៤០ – ៧០ ភាគរយ នៃជាតិប្រូតេអ៊ីន ដែលប្រជាពលរដ្ឋបរិភោគក្នុងមួយឆ្នាំ ហើយផ្ដល់ជីវភាពដ៏ចាំបាច់ សម្រាប់ប្រជារាស្ត្រកម្ពុជា ប្រមាណពីរលាននាក់។

នៅពេលសរសេររបាយការណ៍នេះ មានការស្ទង់ដីដោយការរញ្ជួយដី ប្រតិបត្តិដោយក្រុមហ៊ុនឯកជន ហៅថា Petroleum Geo Services [សេវាកម្មប្រេងកាត ជីយ៉ូ] (PGS)។[២០] លទ្ធផលមិនទាន់បញ្ចេញឲ្យសាធារណជនដឹងនៅឡើយទេ ប៉ុន្តែ Global



ក្មេងៗ ដើរហួសឡានដឹកម៉ាស៊ីនប្រដាប់ប្រដាចិន ទៅកាន់ការដ្ឋានអណ្ដូងរ៉ែមួយ នៅក្នុងស្រុករវៀង ខេត្តព្រះវិហារ

Witness ត្រូវបានគេប្រាប់ថា ទិន្នន័យចង្អុលបង្ហាញ "លទ្ធភាពល្អប្រសើរ"។

ក្រុមហ៊ុនថាមពល PT ម៉ិដកូ អន្តរជាតិ[21] ត្រូវបានប្រគល់សម្បទានដីគោកមួយប្លុក។ ក្រុមហ៊ុនផ្សេងទៀត ក៏អះអាងថាខ្លួនត្រូវបានចែកសម្បទានដែរ។ ដល់ខែសីហាឆ្នាំ ២០០៨ មានការពិគ្រោះ និងការជំរាបអ្នកស្រុកយ៉ាងតិចណាស់ ទោះបីមន្ត្រីប្រទេសកម្ពុជាបានផ្ដល់ការអនុញ្ញាតរួចជាស្រេច ឲ្យក្រុមហ៊ុន PGS បន្តការស្ទង់ដីរបស់គេចូលក្នុងវាលស្រែ ក្រោយពីការបញ្ចប់រដូវច្រូតកាត់នាចុងឆ្នាំ ២០០៨ ក៏ដោយ។

## ១២ ទាយកអន្តរជាតិរបស់ប្រទេសកម្ពុជា មិនប្រើអានុភាពដែលមានដោយសារប្រាក់ ជំនួយអភិវឌ្ឍន៍ដែលគេផ្ដល់ឲ្យ ដើម្បីកែលំអអភិបាលកិច្ចទេ។

ទាយកអន្តរជាតិផ្ដល់ជំនួយ ស្មើនឹងប្រហែលពាក់កណ្ដាលនៃថវិកាជាតិរបស់ប្រទេសកម្ពុជា រៀងរាល់ឆ្នាំ។ ទាយកមិនបានប្រើអានុភាពដែលគេមានដោយសារប្រាក់ជំនួយនេះ ដោយប្រសិទ្ធិភាពឡើយ។ និយាយលំអិត ពួកគេមិនព្រមទទួលស្គាល់ថារដ្ឋាភិបាលពុករលួយទាំងស្រុង ហើយមិនធ្វើការសម្រាប់ផលប្រយោជន៍នៃប្រជារាស្ត្រទេ។ លទ្ធផល គឺថាប្រាក់ជំនួយរាប់ពាន់លានដុល្លារ ផ្ដល់ដោយអ្នកបង់ពន្ធដារនៅក្នុងបស្ចិមប្រទេស ហើយនិងប្រទេសចិនឥឡូវដែរ គឺមានផលប្រយោជន៍តិចតួច ដើម្បីកែលំអជីវិតនៃពលរដ្ឋកម្ពុជាធម្មតា។ ម៉្យាងទៀត ជំនួយគាំទ្រពីទាយកបានបរាជ័យ ក្នុងការជំរុញការកែទម្រង់ ដែលអាចធ្វើឲ្យរដ្ឋាភិបាលទទួលខុសត្រូវចំពោះពលរដ្ឋរបស់ខ្លួនច្រើនជាង។ ផ្ទុយទៅវិញ រដ្ឋាភិបាលកំពុងតែប្រើប្រាស់ជំនួយអន្តរជាតិ ជាលេសដើម្បីអះអាងភាពត្រឹមត្រូវស្របច្បាប់ នៅក្នុងវិស័យនយោបាយ។

## ១៣ រដ្ឋាភិបាលបានដកថយក្រោយរួចហើយ នៅក្នុងការតម្រូវតម្លាភាពពីឧស្សាហកម្មដកស្រង់។

ក្រោយពីរដ្ឋាភិបាលកម្ពុជាបានយល់ព្រមអនុម័តគម្រោងជំរុញតម្លាភាពឧស្សាហកម្មដកស្រង់ នោះរដ្ឋាភិបាលបានប្រកាសថា នឹងមិនអនុម័តវិញ។

## ១៤ ការខូចខាតដែលកើតឡើងរួចជាស្រេច គឺមិនទាន់ដល់កម្រិតជួសជុលលែងបាននៅឡើយទេ ហើយនៅមានឱកាសស្ដើងដើម្បីកែលំអអភិបាលកិច្ចនៃឧស្សាហកម្មដកស្រង់របស់ប្រទេសកម្ពុជានៅឡើយ។

ការនេះត្រូវតែចាប់ផ្ដើមជាមួយនឹងការព្យួរទុកបណ្ដោះអាសន្នចំពោះការប្រគល់សម្បទានថ្មី ការត្រួតពិនិត្យនៃសម្បទានដ៏ប្រគល់ហើយនាបច្ចុប្បន្ន ហើយនិងតម្លាភាពទាំងស្រុង នៅក្នុងការចែករំលែក និងការគ្រប់គ្រង នូវធនធានសាធារណៈដ៏សំខាន់ទាំងនេះ។ ទាយកគួរគេប្បីភ្ជាប់ការចែកប្រាក់ជំនួយ ក្រៅពីជំនួយមនុស្សធម៌ ទៅនឹងការចម្រើនទៅមុខដ៏ជាក់ស្ដែង ក្នុងការអនុវត្តវិធានការទាំងនេះ។

**ឧស្សាហកម្មដកស្រង់របស់ប្រទេសកម្ពុជា កំពុងតែចេញសញ្ញាឲ្យដឹងមុន ពីការចាប់ដោយរដ្ឋចោរធិបតេយ្យ ...**


ជំពូកទី ១
ឧស្សាហកម្ម
ដកស្រង់របស់
ប្រទេសកម្ពុជា
global witness

# ជំពូកទី ១

# ឧស្សាហកម្មដកស្រង់របស់ប្រទេសកម្ពុជា – មានរង្វាន់ថ្លៃ

*"យើងកំពុងស្ថិតនៅក្នុងដំណាក់កាល ដែលយើងហៅថា សម័យផ្លាស់ប្ដូរ"*

ប្រសាសន៍របស់ ឯកឧត្តម ម៉ុក ម៉ារ៉ែត[២២] រដ្ឋមន្ត្រីក្រសួងបរិស្ថានកម្ពុជា ស្ដីពីឧស្សាហកម្មដកស្រង់ដែលកំពុងលូតឡើង។[២៣]

ប្រទេសកម្ពុជា មើលទៅ កំពុងមានលទ្ធភាពទទួលផលលាភយ៉ាងសន្ធឹក ដោយសារប្រេង ឧស្ម័ន និងធាតុរ៉ែ។ តំរូវការខ្ពស់ជុំវិញពិភពលោក ស្រាប់ផលិតផលទាំងនេះ បាននាំឲ្យមានថ្លៃខ្ពស់ រហូតដល់ពេលថ្មីនេះ។ លទ្ធផលមួយ គឺថាក្រុមហ៊ុននានាចាប់ផ្ដើមរកប្រភពធនធានដ៏អាចចំណេញបាន នៅក្នុងប្រទេសដែលមិនដែលដកស្រង់ធនធានទាំងនេះកន្លងមកទេ ដែលពីមុនប្រទេសទាំងនោះត្រូវបានគេគិតថា ខ្វះស្ថិរភាពនយោបាយពេកទើបមិនអាចប្រតិបត្តិការក្នុងប្រទេសទាំងនោះបានទេ។ ប្រទេសកម្ពុជាគឺជាឧទាហរណ៍ដ៏ជាក់ស្ដែង នៃបាតុភូតនេះ។

នៅក្នុងរយៈពេលពីរឆ្នាំកន្លងមកនេះ វិស័យអាជីវកម្មរ៉ែ និងប្រេងបានអភិវឌ្ឍយ៉ាងលឿន ដោយក្រុមហ៊ុនថ្មីស្ទង់លទ្ធភាពនៃទ្រព្យសម្បត្តិជាតុរ៉ែ និងប្រេងកាត នៅក្រោមដីគោក និងដីបាតសមុទ្ររបស់ប្រទេស។ ផលចំណូលដែលរកបាន មុខជាតិចតួច បើប្រៀបធៀបនិងប្រទេសមហាផលិតប្រេងកាត និងធាតុរ៉ែ ដូចជាប្រទេសអ៊ីរ៉ាក់ និងប្រទេសអាហ្វ្រិកខាងត្បូង ប៉ុន្តែបើធនធានទាំងនេះត្រូវបានគ្រប់គ្រងដោយត្រឹមត្រូវ វាអាចជាឱកាសដ៏ល្អប្រសើរបំផុតនៅក្នុងជំនាន់នេះ ដើម្បីរួចខ្លួនពីអន្ទាក់នៃភាពក្រីក្របាន។

ទោះជាប្រទេសកម្ពុជាមានកំណើនសេដ្ឋកិច្ចយ៉ាងលឿន នៅក្នុងប៉ុន្មានឆ្នាំកន្លងមកនេះក៏ដោយ ក៏ប្រជាជនភាគច្រើននៅតែក្រីក្រ ហើយខ្វះធនធានសំខាន់ជាមូលដ្ឋាន។ 'សន្ទស្សន៍អភិវឌ្ឍន៍មនុស្ស' ឆ្នាំ ២០០៧ របស់កម្មវិធីអភិវឌ្ឍន៍នៃអង្គការសហប្រជាជាតិ បានដាក់ប្រទេសកម្ពុជាជាលំដាប់ថ្នាក់ទី ១៣១ ក្នុងចំណោម ១៧៧ ប្រទេស ដោយ ៧៨ ភាគរយនៃប្រជាជនត្រូវបានប៉ាន់ស្មានថា រស់នៅដោយប្រាក់តិចជាង US$២ ក្នុងមួយថ្ងៃប៉ុណ្ណោះ។[២៤] ទន្ទឹមនឹងនេះ អាយុកាលមធ្យមនៃប្រជាជនគឺតែ ៥៨ ឆ្នាំ ប៉ុណ្ណោះ ហើយកុមារក្រោមអាយុប្រាំឆ្នាំ ចំនួនមួយភាគបី ត្រូវបានចាត់ទុកថា ខ្វះអាហារគ្រប់គ្រាន់។[២៥] ចំពោះប្រជាជនកម្ពុជាភាគច្រើន ជីវិតនៅតែខ្លី ហើយលំបាក។



ទោះជាប្រទេសកម្ពុជាមានកំណើនសេដ្ឋកិច្ចយ៉ាងលឿន នៅក្នុងប៉ុន្មានឆ្នាំកន្លងមកនេះ ក៏ដោយ ក៏ប្រជាជនភាគច្រើននៅតែក្រីក្រ ហើយខ្វះធនធានសំខាន់ជាមូលដ្ឋាន

អង្គការ IMF ទាយថា ផលចំណូលប្រចាំឆ្នាំមកពីប្រេងនឹងកើនឡើងបន្តិចម្ដងៗ ពី US$១៧៤ លាន នៅក្នុងឆ្នាំ ២០១១ រហូតដល់ចំនួនអតិបរមា US$១,៧ ពាន់លាន នៅក្នុងឆ្នាំ ២០២១ (ប្រមាណ ៤ ភាគរយនៃ GDP) រួចហើយធ្លាក់ចុះវិញយ៉ាងលឿន។[២៦] បើសិនជាការប៉ាន់ស្មាននេះគឺត្រឹមត្រូវ ផលចំណូលប្រេងនឹងផ្លាស់ប្ដូរអនាគតរបស់ប្រទេសយ៉ាងខ្លាំង។

ប្រភពព័ត៌មានផ្សេងទៀត មិនសូវមានសុទិដ្ឋិនិយមច្រើនដូចនេះទេ។ អ្នកជំនាញក្នុង

វិស័យឧស្សាហកម្ម ដែលមានទិន្នន័យថ្មីបំផុត បានថ្លែងដោយការព្រួយបារម្ភ ថាអង្គការ IMF រដ្ឋាភិបាល និងប្រព័ន្ធផ្សព្វផ្សាយ បានបរាជ័យក្នុងការវែកញែកគ្រប់គ្រាន់ រវាងចំនួនប្រេង និងឧស្ម័ន ដែលមាននៅក្រោមដី ហើយនិងចំនួនដែលមានលទ្ធភាពដកស្រង់ចេញបាន។ គេឲ្យដំបូន្មានថា ការទាយរបស់អង្គការ IMF គឺមិនត្រឹមត្រូវទេ ហើយត្រូវតែកែលេខចុះក្រោម។ សំអាងលើការទាយរបស់គេ លំហូរចូលក្នុងប្រព័ន្ធសេដ្ឋកិច្ច នៃផលចំណូលយ៉ាងច្រើននោះ គឺប្រហែលជាមិនកើតឡើងដូច្នោះទេ។ ទោះជាយ៉ាងណាក៏ដោយ ផលចំណូលដែលមានលទ្ធភាពកើតឡើងនោះ នៅតែធំ ហើយសំខាន់ បើយោងតាមខ្នាតប្រទេសកម្ពុជា។[២៧]



ការវិនិយោគ និងការចាប់អារម្មណ៍លើវិស័យអាជីវកម្មរ៉ែ របស់ប្រទេសកម្ពុជា កំពុងតែកើនឡើងយ៉ាងលឿន

ទន្ទឹមនឹងពេលនេះ វិស័យអាជីវកម្មរ៉ែនៅតែអភិវឌ្ឍយ៉ាងស្ងាត់ស្ងៀម។ ដោយខ្វះទិន្នន័យស្តីពីចំនួនប្រភពធនធានរ៉ែរបស់ប្រទេសកម្ពុជា ហើយនិងស្ថានភាពនៃការស្វែងរុករកធនធានរ៉ែ នៅឯការដ្ឋានអាជីវកម្មរ៉ែជាច្រើននោះ យើងគ្មានលទ្ធភាពប៉ាន់ស្មានពីចំនួនផលចំណូល ដែលវិស័យអាជីវកម្មរ៉ែរបស់ប្រទេសកម្ពុជា អាចផលិតបាន ក៏ប៉ុន្តែការវិនិយោគ និងការចាប់អារម្មណ៍លើវិស័យនេះ កំពុងតែកើនយ៉ាងលឿន។ នៅក្នុងពាក់កណ្តាលទសវត្សរ៍ ១៩៩០ គ្មានគម្រោងអាជីវកម្មរ៉ែធំណាចាប់ផ្តើមឡើយ ក៏ប៉ុន្តែដល់ឆ្នាំ ២០០៦ ពិតជាមានការប្រញាប់ប្រញាល់រកធនធានរ៉ែ៖ គឺស្ថាប័នរដ្ឋាភិបាល ដែលមានភារកិច្ចលើកទឹកចិត្តការវិនិយោគបរទេស – គឺក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា[២៨] – បានអនុម័តចំពោះការវិនិយោគ US$៤០៣ លាន នៅក្នុងវិស័យអាជីវកម្មរ៉ែ នៅក្នុងឆ្នាំនោះ។[២៩] ហេតុការណ៍នេះ ធ្វើឲ្យលេចឡើងនូវលទ្ធភាពមួយ គឺថាទោះជាមានការចាប់ផ្តើមដ៏ស្ងាត់ក៏ដោយ ប្រហែលគឺជាវិស័យអាជីវកម្មរ៉ែរបស់ប្រទេសកម្ពុជាវិញ – មិនមែនប្រេងទេ – ដែលមានលទ្ធភាពច្រើនជាង ក្នុងការជួយដល់សេដ្ឋកិច្ចជាតិ។

និយាយរួម បន្ថែមទៀត រតនាគារជាតិអាចទទួលចំណូលរាប់លានដុល្លារ ពីឧស្សាហកម្មដកស្រង់ ដែលនេះជាហេតុការណ៍ដ៏គួរឲ្យអបអរសាទរ នៅក្នុងប្រទេសមួយដែលនៅតែពឹងពាក់លើសហគមន៍ជំនួយអន្តរជាតិ សម្រាប់ប្រាក់ជំនួយស្មើនឹងពាក់កណ្តាលនៃថវិកាជាតិប្រចាំឆ្នាំ។[៣០] ក៏ប៉ុន្តែគំរូនៃការគ្រប់គ្រងធនធានផ្សេងទៀតរបស់រដ្ឋ – គឺដី ធនធានជលផល ព្រៃឈើ និងកន្លែងបេតិកភណ្ឌជាតិ – នាំឲ្យសង្ស័យថា រដ្ឋាភិបាលប្រទេសកម្ពុជាប្រហែលជាខ្ជះខ្ជាយឱកាសនេះ។ ជំនួសការប្រើប្រាក់រាប់លានដុល្លារនេះ ដើម្បីលើកប្រជាជនចេញផុតពីភាពក្រីក្រ រដ្ឋាភិបាលប្រទេសកម្ពុជា ប្រហែលជាបន្តដើរតាមគំរូនៃប្រទេសជិតខាង ភូមា ដែលនៅទីនោះពួកវរជនអត្តាធិបតេយ្យ ប្រើប្រាស់ប្រាក់ដែលរកបានដោយសារទ្រព្យសម្បត្តិធនធានធម្មជាតិរបស់ប្រទេស ដើម្បីគ្រប់គ្រងលើប្រជាជនភាគច្រើនដ៏ក្រីក្រ ដោយមិនអើពើប៉ុន្មាន ចំពោះសុខុមាលភាព ឬសិទ្ធិនៃប្រជាជនឡើយ។

ឥឡូវនេះ ការសម្រេចចិត្តកំពុងតែកើតឡើង អំពីរបៀបដើម្បីគ្រប់គ្រងឧស្សាហកម្មទាំងនេះ។ លទ្ធផលនៃការសម្រេចចិត្តនឹងកំណត់ថា តើដំណាក់កាល 'ផ្លាស់ប្តូរ' របស់ប្រទេសកម្ពុជា នាំប្រទេសចេញផុតពីភាពក្រីក្រ ឬមួយឲ្យជាប់អន្ទាក់នៃបណ្តាសាធនធានវិញ។

## ធនធានរ៉ែ – លំនាំដើម

ទ្រព្យសម្បត្តិធាតុរ៉ែនៃប្រទេសកម្ពុជា ត្រូវបានគេគូផែនទី ចាប់តាំងពីចុងសតវត្សទី ១៩ ដោយភូគព្ភវិទូបារាំង និងចិន។[៣១] ធាតុរ៉ែដែលសំគាល់បាន គឺមានបុកស៊ីត ថ្មកាបូណាត ត្បូងថ្មម៉ាំងកានីស ហ្វូសហ្វាត អំបិល ស៊ីលីកាត និងពេជ្រថៃ [ហ្ស៊ីរកុន]។[៣២] ពេលថ្មីជាង មានគេរកឃើញធាតុរ៉ែដ៏សំខាន់ជាង ដូចជាក្រូម ស្ពាន់ ដែក ថ្មកំបោរ នីកែល និងតង់ស្តែន។[៣៣] ទោះមានលទ្ធភាពអស់ទាំងនេះក៏ដោយ ក៏ធនធានរ៉ែរបស់ប្រទេសកម្ពុជាខ្វះការអភិវឌ្ឍន៍រហូតដល់សព្វថ្ងៃ ដោយសារសង្គ្រាមជំលោះទាស់ទែងផ្ទៃក្នុង និងកង្វះការវិនិយោគ។

សព្វថ្ងៃនេះ វិស័យអាជីវកម្មរ៉ែជិតផ្លាស់ប្តូរពីការជីកខ្នាតតូចតាចដោយសហគមន៍អ្នកស្រុក ទៅជាការដកស្រង់ចេញខ្នាតធំ ដោយក្រុមហ៊ុនធំៗ។ ក្រុមហ៊ុនចំនួនកាន់តែច្រើន កំពុងតែយកចិត្តទុកដាក់ចំពោះវិស័យនេះ។ ទោះបីជាព័ត៌មានអំពីការចែកអាជ្ញាប័ណ្ណអាជីវកម្មរ៉ែ នៅក្នុងប្រទេសកម្ពុជា គឺពិបាករកក៏ដោយ ក៏ការស្រាវជ្រាវរបស់ Global Witness នៅក្នុងឆ្នាំ ២០០៨ បានសំគាល់អាជ្ញាប័ណ្ណជាង ១០០ សន្លឹក ដែលបានចែកសម្រាប់

គោលបំណងស្វែងរុករកធនធានរ៉ែ។[៣៤] ទន្ទឹមនឹងនេះ រដ្ឋាភិបាលកម្ពុជា បានតាំងអាជីវកម្មរ៉ែជាគោលបំណងដ៏មាន 'អាទិភាព' នៅក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខនេះ ហើយកំពុងតែស្វែងរកដោយសកម្ម នូវការវិនិយោគបន្ថែម ដោយក្រុមហ៊ុនបរទេស និងក្រុមហ៊ុនខ្មែរ។[៣៥]

សម្បទានអាជីវកម្មរ៉ែទាំងនេះ កំពុងស្ថិតនៅក្នុងដំណាក់កាលផ្សេងៗ នៃការ អភិវឌ្ឍន៍។ ក្រុមហ៊ុនទទួលសម្បទានមួយចំនួន កំពុងតែខួងអណ្ដូងសាកល្បង ហើយវិភាគសំណាក។ ឧទាហរណ៍ នៅក្នុងខេត្តព្រះវិហារ មានសញ្ញាចង្អុលបង្ហាញស្រទាប់មាស និងដែក ដ៏មានតម្លៃរាប់កោដិដុល្លារ។[៣៦] សម្បទានខ្លះ គ្រាន់តែកំណត់ផ្ទៃដីដែលកំពុងប្រើប្រាស់សម្រាប់អាជីវកម្មរ៉ែរួចហើយ ដូចជាកន្លែងយកថ្មកែវ នៅក្នុងតំបន់ជាប់ស្រយាលនៃខេត្តពោធិ៍សាត់ជាដើម។ ដីសម្បទានខ្លះទៀត មើលទៅ មានតែការប្រមើលពិចារណាប៉ុណ្ណោះ ប៉ុន្តែមិនទាន់អភិវឌ្ឍនៅឡើយទេ។

## ប្រេង និងឧស្ម័ន – លំនាំដើម

*"ប្រេងនៅតែនៅក្នុងដីនៅឡើយ។ វាដូចជាត្រីនៅក្នុងសមុទ្រ។ យើងមិនទាន់ដឹងថា ត្រីធំ ឬតូចទេ។ តើវាមានស្រកាឬទេ? មុនយើងចម្អិនត្រីបាន យើងត្រូវតែដឹងថា ត្រីប្រភេទអ្វីសិន។"*



តែ ដួងតារា អគ្គនាយកនៃអាជ្ញាធរប្រេងកាតជាតិកម្ពុជា ផ្ដល់ការវិភាគរបស់លោក អំពីការស្វែងរុករកប្រេង និងឧស្ម័ន នៅក្នុងប្រទេសកម្ពុជា នៅឯសន្និសីទអន្តរជាតិស្ដីពីប្រេងកាត ធ្វើឡើងនៅទីក្រុងភ្នំពេញ ថ្ងៃ ២៦–២៨ ខែមីនា ឆ្នាំ ២០០៨។[៣៧]

ដូចជាឧស្សាហកម្មរ៉ែដែរ វិស័យប្រេងកាតរបស់ប្រទេសកម្ពុជា នៅតែស្ថិតក្នុងវ័យកុមារភាពនៅឡើយ។ ក៏ប៉ុន្តែ មិនដូចឧស្សាហកម្មរ៉ែទេ វិស័យនេះបានទាក់ទាញការយកចិត្តទុកដាក់ និងការប្រមើលពិចារណាជាច្រើន ពីប្រព័ន្ធផ្សព្វផ្សាយ ហើយជាការច្បាស់លាស់ណាស់ថា ឧស្សាហកម្មប្រេងនិងឧស្ម័ន ត្រូវបានគេចាត់ទុកថា ជាកត្តាសំខាន់ណាស់ នៅក្នុងអនាគតនៃប្រទេសជាតិ។ លទ្ធភាពនៃទ្រព្យសម្បត្តិប្រេងបានធ្វើឲ្យមានការរួសរាន់រក 'មាសខ្មៅ' នេះ ដោយពាក់ព័ន្ធក្រុមហ៊ុនអាមេរិក អូស្ត្រាលី ចិន ឥណ្ឌូណេស៊ី ជប៉ុន និងកូរ៉េ ដែលសុទ្ធតែប្រកួតប្រជែងរកសម្បទានដ៏មានលទ្ធភាពផ្ដល់ផលចំណេញច្រើន។

ប្លុកសម្បទានសមុទ្រទាំងអស់របស់ប្រទេសកម្ពុជា (ហៅថា A-F) ហើយនិងប្លុកដីគោក យ៉ាងហោចណាស់មួយប្លុក ត្រូវបានចែកទៅឲ្យក្រុមហ៊ុនខ្មែរ និងក្រុមហ៊ុនបរទេសរួចហើយ។ មានតែផ្ទៃទំហំ ២៧.០០០ គ.ម. ក្រឡា ប៉ុណ្ណោះ នៅក្នុងដែនសមុទ្រសៀមហៅថា តំបន់ទាមទារជាន់គ្នា (OCA) ដែលនៅតែមិនទាន់សម្រេចបាន ដោយសារមានទំនាស់រវាងប្រទេសថៃ និងប្រទេសកម្ពុជា អំពីតើអ្នកណាជាម្ចាស់ពិត។ ការពិភាក្សាដើម្បីដោះស្រាយទំនាស់នេះ រវាងរដ្ឋាភិបាលថៃ និងខ្មែរ បានចាប់ផ្ដើមជាថ្មីឡើងវិញ នៅក្នុងខែមេសា ឆ្នាំ ២០០៨។ ក៏ប៉ុន្តែ ភាពចលាចលនយោបាយពេលថ្មីនេះ នៅក្នុងប្រទេសថៃ រួមជាមួយនឹងជំលោះព្រំដែនរវាងប្រទេសទាំងពីរ មានន័យថា គ្មានការដោះស្រាយនៅជិតឡើយ។[៣៨] ទោះជាមានការទាល់ច្រកយ៉ាងនេះក៏ដោយ ក៏នៅក្នុងខែកញ្ញា ឆ្នាំ ២០០៨ CNPA បានចាប់ផ្ដើមចែកសម្បទានជាថ្មីម្ដងទៀត ចំពោះអាជ្ញាប័ណ្ណណាដែលបានផុសកំណត់ នៅក្នុងប្លុក OCA ដើម្បីជួយពង្រឹងដល់ការអះអាងទាមទាររបស់ខ្លួន ចំពោះធនធាននោះ។[៣៩] រដ្ឋាភិបាលមានផែនការបង្កើតរោងចក្រស្លប្រេងកាតតូចមួយនៅក្នុងស្រុក ទន្ទឹមពេលដែលអាជ្ញាធរប្រេងកាតជាតិកម្ពុជាចាប់ផ្ដើមនិយាយអំពីការបង្កើតក្រុមហ៊ុនប្រេងកាតជាតិមួយ។[៤០] ក្រុមហ៊ុនអាមេរិកាំង Chevron [សេវរ៉ន់][៤១] កាន់សិទ្ធិសម្បទាន សម្រាប់ប្លុក A – ដែលជាប្លុកដ៏នាំមុខគេបង្អស់ ក្នុងចំណោមប្លុកសមុទ្ររបស់ប្រទេសកម្ពុជា បើនិយាយអំពីការស្វែងរុករកប្រេង។ អ្នកសង្កេតឧស្សាហកម្ម រំពឹងគិតថា ការផលិតប្រេងនៅក្នុងប្លុកនេះ នឹងចាប់ផ្ដើមនៅក្នុងឆ្នាំ ២០១១។[៤២]

*“ភាពថ្លៃថ្នូរនៃមនុស្ស ភាពស្មើគ្នា ការបំពេញសេចក្ដីត្រូវការជាមូលដ្ឋាននៃប្រជាជនការចូលរួម ហើយនិងការអភិវឌ្ឍន៍នូវសមត្ថភាព និងការជ្រើសរើសរបស់ប្រជាជន នោះគឺស្ថិតក្នុងចំណោម គោលការណ៍ និងកម្មវត្ថុចម្បង នៃសិទ្ធិមនុស្ស។ គោលនយោបាយ និងដំណើរការខាងផ្នែក នយោបាយ និងសេដ្ឋកិច្ច នៅក្នុងប្រទេសកម្ពុជា គឺមិនផ្ដោតការសំខាន់អ្វីប៉ុន្មាន ចំពោះគុណសម្បត្តិ ទាំងនេះឡើយ។”*

សំដីដកស្រង់ពីសេចក្ដីថ្លែងទៅកាន់ក្រុមប្រឹក្សាសិទ្ធិមនុស្ស នៃអង្គការសហប្រជាជាតិ ដោយអ្នកតំណាងអគ្គលេខាធិការពិសេស សម្រាប់សិទ្ធិមនុស្ស ប្រចាំប្រទេសកម្ពុជា លោក យ៉ាស ហ្កាយ ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ ២០០៧។[៣]

## ប្រទេសកម្ពុជាសព្វថ្ងៃនេះ៖ ពីការពិសោធន៍ប្រជាធិបតេយ្យ ទៅជាចោរធិបតេយ្យគណបក្សតែមួយវិញ

ក្រោយពីសង្គ្រាមរាប់ទសវត្ស ហើយនិងព្រឹត្តិការណ៍ដ៏អាក្រក់បំផុតមួយនៅក្នុងប្រវត្តិមនុស្សលោកជំនាន់ថ្មីនេះ – គឺរបបខ្មែរក្រហម – បក្ខពួកតស៊ូប្រឆាំងគ្នាទាំងឡាយរបស់ប្រទេសកម្ពុជា បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាព នៅក្នុងឆ្នាំ ១៩៩១។ ការនេះ បាននាំឲ្យចាប់ផ្ដើមប្រតិបត្តិការរក្សាសន្តិភាពដ៏ធំ និងថ្លៃបំផុតមួយនៅក្នុងប្រវត្តិសាស្ត្រ ហើយជាការចាប់ផ្ដើមនៃកិច្ចប្រឹងប្រែងអន្តរជាតិ ដើម្បីនាំលទ្ធិប្រជាធិបតេយ្យ និងការអភិវឌ្ឍន៍មកកាន់ប្រទេសកម្ពុជា។ ការរំពឹងគិតថា ការបោះឆ្នោត ដែលរៀបចំដោយអង្គការ UN នៅក្នុងឆ្នាំ ១៩៩៣ នឹងនាំមកការផ្លាស់ប្ដូរផ្នែកនយោបាយយ៉ាងធំនោះ មិនបានក្លាយជាការពិតទេ។ គណបក្សប្រជាជនកម្ពុជា ដែលជាគណបក្សកាន់អំណាច ដែលអ្នកដឹកនាំសុទ្ធតែជាអតីតកម្មាភិបាលខ្មែរក្រហម នោះបានបដិសេធ មិនយល់ព្រមទទួលស្គាល់ថា គណបក្សខ្លួនឯងមិនបានជាប់ឆ្នោតទេ ហើយបានលុកចូលរដ្ឋាភិបាលដោយការបង្ខិតបង្ខំ។ ពួកគេបានបង្កើយនូវការដកថយក្រោយពីដំណើរឆ្ពោះទៅកាន់លទ្ធិប្រជាធិបតេយ្យ នៅក្នុងខែកក្កដា ឆ្នាំ ១៩៩៧ នៅពេលគេបានទម្លាក់ដៃគូរដ្ឋាភិបាលចម្រុះ នៅក្នុងរដ្ឋប្រហារមួយប្រកបដោយការបង្ហូរឈាម។[៤]

ឥឡូវនេះ ១៧ ឆ្នាំកន្លងផុតហើយ តាំងពីការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីស៍ ហើយប្រទេសដែលធ្លាប់ត្រូវគេស្គាល់ជាគំរូសម្រាប់ការកសាងជាតិក្រោយពីសង្គ្រាម ឥឡូវនេះបានក្លាយជារដ្ឋចោរធិបតេយ្យដ៏ថ្មីជាងគេ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ កេរ្តិ៍ឈ្មោះរបស់ប្រទេសនេះ ត្រូវបានប្រឡាក់ដោយសារការពុករលួយខ្លាតធំ ការបំពានសិទ្ធិមនុស្ស ការមិនដាក់ទោសពៃរ៍ ការគាបសង្កត់ និងអភិបាលកិច្ចខ្វះលក្ខណៈប្រជាធិបតេយ្យ។ ផ្ទុយពីបំណងនៃកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីស៍ឆ្នាំ ១៩៩១ អំណាចនយោបាយ និងទ្រព្យសម្បត្តិនៃប្រទេសកម្ពុជា សុទ្ធតែស្ថិតនៅក្នុងដៃនៃក្រុមវរជនកាន់អំណាចចំនួនតិច។ វិតិកម្មលើធនធានធម្មជាតិដ៏ថ្លៃវិសេសនៃប្រទេសជាតិ – គឺព្រៃឈើ ដី និងធនធានជលផល – គឺជាមូលដ្ឋានគ្រឹះនៃការប្រមូលទ្រព្យសម្បត្តិ និងអំណាចនយោបាយនេះ។


អគ្គនាយករដ្ឋមន្ត្រី ហ៊ុន សែន

## ប្រអប់ទី១ | ឈើខ្ជះខ្ជាយ – មេរៀននៃការកាប់ឈើខុសច្បាប់

នៅក្នុងទសវត្ស ១៩៩០ ព្រៃឈើរបស់ប្រទេសកម្ពុជា ត្រូវបានធនាគារពិភពលោកពិពណ៌នាជា 'ធនធានដ៏សំខាន់បំផុត សម្រាប់ការអភិវឌ្ឍន៍' របស់ប្រទេស។[៤៥] សព្វថ្ងៃនេះ វាខូចខាតយ៉ាងច្រើន។ អស់រយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ឈើមានតម្លៃជាច្រើន ត្រូវបានលក់ចេញ ដោយអ្នកនយោបាយធំខ្ពស់ ទៅកាន់ក្រុមហ៊ុនឯកជន ឬបុគ្គលដែលរកផលចំណេញឆាប់រហ័ស ដោយការកាប់ព្រៃឈើគ្មានកម្រិត។ ទ្រព្យសម្បត្តិភាគច្រើន ដែលបានមកពីការកាប់ឈើនេះ មិនបានចូលទៅក្នុងហិបរបស់ប្រទេសជាតិឡើយ គឺផ្ទុយទៅវិញ មើលទៅ វាបានចូលទៅក្នុងគណនីធនាគាររបស់អ្នកកាប់ព្រៃឈើ ហើយនិងអតិថិជននយោបាយរបស់គេ។[៤៦]



Global Witness បានចាប់ផ្ដើមបញ្ចេញឲ្យដឹងព័ត៌មាន អំពីការកាប់ព្រៃឈើខុសច្បាប់ នៅក្នុងប្រទេសកម្ពុជា ហើយនិងតំណភ្ជាប់នៃកិច្ចការនេះ ជាមួយនឹងជំលោះទាស់ទែង ការពុករលួយ និងការបំពានសិទ្ធិមនុស្ស នៅក្នុងឆ្នាំ ១៩៩៥។

ការស្រាវជ្រាវដំបូង បានបង្ហាញឲ្យឃើញថា នៅក្នុងប៉ុន្មានឆ្នាំចុងក្រោយនៃសង្គ្រាមស៊ីវិលរបស់ប្រទេសកម្ពុជា ទាំងខ្មែរក្រហម និងរដ្ឋាភិបាលភ្នំពេញ បានប្រើការកាប់លក់ឈើ ដើម្បីឧបត្ថម្ភយុទ្ធនាការ ហើយក៏បានប្រើយុទ្ធនាការជាលេស ដើម្បីកាប់ព្រៃឈើបន្ថែមទៀត។ ការស៊ើបអង្កេតបានបង្ហាញឲ្យឃើញថា មានការលក់ដូរឈើឆ្លងកាត់ព្រំដែន ជាមួយប្រទេសថៃ ដ៏មានតម្លៃ $១០–២០ លានក្នុងមួយខែ។ ក្រោយពីការបោះពុម្ពផ្សាយព័ត៌មាននេះ ព្រំដែនថៃត្រូវបានបិទមិនឲ្យឈើខ្មែរចូលទៀត – ការនេះបានផ្ដាច់ប្រភពដ៏សំខាន់មួយ នៃការឧបត្ថម្ភកងយោធាសម្រាប់សង្គ្រាមស៊ីវិល។

ក៏ប៉ុន្តែ នេះមិនមែនជាទីបញ្ចប់នៃការកាប់ឈើខុសច្បាប់ នៅក្នុងព្រៃឈើរបស់ប្រទេសកម្ពុជាទេ។ នៅក្នុងពាក់កណ្ដាលទសវត្ស ១៩៩០ មន្ត្រីរដ្ឋាភិបាលតំណែងខ្ពស់បានប្រគល់សម្បទានកាប់ឈើ ៣០ ទៅ ៤០ សម្បទាន ទៅកាន់ក្រុមហ៊ុនខ្មែរ និងបរទេស។ ព្រៃឈើជាងប្រាំពីរលានហ.ត. – គឺ ៣៩ ភាគរយនៃផ្ទៃដីរបស់ប្រទេសកម្ពុជា – ត្រូវប្រគល់ចេញ នៅក្នុងកិច្ចព្រមព្រៀងទាំងនេះ ដែលមានលក្ខណៈសទ្ធាណាស់ ចំពោះគោលបំណងនៃសម្បទានិក។[៤៧] សម្បទានិកទាំងអស់ បានបំពានច្បាប់ ឬលក្ខខណ្ឌនៃកិច្ចព្រមព្រៀងគេ ឬទាំងពីរ ដើម្បីច្រូតផលចំណេញយ៉ាងលឿន។ ដល់ទីបញ្ចប់នៃទសវត្សនោះ ក្រុមហ៊ុនទាំងនោះគឺជាភាគីប្រព្រឹត្តការកាប់ឈើខុសច្បាប់ភាគច្រើន នៅក្នុងប្រទេសកម្ពុជា។[៤៨]

នៅក្នុងគ្រានេះ បុគ្គលិកនៃក្រុមហ៊ុនទាំងនោះ បានប្រព្រឹត្តការបំពានសិទ្ធិមនុស្សយ៉ាងធ្ងន់ ទៅលើប្រជាជនដែលរស់នៅលើ ឬជិតដីសម្បទានព្រៃឈើ។ នេះមានរួមទាំងការហាមមិនឲ្យចូលតំបន់ព្រៃឈើ ការគំរាមកំហែង ការរំលោភផ្លូវភេទ ហើយ ក្នុងករណីយ៉ាងហោចណាស់មួយ ឃាតកម្ម។

នៅទីបំផុត ការគាបសង្កត់ពីទាយក និងអង្គការអន្តរជាតិ បាននាំឲ្យរដ្ឋាភិបាលកម្ពុជាព្យួរទុកប្រព័ន្ធកាប់ព្រៃឈើដោយ 'សម្បទានិក' នៅក្នុងឆ្នាំ ២០០២។ ក៏ប៉ុន្តែទោះបីមានការសន្យាឲ្យកែប្រែនៅក្នុងទីសាធារណៈក៏ដោយ ក៏រដ្ឋស្រមោលរបស់ប្រទេសកម្ពុជាបានបន្តរកប្រាក់ចំណេញពីវិស័យព្រៃឈើ។ មន្ត្រីដែលទទួលបន្ទុកអនុវត្តការកែទម្រង់ទាំងនេះ បានបែរជាធ្វើវិទ្ធង្សនាវិញ។ លទ្ធផលគឺថា ការកាប់ព្រៃឈើខុសច្បាប់បានបន្តដោយទម្រង់ផ្សេងៗ ហើយនៅតែបង្កការខូចខាតដ៏ធ្ងន់ធ្ងរ ទៅលើព្រៃឈើដែលនៅសល់របស់ប្រទេសកម្ពុជា។

ពួកវរជននយោបាយដដែល ដែលបានខ្ជះខ្ជាយធនធានព្រៃឈើរបស់ប្រទេសជាតិ ឥឡូវនេះមានភារកិច្ចគ្រប់គ្រងទ្រព្យសម្បត្តិជាតិរ៉ែ និងប្រេងកាតរបស់ប្រទេសជាតិដែរ។ ដូចជាឈើថ្លៃដែរ ធនធានទាំងនេះគឺជាឱកាសមានតែមួយពេលគត់។ ពេលណាវាអស់ គឺវាអស់ជានិច្ចហើយ។[៤៩]



ខាងលើ៖ កិច្ចព្រមព្រៀងសម្បទានព្រៃឈើ ចុះនៅឆ្នាំ ១៩៩៧ ដោយលោក សុខ អានដែលជាឧបនាយករដ្ឋមន្ត្រីកម្ពុជា និងប្រធាននៃ CNPA។ នៅកណ្ដាលទសវត្ស ៩០ លោកបានចុះកិច្ចព្រមព្រៀងប្រគល់ព្រៃ ៧ លាន ហ.ត. ឲ្យក្រុមហ៊ុនឯកជន ដោយលក្ខខណ្ឌដ៏សទ្ធាចំពោះបំណងរបស់ក្រុមហ៊ុនកាប់ឈើ។[៥០]
ខាងលើ(ក្រោម)៖ ឡានរបស់សម្បទានិក។ នៅទសវត្ស ៩០ សកម្មភាពនៃក្រុមហ៊ុនទាំងនេះ ធ្វើឲ្យធនធានព្រៃរបស់កម្ពុជា ចុះអន់ថយយ៉ាងធ្ងន់។

មន្ត្រីរដ្ឋាភិបាល អ្នកយោធាឋានៈធំ ហើយនិងសហការីអាជីវកម្មរបស់គេ ប្រើប្រាស់ប៉ូលិស និងកងយោធពល ដូចជាកងទ័ពឯកជនរបស់ខ្លួន ដោយមានគុណភាពតិចតួចណាស់ ពីប្រព័ន្ធតុលាការដែលត្រូវបានគ្រប់គ្រងដោយអ្នកនយោបាយ ឬពីសង្គមស៊ីវិល ដែលត្រូវបានបង្ក្រាបបន្តិចម្តងៗ អស់ប៉ុន្មានឆ្នាំនេះ ដោយការសម្លាប់ និងការគំរាមកំហែង។ មន្ត្រីរដ្ឋ និងអ្នកមានអំណាចនៅជុំវិញពួកគេ មានសមត្ថភាពដើម្បីចាប់យកធនធានធម្មជាតិ និងធនធានសេដ្ឋកិច្ច ព្រមទាំងទ្រព្យសម្បត្តិរបស់អ្នកដទៃ យាយីគូបដិបក្ខ ហើយបង្ក្រាបសិទ្ធិរបស់គេ។[៥១]

ធនធានធម្មជាតិរបស់ប្រទេសកម្ពុជា អាចផ្តល់មធ្យោបាយដើម្បីជំរុញសេដ្ឋកិច្ចជាតិក្រោយពីសង្គ្រាមបាន។ ផលចំណូលមកពីការកាប់ឈើ ចម្ការ និងធនធានជលផល អាចប្រើប្រាស់ដើម្បីបន្ធូរភាពក្រីក្រ ហើយកសាងឡើងវិញ នូវហេដ្ឋារចនាសម្ព័ន្ធចាំបាច់។ ប៉ុន្តែ ផ្ទុយទៅវិញ ការពុករលួយជាយថាក្រម ពាសពេញគ្រប់ស្ថាប័ន ព្រមទាំងការគ្រប់គ្រងសេដ្ឋកិច្ចដោយខុសឆ្គងនោះ បានដកហូតពីប្រជាជនទាំងអស់ នូវផលចំណូល ដែលកុំអីអាចកើតមកពីផលិតផលសាធារណៈទាំងនេះបាន។

## ដំណើរការ គឺជាការសំខាន់៖ ហេតុអ្វីបានជាការចែករំលែកសម្បទាន នៅក្នុងប្រទេសកម្ពុជា ជាការសំខាន់

ដល់សព្វថ្ងៃនេះ ការយកចិត្តទុកដាក់ភាគច្រើន លើវិស័យប្រេង និងជាតុរ៉ែ នោះបានផ្តោតលើ តើប្រាក់នឹងទៅណាខ្លះ នៅពេលដែលចាប់ផ្តើមបង្កើតផលចំណូល។ មានការនិយាយតិចតួចអំពីតើសម្បទានត្រូវប្រគល់ឲ្យអ្នកណាខ្លះរួចជាស្រេច ហើយដោយដំណើរការអ្វី។ ក៏ប៉ុន្តែ ទោះជាការពុករលួយ និងអំពើខុសច្បាប់ មាននៅក្នុងគ្រប់ដំណាក់កាលនៃការដកស្រង់ធនធានធម្មជាតិ ទាំងនៅក្នុងប្រទេសកម្ពុជាក្តី និងប្រទេសមានធនធានច្រើនដទៃទៀតក្តី ក៏ការពុករលួយតែងតែចាប់ផ្តើមត្រឹមចំណុចចូលដំណើរការមោលាធនធានធម្មជាតិ៖ គឺត្រឹមការចែកសម្បទានសម្រាប់ធនធាននោះឯង។

នៅកន្លែងណាដែលធនធានត្រូវបានចែករំលែកដោយពុករលួយនោះវាធ្វើឲ្យខូចរូបភាពពិតនៃទីផ្សារ។ ធម្មតា នេះនាំឲ្យមានការប្រើប្រាស់ធនធាន ដោយរបៀបដ៏មិនសូវមានប្រសិទ្ធិភាព ហើយបង្កលទ្ធផលអភិវឌ្ឍន៍ដ៏មិនល្អ។ ការចែករំលែកធនធានក៏ផ្លាស់ប្តូរសភាពការណ៍នយោបាយផងដែរ។ ផលចំណូលដែលរកបាន មកពីការចែករំលែកខុសឆ្គងនោះ បានពង្រឹងជំហរ និងការមិនទទួលទោសពៃរ៍ នៃពួកវរជន ហើយបានពង្រឹងជាបន្ថែមទៀត នូវសមត្ថភាពរបស់អ្នកទាំងនោះ ដើម្បីចាប់ប្រើដងគំនាស់នៃអំណាច៖ គឺរដ្ឋាភិបាល ច្បាប់ តុលាការ កងយោធពល ហើយនិងការិយាធិបតេយ្យ។ និយាយម្យ៉ាងទៀត ការចែករំលែកសម្បទានដោយភាពស្មើគ្នា គឺជាផ្នែកដ៏សំខាន់មួយ សម្រាប់ការអភិវឌ្ឍន៍រដ្ឋមួយ ដែលប្រតិបត្តិដើម្បីប្រយោជន៍នៃពលរដ្ឋខ្លួនឯង។ នៅពេលវិភាគមើលបញ្ហាតាមបែបនេះ ដំណើរការចែករំលែកសម្បទានសេដ្ឋកិច្ច នៅក្នុងវិស័យឧស្សាហកម្មប្រេង និងជាតុរ៉ែនៅក្នុងប្រទេសកម្ពុជា ក្លាយទៅជារឿងដ៏សំខាន់បំផុត។

នៅក្នុងរបាយការណ៍នេះ Global Witness ពិនិត្យមើលករណីផ្សេងៗ ក្នុងវិស័យដកស្រង់ដ៏កំពុងលូតឡើង របស់ប្រទេសកម្ពុជា ដោយមានគោលបំណងវាយតម្លៃការប្រព្រឹត្តរបស់រដ្ឋាភិបាលកម្ពុជា ហើយនិងក្រុមហ៊ុនជាដៃគូ ហើយស្វែងយល់ពីអនាគតលទ្ធភាព នៃផលចំណូលមកពីប្រេង និងជាតុរ៉ែ។

នៅក្នុងរបាយការណ៍នេះ Global Witness ពិនិត្យមើលករណីផ្សេងៗ ក្នុងវិស័យដកស្រង់ដ៏កំពុងលូតឡើង របស់ប្រទេសកម្ពុជា ដោយមានគោលបំណងវាយតម្លៃការប្រព្រឹត្តរបស់រដ្ឋាភិបាលកម្ពុជា ហើយនិងក្រុមហ៊ុនជាដៃគូ ហើយស្វែងយល់ពីអនាគតលទ្ធភាព នៃផលចំណូលមកពីប្រេង និងជាតុរ៉ែ។

## ប្រអប់ទី ២ | ការវិនិយោគលើដីធ្លី នៅក្នុងប្រទេសកម្ពុជា – ដូចជាការប្លន់អញ្ចឹង!

*"ការបណ្ដេញចេញនានាពេលថ្មីនេះ មានលក្ខណៈស្រដៀងគ្នា គួរឲ្យកត់សំគាល់។ ប៉ូលិសបង្រ្កាបបាតុកម្ម ប្រដាប់ដោយកាំភ្លើង ដំបងឆក់ ឧស្ម័នបង្ហៀរទឹកភ្នែក និងខែល ហ៊ុំព័ទ្ធជុំវិញកន្លែងបណ្ដេញចេញ មុនថ្ងៃរះ ដើម្បីឃាត់អ្នកសង្កេតសិទ្ធិមនុស្ស អ្នកសង្កេតអង្គការ U.N. ហើយនិងអ្នករាយការណ៍ព័ត៌មាន។ នៅក្នុងករណីជាច្រើន ប៉ូលិសគំរាមកំហែង ឬប្រើកម្លាំងបង្ខិតបង្ខំជ្រុល ឬមិនចាំបាច់ ដើម្បីដេញប្រជាជនចេញ ហើយបំផ្លាញផ្ទះរបស់គេ។"*

អង្គការ Human Rights Watch កត់សំគាល់អំពីការដេញប្រជាជនដោយបង្ខិតបង្ខំ នៅក្នុងប្រទេសកម្ពុជា ឆ្នាំ ២០០៦។[៥២]

ប្រទេសកម្ពុជាកំពុងស៊ូរងជំងឺចាប់ហូតដី។ រវាងឆ្នាំ ១៩៩៣ និង ១៩៩៩ រដ្ឋាភិបាលបានប្រគល់សម្បទានដីសេដ្ឋកិច្ច សម្រាប់ប្រហែលមួយភាគបី នៃដីដ៏បង្កើតផលច្រើនបំផុតរបស់ប្រទេស សម្រាប់ការអភិវឌ្ឍន៍ពាណិជ្ជកម្ម ដោយក្រុមហ៊ុនឯកជន។[53] តាំងពីគ្រានោះមក រដ្ឋាភិបាលនៅតែបន្តចែកសម្បទានដីយ៉ាងរហ័ស។ រដ្ឋាភិបាលរបស់សម្ដេច ហ៊ុន សែន បានបរិច្ចាគដីស្រែយ៉ាងធំសម្បើម និងដីឡូត៍ក្នុងទីក្រុង ដែលឥឡូវនេះសរុបមកគឺ ៤៥ ភាគរយនៃដីរបស់ប្រទេសកម្ពុជា។[54] អ្នកវិនិយោគត្រូវបានផ្ដល់អត្រាថ្លៃដ៏សទ្ធា និងការរួចពន្ធដារ។ ធម្មតា អ្នកដែលរស់នៅលើដីនោះស្រាប់ ត្រូវបានផ្ដល់ប្រយោជន៍ដ៏សទ្ធាតិចជាង ដោយជារឿយៗ ពួកគេត្រូវបានដេញចេញពីដីដោយបង្ខំ ដោយមិនសងអ្វីឡើយ។ លទ្ធផល គឺថាការចាប់ក្ដាប់ដីគឺជាដើមហេតុដ៏ធំបំផុតមួយ នៃការបំពានសិទ្ធិមនុស្ស និងការបង្កើតភាពក្រីក្រ នៅក្នុងប្រទេសកម្ពុជា ដោយមនុស្សរាប់ពាន់នាក់ត្រូវបានបណ្ដេញចេញពីដីរបស់ខ្លួន រៀងរាល់ឆ្នាំ។[៥៥] ជំនួសកិច្ចការពារពលរដ្ឋកម្ពុជា ពីផលអាក្រក់នៃការអភិវឌ្ឍន៍ពាណិជ្ជកម្ម ពួកសមត្ថកិច្ចអនុវត្តការដេញចេញ តាមបញ្ជាពីអ្នកដែលកាន់អំណាចសេដ្ឋកិច្ច និងនយោបាយវិញ។[56] ជនរងគ្រោះត្រូវបានបណ្ដេញចេញពីផ្ទះ និងដីរបស់ខ្លួន ដោយស្ថាប័នរដ្ឋ ដែលទទួលភារកិច្ចខាងផ្នែកប្រើប្រាស់កម្លាំង – គឺកងទ័ព កងអាវុធហត្ថ ឬប៉ូលិស – ធម្មតាដោយមិនសូវឲ្យដឹងមុន ឬមិនឲ្យដឹងមុនសោះ ដោយមិនផ្ដល់ទីជម្រកផ្សេងឲ្យរស់នៅ ហើយមិនផ្ដល់ផ្លូវដើម្បីរកយុត្តិធម៌ពិតឡើយ។ មានការរាយការណ៍ជាច្រើនដែរ អំពីការគំរាមកំហែង ការបន្លាច ការប្រើកម្លាំងជ្រុល និងការដុតផ្ទះ។



ការបណ្ដេញប្រជាជន៖ នាព្រឹកថ្ងៃទី ២០ ខែមេសា ឆ្នាំ ២០០៧ សមាជិកកងអាវុធហត្ថ ប៉ូលិស និងកងឃោធពលខេមរភូមិន្ទ ចំនួន ១៥០ នាក់ បានមកដល់ក្រុមទី ៦ នៅក្នុងសង្កាត់មិត្តភាព ក្រុងព្រះសីហនុ ប្រដាប់ដោយកាំភ្លើង ដំបងឆក់ ខែល និង ឧស្ម័នបង្ហៀរទឹកភ្នែក។ បន្ទាប់មក ពួកគេបានបណ្ដេញ ១០៥ គ្រួសារចេញពីភូមិនោះ។[៥៧]




[iii] ដោយសារការខ្វះតម្លាភាព នៅក្នុងវិស័យអាជីវកម្មរ៉ែនាបច្ចុប្បន្ន Global Witness មិនអាចបញ្ជាក់ពីស្ថានភាពផ្លូវច្បាប់ ឬប្រតិបត្តិការ នៃសម្បទានទាំងអស់នេះបានទេ។ ដូច្នេះ ផែនទីនេះគឺជាការប៉ាន់ស្មានអំពីស្ថានភាពនៃវិស័យអាជីវកម្មរ៉ែរបស់ប្រទេសកម្ពុជា តាមការចេះដឹងល្អបំផុតរបស់ Global Witness នៅក្នុងដើមឆ្នាំ ២០០៩។


ជំពូកទី ២
អាជីវកម្មរ៉ែ
global witness

# ជំពូកទី ២

# អាជីវកម្មរ៉ែ

ដល់សព្វថ្ងៃនេះ ឧស្សាហកម្មរ៉ែរបស់ប្រទេសកម្ពុជា បានអភិវឌ្ឍ ដោយសម្ងាត់ មិនសូវមានអ្នកណាចាប់អារម្មណ៍ទេ។ ក៏ប៉ុន្តែ អាជីវកម្មរ៉ែមានលទ្ធភាពសម្រាប់ការប៉ះពាល់យ៉ាងធំ ទៅលើ សេដ្ឋកិច្ច សង្គម និងបរិស្ថាន ដែលកន្លងមកត្រូវបានព្រងើយ កន្តើយមិនយកចិត្តទុកដាក់ ជាទូទៅ។

Global Witness បានចងក្រងបញ្ជីនៃអាជ្ញាប័ណ្ណស្វែងរុករកធន ធានរ៉ែ ដែលត្រូវបានប្រគល់ដោយរដ្ឋាភិបាល។ សំអាងលើ ព័ត៌មានពីប្រភពដើម និងប្រភពបន្ទាប់បន្សំ បានឲ្យដឹងថា រដ្ឋាភិបាលប្រទេសកម្ពុជា បានប្រគល់អាជ្ញាប័ណ្ណស្វែងរុករកធន ធានរ៉ែ សម្រាប់ជាង ១០០ កន្លែង ពាសពេញប្រទេស ហើយ ដំណើរការនេះ មើលទៅ ចាប់ផ្ដើមកើនល្បឿន។ Global Witness ដឹងអំពីអាជ្ញាប័ណ្ណអាជីវកម្មធនធានរ៉ែចំនួន ២១ សន្លឹក ដែលបានចែកនៅក្នុងឆ្នាំ ២០០៨។[៥៨] ក្រសួងមានសមត្ថកិច្ច ហើយនិងក្រុមហ៊ុន មិនសូវបើកព័ត៌មានឲ្យសាធារណជនដឹង អំពី ការចែកអាជ្ញាប័ណ្ណទាំងនេះសោះ។

Global Witness បានទៅដល់កន្លែងធ្វើអាជីវកម្មរ៉ែមួយចំនួន នៅ ក្នុងឆ្នាំ ២០០៨ ដើម្បីឃើញការអភិវឌ្ឍន៍អាជីវកម្មរ៉ែ ដោយផ្ទាល់ ភ្នែក។ អ្នកស៊ើបអង្កេតរបស់យើងបានរកឃើញភស្តុតាងថា ដូច ជាវិស័យព្រៃឈើពីមុន ការកាន់កាប់ ឬគ្រប់គ្រងនៃក្រុមហ៊ុន អាជីវកម្មរ៉ែទាំងនេះ ស្ថិតនៅក្នុងដៃនៃពួកវរជននៃរបបគ្រប់គ្រង ប្រទេស។ បើសិនជាអាជីវកម្មរ៉ែទាំងនេះចាប់ផ្ដើមដំណើរការពេញ លេញ គឺបុគ្គលទាំងនេះឯង ដែលនឹងទទួលផលប្រយោជន៍ខាង ផ្លូវហិរញ្ញវត្ថុ។

មានការពាក់ព័ន្ធកងយោធាកាន់តែច្រើនឡើង នៅក្នុងវិស័យ អាជីវកម្មរ៉ែ ដោយសមាជិកនៃកងយោធពលខេមរភូមិន្ទ ចូលរួម ក្នុងការយាមអាជីវកម្មរ៉ែប្រាំកន្លែង នៅក្នុងចំណោមប្រាំមួយកន្លែង ដែលអ្នកស៊ើបអង្កេតរបស់ Global Witness បានស្ទង់មើល នៅ ក្នុងខេត្តស្ទឹងត្រែង ព្រះវិហារ និងពោធិ៍សាត់។ នៅក្នុងករណីផ្សេង ទៀតមួយចំនួន មានគេរាយការណ៍ថា សមាជិកនៃ RCAF ជា ម្ចាស់ទទួលប្រយោជន៍ នៃក្រុមហ៊ុនដែលពាក់ព័ន្ធក្នុងសកម្មភាព អាជីវកម្មរ៉ែ។ នៅកន្លែងខ្លះ ដីត្រូវបានរឹបអូសពីអ្នកស្រុក ហើយ មានសេចក្ដីរាយការណ៍ អំពីករណីគំរាមកំហែងអ្នកស្រុកដែរ។ នៅក្នុងករណីទាំងអស់នេះ គ្មានការយល់ព្រមដោយសេរី ដោយ ការជ្រាបដឹងមុន ពីអ្នកស្រុកទាំងនេះសោះ។

រដ្ឋាភិបាលប្រទេសកម្ពុជាបានសម្រេចចិត្ត ដើម្បីឲ្យអាជីវកម្មរ៉ែមាន អាទិភាពជាងសេចក្ដីត្រូវការ និងកិច្ចការពារនៃបរិស្ថាន។ តាម និន្នាការបច្ចុប្បន្ន តំបន់ដែលពីមុនមិនទាន់មានអ្នកណាផ្សងប្រេង ស្វែងរុករងធនធាននៅឡើយ នៅក្នុងតំបន់ជួរភ្នំក្រវាញ ព្រៃឡង់ និងដែនជម្រកសត្វព្រៃភ្នំក្រសោប នោះនឹងត្រូវបានធ្វើឲ្យខូចខាត ឬបំផ្លិចបំផ្លាញជាអចិន្ត្រៃយ៍។ នៅក្នុងចំណោមតំបន់ការពារទាំង ២៣ តំបន់របស់ប្រទេសកម្ពុជា មានយ៉ាងហោចណាស់ ៦ តំបន់ ដែលមានសកម្មភាពអាជីវកម្មរ៉ែប្រភេទណាមួយ កំពុងតែកើត ឡើងនៅក្នុងខ្សែព្រំដែនតំបន់។[iv] នៅពេលដែលអាជីវកម្មរ៉ែទាំង នេះ ចាប់ផ្ដើមដំណើរការយ៉ាងពេញលេញ ហើយផ្លូវត្រូវបានឆ្ការ ទៅកាន់កន្លែងទាំងនោះ តំបន់ធំធេង នៃព្រៃឈើដែលពីមិនគ្មាន អ្នកណាប៉ះពាល់សោះ នឹងត្រូវបានបើកឡើង ដើម្បីស៊ូរងការគំរាម កំហែងផ្សេងៗទៀត ដូចជាការកាប់ព្រៃឈើខុសច្បាប់ និងការ សម្លាប់សត្វព្រៃខុសច្បាប់ជាដើម។

ផ្នែកដូចតទៅនេះ ផ្ដល់ព័ត៌មានបន្ថែម ដើម្បីគាំទ្រការសន្និដ្ឋាន ទាំងនេះ។

---

[iv] តំបន់អភិរក្សទាំងនេះ គឺ៖ ឧទ្យានជាតិវីរៈជ័យ តំបន់ប្រើប្រាស់ច្រើនយ៉ាង សំឡូត ហើយនិងដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ភ្នំពេជ្រ ភ្នំសំកុះ និងពាមក្រសោប។

## ការដាក់កម្រិតលើអាជីវកម្មរ៉ែ នៅក្នុងប្រទេសកម្ពុជា

*"រដ្ឋត្រូវរក្សាការពារបរិស្ថាន និង តុល្យភាពនៃភោគទ្រព្យធម្មជាតិ ហើយត្រូវចាត់ចែងឲ្យមានផែនការច្បាស់លាស់ ក្នុងការគ្រប់គ្រង មានជាអាទិ៍ ដីធ្លី ទឹក អាកាស ខ្យល់ ភូគព្ភសាស្ត្រ ប្រព័ន្ធអេកូឡូស៊ី រ៉ែ ថាមពល ប្រេងកាត និងឧស្ម័ន ថ្ម និងខ្សាច់ ត្បូងថ្ម ព្រៃឈើ និងអនុផលព្រៃឈើពពួកសត្វព្រៃ មច្ឆាជាតិ ធនធានជលផល"*

មាត្រាទី ៥៩ នៃរដ្ឋធម្មនុញ្ញប្រទេសកម្ពុជា

*"ក្រុមហ៊ុនគ្រាន់តែដើរក្នុងព្រៃ ហើយខួងដីខ្លះ ដើម្បីសាករកជាតុរ៉ែប៉ុណ្ណោះ។"*

ប្រសាសន៍របស់ឯកឧត្តម ស៊ុយ សែម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឆ្លើយទៅកាន់ NGO ដែលសូមវិធានការដ៏តឹងរឹងជាង ក្នុងការគ្រប់គ្រងវិស័យរ៉ែ តាមការរាយការណ៍របស់កាសែត *Cambodia Daily* ថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ ២០០៨។[៥៩]

នៅក្រោមរដ្ឋធម្មនុញ្ញរបស់ប្រទេសកម្ពុជា ធនធានរ៉ែទាំងអស់ គឺជាទ្រព្យរបស់រដ្ឋ ហើយត្រូវបានគ្រប់គ្រងដោយច្បាប់។[៦០] ច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ ឆ្នាំ ២០០១ ហើយនិង ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ឆ្នាំ ១៩៩៦ គឺជាគោលនយោបាយ ដែលគួរគប្បីជាមូលដ្ឋានដែលការស្វែងរុករកជាតុរ៉ែទាំងអស់ នៅក្នុងប្រទេសកម្ពុជាសំអាងលើនោះ។ នៅក្នុងប្រព័ន្ធច្បាប់របស់ប្រទេសកម្ពុជា ច្បាប់ត្រូវបានអធិប្បាយបន្ថែម ដោយអនុក្រឹត្យ និងប្រកាស[v] ដែលផ្តល់សេចក្តីលំអិតបន្ថែម អំពីទម្រង់បែបបទ ដើម្បីទទួលសម្បទានរ៉ែ។[៦១] ឯកសារទាំងនេះមិនបានផ្តល់ជូនឲ្យសាធារណជនមើលទេ ក៏ប៉ុន្តែ Global Witness បានទទួលសំណៅនៃអនុក្រឹត្យ និងប្រកាសខ្លះៗ។ ឯកសារទាំងនេះ អាចទាញយក ពី http://www.globalwitness.org/media_library_detail.php/691/en/cambodia_mining_legislation បាន។ Global Witness ខ្វល់ខ្វាយត្រង់ថា ច្បាប់ស្តីពីការគ្រប់គ្រងជាតុរ៉ែ គឺខ្សោយ មិនទៀងទាត់ មានចន្លោះធំ ហើយអនុវត្តដោយមិនសូវបានល្អទេ។

[v] អនុក្រឹត្យ គឺត្រូវបានអនុម័តដោយក្រុមប្រឹក្សារដ្ឋមន្ត្រី ហើយចុះហត្ថលេខាដោយអគ្គនាយករដ្ឋមន្ត្រី។ អនុក្រឹត្យត្រូវតែសមស្របយ៉ាងតឹងរឹង ជាមួយនឹងច្បាប់យោង។ ប្រកាស គឺជាការសម្រេចចិត្តដោយក្រសួងមួយ ឬក្រសួងច្រើន ដែលចុះហត្ថលេខាដោយរដ្ឋមន្ត្រីមានសមត្ថកិច្ច។ សេចក្តីប្រកាស ត្រូវតែសមស្របនឹងរដ្ឋធម្មនុញ្ញ ព្រមទាំងច្បាប់ ឬអនុក្រឹត្យយោង។ (http://cambodia.ohchr.org/klc_pages/klc_english.htm)

## អាជ្ញាប័ណ្ណដើម្បីខួង?

ច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ឆ្នាំ ២០០១ ចែងថា 'ស្ថាប័នមានសមត្ថកិច្ច' ត្រូវគ្រប់គ្រងធនធានរ៉ែទាំងនេះ ហើយមានភារកិច្ចដើម្បីចែកអាជ្ញាប័ណ្ណស្វែងរុករក ឬធ្វើអាជីវកម្មធនធានរ៉ែ។ នៅពេលបច្ចុប្បន្ននេះ ស្ថាប័នមានសមត្ថកិច្ចនេះ ត្រូវបានចាត់ទុកថា ជាក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល (MIME)។[៦២] ក៏ប៉ុន្តែ ក្រុមហ៊ុនរ៉ែណាដែលចង់ធ្វើប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា ក៏ត្រូវតែដាក់ពាក្យសុំដល់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) សម្រាប់សម្បទានរ៉ែ។ ក្របខណ្ឌច្បាប់ សម្រាប់របៀបដែលក្រុមហ៊ុនទាំងនេះទទួលសម្បទាន គឺមិនច្បាស់លាស់ទេ ប៉ុន្តែបុគ្គលិកម្នាក់របស់ MIME បានអះអាងថា ការសម្រេចចិត្តត្រូវបានធ្វើឡើង នៅក្នុងការប្រជុំថ្នាក់ខ្ពស់ រវាងមន្ត្រី MIME និងមន្ត្រី CDC។[៦៣] ក្រៅពីភាពស្រពិចស្រពិល អំពីរបៀបប្រគល់សម្បទាន ក៏វាមិនច្បាស់ដែរថា តើសម្បទានទាំងនេះត្រូវបានប្រើយ៉ាងដូចម្តេច អ្នកណាគ្រប់គ្រងវា ហើយវាទាក់ទងនឹងអាជ្ញាប័ណ្ណធនធានរ៉ែយ៉ាងដូចម្តេចនោះទេ។ នៅពេលបច្ចុប្បន្ននេះ សម្បទានរ៉ែត្រូវបានប្រគល់នៅក្នុង ឬមុន ដំណាក់កាលស្វែងរុករក ពីមុនកិច្ចព្រមព្រៀងដកយកធនធានរ៉ែត្រូវបានចុះហត្ថលេខា។ ដីសម្បទានមួយចំនួនច្រើន មានទំហំធំលើសពីទំហំអតិបរមាដែលកំណត់តាមច្បាប់។[៦៤]

## អ្នកណាជាម្ចាស់ដី?

កង្វះដែលគួរឲ្យព្រួយបារម្ភបំផុតមួយ នៅក្នុងកម្រងច្បាប់ស្តីអាជីវកម្មរ៉ែ គឺជាការខ្វះវិធានការជួយអ្នកដែលត្រូវបានបណ្តេញចេញពីដីធ្លី ដោយសារប្រតិបត្តិការធនធានរ៉ែ។ ច្បាប់ចែងថា មុនសម្បទានិកអាចចូលទៅក្នុងដីដែលជាកម្មសិទ្ធិឯកជន ដើម្បីស្វែងរុករក ឬជីកយកធនធានរ៉ែ សម្បទានិកត្រូវតែទូទាត់សង 'ម្ចាស់កម្មសិទ្ធិដីធ្លី' សម្រាប់ការខូចខាតដែលកើតមាននៅលើដីធ្លី។[៦៥]



រដ្ឋមន្ត្រីខាងរ៉ែ ឯកឧត្តម **ស៊ុយ សែម** (នៅក្នុងរូបថត)[៦៦] មានភារកិច្ចដើម្បីចែកអាជ្ញាប័ណ្ណអាជីវកម្មរ៉ែ នៅក្នុងប្រទេសកម្ពុជា។ Global Witness បានទទួលដំណឹងថា ភរិយារបស់ឯកឧត្តម លោកជំទាវ **ជា ខេង**[៦៧] គឺជាម្ចាស់ទទួលប្រយោជន៍ នៃការដ្ឋានអាជីវកម្មរ៉ែ យ៉ាងតិចណាស់មួយកន្លែង នៅក្នុងខេត្តពោធិ៍សាត់ ប្រទេសកម្ពុជា។ លោកជំទាវត្រូវបានគេរាយការណ៍ថា ជាអ្នកមានអំណាចច្រើន ហើយត្រូវបានគេដឹងថា ជាមនុស្សជំនិតនឹងលោកជំទាវ **ប៊ុន រ៉ានី** ដែលជាភរិយារបស់អគ្គនាយករដ្ឋមន្ត្រី **ហ៊ុន សែន**។[៦៨]

ម្ចាស់កម្មសិទ្ធិដីធ្លីឯកជន និយាយសំដៅទៅអ្នកដែលមានប័ណ្ណកម្មសិទ្ធិ នៅក្នុងបញ្ជីសុរិយោដី។ ដោយសារមានការផ្លាស់ទីកន្លែងដ៏មហាធំធេង នៅក្នុងជំនាន់ខ្មែរក្រហម គ្រួសារភាគច្រើននៅក្នុងប្រទេសកម្ពុជា មិនមានប័ណ្ណកម្មសិទ្ធិស្របច្បាប់ សម្រាប់ដីធ្លីដែលគេរស់នៅនោះទេ។ ដូច្នេះ ពួកគេមានកិច្ចការពារតិចតួចណាស់ ពីសកម្មភាពនៃក្រុមហ៊ុនរ៉ែ ដែលចង់ស្វែងរុករកនៅលើដីធ្លី ដែលពួកគេពឹងពាក់ ដើម្បីជីវភាពរបស់ខ្លួន។[69] តាមការពិត អ្នកដែលគ្មានប័ណ្ណកម្មសិទ្ធិស្របច្បាប់ ឬកម្មសិទ្ធិជនជាតិដើមភាគតិច នៅគួរតែគប្បីទទួលកិច្ចការពារ ដោយសាររដ្ឋាភិបាលកម្ពុជាបានអនុម័តកិច្ចព្រមព្រៀងអន្តរជាតិ ស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ (ICESCR) ដែលមានរួមទាំងកាតព្វកិច្ចគោរពសិទ្ធិរបស់ពលរដ្ឋ ដើម្បីមានផ្ទះសម្បែងល្មមគ្រប់គ្រាន់ ហើយហាមឃាត់ចំពោះការបំផ្លាញដីធ្លី ដែលចាំបាច់ដើម្បីចិញ្ចឹមជីវិត។ ក៏ប៉ុន្តែ ដូចបានឃើញជាច្រើនដងពីមុនហើយ ស្ថាប័នរដ្ឋដែលមានភារកិច្ចខាងផ្នែកការអនុវត្តកិច្ចព្រមព្រៀងទាំងនេះ ជារឿយៗបានព្រងើយកន្តើយ ហើយធ្វើវិទ្ធង្សនា ចំពោះកិច្ចព្រមព្រៀងទាំងនេះ (សូមមើលប្រអប់ទី ១, ២, ៥ និង ៦)។

## ការផ្តល់ព័ត៌មាន

គំរូវការផ្លូវច្បាប់ ស្តីពីលទ្ធភាពមើលព័ត៌មាន នៅក្នុងវិស័យឧស្សាហកម្មរ៉ែរបស់ប្រទេសកម្ពុជា គឺស្មុគស្មាញណាស់។ ច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ ឆ្នាំ ២០០១ ចែងដោយជាក់ស្តែងថា គ្រប់លិខិតស្នើសុំ របាយការណ៍ ផែនការ និងលិខិតជូនដំណឹង ស្តីពីអាជីវកម្មរ៉ែ នោះត្រូវរក្សាជាការសម្ងាត់។[70] នេះមានន័យថា តាមការពិត កង្វះតម្លាភាពត្រូវបានរួមបញ្ចូលនៅក្នុងក្របខណ្ឌច្បាប់ ហើយនេះធ្វើឲ្យមានលទ្ធភាពថា ពលរដ្ឋខ្មែរអាចបាត់បង់ដីធ្លីដែលគេរស់នៅ ទៅកាន់ក្រុមហ៊ុនមួយដែលគេមិនដឹងអ្វីសោះអំពីក្រុមហ៊ុននោះ ដោយសាររដ្ឋរក្សាព័ត៌មាននោះជាការសម្ងាត់។ ផ្ទុយទៅវិញ ច្បាប់បរិស្ថានចែងថា តាមការស្នើសុំរបស់សាធារណជន ក្រសួងបរិស្ថាន (MoE) ត្រូវផ្តល់ព័ត៌មានស្តីពី 'សកម្មភាព' នៃក្រុមហ៊ុនណាមួយតាមសំណើ ហើយត្រូវលើកទឹកចិត្តការចូលរួមរបស់សាធារណជន នៅក្នុងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។[71]

## តំបន់អភិរក្ស គឺមិនមែនបំពាន់អត់បាននោះទេ"

*"ប្រសាសន៍របស់ឯកឧត្តម... ស្តាប់ទៅ ដូចជាមានអត្ថន័យថា កិច្ចខំប្រឹងប្រែងទាំងអស់ ដែលរដ្ឋាភិបាល និងអង្គការអភិរក្សបានធ្វើកន្លងមក ប្រហែលជាអត់បានប្រយោជន៍សោះ។"*
សំដីដកស្រង់ចេញពីសំបុត្ររួម មកពី NGO មួយចំនួន ចុះថ្ងៃទី ៣១ ខែតុលា (សូមមើលខាងក្រោម)។[៧២]

ច្បាប់ស្តីពីអាជីវកម្មរ៉ែ គឺកាន់តែស្រពិចស្រពិល នៅពេលទាក់ទងនឹងអាជីវកម្មរ៉ែ នៅក្នុងតំបន់ដែលត្រូវបានច្បាប់កម្ពុជាកំណត់ជាតំបន់ 'ការពារ' ដោយសារតម្លៃអភិរក្ស និងភាពសម្បូរណ៍បែបសត្វនិងរុក្ខជាតិ នៅក្នុងតំបន់ទាំងនោះ។

តំបន់ការពារទាំង ២៣ តំបន់របស់ប្រទេសកម្ពុជា ត្រូវបានបង្កើតនៅក្នុងឆ្នាំ ១៩៩៣ ដោយរាជក្រឹត្យ។ រួមគ្នា តំបន់ទាំងនេះមានផ្ទៃដីសរុបជាង ៣២.២៨៩ គ.ម. ក្រឡា។173 នាយកដ្ឋានការពារ និងអភិរក្សធម្មជាតិ នៅក្នុង MoE គឺជាស្ថាប័នដែលមាននាមត្រួតពិនិត្យតំបន់ទាំងនេះ។[៧៤]

*"នៅពេលដែលយើងបានបង្កើត [ប្រព័ន្ធតំបន់ការពារ] យើងមិនបានដឹងអំពីសក្តានុពល នៃធនធានធម្មជាតិរបស់យើង ទ្រព្យមានតម្លៃរបស់យើងទេ... បើខ្ញុំទទួលស្គាល់ការអភិរក្សនូវតំបន់នេះ ដែលជាតំបន់ស្ងួល ប្រសិនបើយើងអាចរកបានមួយពាន់លានដុល្លារ ដោយសារអាជីវកម្មរ៉ែនៅទីនោះ តើយើងអាចធ្វើអាជីវកម្មបានរាប់លានដុល្លារនោះម៉េចកើត?"*

ប្រសាសន៍របស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន ឯកឧត្តម ម៉ុក ម៉ារ៉េត ដកស្រង់នៅក្នុងអត្ថបទកាសែត *Cambodia Daily* មានចំណងជើង 'Conservation Areas Not Inviolable, Says Minister' [តំបន់អភិរក្ស គឺមិនមែនបំពាន់អត់បាននោះទេ ប្រសាសន៍របស់រដ្ឋមន្ត្រី]។[៧៥]



ព្រៃឈើដែលបានរួចខ្លួនពីការកាប់ឈើខុសច្បាប់ ឥឡូវនេះប្រឈមមុខនឹងគ្រោះថ្នាក់ មកពីសកម្មភាពអាជីវកម្មរ៉ែវិញ

នៅក្នុងខែសីហា ឆ្នាំ ២០០៦ ប្រកាសស្ដីពីតំបន់ការពារ ឆ្នាំ ១៩៩៤ – ដែលនៅក្រោមច្បាប់នោះ អាជីវកម្មរ៉ែត្រូវបានហាមឃាត់នៅក្នុងតំបន់ការពារកន្លងមក – ត្រូវបានទុកជាមោឃៈ យ៉ាងសម្ងាត់។[៧៦] ដោយសារច្បាប់ស្ដីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ ឆ្នាំ ២០០១ មិនបានហាមឃាត់អាជីវកម្មរ៉ែ នៅក្នុងតំបន់ទាំងនេះ ដោយជាក់លាក់ទេ តំបន់ការពាររបស់ប្រទេសកម្ពុជា កំពុងស្ថិតក្នុងស្ថានភាពស្រពិចស្រពិល។[៧៧]

ការខ្វះកិច្ចការពារផ្លូវច្បាប់ពីអាជីវកម្មរ៉ែ នៅក្នុងតំបន់ការពារ នោះត្រូវបានគេឆ្លៀតឱកាសយ៉ាងឆាប់រហ័ស ហើយរវាងខែសីហា ឆ្នាំ ២០០៦ និង ខែមករា ឆ្នាំ ២០០៨ Global Witness បានសង្កេតឃើញនូវការចាប់ផ្ដើមនៃប្រតិបត្តិការធនធានរ៉ែ នៅក្នុងតំបន់ការពារចំនួនប្រាំតំបន់ របស់ប្រទេសកម្ពុជា។ [៧៨] ស្ថានភាពនេះធ្ងន់ជាពិសេស នៅក្នុងខេត្តមណ្ឌលគីរី តំបន់មួយដែលមានព្រៃឈើច្រើន នៅទិសខាងឦសាន នៃប្រទេសកម្ពុជា ដែលនៅទីនោះមានការចែកសម្បទានរ៉ែចំនួនច្រើនហើយ។ ផ្ទៃដី ២៨២.៧០០ ហ.ត. នៃដីសម្បទានរ៉ែទាំងនេះ ស្ថិតនៅក្នុងតំបន់ការពារ – គឺ ២១ ភាគរយនៃផ្ទៃដីសរុប នៃតំបន់ការពារទាំងអស់របស់ខេត្តនោះ។[៧៩]

ភាពស្មុគស្មាញអំពីស្ថានភាពនៃតំបន់ការពារ គួរណាស់តែត្រូវបានធ្វើឲ្យច្បាស់ឡើង ដោយច្បាប់តំបន់ការពារថ្មី ដែលត្រូវបាននិពន្ធឡើង ដោយជំនួយបច្ចេកទេសពី 'គម្រោងគ្រប់គ្រងជីវៈចំរុះ និងតំបន់ការពារធម្មជាតិ' របស់ធនាគារពិភពលោក ហើយដែលត្រូវបានអនុម័តនៅក្នុងខែមករា ឆ្នាំ ២០០៨។[80]

ច្បាប់ថ្មីចែងឲ្យតំបន់ការពារនីមួយៗ ត្រូវបានបែងចែកជាតំបន់គ្រប់គ្រងបួនប្រភេទៈ តំបន់ស្នូល តំបន់អភិរក្ស តំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍។ នៅក្រោមច្បាប់នេះ តំបន់ការពារនីមួយៗ ដំបូងត្រូវអនុវត្តដំណើរការបែងចែកទឹកដីទៅជាតំបន់គ្រប់គ្រង បន្ទាប់មកអាចអនុញ្ញាតឲ្យសកម្មភាពយករ៉ែកើតឡើងបាន ប៉ុន្តែបានតែនៅក្នុងតំបន់គ្រប់គ្រង ដែលត្រូវបានកំណត់ជា 'តំបន់ប្រើប្រាស់ដោយចីរភាព' ប៉ុណ្ណោះ។[៨១] ក្រោយពីការពិគ្រោះជាមួយក្រសួង អាជ្ញាធរ និងសហគមន៍ដ៏មានសមត្ថកិច្ចទាំងឡាយ រដ្ឋាភិបាលកម្ពុជាអាចអនុញ្ញាតឲ្យមានសកម្មភាពអភិវឌ្ឍន៍ និងវិនិយោគ នៅក្នុងតំបន់នោះបាន ប៉ុន្តែឲ្យតែបានស្របតាមសំណើពី MoE ប៉ុណ្ណោះ។[៨២]

ក៏ប៉ុន្តែ ការពិភាក្សាអំពីអត្ថន័យបកស្រាយនៃច្បាប់នេះ មើលទៅត្រូវបានក្លាយជារឿងអរូបីតែប៉ុណ្ណោះ ដោយសារកិច្ចការរបស់រដ្ឋាភិបាល។ បន្ទាប់ពីការអនុម័តច្បាប់នោះភ្លាម រដ្ឋាភិបាលបានប្រគល់សិទ្ធិស្វែងរុករកឲ្យក្រុមហ៊ុនរ៉ែមួយចំនួន នៅក្នុងតំបន់ការពារភ្នំក្រវ៉ាញ និងឧទ្យានជាតិវីរៈជ័យ – ខ្លះនៅក្នុងតំបន់គ្រប់គ្រង ដែលពីមុនត្រូវបានកំណត់ជាតំបន់ស្នូល នៃតំបន់ការពារ។ នៅក្នុងករណីទាំងនេះភាគច្រើន គ្មានការពិគ្រោះជាមួយ MoE ទេ ហើយក្រសួងនោះមិនបានដឹងអំពីផែនការធ្វើអាជីវកម្មរ៉ែ នៅក្នុងតំបន់ទាំងនោះទេ។[៨៣]

នៅពេលរឿងនេះ ត្រូវបានគេលើកឡើងនិយាយ នៅក្នុងការប្រជុំរវាងអ្នកវិស័យអាជីវកម្មរ៉ែ NGO និង MoE នៅក្នុងខែធ្នូ ឆ្នាំ ២០០៧ អង្គការដែលមានការខ្វល់ខ្វាយត្រូវបានប្រាប់ថា ផែនការជាតិ ស្ដីពីការអភិវឌ្ឍន៍វិស័យធនធានរ៉ែ នឹងត្រូវបានបង្កើតមុនសិន ហើយមានតែក្រោយពីនោះប៉ុណ្ណោះ ទើបនឹងមានការសម្រេចចិត្តអំពី តើតំបន់ណាខ្លះ ដែលត្រូវកំណត់ជាតំបន់ដែលអាចមានសកម្មភាពពាណិជ្ជកម្មបាន។[៨៤] និយាយពាក្យម្យ៉ាងទៀត ការបែងចែកតំបន់ការពារនឹងសំអាងលើកត្តាតម្លៃសេដ្ឋកិច្ច មិនមែនតម្លៃបរិស្ថានទេ ហើយសកម្មភាពនឹងកំណត់ការអនុវត្តច្បាប់ មិនមែនផ្ទុយវិញទេ។ គោលនយោបាយនេះ កំពុងតែប៉ះពាល់តំបន់ការពារសំខាន់មួយចំនួនហើយ រួមទាំង ប៉ុន្តែមិនកំណត់ចំពោះឧទ្យានជាតិវីរៈជ័យ។

## ប្រអប់ទី ៣ ៖ ការធ្វើអាជីវកម្មរ៉ែ នៅក្នុងឧទ្យានជាតិវីរៈជ័យ

ទោះបីតំបន់ការពារទាំងឡាយរបស់ប្រទេសកម្ពុជា ត្រូវបានចុះអន់ថយយ៉ាងខ្លាំង ដោយសារការកាប់ព្រៃឈើខុសច្បាប់ អស់ប៉ុន្មានឆ្នាំកន្លងមកនេះក៏ដោយ ក៏តំបន់ការពាររបស់ប្រទេសកម្ពុជា នៅតែមានតម្លៃបរិស្ថានយ៉ាងខ្ពស់នៅឡើយ។ មានជំពូកសត្វតំណាង[vi] ចំនួនច្រើនណាស់នៅក្នុងប្រទេសកម្ពុជា ហើយមានជំពូកថនិកសត្វ ត្រី និងសត្វស្លាបដ៏រងគ្រោះដាច់ពូជ ជាច្រើនជំពូក ជាងប្រទេសអាស៊ីអាគ្នេយ៍ឯទៀតៗ ទាំងអស់។[៨៥]

ដោយទទួលស្គាល់ហេតុការណ៍នេះ ធនាគារពិភពលោក បានសហការជាមួយរដ្ឋាភិបាលកម្ពុជា រវាងឆ្នាំ ២០០០ និង ២០០៧ នៅក្នុងគម្រោងមួយ ដើម្បីគ្រប់គ្រងតំបន់ទាំងនេះ ដោយប្រសិទ្ធិភាពកាន់តែច្រើនឡើង។ ហៅថាគម្រោងគ្រប់គ្រងជីវៈចំរុះ និងតំបន់ការពារធម្មជាតិ ឬ BPAMP គម្រោងនេះមានគោលបំណងនឹង 'អភិវឌ្ឍប្រព័ន្ធតំបន់ការពារប្រចាំជាតិ ដ៏មានប្រសិទ្ធិភាព ដែលសំអាងលើទម្រង់បែបបទមួយក្រុមដ៏ទៀងទាត់ ហើយដាក់លាក់ក្បោះក្បាយ ខាងផ្នែកការគ្រប់គ្រងហិរញ្ញវត្ថុ និងស្ថាប័ន '។ គម្រោង BPAMP មានទំហំធំណាស់ – អស់ថវិកាជិត US$៥ លាន ដែលឧបត្ថម្ភភាគច្រើន ដោយប្រាក់កម្ចីពីធនាគារពិភពលោក ហើយអំណោយប្រាក់ពីអង្គការមូលនិធិបរិស្ថានពិភពលោក។[៨៦]

តំបន់យកចិត្តទុកដាក់ សម្រាប់ BPAMP គឺឧទ្យានជាតិវីរៈជ័យ តំបន់ការពារទំហំ ៣.៣២៥ គ.ម. ក្រឡា នៅក្នុងខេត្តរតនគិរី និងស្ទឹងត្រែង នៅក្នុងផ្នែកខាងឦសាន នៃប្រទេសកម្ពុជា។ ឧទ្យានជាតិវីរៈជ័យ មានសត្វ និងរុក្ខជាតិជាច្រើនមុខណាស់ ដោយមានជំពូកសត្វតំណាងជាច្រើនជំពូក ដូចជាដំរីអាស៊ី ហើយនិងខ្លាឃ្មុំ ហើយក៏ជាមជ្ឈដ្ឋានសម្រាប់ជំពូកសត្វរងគ្រោះដាច់ពូជ ដូចជាសត្វល្មងជាដើម។[៨៧] មជ្ឈដ្ឋានសត្វច្រើនបែបយ៉ាង តាំងពីព្រៃស្មៅខ្ពស់ ទៅប្រព័ន្ធបរិស្ថានតំបន់ភ្នំនោះ បង្កើតជាទេសភាពមួយដ៏មានជីវៈចំរុះច្រើន។ ឧទ្យាននេះ ក៏មានតម្លៃសំខាន់ជាតំបន់ទីប្រមូលទឹក។ ទឹកពីឧទ្យានជាតិហូរចូលទន្លេសាន និងកុង ហើយរួមជាមួយប្រព័ន្ធទន្លេស្រែពក នោះវាផ្ដល់ ២០ ភាគរយនៃទឹកដែលហូរក្នុងទន្លេមេកុង។[៨៨] ម្យ៉ាងទៀត តំបន់នេះមានក្រុមជនជាតិភាគតិចមួយចំនួន ដែលពឹងពាក់លើធនធាននៃតំបន់វីរៈជ័យ ដើម្បីចិញ្ចឹមជីវភាព។[៨៩]

កិច្ចការរបស់គម្រោង BPAMP នៅទីនោះ មានរួមទាំងការបង្កើតយុទ្ធសាស្ត្រប្រាំឆ្នាំដើម្បីជំរុញទេសចរណ៍បរិស្ថាន ការព្រមព្រៀងគ្នាអំពីព្រំដែននៃតំបន់ការពារសហគមន៍ទាំងបួនតំបន់ ហើយនិងការបង្កើតច្បាប់ស្ដីពីតំបន់ការពារសហគមន៍។[៩០] ការប្រឹងប្រែងទាំងអស់នេះ បានរងគ្រោះថ្នាក់ទាំងស្រុង នៅពេល ក្នុងឆ្នាំ ២០០៧ រដ្ឋាភិបាលបានប្រគល់សិទ្ធិស្វែងរុករក សម្រាប់ផ្ទៃដីទំហំ ១.៨០០ គ.ម. ក្រឡា – គឺ ៥៤ ភាគរយ – នៃឧទ្យានជាតិវីរៈជ័យ ទៅក្រុមហ៊ុនអូស្ត្រាលីមួយ មិនសូវមានអ្នកណាស្គាល់ទេ ឈ្មោះថា Indochine Resources [ធនធានឥណ្ឌូស៊ីន]។[៩១]

ជំនួសការជំទាស់ ដោយសាររដ្ឋាភិបាលបានប្រព្រឹត្តយ៉ាងទ្រគោះ ទៅលើកិច្ចការនៃគម្រោងរយៈពេលប្រាំឆ្នាំ និងតម្លៃ US$៥ លាននោះ អ្នកតំណាងធនាគារពិភពលោកម្នាក់បានឆ្លើយតបដោយសេចក្ដីថ្លែងដូចតទៅនេះ ទៅកាន់ប្រព័ន្ធផ្សព្វផ្សាយកម្ពុជា៖

"យើងបានលើករឿងនេះឡើងនិយាយជាមួយរដ្ឋាភិបាល ហើយបានចាប់ផ្ដើមការពិភាក្សាមួយ ជាមួយក្រសួងបរិស្ថាន ក្នុងកិច្ចប្រឹងប្រែងដើម្បីបំភ្លឺគោលបំណងនៃរដ្ឋាភិបាល។" អ្នកតំណាងបានបន្ថែមថា "យើងយល់ថា អាជ្ញាប័ណ្ណដែលបានបញ្ចេញឲ្យក្រុមហ៊ុន ធនធានឥណ្ឌូស៊ីន ចំកាត់ អនុញ្ញាតចំពោះការស្វែងរុករកធនធានរ៉ែ ប៉ុន្តែមិនមែនអាជីវកម្មធនធានរ៉ែនោះទេ។"[៩២]

នៅពេលបោះពុម្ពរបាយការណ៍នេះ ក្រុមហ៊ុន ធនធានឥណ្ឌូស៊ីន បានចាប់ផ្ដើមសាងសង់ទីចតយន្តហោះឧទ្ធម្ភាគចក្រ នៅក្នុងឧទ្យានជាតិវីរៈជ័យ ដើម្បីឲ្យភូគព្ភវិទូអាចចូលទៅក្នុងតំបន់ ហើយចាប់ផ្ដើមធ្វើផែនទីរកធនធានរ៉ែបាន។[៩៣]

ដោយសារឧទ្យានជាតិនេះ ត្រូវបានសំគាល់ជាតំបន់មានសារៈសំខាន់ខ្ពស់ខាងបរិស្ថាន ហើយមានការវិនិយោគប្រាក់ US$៥ លាន ដើម្បីរក្សាតម្លៃនោះ Global Witness មានការពិបាកក្នុងការយល់អំពីមូលហេតុ ដែលរដ្ឋាភិបាលបានជ្រើសរើសដើម្បីបើកតំបន់នោះ សម្រាប់ការស្វែងរុករកធនធានរ៉ែ ហើយមូលហេតុដែលធនាគារពិភពលោកមិនបានឆ្លើយតបដោយតឹងរឹងជាង ចំពោះការគំរាមកំហែងដែលហេតុការណ៍នេះបានបង្ក ទៅលើបូរណភាពនៃគម្រោង BPAMP។



ខាងលើ៖ នៅក្នុងចុងឆ្នាំ ២០០៧ រដ្ឋាភិបាលបានប្រគល់សិទ្ធិស្វែងរុករក សម្រាប់ផ្ទៃដីទំហំ ១.៨០០ គ.ម. ក្រឡា – គឺ៥៤ ភាគរយ – នៃឧទ្យានជាតិវីរៈជ័យ ទៅក្រុមហ៊ុនអូស្ត្រាលីមួយឈ្មោះថា ធនធានឥណ្ឌូស៊ីន



ខាងលើ ស្ដាំ៖ សំបុត្រមួយពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ជម្រាបក្រសួងបរិស្ថានថា ក្រុមហ៊ុន ធនធានឥណ្ឌូស៊ីន មានការអនុញ្ញាតដើម្បីបង្កើតជំរំមូលដ្ឋានបីកន្លែង សម្រាប់ការស្វែងរុករកធនធានរ៉ែ នៅក្នុងខេត្តរតនគិរី និងស្ទឹងត្រែង ចុះថ្ងៃទី ២៥[៩៤]

[vi] ជំពូកសត្វតំណាង គឺជាជំពូកសត្វមួយ ដែលត្រូវបានជ្រើសរើសជាទូត សញ្ញា ឬនិមិ... មួយ។ ដោយយកចិត្តទុកដាក់ ហើយសម្រេចការអភិរក្សនៃជំពូកសត្វមួយនោះ ស្ថានភ... ស៊ូរងការគំរាមកំហែងដូចគ្នា – គឺអាចចម្រើនឡើងបានដែរ។




ផ្លូវចូលការដ្ឋានអណ្ដូងរ៉ែ របស់ក្រុមហ៊ុន ថ្មរតនៈ។ រហូតមកដល់ខែឧសភា ឆ្នាំ ២០០៨ អណ្ដូងរ៉ែដែកនេះ នៅក្នុងខេត្តព្រះវិហារ មើលទៅត្រូវបានកាន់កាប់ដោយក្រុមហ៊ុនរបស់រដ្ឋចិនមួយ ក្រុមហ៊ុនដ៏មានអំណាចរបស់ប្រទេសកម្ពុជាមួយ ហើយនិងក្រុមហ៊ុនមួយដែលកាន់កាប់ដោយអគ្គមេបញ្ជាការនៃកងទ័ពកម្ពុជា នាយឧត្តមសេនីយ៍ ប៉ុល

## ថ្មរតនៈ–អណ្ដូងរ៉ែ ខិននីតិក

អណ្ដូងរ៉ែ Rattanak Stone [ថ្មីរតនៈ] នៅក្នុងខេត្តព្រះវិហារ ត្រូវបានគេជឿថា ជាកម្មសិទ្ធិរបស់លោកនាយឧត្តមសេនីយ៍ ប៉ុល សារឿន អគ្គមេបញ្ជាការ នៃកងទ័ពកម្ពុជា ហើយជានាយអគ្គសេនាធិការរួម។ របាយការណ៍របស់ប្រព័ន្ធផ្សព្វផ្សាយបានអះអាងថា ក្រុមហ៊ុន ថ្មីរតនៈ បានបង្កើតសហគ្រាសរួម នៅក្នុងឆ្នាំ ២០០៥ ជាមួយក្រុមដ៏មានអំណាចបំផុតមួយ នៅក្នុងប្រទេសកម្ពុជា គឺក្រុមហ៊ុន ភាពីម៉ិច ហើយនិងក្រុមហ៊ុនកាន់កាប់ដោយរដ្ឋាភិបាលចិន China National Machinery & Equipment Import & Export Corporation [ក្រុមហ៊ុនអាហរ័ណ នីហរ័ណគ្រឿងប្រដាប់ និងម៉ាស៊ីន ប្រទេសជាតិចិន]។ នៅក្នុងខែឧសភា ឆ្នាំ ២០០៨ ក្រុមហ៊ុនកូរ៉េ Kenertec [ខិននីតិក] បានប្រកាសថា គេបានទិញហ៊ុន ៨៥ ភាគរយ នៃអណ្ដូងរ៉ែនោះ នៅក្នុងកិច្ចព្រមព្រៀងសហគ្រាសរួម ជាមួយក្រុមហ៊ុនថ្មរតនៈ។

សមាជិកនៃកងយោធពលខេមរភូមិន្ទ (RCAF) ត្រូវបានជួលដើម្បីយាមការដ្ឋាន។ អ្នកស្រុកបានរាយការណ៍អំពីករណីឆក់យកដីធ្លីតាំងពីដើមដំបូង ហើយពួកគេខ្លាចថានឹងមានទៀត។

ទោះបីគ្មានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬសង្គម សម្រាប់គម្រោងនេះក៏ដោយ ក៏ព័ត៌មានដែលអាចរកបាន ចង្អុលបង្ហាញនូវការផ្លាស់ប្ដូរយ៉ាងរហ័ស នៃតំបន់ព្រៃឡង់ និងទន្លេមេកុងខាងលើ ដែលជាតំបន់ដ៏ងាយរងគ្រោះថ្នាក់ និងសំខាន់សម្រាប់បរិស្ថាន ទៅជាតំបន់ឧស្សាហកម្មមួយ។

ក្រុមហ៊ុន Rattanak Stone Cambodia Development Company Ltd [ក្រុមហ៊ុនអភិវឌ្ឍន៍ថ្មរតនៈកម្ពុជា ចំកាត់][៩៥] បានលេចឡើងឲ្យ Global Witness ដឹងមុនដំបូង នៅក្នុងឆ្នាំ ២០០៥ នៅពេលដែលអ្នករាយការណ៍ព័ត៌មាន បានចាប់ផ្ដើមរាយការណ៍អំពីប្រតិបត្តិការជីកយករ៉ែដែក នៅព្រំដែនខាងជើងនៃព្រៃឡង់ នៅក្នុងស្រុករវៀង ខេត្តព្រះវិហារ។ តាម MIME បានឲ្យដឹងថា ថ្មីរតនៈ ត្រូវបានផ្ដល់អនុញ្ញាត ដើម្បីអនុវត្តការស្វែងរុករករ៉ែដែក នៅក្នុងឆ្នាំ ២០០៤ និង ២០០៥ នៅពីរកន្លែង នៅក្នុងស្រុករវៀង – គឺភ្នំកោះកែវ និងភ្នំថ្ម។[៩៦] ទោះជាក្រុមហ៊ុនបានទទួលការអនុញ្ញាតនេះក៏ដោយ ក៏ការបើកអណ្ដូងរ៉ែ ដោយមិនប្រកាសឲ្យដឹង ហើយនិងការរៀបរបងជុំវិញដីធ្លី ៣២ គ.ម. ក្រឡា បានធ្វើឲ្យមានការភ្ញាក់ផ្អើល ចំពោះសហគមន៍អ្នកស្រុក ដែលរស់នៅ ហើយធ្វើស្រែនៅទីនោះ។[៩៧]

## ម្ចាស់កម្មសិទ្ធិពីដំបូង

ការចាប់បើកនៃអណ្ដូងរ៉ែនេះ បានធ្វើឲ្យប្រព័ន្ធផ្សព្វផ្សាយប្រទេសចិនចាប់អារម្មណ៍ ដោយសារការពាក់ព័ន្ធនៃក្រុមហ៊ុនមួយរបស់រដ្ឋចិន គឺក្រុមហ៊ុនអាហរ័ណ នីហរ័ណគ្រឿងប្រដាប់ និងម៉ាស៊ីន ប្រទេសជាតិចិន។[៩៨] នៅថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០០៥ ទីភ្នាក់ងារសារព័ត៌មានចិន ស៊ីនហ្វា បានរាយការណ៍ថា ក្រុមហ៊ុនអាហរ័ណ នីហរ័ណគ្រឿងប្រដាប់ និងម៉ាស៊ីន ប្រទេសជាតិចិន បានសម្រេចចិត្តដើម្បីសហការនៅក្នុងការធ្វើអាជីវកម្មធនធានរ៉ែដែក នៅក្នុងខេត្តព្រះវិហារ ប្រទេសកម្ពុជា។ ភាគីខ្មែរទាំងពីរភាគី គឺជាក្រុមហ៊ុន ភាពីម៉ិច គ្រុប (ភាពីម៉ិច) និងក្រុមហ៊ុនអភិវឌ្ឍន៍ថ្មីរតនៈកម្ពុជា ចំកាត់។[៩៩]



អគ្គមេបញ្ជាការនៃកងទ័ពកម្ពុជា នាយឧត្តមសេនីយ៍ **ប៉ុល សារឿន** ត្រូវបានគេជឿថា ជាម្ចាស់កម្មសិទ្ធិទទួលប្រយោជន៍នៃក្រុមហ៊ុន ថ្មរតនៈ ដែលប្រតិបត្តិអណ្ដូងរ៉ែដែកមួយ នៅក្នុងស្រុករវៀង ខេត្តព្រះវិហារ តាំងពីឆ្នាំ ២០០៥។ ពេលថ្មីនេះ ក្រុមហ៊ុនថ្មរតនៈបានពង្រីកសកម្មភាពពាណិជ្ជកម្ម។ នៅក្នុងខែសីហា ឆ្នាំ ២០០៨ ក្រុមហ៊ុននេះ ត្រូវបានប្រគល់ព្រៃឈើទំហំ ៤៧៩ ហ.ត. នៅក្នុងឃុំពីរធ្នូ ស្រុកស្នួល ខេត្តក្រចេះ ដោយមានគោលបំណងប្រែទៅជាចម្ការកៅស៊ូ។[១០០] នៅក្នុងខែកញ្ញា ឆ្នាំ ២០០៨ ក្រុមហ៊ុននេះត្រូវបានប្រគល់សម្បទានដីរ៉ែ ទំហំ ២៥ គ.ម. ក្រឡា ដើម្បីដកយកថ្មីសាងសង់អាគារ។ ការដ្ឋានធនធានរ៉ែថ្មីនេះ មានទីតាំងនៅឯ ស្រា ង៉ាម ឃុំគីរីវន្ត ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។[១០១]

ការពាក់ព័ន្ធនៃក្រុមហ៊ុន ភាពីម៉ិច ដែលជាក្រុមហ៊ុនដ៏មានអំណាចបំផុតមួយ របស់ប្រទេសកម្ពុជា គឺជាការដកថយពីអាជីវកម្មចម្បងរបស់វា គឺការកាប់ព្រៃឈើ។ នៅពេលនោះ មានសេចក្ដីរាយការណ៍ថា អគ្គនាយករដ្ឋមន្ត្រី **ហ៊ុន សែន** បានផ្ដល់ការគាំទ្រទាំងស្រុងចំពោះគម្រោងនោះ។[១០២]

នៅពេល Global Witness បានទៅដល់ការដ្ឋាន ថ្មរតនៈ នៅក្នុងឆ្នាំ ២០០៥ និង ២០០៨ អ្នកធ្វើការនៅអណ្ដូងរ៉ែ មន្ត្រីក្នុងស្រុក ហើយនិងបុគ្គលិកយោធាដែលយាមការដ្ឋាន ទាំងអស់គ្នាបាននិយាយថា ម្ចាស់កម្មសិទ្ធិនៃអណ្ដូងរ៉ែ ថ្មរតនៈ គឺលោកនាយឧត្តមសេនីយ៍ **ប៉ុល សារឿន** អគ្គមេបញ្ជាការនៃកងទ័ពកម្ពុជា ហើយជានាយអគ្គសេនាធិការ។[១០៣] កម្មករម្នាក់នៅឯការដ្ឋានអណ្ដូងរ៉ែមួយ បានរ៉ាយរ៉ាប់ប្រាប់ Global Witness ថា ឧត្តមសេនីយ៍ **ប៉ុល សារឿន** បានធ្វើទស្សនកិច្ចមកកាន់ទីកន្លែងនៅក្នុងដើមឆ្នាំ ២០០៨។ នៅពេលនោះ ទាហានដែលយាមការដ្ឋាន បានឈរត្រង់ ហើយធ្វើវន្ទនាការលោក។[១០៤] Global Witness ធ្លាប់កត់ជាឯកសារ អំពីការពាក់ព័ន្ធរបស់ឧត្តមសេនីយ៍ **ប៉ុល សារឿន** នៅក្នុងវិស័យកាប់លក់ឈើខុសច្បាប់ នៅក្នុងប្រទេសកម្ពុជា។[១០៥]

ដូច្នេះ ជាការសង្ខេប រហូតដល់ខែឧសភា ឆ្នាំ ២០០៨ អណ្ដូងរ៉ែដែក នៅក្នុងខេត្តព្រះវិហារ មើលទៅបានស្ថិតនៅក្រោមការកាន់កាប់ពីក្រុមហ៊ុនរបស់រដ្ឋចិន ក្រុមហ៊ុនដ៏មានអំណាចបំផុតមួយរបស់ប្រទេសកម្ពុជា ហើយនិងក្រុមហ៊ុនមួយដែលគ្រប់គ្រងដោយអគ្គមេបញ្ជាការ នៃកងទ័ពកម្ពុជា នាយឧត្តមសេនីយ៍ ប៉ុល សារឿន។

នៅក្នុងខែឧសភា ឆ្នាំ ២០០៨ ក្រុមហ៊ុន ខិននីតិក ចំកាត់[106] ដែលជាក្រុមហ៊ុនរ៉ែមកពីប្រទេសកូរ៉េខាងត្បូង បានចេញសេចក្ដីប្រកាសសារព័ត៌មាន អះអាងថាបានបង្ហើយកិច្ចព្រមព្រៀងមួយ ដើម្បីទិញចំណែកហ៊ុន ៨៥ ភាគរយ នៅក្នុងអណ្ដូងរ៉ែរវៀង ជាសហគ្រាសរួមជាមួយនឹងក្រុមហ៊ុន ថ្មរតនៈ។[107] វាមិនច្បាស់ទេ ថាតើក្រុមហ៊ុន ភាពីម៉ិច និងក្រុមហ៊ុនអាហរ័ណ នីហរ័ណគ្រឿងប្រដាប់ និងម៉ាស៊ីនប្រទេសជាតិចិន នៅតែមានភាគហ៊ុននៅឡើយ ឬក៏តើគេបានដកថយពីសហគ្រាសនាដំណាក់កាលនេះ។ Global Witness បានសរសេរសំបុត្រទៅឧត្តមសេនីយ៍ **ប៉ុល សារឿន** ក្រុមហ៊ុន ភាពីម៉ិច ហើយនិងក្រុមហ៊ុន អាហរ័ណ នីហរ័ណគ្រឿងប្រដាប់ និងម៉ាស៊ីនប្រទេសជាតិចិន ដើម្បីសាកសួរ អំពីការពាក់ព័ន្ធរបស់គេ នៅក្នុងអណ្ដូងរ៉ែនោះ។ នៅពេលបោះពុម្ពរបាយការណ៍នេះ Global Witness មិនទាន់ទទួលចម្លើយអ្វីទេ។

ប្រភពព័ត៌មានមួយរូប ដែលជិតស្និទ្ធនឹងក្រុមហ៊ុន បានអះអាងថា ជាការចាំបាច់ត្រូវតែបង់ 'ប្រាក់រង្វាន់' ដើម្បីចាប់ផ្ដើមធ្វើការ ហើយថាក្រុមហ៊ុន ខិននីតិក បានបង់ប្រាក់ប្រមាណ US$១ លាន ដើម្បីទទួលការអនុញ្ញាតចាប់ផ្ដើមធ្វើការ។[១០៨] ស្ថានភាពផ្លូវច្បាប់ នៃការបង់ប្រាក់រង្វាន់នេះ មិនច្បាស់លាស់ទេ។ ច្បាប់ស្ដីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ របស់ប្រទេសកម្ពុជា មិននិយាយអ្វីសោះ អំពីការបង់ប្រាក់រង្វាន់ ដើម្បីទទួលសម្បទាន។[១០៩]

Global Witness បានសរសេរសំបុត្រមួយទៅក្រសួងហិរញ្ញវត្ថុ នៅក្នុងខែតុលា ឆ្នាំ ២០០៨ ដើម្បីសាកសួរថា តើប្រាក់នោះត្រូវបានទទួលឲ្យចូលក្នុងថវិកាជាតិឬទេ ប៉ុន្តែមិនទាន់ទទួលចម្លើយនៅឡើយទេ។

*"ខ្ញុំឃើញលុយនៅគ្រប់ទីកន្លែង នៅក្នុងដើមឈើ នៅក្នុងដី គ្រប់កន្លែង!"*

ប្រសាសន៍របស់បុគ្គលិកក្រុមហ៊ុន ខិននីតិក និយាយអំពីសក្ដានុពលនៃប្រទេសកម្ពុជាជាឱកាសវិនិយោគ នៅក្នុងបទសម្ភាសន៍ជាមួយ Global Witness ឆ្នាំ ២០០៨។[១១០]

## ប្រអប់ទី ៤ ៖ តើសិទ្ធិអាជីវកម្មរ៉ែ ថ្លៃប៉ុន្មាន?

ទន្ទឹមពេលដែលដីសម្បទានរ៉ែត្រូវបានចែកយ៉ាងរហ័ស ក៏មានការខ្វះខាត នូវទម្រង់ការដ៏ច្បាស់លាស់ និងដ៏មានតម្លាភាព ដើម្បីក្រុមហ៊ុនបង់ប្រាក់ទទួលសិទ្ធិប្រើប្រាស់ធនធានរ៉ែទាំងនេះ។

នៅក្រោមច្បាប់ស្ដីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ របស់ប្រទេសកម្ពុជា ក្រុមហ៊ុនត្រូវតែបង់ថ្លៃទៅរដ្ឋកម្ពុជា សម្រាប់ការចុះឈ្មោះ ការដាក់ពាក្យសុំការពន្យារ ការបន្ត ការផ្ទេរផ្សេងៗ និងឈ្នួលប្រចាំឆ្នាំ ក៏ប៉ុន្តែព័ត៌មានល្អិតល្អន់អំពីការបង់ថ្លៃទាំងនេះ មិនបានឲ្យដឹងឡើយ។[១១១] Global Witness បានសម្ភាសបុគ្គលិកមួយរូប នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នាចុងឆ្នាំ ២០០៨ ហើយត្រូវបានប្រាប់ថា ទោះបីមានអត្រាថ្លៃជាខ្នាតទៀងទាត់ សម្រាប់សេវាកម្ម ដូចជាប្រាក់បង់ថ្លៃឈ្នួល និងពន្ធដារបង់ដោយក្រុមហ៊ុនក៏ដោយ ក៏ថ្លៃទាំងនេះមិនទាន់បានអនុម័ត ឬកំណត់ដោយសភាទេ។[១១២] ទោះជាមានការខ្វះតម្លាភាពបែបនេះក៏ដោយ ផលចំណូលពិតជាកើតមានពីវិស័យនេះ។ សំអាងលើរបាយការណ៍ប្រចាំខែ ផ្ដល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ Global Witness បានវិភាគចំណែករបស់វិស័យអាជីវកម្មរ៉ែរបស់ប្រទេសកម្ពុជា នៅក្នុងសេដ្ឋកិច្ចជាតិ នៅក្នុងរយៈពេលប្រាំមួយឆ្នាំកន្លងមកនេះ។ តាមទិន្នន័យនេះ រវាងឆ្នាំ ២០០២ និង ២០០៨ វិស័យនេះបានផ្ដល់ផលចំណូល US$៣ លាន ឲ្យសេដ្ឋកិច្ចជាតិ។

ប៉ុន្តែហេតុការណ៍នេះ មិនស៊ីគ្នាជាមួយព័ត៌មានដទៃទៀត Global Witness បានទទួលនោះទេ។ សំអាងលើក្រុមហ៊ុនចំនួនតិចតួច ដែលផ្ដល់ព័ត៌មានឲ្យមើលចំនួនប្រាក់ដែលចូលថវិការបស់ប្រទេសជាតិ គួរតែលើសពីនេះ យ៉ាងច្រើន។ ដោយសារការខ្វះតម្លាភាព នៅក្នុងទំនាក់ទំនងជំនួញទាំងនេះ វាពិបាកណាស់ដើម្បីប៉ាន់ស្មានផលសរុបដោយត្រឹមត្រូវ ក៏ប៉ុន្តែ សំអាងលើកស្តុតាងដែលបានប្រមូលពីប្រភពផ្សេងៗ Global Witness ប៉ាន់ស្មានថា ចំនួនសរុប ត្រូវមានចំនួនប្រហែល US$៧ លាន។

អ្នកវិភាគឧស្សាហកម្ម ដែល Global Witness បានសម្ភាស បានអះអាងថា ក្រុមហ៊ុនរ៉ែ ដែលចង់ប្រតិបត្តិនៅក្នុងប្រទេសកម្ពុជា ត្រូវតែបង់ប្រាក់ជាខ្នាត US$៥០.០០០ សម្រាប់អាជ្ញាប័ណ្ណធនធានរ៉ែនីមួយៗ។[១១៣] មើលទៅ ក្រុមហ៊ុនផ្សេងទៀត បង់ប្រាក់ច្រើនជាងនេះទៅទៀត។ លើសពីការអះអាង ថាក្រុមហ៊ុន ខិននីតិក បានបង់ប្រាក់ម្ងាន់ប្រហែល US$១ លាន ក៏រដ្ឋាភិបាលកម្ពុជាបានឲ្យដឹងថា ក្រុមហ៊ុនរ៉ែធំ ពីប្រទេសអូស្ត្រាលី BHP Billiton [BHP ប៊ិលលិតុន][១១៤] បានបង់ប្រាក់ច្រើន ដើម្បីទទួលសិទ្ធិស្វែងរុករក នៅក្នុងដី ១០០.០០០ ហ.ត. នៅខេត្តមណ្ឌលគិរី ដើម្បីស្វែងរុករករ៉ែបុកស៊ីត។[១១៥]

តាមអត្ថបទមួយ បោះពុម្ពនៅក្នុងកាសែត *Cambodia Daily* នៅថ្ងៃទី ២៤ ខែឧសភា ឆ្នាំ ២០០៧ រដ្ឋមន្ត្រីក្រសួងធនធានទឹក ឯកឧត្តម លឹម គានហោ[១១៦] បានប្រាប់សភាជាតិ ថាក្រុមហ៊ុន BHP ប៊ិលលិតុន បានបង់ប្រាក់ US$២,៥ លាន ទៅរដ្ឋាភិបាល ដើម្បីឲ្យបានដីសម្បទានរ៉ែបុកស៊ីត។ នៅក្នុងអត្ថបទដដែល មានគេរាយការណ៍ថា ឯកឧត្តម លឹម គានហោ បានពិពណ៌នាការបង់ប្រាក់នេះ ជា 'លុយទឹកតែ' ដែលជាពាក្យគ្រាមភាសានៅក្នុងប្រទេសកម្ពុជា មានន័យថា ការបង់ប្រាក់ក្រៅផ្លូវការ។[១១៧]

Global Witness បានសរសេរសំបុត្រទៅក្រុមហ៊ុន BHP នៅក្នុងខែតុលា ឆ្នាំ ២០០៨ ដើម្បីសុំឲ្យគេបញ្ជាក់ថា តើប្រសាសន៍របស់ឯកឧត្តមរដ្ឋមន្ត្រីត្រឹមត្រូវ ឬទេ។ ចម្លើយតបរបស់ក្រុមហ៊ុន បានបញ្ជាក់ថា ក្រុមហ៊ុនបានបង្កើតមូលនិធិអភិវឌ្ឍន៍សង្គម ក្នុងចំនួន US$២,៥ លានសម្រាប់ប្រទេសកម្ពុជា ប៉ុន្តែគេបានថ្លែងថា "ក្រុមហ៊ុន BHP ប៊ិលលិតុនមិនដែលបង់ប្រាក់ទៅមន្ត្រី ឬអ្នកតំណាងនៃរដ្ឋាភិបាលកម្ពុជា ហើយយើងបដិសេធការអះអាងថា ការបង់ប្រាក់នៅក្រោមកិច្ចព្រមព្រៀងស្វែងរុករកធនធានរ៉ែ ឬប្រាក់ដែលបានបរិច្ចាគឲ្យមូលនិធិគម្រោងអភិវឌ្ឍន៍សង្គម គឺជា 'លុយទឹកតែ'។"

តាមសំបុត្រពីក្រុមហ៊ុន BHP ទៅ Global Witness បានឲ្យដឹងថាកម្មវិធីអភិវឌ្ឍន៍សង្គម "ត្រូវបានបង្កើតឡើង ដើម្បីកែលំអសុខភាព ការអប់រំ វប្បធម៌ និងសុខុមាលភាពទូទៅ នៃប្រជាជនកម្ពុជា … ប្រាក់នេះអាចចាយបានតែលើកម្មវិធីប្រចាំសហគមន៍ ដែលផ្ដល់ប្រយោជន៍ឲ្យប្រជាជនកម្ពុជា តែប៉ុណ្ណោះ។ ក្នុងនាមជាតំណាងនៃដៃគូសហគ្រាសរួម ក្រុមហ៊ុន BHP ត្រូវតែអនុញ្ញាតចំពោះការបង់ប្រាក់ទាំងអស់ ហើយយើងមានបំណងអនុវត្តអំណាចវេតូ នៅក្នុងករណីដែលយើងមានកង្វល់អំពីគម្រោងណាមួយ។" ក្រុមហ៊ុន BHP ក៏បានបញ្ជាក់ផងដែរ ថាក្រុមហ៊ុននោះបានបង់ប្រាក់បន្ថែមទៅរដ្ឋាភិបាលកម្ពុជា ដើម្បីឲ្យបានសម្បទានរ៉ែនោះ ដោយថ្លែងថា "ស្របតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងស្វែងរុករកធនធានរ៉ែ ជាមួយរដ្ឋាភិបាលកម្ពុជា ដែលបានផ្ដល់ឲ្យក្រុមហ៊ុន BHP ប៊ិលលិតុន និងក្រុមហ៊ុនមិតស៊ូប៊ីស៊ី នូវសិទ្ធិដើម្បីស្វែងរុករករ៉ែបុកស៊ីតនោះ ប្រាក់ចំនួន US$១ លាន ត្រូវបានបង់ ដោយផ្លូវការ ទៅកាន់រដ្ឋាភិបាលកម្ពុជា នៅក្នុងខែកញ្ញា ឆ្នាំ ២០០៦។"[១១៨]

Global Witness បានទទួលសំណៅមួយច្បាប់ នៃឯកសារ 'Tableau des Opérations Financières de l'Etat' (TOFE) របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលផ្ដល់ព័ត៌មានអំពីផលចំណូលប្រចាំឆ្នាំ មកកាន់រដ្ឋកម្ពុជា។ តាមឯកសារនេះ ប្រាក់ចំណូលមកពីសម្បទានរ៉ែ ក្រៅពីពន្ធដារ នៅក្នុងឆ្នាំ ២០០៦ គឺ US$៤៤៣.៨៦៦។[១១៩] បើប្រាក់នេះមានដាក់រាយនៅកន្លែងផ្សេង នៅក្នុងឯកសារ TOFE គឺវាមិនច្បាស់ថា កន្លែងណានោះទេ។ នេះនាំឲ្យមានសំណួរថា តើប្រាក់ US$១ លាន របស់ក្រុមហ៊ុន BHP ប៊ិលលិតុន ដែលបានបង់នៅក្នុងខែកញ្ញា ឆ្នាំ ២០០៦ បានទៅណាបាត់។

តាំងពីការទិញអណ្ដូងរ៉ែ ក្រុមហ៊ុន ខិននីតិក មានការរំភើបចិត្ត អំពីលទ្ធភាពនៃអណ្ដូងរ៉ែនោះ។ ការប្រកាសព័ត៌មាន នៅក្នុងខែឧសភា ឆ្នាំ ២០០៨ បានថ្លែងថា៖

"ដីឡូត៍អណ្ដូងរ៉ែនេះ ត្រូវបានគេប៉ាន់ស្មានថា មានជាតុរ៉ែដែកប្រហែល ២០០ លានតោនរៀបចំហ៊ុន ខិននីតិក បានក្រុម …
ប្រចាំលក់ថា ផលគិតរំពឹងតោន ហើយលាន ២ផលិតកម្ម ផែនការ
លានពាន់ ១៦០ចំនួន មានឆ្នាំ នឹងវ៉ុនកូរ៉េ តម្លៃតាមលក់)

(តោន/៨០$ ហើយផលចំណេញនឹងមានចំនួនជាង ៤០ ពាន់លានវ៉ុនកូរ៉េ រាល់ឆ្នាំ។"[120]

និយាយម៉្យាងទៀត ពួកគេប៉ាន់ស្មានផលចំណេញរបស់គេ មកពីរ៉ែដែក គឺជិត US$៣២ លាន ក្នុងមួយឆ្នាំ។



នៅពេល Global Witness បានទៅដល់ការដ្ឋាន រតនៈ/ខិននីតិក នៅក្នុងឆ្នាំ ២០០៨ អ្នកស៊ើបអង្កេតបានឃើញសំណាកថ្មខួង ដែលគេត្រូវបានប្រាប់ថា មានវត្ថុមាននៃរ៉ែដែក ស្ពាន់ និងមាស។

ការដ្ឋាននោះ ក៏មានធាតុរ៉ែផ្សេងទៀតផងដែរ។ នៅពេលតំណាង Global Witness បានទៅដល់កន្លែងនៅក្នុងឆ្នាំ ២០០៨ អ្នកស៊ើបអង្កេតបានឃើញសំណាកថ្ម ដែលខួងយកពីការដ្ឋានភ្នំថ្ម ដែលគេត្រូវបានប្រាប់ថា មានវត្ថុមាននៃរ៉ែដែក ស្ពាន់ និងមាស។ តាមបុគ្គលិកខិននីតិកម្នាក់ បានឲ្យដឹងថា ការដ្ឋានភ្នំថ្ម អាចមានមាសពីរក្រាមក្នុងថ្មមួយតោន។ គាត់ប៉ាន់ស្មានថា រ៉ែមាសនៅការដ្ឋានតែមួយនេះ អាចមានតម្លៃ US$៤០ លាន។[១២១]

ដីសម្បទានទាំងពីរ នៅក្នុងខេត្តព្រះវិហារ គឺជាសម្បទានតែពីរប៉ុណ្ណោះ ដែលខិននីតិកមានអាជ្ញាប័ណ្ណ។ របាយការណ៍ត្រួតពិនិត្យឆ្នាំ ២០០៧ មួយបានថ្លែងថា ក្រុមហ៊ុន ខិននីតិក បានទទួលសិទ្ធិស្វែងរុករក សម្រាប់ការដ្ឋានចំនួនប្រាំបីកន្លែង នៅក្នុងប្រទេសកម្ពុជា មានផ្ទៃដីសរុប ១.៥២០ គ.ម. ក្រឡា។[១២២] អ្នកតំណាងក្រុមហ៊ុនម្នាក់បានប្រាប់ Global Witness ថា សម្បទានមានរួមទាំងបីកន្លែង នៅក្នុងជ្រុងផ្នែកខាងពាយ័ព្យនៃប្រទេសកម្ពុជា ដែលត្រូវគេសង្ស័យថា មានត្បូងថ្ម ហើយដីសម្បទានផ្សេងទៀត ត្រូវគេសង្ស័យថា មានរ៉ែដែក ឬមាស ឬទាំងពីរ។[១២៣]

ក្រៅពីការទាក់ទិនជាមួយនាយឧត្តមសេនីយ៍ **ប៉ុល សារឿន** មានការពាក់ព័ន្ធយ៉ាងជាក់ស្ដែង ពីកងយោធា នៅឯការដ្ឋានអណ្ដូងរ៉ែ។ នៅពេល Global Witness បានទៅដល់កន្លែងនៅក្នុងឆ្នាំ ២០០៨ មានទាហាន ១៥ នាក់ ដែលត្រូវបាន ខិននីតិក ជួល ដើម្បីយាមការដ្ឋានអណ្ដូងរ៉ែ នៅក្រោមការដឹកនាំពីបុគ្គលមួយរូប ដែលគេហៅជាមេទ័ពប្រចាំស្រុក ឈ្មោះថា លោក ចាយ។[១២៤] ក្រុមហ៊ុន ខិននីតិក បង់ប្រាក់ប្រមាណ US$១០០០ ទៅលោក ចាយ ផ្ទាល់រាល់ខែ ហើយគាត់បែរជាចែកប្រាក់នេះឲ្យកូនទាហាន។[១២៥]

តាំងពីឆ្នាំ ២០០៥ មក អណ្ដូងរ៉ែនេះបានអភិវឌ្ឍន៍ប្រតិបត្តិការរបស់ខ្លួន ហើយកម្មករចិនបានសាងសង់ផ្លូវដីកៀរ ទៅកាន់ការដ្ឋាន។[១២៦]

ចាប់ផ្ដើមខែសីហា ឆ្នាំ ២០០៨ ក្រុមហ៊ុនបានចាប់ផ្ដើមសាងសង់ផ្លូវដើម្បីភ្ជាប់ការដ្ឋានកោះកែរ និងភ្នំថ្ម។ នៅពេលនិពន្ធរបាយការណ៍នេះ ផ្លូវនេះត្រូវបានគេរាយការណ៍ថា បានសាងសង់រហូតដល់កៀនវាលស្រែ ប៉ុន្តែការសាងសង់បានឈប់សិន សម្រាប់រដូវភ្លៀងដើម្បីឲ្យអ្នកស្រុកអាចច្រូតកាត់ស្រូវរបស់ខ្លួនសិន។ ក៏ប៉ុន្តែអ្នកស្រុកនៅតែព្រួយបារម្ភថា ការសាងសង់ផ្លូវនឹងបន្តទៀត ក្រោយពីទីបញ្ចប់នៃរដូវភ្លៀង ហើយដីរបស់ពួកគេនឹងត្រូវបាដណ្ដើមយកដោយគ្មានការសងឡើយ។[១២៧] នៅក្នុងខែឧសភា ឆ្នាំ ២០០៨ អ្នកតំណាងសហគមន៍បានរៀបចំការប្រជុំជាមួយអភិបាលរងស្រុក លោក គាត គឹមតោះ[១២៨] ដើម្បីលើកឡើងការបារម្ភរបស់គេ អំពីការចាប់យកដីធ្លី។ នៅក្នុងការប្រជុំនោះ ពួកគេត្រូវបានប្រាប់ឲ្យរង់ចាំការដោះស្រាយពីរដ្ឋាភិបាល។[១២៩] នៅពេលបោះពុម្ពរបាយការណ៍នេះ ការដោះស្រាយនេះមិនទាន់ឃើញកើតឡើងនៅឡើយទេ។

## អណ្ដូងរ៉ែ ហុងហ្វ៊ូ-ទ្រី ភាព

ក្រុមហ៊ុនដែលទទួលភារកិច្ច សម្រាប់អណ្ដូងរ៉ែដែក ហុងហ្វ៊ូ-ទ្រី ភាព មើលទៅ គឺជាក្រុមហ៊ុន (Cambodia) Hongfu Try Pheap Mining Development Construction Co. Ltd, [ក្រុមហ៊ុនសំណង់អភិវឌ្ឍន៍រ៉ែ ហុងហ្វ៊ូ ទ្រី ភាព ចំកាត់] ដែលក្នុងចំណោមនាយកក្រុមហ៊ុន មានសមាជិកពីររូប នៃពួកវរជនប្រទេសកម្ពុជា – គឺលោកឧកញ៉ា ទ្រី ភាព និងសមាជិកព្រឹទ្ធសភា ឯកឧត្ដម ឡៅ ម៉េងឃីន។ លោកឧកញ៉ា ទ្រី ភាព គឺជាមហាសេដ្ឋីដ៏ល្បីឈ្មោះ។ សមាជិកព្រឹទ្ធសភាឯកឧត្តម ឡៅ ម៉េងឃីន គឺសមាជិកព្រឹទ្ធសភាដ៏ល្បីឈ្មោះ ពីគណបក្ស CPP ហើយជានាយកនៃក្រុមហ៊ុនល្បីឈ្មោះភាពីម៉ិច។

សមាជិកនៃកងយោធពលខេមរភូមិន្ទ មានតួនាទីសំខាន់ នៅក្នុងការយាមការដ្ឋានអណ្ដូងរ៉ែ។ អ្នកស្រុកដែលរស់នៅក្នុងតំបន់ជុំវិញ

## ការដ្ឋានអណ្ដូងរ៉ែ ខ្លាចការដេញចេញពីផ្ទះសម្បែង នៅពេលដែលប្រតិបត្តិការក្រុមហ៊ុនរីករាលដាល នាពេលអនាគត។

អណ្ដូងរ៉ែ ហុងហ្វូ-ទ្រី ភាព មានទីតាំងនៅក្នុងឃុំអន្លង់វេ ស្រុកថាឡាបរិវ៉ាត់ នៅក្នុងខេត្តជិតខាង ស្ទឹងត្រែង។ នៅទីនេះដែរ អ្នកសន្ដិសុខក្រុមហ៊ុន ត្រូវបានសម្រិតសម្រាំងពីក្នុងចំណោមជួរ RCAF។ ពួកគេមានវត្តមានច្រើនណាស់ នៅក្នុងតំបន់នេះ ដោយមានជំរំមូលដ្ឋានចំនួនបីកន្លែង នៅក្នុងបណ្ដាភូមិជុំវិញការដ្ឋាន៖ ភូមិអន្លង់ជ្រៅ ភូមិមង និងភូមិធ្មេង។ មិនដូចការដ្ឋានអណ្ដូងរ៉ែនៅក្នុងខេត្តព្រះវិហារ ដែលនៅ ក្នុងតំបន់ព្រៃ និងស្រែទេ អណ្ដូងរ៉ែ ទ្រី ភាព ស្ថិតនៅក្នុងតំបន់មានមនុស្សច្រើនរស់នៅ។ តាមអ្នកធ្វើការ NGO បានឲ្យដឹងថា អ្នករស់នៅជុំវិញអណ្ដូងរ៉ែ រំពឹងថាខ្លួននឹងត្រូវបានដេញចេញពីផ្ទះ នៅពេលប្រតិបត្តិការរីករាលដាលនាអនាគត។ ការសង្ស័យត្រូវបានពង្រឹងកាន់តែច្បាស់ឡើង នៅពេលកម្មការពីការដ្ឋានរ៉ែ បានដាក់បង្គោលស៊ីម៉ង់នៅលើដីធ្លីរបស់គេ ដើម្បីកំណត់កន្លែងសាងសង់ នៅក្នុងខែមីនា ឆ្នាំ ២០០៨។[១៣០]

ឯកសារចុះឈ្មោះក្រុមហ៊ុន សម្រាប់ក្រុមហ៊ុនរ៉ែ ហុងហ្វូ-ទ្រី ភាព បង្ហាញថា នាយករបស់ក្រុមហ៊ុន គឺលោក **ទ្រី ភាព៖** មហាសេដ្ឋីជំនួញដ៏មានអំណាច ដែលមាននាមជា ឧកញ៉ា ហើយមានភាគហ៊ុនច្រើន នៅក្នុងកាស៊ីណូ ការអភិវឌ្ឍន៍កោះ និងចម្ការកៅស៊ូ។ កន្លងមក លោកឧកញ៉ាត្រូវបានរិះគុនដោយ NGO ដោយសារតួនាទីនៃក្រុមហ៊ុនលោកឧកញ៉ា ក្នុងការដេញប្រជាជនដោយបង្ខិតបង្ខំ នៅក្នុងដីជុំវិញគម្រោងការទាំងនេះខ្លះ។[១៣១]



បុគ្គលមួយរូបទៀត ដែលមាននាមជានាយករួមនៃក្រុមហ៊ុន នៅក្នុងឯកសារចុះឈ្មោះក្រុមហ៊ុន គឺឯកឧត្ដម **ឡៅ ម៉េងឃីន** – ពាក់កណ្ដាលនៃគូស្វាមីភរិយាល្បីឈ្មោះ ដែលកាន់កាប់ក្រុមហ៊ុន ភាពីម៉ិច ហើយក៏ជានាយកមួយរូប នៃក្រុមហ៊ុនមួយ ហៅថា Shukaku Ltd. [ស៊ូកាគុ ចំកាត់] (សូមមើល ប្រអប់ទី ៥ សម្រាប់ព័ត៌មានលំអិតបន្ថែម)។[១៣២]

ឯកសារចុះឈ្មោះក្រុមហ៊ុន សម្រាប់ក្រុមហ៊ុនរ៉ែ ហុងហ្វូ ទ្រី ភាព បង្ហាញឲ្យឃើញថា នាយកក្រុមហ៊ុន គឺលោកឧកញ៉ា ទ្រី ភាព មហាសេដ្ឋីមានអំណាចមួយរូប។ នាយកមួយទៀត គឺឯកឧត្ដម ឡៅ ម៉េងឃីន ដែលជាសមាជិកព្រឹទ្ធសភាពី គណបក្ស CPP ហើយជានាយករួម នៃក្រុមហ៊ុន ភាភីម៉ិច។

តាមប្រព័ន្ធផ្សព្វផ្សាយ និងរដ្ឋាភិបាលនៃប្រទេសវៀតណាម បានឲ្យដឹងថា ក្រុម ទ្រី ភាព បានចុះកិច្ចព្រមព្រៀងនៅក្នុងខែកក្កដា ឆ្នាំ ២០០៧ ដើម្បីប្រតិបត្តិការដ្ឋាននោះ រួមជាមួយនឹងក្រុមធ្យូងថ្ម និងជាតុរ៉ែ របស់ប្រទេសវៀតណាម (ហៅក្រោយថា Vinacomin [វីណាកូមិន])[១៣៣] ហើយនិងក្រុមហ៊ុន Mom Good Luck Mining [ក្រុមហ៊ុនរ៉ែ មុំ ហ្គូដឡាក់]។[១៣៤] (ឈ្មោះក្រុមហ៊ុន វីណាកូមិន នឹងលេចឡើងម្ដងទៀត នៅក្នុងផ្នែកបន្ទាប់ទៀត នៃរបាយការណ៍នេះ ស្ដីពីក្រុមហ៊ុនរ៉ែ សារជើន)។ ប្រភពបានអះអាងថា ក្រុមហ៊ុន វីណាកូមិន ក៏មានផែនការដើម្បីសាងសង់រោងចក្រស្ល ប្រេងកាត់មួយ នៅក្នុងស្រុកនោះដែរ។[១៣៥] Global Witness បានសូមក្រុមហ៊ុនទាំងពីរ ឲ្យបញ្ជាក់ថា តើនេះពិតឬទេ។ ក្រុមហ៊ុន វីណាកូមិន បានឆ្លើយតប ដោយថ្លែងដូចតទៅនេះ៖

"ក្រុមហ៊ុន វីណាកូមិន បានចាប់ផ្ដើមសកម្មភាពស៊ើបអង្កេត និងស្វែងរុករកធនធានរ៉ែ នៅក្នុងប្រទេសកម្ពុជា ដោយទទួលការអនុញ្ញាត និងការគាំទ្រ ពីរាជរដ្ឋាភិបាល កម្ពុជា ហើយនិងក្រសួង និងទីភ្នាក់ងារដែលមានសមត្ថកិច្ច។ ក្រុមហ៊ុន វីណាកូមិន កំពុងតែអនុវត្តសកម្មភាពស៊ើបអង្កេត និងស្វែងរុករក ទន្ទឹមនឹងពេលដែលស្រាវជ្រាវ យ៉ាងលំអិត នូវច្បាប់របស់រាជរដ្ឋាភិបាលកម្ពុជា ស្ដីពីវិស័យឧស្សាហកម្មដកស្រង់ធនធានរ៉ែ។

យើងខ្ញុំក៏ចាប់អារម្មណ៍លើគ្រប់រឿងរ៉ាវ ដែល Global Witness បានលើងឡើងផងដែរ។ យើងកំពុងតែសិក្សា និងស្រាវជ្រាវរឿងរ៉ាវទាំងនោះ ដើម្បីយើងអាចមានព័ត៌មានគ្រប់គ្រាន់ ដើម្បីឆ្លើយតបសំណួរពី Global Witnessបាន។"[១៣៦]

## ប្រអប់ទី ៥ | អាជីវកម្មនៃក្រុមហ៊ុនភាពីម៉ិច

សកម្មភាពនៃក្រុមហ៊ុន ភាពីម៉ិច បានលេចឡើងយ៉ាងទៀងទាត់ នៅក្នុងរបាយការណ៍ Global Witness ស្តីពីការកាប់ឈើខុសច្បាប់ នៅក្នុងរយៈពេល ១៣ ឆ្នាំកន្លងមកនេះ។ ក្រុមហ៊ុន ភាពីម៉ិច ត្រូវបានកាន់កាប់ដោយគូស្វាមីភរិយា ដែលជិតស្និទ្ធជាមួយអគ្គនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ហើយនិងភរិយា លោកជំទាវ **ប៊ុន រ៉ានី**។[១៣៧] នាយកក្រុមហ៊ុន ឯកឧត្តម **ឡៅ ម៉េងឃីន** គឺជាសមាជិកព្រឹទ្ធសភាដ៏ល្បីឈ្មោះ នៅក្នុងគណបក្សកាន់អំណាច គឺគណបក្សប្រជាជនកម្ពុជា។ ភរិយារបស់ឯកឧត្តម លោកស្រី **ជឹង សុភាព**[១៣៨] (ហៅក្រៅថា យាយ ភូ) គឺជាអ្នកដឹកនាំមួយរូបនៃអង្គការកាកបាទក្រហមកម្ពុជា ហើយជាញឹកញាប់ ចេញមុខជាសាធារណៈជាមួយភរិយានៃអគ្គនាយករដ្ឋមន្ត្រី។ ទាំងលោកស្រី **ជឹង សុភាព** និងឯកឧត្តម **ឡៅ ម៉េង ឃីន** ធ្លាប់អមទស្សនកិច្ចផ្លូវទូត របស់អគ្គនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ទៅប្រទេសចិន។[១៣៩]

ក្រុមហ៊ុន ភាពីម៉ិច បានទទួលភាពល្បីមុនដំបូង ដោយសារជាសម្បទានិកកាប់ព្រៃឈើ នៅក្នុងទសវត្ស ១៩៩០ (សូមមើល ប្រអប់ទី ១ សម្រាប់ព័ត៌មានលំអិតបន្ថែម អំពីប្រព័ន្ធសម្បទានិក)។ នៅក្នុងវិស័យកាប់ឈើ ដ៏ពោពេញដោយការកាប់ឈើខុសច្បាប់ និងការប៉ះទង្គិចជាមួយអ្នកស្រុក ភាពីម៉ិច មានកេរ្តិ៍ឈ្មោះមិនសូវល្អ នៅក្នុងចំណោមសម្បទានិកទាំងឡាយ ដោយសារភាពគ្មានមេត្តា និងកម្រិតនៃការបំផ្លិចបំផ្លាញ ដែលបានប្រើទៅលើតំបន់ដីសម្បទានរបស់វា។ ក្រុមហ៊ុននេះមានទំនាក់ទំនងដ៏យូរអង្វែង ជាមួយកងយោធពលរបស់ប្រទេសកម្ពុជា ហើយបានប្រើសមាជិកកងយោធា ដើម្បីផ្តល់សន្តិសុខ និងអនុវត្តការគ្រប់គ្រងទៅលើសម្បទានព្រៃឈើរបស់វា។[១៤០]



ឯកឧត្តម **ឡៅ ម៉េងឃីន** និងលោកស្រី **ជឹង សុភាព** (ហៅក្រៅថា យាយ ភូ ដែរ) កាន់កាប់ក្រុមហ៊ុន ភាពីម៉ិច ដែលជាក្រុមហ៊ុនមានអំណាចបំផុតមួយ នៅក្នុងប្រទេសកម្ពុជា។ តាមរយៈសម្បទានព្រៃឈើ សម្បទានរ៉ែ និងសម្បទានដីសេដ្ឋកិច្ចរបស់វា ភាពីម៉ិច កាន់កាប់ជាង ៧ ភាគរយ នៃផ្ទៃដីសរុងរបស់

នៅពេលការគាបសង្កត់ពីទាយក និងអង្គការ បាននាំអគ្គនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ឲ្យដាក់ការព្យួរទុកបណ្តោះអាសន្ន ទៅលើសម្បទានកាប់ឈើនៅក្នុងប្រទេសកម្ពុជា នាឆ្នាំ ២០០២ ក្រុមហ៊ុន ភាពីម៉ិច មិនខ្វល់ខ្វាយសោះ។ រៀងរាល់ឆ្នាំ រវាងឆ្នាំ ២០០១ និង ២០០៤ Global Witness បានឃើញអ្នកម៉ៅការបន្តរបស់ក្រុមហ៊ុន ភាពីម៉ិច ហើយនិងសមាជិក RCAF កាប់ និងធ្វើប្រព្រឹត្តិកម្មឈើយ៉ាងច្រើន ដោយខុសច្បាប់ នៅក្នុងដីសម្បទានរបស់ក្រុមហ៊ុននោះ។[១៤១] Global Witness បានបោះពុម្ពព័ត៌មានលំអិត អំពីសកម្មភាពទាំងនេះ នៅក្នុងខែមិថុនា ឆ្នាំ ២០០៤។ ក្នុងនាមជាក្រុមហ៊ុន ភាពីម៉ិច មិនដែលតវ៉ាការពារកេរ្តិ៍ឈ្មោះខ្លួនឯង ហើយខែមិថុនា ឆ្នាំ ២០០៤ មិនមែនជាករណីលើកលែងទេ។ ផ្ទុយទៅវិញ អគ្គនាយករដ្ឋមន្ត្រី ហ៊ុន សែន បានវាយប្រហារទៅលើរបាយការណ៍នោះ ដោយប្រាប់អ្នករាយការណ៍ព័ត៌មានថា " Global Witness ធ្លាប់កុហកពីមុន ហើយថ្ងៃនេះ ពួកគេកុហកម្តងទៀតហើយ។"[១៤២]

ក្នុងការប៉ុនប៉ងព្យាយាមទទួលការអធិប្បាយ Global Witness បានសរសេរសំបុត្រមួយទៅសម្តេច **ហ៊ុន សែន** និងលោកជំទាវ **ប៊ុន រ៉ានី** នៅក្នុងខែតុលា ឆ្នាំ ២០០៨ ដើម្បីសួរលោកពីររូបថា តើគាត់មានភាគហ៊ុន ឬទំនាក់ទំនងទទួលប្រយោជន៍ផ្ទាល់ខ្លួនបែបណាផ្សេងទៀត ជាមួយក្រុមហ៊ុន ភាពីម៉ិច ឬក្រុមហ៊ុនជាសាខាណាមួយរបស់វា ឬទេ។ នៅពេលបោះពុម្ពរបាយការណ៍នេះ Global Witness មិនបានទទួលចម្លើយអ្វីទេ។

តាំងពីពាក់កណ្តាលទសវត្សកៅសិប ក្រុមហ៊ុន ភាពីម៉ិច បានពង្រីកវិស័យពាណិជ្ជកម្មរបស់វា ដើម្បីរួមបញ្ចូលសម្បទានសម្រាប់ការនាំចូលថ្នាំពេទ្យ ការសាងសង់សណ្ឋាគារ ហើយនិងតំបន់សេដ្ឋកិច្ចពិសេស។[១៤៣] តាមរយៈសម្បទានកាប់ឈើ និងសម្បទានដីសេដ្ឋកិច្ចរបស់វា ក្រុមហ៊ុន ភាពីម៉ិច កាន់កាប់ ៧,៤ ភាគរយនៃផ្ទៃដីសរុប របស់ប្រទេសកម្ពុជា។[១៤៤] ពេលថ្មីនេះ ក្រុមហ៊ុន ភាពីម៉ិចបានពាក់ព័ន្ធនៅក្នុងការប្រមូលទំនប់ទឹកជលាថាមពល ពាសពេញប្រទេសកម្ពុជា។ ឯកសារដែល Global Witness យកបាន មានឈ្មោះ **ជឹង សុភាព** និង **ឡៅ ម៉េងឃីន** ជានាយកនៃក្រុមហ៊ុនទំនប់ទឹកថ្មីពីរ ដែលមានគម្រោងនឹងសាងសង់ទំនប់ទឹកនៅក្នុងខេត្តកំពត – គឺក្រុមហ៊ុន Petro Camchin [ប៉េត្រូ កាំជីន] និង Sino Hydropower [ជលាថាមពល ស៊ីណូ]។[១៤៥]

ចក្រភពជំនួញនេះ ឥឡូវនេះ កំពុងតែត្រូវបានពង្រីក ដើម្បីលេបការដ្ឋានអាជីវកម្មរ៉ែ ពាសពេញប្រទេស។ ក្រៅពីការកាន់ឈ្មោះជានាយកនៃក្រុមហ៊ុនរ៉ែ ហុងហ្វូ-ទ្រី ភាព ក៏ការស៊ើបអង្កេតរបស់ Global Witness បានបង្ហាញឲ្យឃើញថា ឯកឧត្តម **ឡៅ ម៉េងឃីន** មានឈ្មោះជានាយកនៅក្នុងក្រុមហ៊ុនធ្វើអាជីវកម្មរ៉ែ យ៉ាងហោចណាស់ មួយទៀត គឺ Zhong Xin Industrial Investment (Cambodia) Co. Ltd. [ក្រុមហ៊ុនវិនិយោគឧស្សាហកម្ម ចុង ស៊ីន (កម្ពុជា) ចំកាត់] ដែលមានអាជ្ញាប័ណ្ណធនធានរ៉ែ ដើម្បីស្វែងរុករកនៅក្នុងស្រុកសំបូរ ខេត្តក្រចេះ។[១៤៦]

ម្ចាស់ក្រុមហ៊ុន ភាពីម៉ិច ឯកឧត្តម **ឡៅ ម៉េងឃីន** ក៏ជានាយកមួយរូប នៅក្នុងក្រុមហ៊ុនមួយ ហៅថា Shukaku Ltd [ស៊ូកាគុ ចំកាត់] ដែលកំពុងតែពាក់ព័ន្ធក្នុងគម្រោងប្រកបដោយវាទប្បដិវាទ ដើម្បីចាក់ដីបំពេញបឹងកក នៅកណ្តាលទីក្រុងភ្នំពេញ។[១៤៧] ក្រុមហ៊ុននេះ បានយល់ព្រមព្រៀងដើម្បីទទួល ៩០ ភាគរយនៃបឹងនោះ ពីទីក្រុងភ្នំពេញ តាមរយៈភតិសន្យា ៩៩ ឆ្នាំ។ តាមទីក្រុងភ្នំពេញ[១៤៨] បានឲ្យដឹងថា ការអភិវឌ្ឍន៍នោះ នឹងផ្តល់ "កន្លែងល្អ សម្រាប់ការលក់ដូរ និងការបម្រើជនទេសចរណ៍ ទាំងអ្នកស្រុកទេស និងជនបរទេស"។[១៤៩] ការអភិវឌ្ឍន៍នេះ គឺមានតម្លៃថ្លៃណាស់៖ គឺផ្ទះ និងជីវភាពនៃអ្នករស់នៅបឹងកក រាប់ពាន់នាក់។ ការិយាល័យប្រចាំប្រទេសកម្ពុជា នៃគណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ បានអះអាងថា ៤.២២៥ គ្រួសារ នឹងត្រូវបានបណ្តេញចេញនៅពេលបឹងនេះត្រូវបានចាក់ដីបំពេញ។[១៥០] អ្នកមានលំនៅនៅទីនោះ អះអាងថា ប្រាក់សំណង គឺតិចជាងតម្លៃទីផ្សារនៃដីធ្លីនោះ ហើយថាផ្ទះសម្បែងផ្សេងទៀត ដែលក្រុមហ៊ុនផ្តល់ឲ្យ គឺមិនល្អគ្រប់គ្រាន់ទេ ហើយនៅឆ្ងាយពីកណ្តាលទីក្រុង។[១៥១] ពួកគេក៏អះអាងថា ក្រុមហ៊ុនមិនបានពិគ្រោះជាមួយគេគ្រប់គ្រាន់ឡើយ នៅក្នុងការចរចាព្រមព្រៀងនោះ។[១៥២]



ផ្ទះមួយលេចទឹក នៅកណ្តាលទីក្រុងភ្នំពេញ នៅពេលបឹងកកត្រូវបានចាក់ដីបំពេញ។ សមាជិកព្រឹទ្ធសភា ឡៅ ម៉េងឃីន គឺជានាយកមួយរូប នៃក្រុមហ៊ុនដែលទទួល

## ក្រុមហ៊ុនរ៉ែ Southern

**Southern Mining Company [ក្រុមហ៊ុនរ៉ែ សាវធើន] មានសម្បទាន ដើម្បីស្វែងរករកររ៉ែក្រូម នៅក្នុងដែនជម្រកសត្វព្រៃភ្នំសំកុះ។ តំបន់នេះពីមុនត្រូវបានចាត់ទុកជាតំបន់ ‘ស្នូល’ ដោយទទួលស្គាល់តម្លៃខ្ពស់ ខាងការអភិរក្សធនធានធម្មជាតិ។ ទោះជាយ៉ាងណាក៏ដោយ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល បានផ្ដល់ការអនុញ្ញាតឲ្យស្វែងរករកធនធានរ៉ែ។**




ផ្លាកមួយ នៅទីចាប់ផ្ដើមសម្បទានរ៉ែ របស់ក្រុមហ៊ុន សាវធើន។

**ការដ្ឋានអណ្ដូងរ៉ែត្រូវបានយាមការពារ ដោយសមាជិកនៃកងយោធពលខេមរភូមិន្ទ (RCAF)។ អ្នកយាមតំណែងខ្ពស់មួយរូប នៅឯការដ្ឋាននោះ បានអះអាងថា ខ្លួនលោកតំណាងឲ្យលោកនាយឧត្ដមសេនីយ៍ មាស សុភា គឺមេបញ្ជាការនៃកងទ័ពថ្មើរជើងរបស់ RCAF។ អ្នកយាមបានប្រាប់បុគ្គលិករបស់ Global Witness ថា ឧត្ដមសេនីយ៍ត្រី អ៊ុក កោសា – ដែលប្រធានយោធភូមិភាគអភិវឌ្ឍន៍នៃប្រទេសកម្ពុជា – គឺជានាយកប្រតិបត្តិចម្បង នៃក្រុមហ៊ុនរ៉ែនោះ។**

**នៅក្នុងឆ្នាំ ២០០៨ ក្រុមហ៊ុន វីណាកូមិន បានទិញចំណែកហ៊ុន ៧០ ភាគរយនៃក្រុមហ៊ុនរ៉ែ សាវធើន។ ម្ចាស់ទទួលប្រយោជន៍នៃចំណែកហ៊ុន ៣០ ភាគរយដែលនៅសល់ គឺមិនបានឲ្យដឹងទេ។**

វត្តមាននៃអណ្ដូងរ៉ែនេះ គឺប្រកបដោយវាទប្បដិវាទ ហើយស្ថានភាពផ្លូវច្បាប់របស់វា គឺមិនច្បាស់លាស់ទេ។ ដូច្នេះ វាជាឧទាហរណ៍ជាក់ស្ដែង នៃភាពតឹងតានរវាងតំបន់ការពារ និងវិស័យអាជីវកម្មរ៉ែ។ វាស្ថិតនៅក្នុងដែនជម្រកភ្នំសំកុះ ទំហំ ៣៣៤.០០០ ហ.ត. នៅផ្នែកខាងលេចនៃជួរភ្នំក្រវាញ ដែលគ្របបដណ្ដប់ ខេត្តពោធិ៍សាត់ បាត់ដំបង និងកោះកុង ទាំងបីខេត្ត។ ក្នុងនាមជាតំបន់ការពារ ដែនជម្រកនេះ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងនៃក្រសួងបរិស្ថាន(MoE)។ ហេតុដូច្នេះ ការមកដល់ នៃក្រុមហ៊ុនរ៉ែសាវធើន[១៥៣] បានបង្កើតចលាចលមួយ នៅក្នុងចំណោមអ្នកគ្រប់គ្រងដែនជម្រកទាំងឡាយ នៅក្នុងឆ្នាំ ២០០៦ នៅពេលដែលឡានដឹកទំនិញយ៉ាងធំ ដែលដឹកម៉ាស៊ីនឈូសដី និងត្រាក់ទ័រ បានចាប់ផ្ដើមមកដល់ដែនជម្រក ដោយគ្មានអ្នកប្រាប់ឲ្យដឹងមុនសោះ។ ម៉ាស៊ីនធំទាំងនោះ ត្រូវបានប្រើប្រាស់ ដើម្បីទាមទារសម្បទានដីទំហំ ១០.០០០ ហ.ត. នៅក្នុងតំបន់ស្នូល របស់តំបន់ភ្នំសំកុះ។[154]

### ឧទ្យានុរក្ស ត្រូវបានឃាត់

ការរួមរស់ដោយមិនសូវស្រួល នៃក្រុមហ៊ុនរ៉ែ ជាមួយគម្រោងអភិរក្ស បានផ្ទុះឡើង នៅថ្ងៃទី ៣ ខែមិថុនា ឆ្នាំ ២០០៧ នៅពេលតាមរបាយការណ៍សារព័ត៌មាន ឧទ្យានុរក្ស MoE មួយចំនួនបានព្យាយាមចូលការដ្ឋានអណ្ដូងរ៉ែ ដើម្បីស៊ើបអង្កេតការចោតប្រកាន់ថា សកម្មភាពកាប់ព្រៃឈើខុសច្បាប់បានកើតឡើង នៅក្នុងការដ្ឋាននោះ។ ពួកគេត្រូវបានឃាត់មិនឲ្យចូល ដោយទាហាន RCAF ប្រដាប់អាវុធអា-កា ៤៧។[១៥៥] តាមច្បាប់ ឧទ្យានុរក្សរបស់ MoE មានភារកិច្ចដើម្បីយាមល្បាតគ្រប់តំបន់នៅក្នុងឧទ្យាន ប៉ុន្តែនៅលើកនេះ ពួកគេត្រូវបានហាមឃាត់ មិនឲ្យបំពេញកិច្ចការនេះ ដោយពួកទាហាន ដែលបានចេញពីឡានថ្លៃមួយគ្រឿង ហ៊ុំព័ទ្ធជុំវិញពួកឧទ្យានុរក្ស ហើយប្រាប់គេឲ្យចេញ ទាំងអះអាងថា ពួកគេមិនមានឯកសារត្រឹមត្រូវ ដើម្បីចូលកន្លែងនោះទេ។[១៥៦]

Global Witness បានសរសេរសំបុត្រមួយទៅ ក្រុមហ៊ុន សាវធើន នៅក្នុងខែតុលា ឆ្នាំ ២០០៨ ដើម្បីសុំការអធិប្បាយរបស់គេ អំពីហេតុការណ៍នេះ។ នៅពេលបោះពុម្ពរបាយការណ៍នេះ Global Witness មិនបានទទួលចម្លើយទេ។

នៅក្នុងការធ្វើដំណើរទៅមើលកន្លែងសម្បទានរ៉ែ នៅក្នុងឆ្នាំ ២០០៨ អ្នកស៊ើបអង្កេត Global Witness ត្រូវបានអ្នកយាមអណ្ដូងរ៉ែប្រាប់ថា នៅក្នុងតំបន់នោះ មានការដ្ឋានស្វែងរុករកពីរ ហើយថាក្រុមហ៊ុននោះបានធ្វើការពីរឆ្នាំហើយ នៅក្នុងចំណោមបួនឆ្នាំនៃការស្វែងរុករក។[១៥៧] អ្នកយាមក៏បានថ្លែងថា ភូគព្ភវិទូកំពុងស្វែងរករ៉ែដែក ក្រូម និងអាន់ទីម៉ូនី (លោហធាតុម្យ៉ាង ដែលគេប្រើដើម្បីលាយពង្រឹងសំណ)។[១៥៨] ពួកគេត្រូវបានប្រាប់ថា ការដ្ឋាននោះប្រហែលមានមាស ឬ ត្បូង ផងដែរ ប៉ុន្តែគេយកចិត្តទុកដាក់ច្រើនជាងគេ លើរ៉ែក្រូម គឺជាធនធានរ៉ែម្យ៉ាង ដែលគេប្រើដើម្បីបង្កើតក្រូម ដែលប្រើប្រាស់នៅក្នុងឧស្សាហកម្មផលិតរថយន្ត និងឧស្សាហកម្មផ្សេងទៀត។ តាមអ្នកយាមការដ្ឋាន បានឲ្យដឹងថា បើគេរកឃើញរ៉ែក្រូមគ្រប់គ្រាន់នៅដីសម្បទាននោះ គេនឹងសាងសង់រោងចក្រធ្វើប្រព្រឹត្តិកម្មរ៉ែ នៅនឹងដីធ្លីនោះ។

**ទាហានខ្មែរ ម្ចាស់វៀតណាម?**

អ្នកស៊ើបអង្កេត Global Witness បានប៉ុនប៉ងទៅមើលដីសម្បទានក្រុមហ៊ុនរ៉ែ សាវជើន នៅក្នុងពាក់កណ្ដាលឆ្នាំ ២០០៨ ប៉ុន្តែផ្លូវចូលដល់ទីនោះ ត្រូវបានឃាត់ដោយអ្នកយាម ដែលអ្នកខ្លះពាក់ឯកសណ្ឋានយោធា RCAF។ អ្នកយាមមានវិទ្យុ ដែលគេនិយាយថា អាចនិយាយជាមួយទីស្នាក់ការក្រុមហ៊ុន នៅឯទីក្រុងភ្នំពេញ។ នៅពេលដែលអ្នកតំណាង Global Witness បានសួរថា តើហេតុអ្វីបានជាគេត្រូវការនិយាយជាមួយទីស្នាក់ការនៅឯទីក្រុងភ្នំពេញ ពួកគេត្រូវបានអ្នកយាមប្រាប់ថា អ្នកដឹកនាំក្រុមហ៊ុនទាំងឡាយខឹង ដោយសារពីមុន សកម្មជនការពារបរិស្ថានចូលដល់ការដ្ឋានបាន ហើយពួកទាហាននោះត្រូវបានចោតប្រកាន់។ បន្ទាប់មក អ្នកយាមត្រូវបានបង្គាប់ឲ្យកាន់វិទ្យុ ហើយទាក់ទងជាមួយទីស្នាក់ការ បើមានអ្នកណាព្យាយាមចូលដល់ការដ្ឋានម្ដងទៀត។




កម្មករនៅឯការដ្ឋានរ៉ែ សីឌីន ពាក់អាវសញ្ញា GEOSIMCO ដែលជាក្រុមហ៊ុនសាខា របស់ក្រុមត្បូងថ្ម និងធាតុរ៉ែ វៀតណាម ដែលត្រូវបានគេរាយការណ៍ថា ទិញចំណែកហ៊ុន ៧០% នៃក្រុមហ៊ុនរ៉ែ សីឌីន នាឆ្នាំ ២០០៨

ការដ្ឋាននោះ យាមដោយទាហាន RCAF ប្រមាណ ១០០ នាក់ ពីកងវរសេនាលេខ ៥០១។ អ្នកយាមតំណែងខ្ពស់មួយរូបនៅទីនោះ បានអះអាងថា ខ្លួនតំណាងឲ្យលោកនាយឧត្ដមសេនីយ៍ **មាស សុភា** មេបញ្ជាការនៃកងទ័ពថ្មើរជើងរបស់ RCAF។[១៥៩]

កម្មករនៅឯការដ្ឋានរ៉ែនោះ ក៏បានអះអាងថា ឧត្ដមសេនីយ៍ត្រី **អ៊ុក កោសា** – ប្រធាននៃតំបន់យោធភូមិភាគអភិវឌ្ឍន៍[vi] – គឺជាប្រធាននឹងនាយកប្រតិបត្តិចម្បង នៃអណ្ដូងរ៉ែនោះ។[160] អ្នកស៊ើបអង្កេត Global Witness ត្រូវបានឲ្យលេខទូរស័ព្ទរបស់លោក ដើម្បីទទួលការអនុញ្ញាតចូលទៅមើលការដ្ឋានរ៉ែ ព្រមទាំងលេខទូរស័ព្ទរបស់មេបញ្ជាការរងរបស់លោក គឺលោកវរសេនីយ៍ **អោច ចាន់នី**។[161] នៅពេល Global Witness បានទាក់ទងលោក **អ៊ុក កោសា** លោកបាននិយាយថា អណ្ដូងរ៉ែនោះត្រូវបានលក់ទៅពួកវៀតណាម ប៉ុន្តែមិនព្រមផ្ដល់ឈ្មោះ ឬលេខទូរស័ព្ទ សម្រាប់ម្ចាស់ថ្មីទេ។

ទាហានយាមការដ្ឋាននោះ បានឲ្យដឹងថា ដីសម្បទានរបស់ក្រុមហ៊ុនរ៉ែ សាវជើន ធ្លាប់ជាកម្មសិទ្ធិរបស់ក្រុមហ៊ុនចិនមួយ ហើយម្ចាស់វៀតណាមបានទទួលយកសម្បទាននោះ នៅប្រហែលខែមេសា ឆ្នាំ ២០០៨។ អ្នកយាមពេញចិត្តនិងស្ថានភាពថ្មី ទាំងអះអាងថា ម្ចាស់ចាស់មិនបានបង់ប្រាក់ខែរបស់គេទាន់ពេលទេ ប៉ុន្តែក្រុមហ៊ុនវៀតណាមបង់ប្រាក់ខែ US$១៥០ យ៉ាងទៀងទាត់ ហើយផ្ដល់ការធានារ៉ាប់រងសុខភាពទៀតផង។[១៦២]

នៅក្នុងការទៅមើលការដ្ឋាន អ្នកស៊ើបអង្កេត Global Witness បានសង្កេតឃើញថា បុគ្គលិកម្នាក់របស់អណ្ដូងរ៉ែបានពាក់អាវមួយ មានសញ្ញាក្រុមហ៊ុន Geosimco [ជីយ៉ូ ស៊ីមកូ][១៦៣] ជាមួយអក្សរវៀតណាម។ ក្រុមហ៊ុន ជីយ៉ូ ស៊ីមកូ គឺជាសាខាមួយ របស់ក្រុមឧស្សាហកម្មត្បូងថ្ម និងធនធានរ៉ែវៀតណាម ហៅក្រៅថា វីណាកូមិន។[១៦៤]

នៅក្នុងខែសីហា ឆ្នាំ ២០០៨ កាសែត *Cambodia Daily* បានរាយការណ៍ថា ក្រុមហ៊ុន វីណាកូមិន បានទិញហ៊ុន ៧០ ភាគរយនៃក្រុមហ៊ុនរ៉ែ សាវជើន។[១៦៥] សំណួរថា ម្ចាស់ទទួលប្រយោជន៍ នៃចំណែកហ៊ុន ៣០ ភាគរយដែលនៅសល់ ជានរណានោះ គឺនៅតែមិនច្បាស់ទេ។




កាតរបស់ឧត្ដមសេនីយ៍ អ៊ុក កុសា។ អ៊ុក កុសា គឺជាប្រធាននៃយោធភូមិភាគអភិវឌ្ឍន៍ របស់ប្រទេសកម្ពុជា។ មានសេចក្ដីរាយការណ៍ថា លោកក៏ជានាយកប្រតិបត្តិចម្បង នៃគម្រោងរបស់ក្រុមហ៊ុនអាជីវកម្មរ៉ែ សីឌីន នៅក្នុងដែនជម្រកសត្វព្រៃភ្នំសំកុះដែរ

---

[vi] យោធភូមិភាគទាំងឡាយរបស់ប្រទេសកម្ពុជា មានដីប្រមាណ ៧០០០.០០០០ ហ.ត. ឬជិតបួនភាគរយ នៃផ្ទៃដីទាំងមូល របស់ប្រទេសកម្ពុជា។

## ប្រអប់ទី ៦ | តួនាទីនៃកងយោធពលរបស់ប្រទេសកម្ពុជា នៅក្នុងការលួចប្លន់ធនធានសាធារណៈ

ក្នុងចំណោមរឿងរ៉ាវដ៏ធ្ងន់ជាច្រើន ដែលត្រូវបានបំភ្លឺ នៅក្នុងការសិក្សាករណីអាជីវកម្មរ៉ែទាំងនេះ គឺជាតួនាទីនៃកងយោធពលខេមរភូមិន្ទ (RCAF) នៅក្នុងអំពើរិតិកម្ម នៃធនធានសាធារណៈទាំងនេះ។ នៅការដ្ឋានប្រាំកន្លែង ក្នុងចំណោមការដ្ឋានទាំងប្រាំមួយកន្លែងដែលបានស្ទង់មើល មានការពាក់ព័ន្ធដ៏ជាក់ស្ដែង នៃ RCAF – ទោះក្នុងការផ្ដល់សេវាកម្មសន្តិសុខឯកជន ដល់ការដ្ឋានអណ្ដូងរ៉ែ ឬតាមរយៈភាពជាម្ចាស់ទទួលប្រយោជន៍ នៃអណ្ដូងរ៉ែនោះឯង។[១៦៦]

តាំងពីទីបញ្ចប់នៃសង្គ្រាមស៊ីវិលរបស់ប្រទេសកម្ពុជា រដ្ឋាភិបាលបានបន្តចំណាយប្រហែល ២៥ ភាគរយ នៃថវិកាដ៏មានកំណត់របស់រដ្ឋ ទៅលើកងទ័ពដ៏ធំសម្បើម មានទាហានប្រមាណ ១១០.០០០ នាក់។[១៦៧] អស់ជាច្រើនឆ្នាំ Global Witness បានកត់ជាឯកសារ ពីរបៀបសមាជិកនៃ RCAF ពាក់ព័ន្ធនៅក្នុងសកម្មភាពរកប្រភពបង្កើតផលចំណូលខុសច្បាប់ ទោះបីពួកគេទទួលចំណែកយ៉ាងធំ នៃថវិការដ្ឋយ៉ាងណាក៏ដោយ។ នេះជាការពិតជាពិសេស ចំពោះផ្នែកនៃកងយោធា ដែលគាំទ្រអគ្គនាយករដ្ឋមន្ត្រី – រួមទាំងអង្គភាពអង្គរក្សខ្លួនផ្ទាល់របស់សម្ដេច។[១៦៨] នៅក្នុងរយៈពេលដប់ឆ្នាំកន្លងមកនេះ Global Witness និងអង្គការខ្មែរដទៃទៀត បានកត់ជាឯកសារយ៉ាងក្បោះក្បាយ ពីរបៀបដែលផលចំណូលពីការលក់ដូរឈើខុសច្បាប់ និងសកម្មភាពខុសច្បាប់ផ្សេងៗទៀត ឧបត្ថម្ភដល់ផ្នែកយោធា នៃរដ្ឋស្រមោលរបស់ប្រទេសកម្ពុជា។ អ្នកដែលពាក់ព័ន្ធក្នុងសកម្មភាពទាំងនេះ ប្រើប្រាស់សមត្ថភាពគំរាមកំហែង និងប្រើកម្លាំងអាវុធ ដើម្បីរក្សាតួនាទីធំសម្រាប់ខ្លួន នៅក្នុងទីងងឹត នៃពិភពពាណិជ្ជកម្មរបស់ប្រទេសកម្ពុជា។ ផលចំណេញសរុបនៃស្ថាប័ននេះ គឺដូចជាផលចំណេញនៃបណ្ដាញបក្សពួកឧក្រិដ្ឋកម្មដ៏ធំមួយ។[១៦៩]

ការពាក់ព័ន្ធនៃ RCAF នៅក្នុងឧស្សាហកម្មរ៉ែ មានបញ្ហាដោយលក្ខណៈច្រើនយ៉ាង។ ពីទស្សនៈនៃសិទ្ធិមនុស្ស វាជាការធ្វើវិទ្ធង្សនានូវស្ថាប័នរដ្ឋ ដើម្បីបម្រើប្រយោជន៍ផ្ទាល់ខ្លួនឯកជន ជំនួសប្រយោជន៍នៃប្រជាពលរដ្ឋទូទៅ។ ការគំរាមប្រើកម្លាំងអាវុធ ធ្វើឲ្យមានការពិបាកខ្លាំងឡើយសម្រាប់សហគមន៍អ្នកស្រុក ក្នុងការទាមទារសិទ្ធិលើដី នឹងធនធាន ដែលស្ថិតនៅក្នុងដីសម្បទាន។ ពីទស្សនៈសាជីវកម្មវិញ មានការប្រថុយថា ទាហានដែលយាមអណ្ដូងរ៉ែ នឹងប្រព្រឹត្តបទបំពានសិទ្ធិមនុស្ស។ នៅក្នុងករណីនោះ ការបង់ប្រាក់ណា ពីក្រុមហ៊ុនដែលប្រតិបត្តិអណ្ដូងរ៉ែនោះ អាចធ្វើឲ្យក្រុមហ៊ុននោះមានទោសរួមចំណែក ក្នុងការបំពានសិទ្ធិមនុស្សនោះ។ ពីទស្សនៈអភិបាលកិច្ច ការដែលកងយោធពលធ្វើជាសហគ្រាសកម្លាំងអាវុធឈ្នួល ក៏មិនគួរឲ្យចង់បានដែរ។ នៅពេលកងយោធាណាមួយចាប់ផ្ដើមរកផលចំណូលខ្លួនវា ពីសកម្មភាពឯកជន ហើយមិនមែនពីថវិកាជាតិទេ ប្រាក់នោះបន្ទន់ដល់សមត្ថភាពនៃរដ្ឋាភិបាលស៊ីវិល ដើម្បីគ្រប់គ្រងកងយោធា តាមរយៈការកាន់កាប់ប្រាក់ថវិកាវា។



ទាហាននៅក្នុងដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់។ ការស៊ើបអង្កេតរបស់ Global Witness នៅទីនោះនាឆ្នាំ ២០០៤ បានរកឃើញថា កងយោធាពាក់ព័ន្ធយ៉ាងសន្ធឹក នៅក្នុងការកាប់ឈើខុសច្បាប់នៅក្នុងដែនជម្រក។

### ក្រុមហ៊ុន Float Asia Friendly Mation

ក្រុមហ៊ុន Float Asia Friendly Mation កំពុងដកស្រង់ថ្មកែវពីតំបន់ការពារ នៃដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ហើយនិងតំបន់អភិរក្សព្រៃឈើជួរភ្នំក្រវ៉ាញភាគកណ្ដាល (CCPF)។

ឯកសារចុះឈ្មោះ របស់ក្រុមហ៊ុននោះ បង្ហាញថា ម្ចាស់អណ្ដូងរ៉ែគឺជាបុរសម្នាក់ ឈ្មោះ ជីង គឹមងួន។ ក៏ប៉ុន្តែ អ្នកទាំងឡាយ ដែលត្រូវបាន Global Witness សម្ភាសបាននិយាយរឿងផ្សេង។ ពួកគេបានសំគាល់ថា ពួកវរជនពីររូបរបស់ប្រទេសកម្ពុជា – គឺឯកឧត្តម ឱម យ៉ិនទៀង និងលោក ឌី ចូច – ជាអ្នកវិនិយោគឧបត្ថម្ភរបស់អណ្ដូងរ៉ែនោះ។ ឱម យ៉ិនទៀង គឺជាទីប្រឹក្សារបស់អគ្គនាយករដ្ឋមន្ត្រី ហ៊ុន សែន ហើយជាប្រធាននៃគណៈកម្មាធិការសិទ្ធិមនុស្ស របស់រដ្ឋាភិបាល។ ឌី ចូច គឺជាប្អូនជាដូនមួយ របស់អគ្គនាយករដ្ឋមន្ត្រី។

អ្នកយាមពីជួរ RCAF កំពុងប្រើកម្លាំងហិង្សាដោយអាវុធ ដើម្បីការពារជំហររបស់ក្រុមហ៊ុននេះ នៅ ក្នុងតំបន់ភ្នំឱរ៉ាល់ ហើយដល់ពេលនេះ មានជោគជ័យក្នុងការប្រឆាំងកិច្ចប៉ុនប៉ងបណ្ដេញគេចេញដោយឧទ្យាននុរក្សរបស់ក្រសួងបរិស្ថាន។

*"ដែនដីខ្ពស់ នៅតំបន់ភ្នំឱរ៉ាល់ ជាទីជម្រកព្រៃឈើមួយដ៏ធំ និងបរិសុទ្ធបំផុត នៅក្នុងតំបន់ឥណ្ឌូស៊ីន។ វាក៏ជាទីជម្រកសម្រាប់ប្រព័ន្ធបរិស្ថានធម្មជាតិ និង 'កន្លែងជីវៈចំរុះសំខាន់' មួយ ដែលសឹងតែគ្មានគូប្រដូច សម្រាប់វិស័យវិជ្ជាសាស្ត្រឡើយ។"*[170]

លោកបណ្ឌិត J. Andrew McDonald [ចេ អាន់ទ្រូ មិកដន់ណាល់ដ៍], Plant Resources Center, University of Texas at Austin [មជ្ឈមណ្ឌលធនធានរុក្ខជាតិ, សាកលវិទ្យាល័យរដ្ឋតិក្សាស់ នៅទីក្រុងអស្ទិន], ឆ្នាំ ២០០៤។




*"រូបសំណាក់ខ្មែរ ទាក់ទាញចំណាប់អារម្មណ៍របស់អ្នកទេសចរណ៍។ រូបសំណាក់ដ៏ឆ្ងាក់យ៉ាងវិចិត្រ តំណាងឲ្យវិចិត្រកម្ម វប្បធម៌ និងវត្ថុសាសនាបុរាណ នៃប្រទេសកម្ពុជា។"*

សំដីដកស្រង់ពីខិត្តប័ណ្ណផ្សាយរបស់ក្រុមហ៊ុន Float Asia Friendly Mation (ខាងលើ)។[១៧១]

សកម្មភាពជីកយកថ្មកែវ នៃក្រុមហ៊ុន Float Asia Friendly Mation មានទីតាំងនៅក្នុងឃុំកោត និងឃុំសន្ទ្រែ ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។[១៧២] តាមឯកសារដែល Global Witness យកបាន បានឲ្យដឹងថា ក្រុមហ៊ុនមានការដ្ឋានបី សម្រាប់ការយកថ្មកែវ។ ការដ្ឋានពីរ មានទីតាំងនៅក្នុងដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់។ ទីបីស្ថិតនៅក្នុងតំបន់អភិរក្សព្រៃឈើជួរភ្នំក្រវាញភាគកណ្ដាល។[១៧៣] ក្រុមហ៊ុននេះ ក៏មានឃ្លាំងធ្វើប្រព្រឹត្តិកម្មថ្មកែវ នៅក្នុងភូមិតាសែ ឃុំកោត ខេត្តពោធិ៍សាត់ ហើយឃ្លាំងថ្មកែវមួយកន្លែង នៅក្នុងទីប្រជុំជនស្រុកភ្នំក្រវាញ។[១៧៤]

នៅពេលដែលអ្នកស៊ើបអង្កេត Global Witness បានធ្វើទស្សនកិច្ចទៅកាន់តំបន់នោះ នៅក្នុងឆ្នាំ ២០០៨ ការធ្វើដំណើរទៅកាន់ការដ្ឋានរាយថ្មមានគ្រោះថ្នាក់ខ្លាំងពេក ដោយសារផ្លូវមានគុណភាពអន់ពេក ហើយមានគ្រោះថ្នាក់ទឹកលេចជន់គ្របផ្លូវលឿន នៅក្នុងរដូវភ្លៀង។ អ្នកតំណាងក្រុមហ៊ុនមួយរូប បានអះអាងថា ក្រុមហ៊ុន Float Asia បាននាំកម្មករចិនចូល ដើម្បីធ្វើផ្លូវទៅកាន់អណ្ដូងរ៉ែ នៅក្នុងឆ្នាំ ២០០៦។ អាជីវកម្មរ៉ែ ត្រូវបានប្រតិបត្តិដោយបុគ្គលម្នាក់ ឈ្មោះ លោក តា ទ្រី[១៧៥] ដែលមានឈ្មោះក្រៅថា តាវ៉ែនតា។[១៧៦] កម្មករទាំងនេះបានកាប់ឆ្ការព្រៃ ប៉ុន្តែបានបរាជ័យក្នុងការសាងសង់ផ្លូវល្អគ្រាន់បើ ហើយគុណភាពផ្លូវនោះបានចុះដុនដាបយ៉ាងលឿន។ ដោយសារការខ្វះហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ សូម្បីតែក្នុងរដូវប្រាំងក៏ដោយ ក្រុមហ៊ុន Float Asia ត្រូវតែប្រើកម្មករជាអ្នកស្រុក ហើយនិងរទេះក្របី ជំនួសឡាន។[១៧៧] អ្នកស៊ើបអង្កេតបានកត់សំគាល់ថា ឃ្លាំងមានថ្ម ប្រដាប់ប្រដាជីកយកថ្ម និងបុគ្គលិក



ដែនជម្រកសត្វព្រៃ ភ្នំឱរ៉ាល់។ ការដ្ឋានអាជីវកម្មរ៉ែពីរកន្លែងរបស់ក្រុមហ៊ុន Float Asia Friendly Nation មានទីតាំងនៅទីនេះ តាមឯកសាររបស់ក្រុមហ៊ុន។





ខាងឆ្វេង៖ អាជ្ញាប័ណ្ណអាជីវកម្មរ៉ែ និងវាយថ្ម របស់ក្រុមហ៊ុន Float Asia Friendly Mation
ខាងស្ដាំ៖ ឯកសារចុះឈ្មោះក្រុមហ៊ុន ដែលបង្ហាញថាឈ្មោះ ជឹង គឹមងួន គឺជាម្ចាស់របស់ក្រុមហ៊ុន Float Asia Friendly Mation

លក់ថ្មជាច្រើន។ ពួកគេបានឃើញអតិថិជនទិញថ្ម ហើយដាក់វានៅក្នុងឡានដឹកទំនិញ។[១៧៨]

ខិត្តប័ណ្ណផ្សាយរបស់ក្រុមហ៊ុន Float Asia និយាយយ៉ាងលំអិតអំពីមូលដ្ឋានច្បាប់នៃប្រតិបត្តិការក្រុមហ៊ុន ទាំងចែងថា បានទទួលអាជ្ញាប័ណ្ណពី MIME សម្រាប់ 'អណ្ដូងរ៉ែបើក និងការដ្ឋានវាយថ្មលេខ ៥៩៧' នៅក្នុងខែមិថុនា ឆ្នាំ ២០០៦។[១៧៩]

ក៏ប៉ុន្តែបុគ្គលិករបស់ MoE ដែលប្រតិបត្តិនៅក្នុងតំបន់នោះ ជំទាស់នឹងមូលដ្ឋានច្បាប់ នៃប្រតិបត្តិការរបស់ក្រុមហ៊ុន ទាំងអះអាងថាក្រុមហ៊ុនប្រតិបត្តិខុសច្បាប់ ដោយយោងច្បាប់ស្ដីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ឆ្នាំ ១៩៩៦។[១៨០]

Global Witness បានទទួលសំណៅមួយច្បាប់ នៃកម្រងឯកសាររបស់ MoE ដែលបានដាក់ផ្ញើនឹងតុលាការខេត្តពោធិ៍សាត់ ស្ដីពីសកម្មភាពរបស់ក្រុមហ៊ុន Float Asia ដែលកម្រងឯកសារនេះនិយាយយ៉ាងល្អិតល្អន់ អំពីភាពតឹងតានរវាងស្ថាប័នរដ្ឋទាំងពីរនេះ។ តាមឯកសារដាក់ផ្ញើតុលាការ បានឲ្យដឹងថាក្រុមសមត្ថកិច្ចរបស់ MoE បានរឹបអូសឡានធំមួយគ្រឿង ត្រាក់ទ័រមួយគ្រឿង និងម៉ាស៊ីនខ្យល់ពីរគ្រឿង ពីកន្លែងប្រតិបត្តិការរបស់ក្រុមហ៊ុន Float Asia។[១៨១] នៅពេលដែលក្រុមសមត្ថកិច្ចបានធ្វើដំណើរត្រលប់មកពីការដ្ឋាននោះវិញ អ្នកតំណាងក្រុមហ៊ុន Float Asia ឈ្មោះលោក **អ៊ាង សុខណាយ**[១៨២] បានបញ្ជាក្រុមយោធាមួយ ដើម្បីបញ្ឈប់ក្រុមសមត្ថកិច្ច ហើយបានគំរាមឲ្យបាញ់ពួកគេ។[១៨៣] ទោះជាមានការគំរាមកំហែងប្រើអំពើហិង្សាទៅលើបុគ្គលិក MoE ក៏ដោយ ក៏ប្រភពបានអះអាងប្រាប់ថា តុលាការខេត្តពោធិ៍សាត់ មិនបានធ្វើរឿងក្ដីផ្ដន្ទាទោសប្រឆាំងនឹងក្រុមហ៊ុន Float Asia ហើយមិនបានតាមដានការចោទប្រកាន់ ដែលរ៉ាយរ៉ាប់នៅក្នុងកម្រងឯកសាររបស់ MoE ឡើយ។[១៨៤]

តាមបទសម្ភាសន៍ជាមួយបុគ្គលិកក្រុមហ៊ុន បុគ្គលិក MoE និងអ្នកស្រុក នោះមើលទៅថា ក្រុមហ៊ុន Float Asia ត្រូវបានគ្រប់គ្រងនិងឧបត្ថម្ភដោយអ្នកមានអំណាច។



កឧត្ដម ឱម យិនទៀង ប្រធាននៃគណៈកម្មាធិការសិទ្ធិមនុស្សរបស់រដ្ឋាភិបាល (នៅក្នុងរូបថត) ហើយនិងលោក ខី ចូច ប្អូនជីដូនមួយរបស់អគ្គនាយករដ្ឋមន្ត្រី។ លោកទាំងពីររូបត្រូវបានអ្នកដ៏ជិតស្និទ្ធនឹងប្រតិបត្តិការរបស់ក្រុមហ៊ុន សំគាល់ថា ជាអ្នកឧបត្ថម្ភអណ្ដូងរ៉ែ

នៅពេលដែលអ្នកស៊ើបអង្កេត Global Witness បានទៅដល់ការិយាល័យរបស់ក្រុមហ៊ុននៅក្នុងទីក្រុងភ្នំពេញ នៅពាក់កណ្ដាលឆ្នាំ ២០០៨ បណ្ណចុះឈ្មោះក្រុមហ៊ុន ដែលព្យួរលើជញ្ជាំងបានសំគាល់បុគ្គលមួយរូប ឈ្មោះ **ជឹង គឹមង្វន**។[185] ក៏ប៉ុន្តែ នៅពេលដេញដោលសួរ បុគ្គលិកមួយរូប ហើយនិងមន្ត្រីមួយរូប ដែលដឹងអំពីប្រតិបត្តិការរបស់ក្រុមហ៊ុននោះ បានឲ្យដឹងថា ឯកឧត្ដម **ឱម យ៉ិនទៀង** ទីប្រឹក្សារបស់សម្ដេច **ហ៊ុន សែន** និងប្រធាននៃគណៈកម្មាធិការសិទ្ធិមនុស្សរបស់រដ្ឋាភិបាល នោះគឺជាអ្នកវិនិយោគឧបត្ថម្ភចម្បង នៃអណ្ដូងរ៉ែនោះ។[186] Global Witness តើទំនាក់ទំនងរបស់លោក ជាមួយក្រុមហ៊ុន មានលក្ខណៈដូចម្ដេច។ នៅពេលបោះពុម្ពរបាយការណ៍នេះ លោកមិនបានឆ្លើយតបទេ។ ប្រភពមួយរូបទៀត ដ៏ជិតស្និទ្ធនឹងក្រុមហ៊ុន ក៏បានអះអាងថា បុគ្គលមួយរូបឈ្មោះលោក **ឌី ចួច** ក៏ជាអ្នកមានអំណាចគ្រប់គ្រងអណ្ដូងរ៉ែ Float Asia (សូមមើល ប្រអប់ទី ៧ សម្រាប់ព័ត៌មានលំអិតបន្ថែម)។[187]



រូបសំណាក់ថ្មកែវ ថតដោយអ្នកស៊ើបអង្កេត Global Witness នៅឯទីស្នាក់ការទីក្រុងភ្នំពេញ របស់ក្រុមហ៊ុន។ ក្រុមហ៊ុន Float Asia Friendly Mation កំពុងតែដកស្រង់ថ្មកែវពីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់

បានសរសេរសំបុត្រទៅឯកឧត្ដម **ឱម យ៉ិនទៀង** នៅក្នុងខែតុលា ឆ្នាំ ២០០៨ ដើម្បីសួរថា

## ប្រអប់ទី ៧ ៖ ការត្រលប់មកវិញ នៃលោក ឌី ចូច

នៅក្នុង ខែមិថុនា ឆ្នាំ ២០០៧ Global Witness បានបោះពុម្ពរបាយការណ៍ *ខ្សែស្រឡាយ អ្នកលួចជាតិ* ជាសេចក្តីបើកហេតុការណ៍ដ៏ស៊ីជម្រៅ ដែលបង្ហាញថា សហាជីពមួយមានខ្សែស្រឡាយរឹងមាំ ប្រកបដោយញាតិសន្តាននៃអគ្គនាយករដ្ឋមន្ត្រី និងមន្ត្រីជាន់ខ្ពស់ផ្សេងទៀត បានគ្រប់គ្រងប្រតិបត្តិការកាប់ឈើខុសច្បាប់ដោយការមិនទទួលទោសពៃរ៍ អស់ជាច្រើនឆ្នាំ។ លោក **ឌី ចូច** ប្អូនជីដូនមួយរបស់សម្តេច **ហ៊ុន សែន** គឺជាសមាជិកយ៉ាងសំខាន់ នៃក្រុមនេះ។ ក្រៅពីការកាប់ឈើខុសច្បាប់ សហាជីពនេះក៏ត្រូវបានចោតប្រកាន់ថា ជាប់ជំពាក់ក្នុងសកម្មភាពស្រដៀងក្រុម ម៉ាហ្វីយ៉ា មានរួមទាំងការចាប់ខ្លួនមនុស្ស និងការប៉ុនប៉ងធ្វើឃាតកម្ម ជាដើម។[១៨៨]

ក្រោយពីការបោះពុម្ពរបាយការណ៍នោះមក គំរូនៃការមិនដាក់ទោសពៃរ៍ ដែលបានអនុញ្ញាតឲ្យសមាជិកនៃក្រុមហ៊ុន សេង គាង អនុវត្តសកម្មភាពកាប់ឈើខុសច្បាប់នោះ បានបន្តឥតឈប់ឈរ។ ជំនួសការស៊ើបអង្កេតសកម្មភាពចោតប្រកាន់នៅក្នុងរបាយការណ៍ អ្នកដឹកនាំប្រទេសកម្ពុជាបានឆ្លើយតប ដោយដាក់បម្រាមលើរបាយការណ៍នោះ ទាំងរឹបអូសសំណៅរបាយការណ៍ ហើយរុករកកូនអ្នកកាសែតដែលបានរាយការណ៍អំពីការសន្និដ្ឋាននៅក្នុងរបាយការណ៍នោះដែរ។ មានការរាយការណ៍ថា បងប្អូនរបស់អគ្គនាយករដ្ឋមន្ត្រីក៏បានគំរាមថា "បើពួកគេ [បុគ្គលិក Global Witness] មកកម្ពុជា ខ្ញុំនឹងវ៉ៃបែកក្បាល។" ទោះបីជាអ្នកតំណាងរដ្ឋាភិបាលមួយរូប បានសន្យាឲ្យមានការស៊ើបអង្កេតនៅពេលនោះក៏ដោយ ក៏ឥឡូវនេះ មិនទាន់មានការតាមដានផ្តន្ទាទោស ហើយគ្មានអ្នកដឹកនាំរដ្ឋាភិបាលណាម្នាក់ ទាក់ទងមកអង្គការ Global Witness ផ្ទាល់ អំពីការចោតប្រកាន់ទាំងនោះ។[189]



ទន្ទឹមនឹងពេលនោះ មើលទៅ លោក **ឌី ចូច** បានផ្លាស់ប្តូរអាជីពរបស់ខ្លួន។ នៅក្នុងអត្ថបទមួយ នៅក្នុងកាសែត *Cambodia Daily* មានចំណងជើងថា 'ម្ចាស់ក្រុមហ៊ុនកាប់ឈើ បដិសេធចំណោតពីការកាប់ឈើខុសច្បាប់' លោក ឌី ចូច ត្រូវបានពិពណ៌នាជា 'មហាសេដ្ឋីថ្មកែវ'។[១៩០]

Global Witness មានហេតុនឹងជឿថា លោក **ឌី ចូច** ជាអ្នកមានអំណាចច្រើន ទាក់ ទិននឹងអណ្តូងរ៉ែ Float Asia Friendly Mation។ ប្រភពមួយរូបដ៏ជិតស្និទ្ធនឹងប្រតិបត្តិការរបស់ក្រុមហ៊ុន បានសំគាល់លោក **ឌី ចូច** ជាម្ចាស់ ឬអ្នកការពារម្នាក់ទៀត របស់ក្រុមហ៊ុន Float Asia Friendly Mation ហើយមានសេចក្តីរាយការណ៍ថា កម្មករនៅការដ្ឋានបានអះអាងថា ឃើញលោក **ឌី ចូច** នៅឯអណ្តូងរ៉ែ ក្រោយពីក្រុមហ៊ុនបានចាប់ផ្តើមប្រតិបត្តិការ។[១៩១] Global Witness បានសរសេរសំបុត្រមួយទៅលោក **ឌី ចូច** នៅក្នុងខែតុលា ឆ្នាំ ២០០៨ ដើម្បីសួរថា តើលោកមានទំនាក់ទំនងអ្វីជាមួយអណ្តូងរ៉ែ Float Asia ដែរឬទេ។ នៅពេលបោះពុម្ពរបាយការណ៍នេះ លោកមិនទាន់ឆ្លើយតបទេ។




របាយការណ៍ឆ្នាំ ២០០៧ *ខ្សែស្រឡាយអ្នកលួចជាតិ*

*"ក្រុមកាប់ឈើដ៏មានអំណាចបំផុតក្នុងប្រទេសកម្ពុជា ដឹកនាំដោយ ឌី ចូច . . . អតីតភរិយារបស់គាត់ សេង គាង និង យុន ថុង ដែលជាដៃគូអាជីវកម្មរបស់ពួកគេ។ ក្រុមនេះប្រតិបត្តិការដោយស្ថិតក្រោមឈ្មោះ ក្រុមហ៊ុន Seng Keang Company។"*

សំដីដកស្រង់ពីរបាយការណ៍ខែមិថុនា ឆ្នាំ ២០០៧ របស់ Global Witness ខ្សែស្រឡាយអ្នកលួចជាតិ

## ខ្សាច់កោះកុង

នៅក្នុងឆ្នាំ ២០០៨ ប្រតិបត្តិការបូមខ្សាច់យ៉ាងធំមួយ បានចាប់ផ្តើមប្រតិបត្តិការ នៅក្នុងខេត្តកោះកុង។ Global Witness ប៉ាន់ស្មានថា សកម្មភាពនេះមានតម្លៃយ៉ាងហោចណាស់ US$៨,៦ លានក្នុងមួយឆ្នាំ នៅក្នុងប្រទេសកម្ពុជា ហើយតម្លៃ US$៣៥ លានក្នុងមួយឆ្នាំ នៅក្នុងប្រទេសសិង្ហបុរី។

មានអ្នកបូមខ្សាច់ និងទិញខ្សាច់ជាច្រើន នៅក្នុងតំបន់នោះ ប៉ុន្តែអ្នកទាំងឡាយដែលត្រូវបានសម្ភាសបានអះអាងថា ប្រតិបត្តិការទូទៅត្រូវបានកាន់កាប់ដោយឯកឧត្តម លី យ៉ុងផាត់ – គឺជាសមាជិកព្រឹទ្ធសភាពីគណបក្ស CPP ហើយជាមហាសេដ្ឋីមួយរូប។ ដូច្នោះ អាជីវកម្មបូមខ្សាច់នៅក្នុងខេត្តកោះកុង គឺជាឧទាហរណ៍មួយទៀត នៃការចាប់ក្តាប់ឧស្សាហកម្មរ៉ែរបស់ប្រទេសកម្ពុជា ដោយពួកវរជនរដ្ឋ។

ករណីនេះ ក៏បង្ហាញបន្ថែមទៀតអំពីតួនាទីរបស់អ្នកក្នុងភូមិភាគអាស៊ីអាគ្នេយ៍ ក្នុងការធ្វើអាជីវកម្មលើធនធានធម្មជាតិរបស់ប្រទេសកម្ពុជា។ ភស្តុតាងដែល Global Witness ប្រមូលបាន គឺចង្អុលបង្ហាញថា ខ្សាច់កោះកុងត្រូវបានដឹកជញ្ជូនទៅសិង្ហបុរី ដើម្បីប្រើប្រាស់ក្នុងសកម្មភាពចាក់ពង្រីកដី និងសំណង់។

នៅក្នុងដើមឆ្នាំ ២០០៨ Global Witness បានទទួលរបាយការណ៍អំពីប្រតិបត្តិការបូមខ្សាច់ដ៏ធំ នៅក្នុងប្រព័ន្ធទន្លេស្ទឹង នៅក្នុងខេត្តកោះកុងភាគខាងលិច ហើយនៅក្នុងសមុទ្រ ជិតមាត់សមុទ្រនៃកម្ពុជាភាគខាងត្បូង។[១៩២]

នៅពេលអ្នកស៊ើបអង្កេត Global Witness បានទៅដល់តំបន់នោះ ពួកគេបានប្រទះស្ថានភាពដ៏ស្មុគស្មាញ ជាមួយអ្នកផ្គត់ផ្គង់ដីខ្សាច់ និងអ្នកទិញដីខ្សាច់ ជាច្រើនភាគី។ លក្ខណៈរួម គឺគ្រប់អ្នកដែលត្រូវបានសម្ភាសទាំងអស់ បានអះអាងថា សិង្ហបុរីគឺជាទីដៅ នៃដីខ្សាច់ដែលបូមយកពីតំបន់នោះ។[១៩៣]

អ្នកស្រុកបានប្រាប់ Global Witness ថាខ្សាច់ភាគច្រើនត្រូវបានបូមពីកន្លែងមួយ ហៅថា ឡាំ ដាំ ដែលស្ថិតនៅចម្ងាយប្រហែល ១៥ គ.ម. ឡើងស្ទឹងពីក្រុងកោះកុង នៅក្នុងស្រុកកោះកុង។[១៩៤] ខ្សាច់ក៏ត្រូវបានបូមពីស្ទឹងកោះប៉ោ នៅកន្លែងមួយក្នុងស្រុកមណ្ឌលសីមា ចម្ងាយប្រហែល ១០ គ.ម. ឡើងស្ទឹងពីក្រុងកោះកុង។ ក្រុមហ៊ុនដែលពាក់ព័ន្ធក្នុងការបូមខ្សាច់នៅកោះប៉ោ មានរួមទាំងក្រុមហ៊ុនថៃ Saroon Concrete Part Ltd. [គ្រឿងស៊ីម៉ងត៍ ស-អរុណ ចំកាត់][១៩៥] ហើយនិងក្រុមហ៊ុនចិនមួយ ដែលមិនដឹងឈ្មោះទេ។ មានរបាយការណ៍ថា ក្រុមហ៊ុនផ្សេងទៀតបូមខ្សាច់នៅក្នុងតំបន់ផ្សេងមួយទៀត ហៅថាកោះកុងក្នុង និងជ្រោយប្រស់។[១៩៦]

ប្រភពពីររូប ដែលមានចំណេះដឹង បានអះអាងថា ក្រុមហ៊ុនខ្មែរពីរជាប់ជំពាក់នៅក្នុងការផ្គត់ផ្គង់ដីខ្សាច់៖ Odom Cement Co. Ltd [ក្រុមហ៊ុនស៊ីម៉ងត៍ ឧត្តម ចំកាត់][១៩៧] ហើយនិង Ly Yong Phat Co. Ltd [ក្រុមហ៊ុន លី យ៉ុង ផាត់ ចំកាត់]។[១៩៨] វាមិនច្បាស់ទេថា តើក្រុមហ៊ុនទាំងនេះបូមខ្សាច់ដោយខ្លួនឯង ឬតើក្រុមទាំងនេះគ្រប់គ្រងសកម្មភាពរបស់អ្នកដទៃ នៅក្នុងទីក្រុងនោះ។

ជាទូទៅ ខ្សាច់ត្រូវបានដឹកលើកប៉ាល់ ៣០០ តោន ពីកន្លែងបូមទៅកាន់ឃ្លាំងខ្សាច់។ នៅទីនោះ គេសំអាតខ្សាច់ ហើយទុកវាសម្រាប់ការនាំចេញពីប្រទេស។ ឃ្លាំងខ្សាច់ពីរ ស្ថិតនៅទល់មុខទន្លេ ពីក្រុងកោះកុង។[១៩៩]

អ្នកស៊ើបអង្កេត Global Witness បានទៅមើលឃ្លាំងទាំងនេះ នៅពាក់កណ្តាលឆ្នាំ ២០០៨។ ក្រុមហ៊ុនមួយដែលពួកគេបានទៅសាកសួរ គឺក្រុមហ៊ុន ស៊ីម៉ងត៍ ស-អរុណ ហើយមួយទៀតគឺជាក្រុមហ៊ុនចិនមួយ ដែលប្រមូលដីខ្សាច់ច្រើន។[២០០] Global Witness បានសួរអំពីឈ្មោះនៃក្រុមហ៊ុននេះ ប៉ុន្តែត្រូវបានប្រាប់ថា មិនទាន់មានឈ្មោះទេ។[២០១] កម្មករនៅឯក្រុមហ៊ុន ស៊ីម៉ងត៍ ស-អរុណ បានអះអាងថា ខ្សាច់ត្រូវបានផ្ទេរចេញពីកប៉ាល់ ៣០០ តោន ដែលឡើងទន្លេ ទៅកាន់កប៉ាល់ ៥.០០០ តោន នៅឯឃ្លាំង។ បន្ទាប់មកខ្សាច់នោះត្រូវបានផ្ទេរទៅកាន់កប៉ាល់ ១៥.០០០ តោន ដែលចតចម្ងាយ ប្រហែល ៣០ គ.ម. ពីច្រាំងសមុទ្រ។ ពីទីនោះ កប៉ាល់ទាំងនេះ ដឹកខ្សាច់ទៅសិង្ហបុរី សម្រាប់ការចាក់ដីថ្មី។[២០២]

Global Witness មិនបានទទួលចម្លើយច្បាស់លាស់ អំពីតើមានការបូមដីខ្សាច់ច្រើនប៉ុណ្ណា ពីកោះកុង។ ក៏ប៉ុន្តែ ពីការសង្កេតរបស់យើង ហើយនិងការសម្ភាសន៍ជាមួយក្រុមហ៊ុន វាច្បាស់ថា គឺជាចំនួនច្រើនណាស់ ហើយមើលទៅខ្សាច់ដែលមានសម្រាប់ការនាំចេញ គ្មានកំណត់ទេ។ នៅឃ្លាំងមួយ កម្មករអះអាងថា ពួកគេចាយ US$១០.០០០ ក្នុងមួយខែ ដើម្បីទិញទឹកសម្អាតខ្សាច់សាងសង់។ ពួកគេក៏បានអះអាងថា នៅក្នុងរយៈពេលបីថ្ងៃ – បើធ្វើការជាប់ – ពួកគេអាចបំពេញកប៉ាល់ ១៥.០០០ តោន សម្រាប់ការនាំខ្សាច់ចេញ។

ក្រុមហ៊ុនផ្គត់ផ្គង់មួយ បានប្រាប់ថា ថ្លៃក្នុងមួយតោន គឺ US$១១។ តាមអត្រាថ្លៃនេះ កប៉ាល់ ១៥.០០០ តោនមួយ អាចផ្ទុកខ្សាច់មានតម្លៃ US$១៦៥.០០០។ ដោយសារចំនួនអ្នកប្រតិបត្តិនៅក្នុងតំបន់នោះ Global Witness អាចប៉ាន់ស្មានថា កប៉ាល់យ៉ាងហោចណាស់មួយគ្រឿង អាចត្រូវបានបំពេញ ក្នុងរយៈពេលមួយអាទិត្យ។ តាមអត្រាថ្លៃដែលបានអះអាង នេះមានន័យថា ផលចំណូលប្រចាំឆ្នាំ សម្រាប់ឧស្សាហកម្មខ្សាច់នៅឯកោះកុង គឺ US$៨,៦ លាន។[២០៣] ពេលខ្សាច់ទៅដល់សិង្ហបុរី តម្លៃខ្សាច់ឡើងមួយជាបី។ តាមអត្រាថ្លៃ ឆ្នាំ ២០០៧ នៅសិង្ហបុរី តម្លៃក្នុងខ្សាច់សំណង់មួយតោន គឺ US$៤៥។[២០៤] នេះមានន័យថា តម្លៃប្រចាំឆ្នាំ នៃការនាំចេញខ្សាច់ របស់តំបន់កោះកុង គឺប្រហែល US$៣៥ លាន។

សំណួរថា តើអ្នកណាជាអ្នកនាំខ្សាច់ចេញនោះ មិនសូវច្បាស់លាស់ទេ។ Global Witness បានទៅមើលចំណុចប្រមូលនិងដឹកជញ្ជូនខ្សាច់ ដ៏នៅផុតពីច្រាំងនោះ ហើយបានឃើញកប៉ាល់ ១៥.០០០ តោនពីរគ្រឿង មកពីប្រទេស ប៉ាណាម៉ា។ កប៉ាល់មួយ – ឈ្មោះថា អាលី ២ – នៅពេលនោះកំពុងត្រូវគេផ្ទេរខ្សាច់ពីកប៉ាល់ ៥.០០០ តោនមួយគ្រឿង។ បុគ្គលិកនៅលើនាវាដ៏ធំជាង ត្រូវបានសង្កេតឃើញថា ស្លៀកពាក់ខោអាវបែបកងទ័ព ដោយមិនពាក់ផ្លាកសញ្ញា ឬកាន់អាវុធទេ។ នៅពេលនិយាយជាមួយអ្នកទាំងនោះ ពួកគេបានឆ្លើយជាភាសាចិនកុកងឺ ដោយសំឡេងចិនដីគោក។ Global Witness បានសុំច្បាប់ឡើងនាវា ប៉ុន្តែត្រូវបានបដិសេធ។ ថ្វីត្បិតតែអ្នកស្រុកនៅឯកោះកុងហៅកម្មករពាក់ឯកសណ្ឋានថា ‘ទាហានចិន’ ក៏ដោយ ប៉ុន្តែ Global Witness មិនអាចបញ្ជាក់ថា ពួកគេមកពីកងយោធារបស់ប្រទេសចិនបានទេ។[២០៥]

តាមរបាយការណ៍ពីអ្នកស្រុក និងកម្មករ ពួកចិនមិនមែនជាក្រុមតែមួយ ដែលនាំខ្សាច់ចេញទៅសិង្ហបុរីពីកោះកុងទេ។ មានរបាយការណ៍ថា ក្រុមហ៊ុនម៉ាឡេស៊ី និងកូរ៉េបានទិញដីខ្សាច់ ដើម្បីដឹកជញ្ជូនផងដែរ។[២០៦]



កប៉ាល់ដ៏តូចជាង ផ្ទេរខ្សាច់ទៅលើកប៉ាល់ អាលី ២ ដែលត្រូវបានថតក្នុងឆ្នាំ ២០០៨ចម្ងាយប្រហែល ៣០ គ.ម. ពីច្រាំង នៅមាត់សមុទ្រកោះកុង ប្រទេសកម្ពុជា។

## ប្រអប់ទី ៨ | សិង្ហបុរី – ដីខ្សាច់ និងការចាក់ពង្រីកដី

កោះសិង្ហបុរីកំពុងតែលូតលាស់យ៉ាងលឿន។ តាមពីទទួលឯករាជ្យភាព ការចាក់ពង្រីកដីយ៉ាងធំ បានជួយឲ្យព្រំដែននៃកោះតូចនេះ រីកទំហំប្រហែល ២០ ភាគរយ ហើយគេមានគោលបំណងពង្រីកផ្ទៃដី ៩៨ គ.ម. ក្រឡា ទៀត នៅក្នុងរយៈពេលប្រាំទសវត្សទៅមុខនេះ ដើម្បីសម្រួលដល់ប្រជាជនដែលកំពុងតែកើនចំនួន។[២០៧] គោលបំណងនេះ ត្រូវបានសម្រេចដោយការចាក់ពង្រីកដី ហើយកិច្ចការនេះត្រូវការខ្សាច់ចំនួនច្រើនអនេកៈ គឺមួយភាគធំ នៃខ្សាច់ចំនួន ៣,៨ លានតោន ដែលសិង្ហបុរីនាំចូលរាល់ឆ្នាំ ត្រូវបានប្រើសម្រាប់គោលបំណងនេះ។[២០៨] ដោយសារសិង្ហបុរីបានប្រើខ្សាច់ខ្លួនឯងឲ្យអស់ នៅក្នុងបណ្ដាឆ្នាំក្រោយពីការទទួលឯករាជ្យភាព ប្រទេសសិង្ហបុរីត្រូវតែរកនៅកន្លែងផ្សេងទៀត ដើម្បីបំពេញសេចក្ដីត្រូវការ ចំពោះខ្សាច់។

រហូតដល់ឆ្នាំ ២០០៧ ប្រទេសឥណ្ឌូណេស៊ី គឺជាប្រទេសផ្គត់ផ្គង់ដីខ្សាច់ច្រើនបំផុត ឲ្យសិង្ហបុរី។ ក៏ប៉ុន្តែ នៅក្នុងខែមករា ឆ្នាំ ២០០៧ រដ្ឋាភិបាលឥណ្ឌូណេស៊ីបានដាក់បម្រាមទូទៅ លើការការនាំចេញនៃខ្សាច់ទាំងអស់។[២០៩] មួយផ្នែកនៃមូលហេតុសម្រាប់បម្រាមនេះ គឺជាការខូចខាតដ៏ធំ ដែលឧស្សាហកម្មខ្សាច់ បានបង្កដល់តំបន់តាមមាត់សមុទ្រ។[២១០] នៅក្នុងក្រុមកោះរីយ៉ាវ នៅជិតសិង្ហបុរី ដែលជាកន្លែងដែលបាននាំចេញខ្សាច់ ២៥០.០០០ ទៅ ៣០០.០០០ តោន ក្នុងមួយខែ កោះខ្លះបានលិចបាត់ ហើយកោះខ្លះទៀតស៊ូរងការខូចខាតយ៉ាងធ្ងន់។[២១១] ការបូមខ្សាច់ បានបន្ថយចំនួនត្រីនៅឯក្រុមកោះរីយ៉ាវ ដែលជាបញ្ហាធំ ក្នុងប្រទេសមួយដែលត្រីជាផ្នែកដ៏សំខាន់ នៅក្នុងអាហាររបស់ប្រជាជន។[២១២]

Global Witness បានសរសេរសំបុត្រមួយទៅរដ្ឋាភិបាលសិង្ហបុរី នៅក្នុងខែតុលា ឆ្នាំ ២០០៨ ដើម្បីសួរអំពីតួនាទីរបស់គេ ក្នុងការដកស្រង់ខ្សាច់ នៅក្នុងខេត្តកោះកុង ហើយបានទទួលការឆ្លើយតបដូចតទៅនេះ៖

"ប្រទេសសិង្ហបុរីប្រើខ្សាច់ដីគោក សម្រាប់សំណង់ និងខ្សាច់សមុទ្រ សម្រាប់គម្រោងចាក់ពង្រីកដី។ ខ្សាច់ទាំងពីរប្រភេទ ត្រូវបាននាំចូល ដោយអ្នកចុះកិច្ចព្រមព្រៀងពីប្រទេសក្រៅ។ ការនាំចូលនៃដីខ្សាច់ គឺជាសកម្មភាពពាណិជ្ជកម្ម ហើយរដ្ឋាភិបាលសិង្ហបុរីមិនជាប់ទាក់ទិនទេ។ រដ្ឋាភិបាលសិង្ហបុរីមិនដាក់បម្រាម អំពីប្រភពខ្សាច់របស់អ្នកចុះកិច្ចព្រមព្រៀងលក់ខ្សាច់ទេ ប៉ុន្តែយើងរំពឹងថា ពួកគេគោរពច្បាប់ទាក់ទងនឹងការដកស្រង់ ប្រព្រឹត្តិកម្ម និងការដឹកជញ្ជូនខ្សាច់ ព្រមទាំងច្បាប់បរិស្ថាន របស់ប្រទេសដែលជាប្រភពនៃខ្សាច់។ កំណត់ហេតុពាណិជ្ជកម្មរបស់យើងបង្ហាញថា ខ្សាច់ខ្លះដែលបាននាំចូលសម្រាប់សំណង់ និងគម្រោងចាក់ពង្រីកដី មានប្រភពនៅប្រទេសកម្ពុជា។ សិង្ហបុរីបានឈប់នាំខ្សាច់ដីគោកចូលពីឥណ្ឌូណេស៊ី នៅក្នុងឆ្នាំ ២០០៧ ហើយនិងខ្សាច់សមុទ្រនៅឆ្នាំ ២០០៣។"[២១៣]


ប្រទេសសិង្ហបុរីនាំចូលខ្សាច់រាប់តោន រាលឆ្នាំ សម្រាប់គម្រោងចាក់ខ្សាច់ពង្រីកផ្ទៃដី

### លោក លី យ៉ុងផាត់ និងឧស្សាហកម្មខ្សាច់

ពាណិជ្ជករថៃ ប្រែខ្លួនជាសមាជិកព្រឹទ្ធសភាខាងគណបក្ស CPP គឺឯកឧត្ដម លី យ៉ុងផាត់[vii] ត្រូវបានគេហៅ 'ស្ដេចកោះកុង' ដោយសារលោកមានសហគ្រាសជំនួញជាច្រើនណាស់ នៅក្នុងខេត្តនោះ។ មើលទៅ ទ្រព្យសម្បត្តិរបស់លោក មកពីការដែលលោកជាម្ចាស់នៃកាស៊ីណូ និងសណ្ឋាគារច្រើន។ ពេលថ្មីនេះ លោកបានពង្រីកវិស័យសកម្មភាព ឲ្យមានរួមទាំងការទិញដី និងចម្ការអំពៅ។[២១៤] ការនេះបានធ្វើឲ្យក្រុមសិទ្ធិមនុស្ស នៅក្នុងប្រទេសកម្ពុជាចាប់អារម្មណ៍លើរូបលោក ទាំងរិះគន់តួនាទីនៃក្រុមហ៊ុនទាំងឡាយរបស់លោក ក្នុងការបណ្ដេញប្រជាជនចេញពីដីធ្លី ដោយការបង្ខិតបង្ខំ សម្រាប់ការធ្វើចម្ការអំពៅ ។[២១៥]

មិនគួរឲ្យភ្ញាក់ផ្អើលសោះ ដែលសេដ្ឋីកោះកុងមួយរូបនេះ បានចាប់អារម្មណ៍លើឧស្សាហកម្មខ្សាច់ ដែលកំពុងលូតលាស់នៅក្នុងតំបន់របស់លោក ហើយអ្នកផ្ទៃក្នុងនៃឧស្សាហកម្មនេះ អះអាងថា លោកប្រើអំណាចគ្រប់គ្រងលើវិស័យខ្សាច់ទាំងស្រុង នៅក្នុងតំបន់កោះកុង។ រហូតមកដល់គ្រាដ៏មានការរវល់ មុនការបោះឆ្នោតជាតិរបស់ប្រទេសកម្ពុជាក្នុងឆ្នាំ ២០០៨ លោកត្រូវបានគេរាយការណ៍ថា ជាអ្នកកំណត់ថ្លៃខ្សាច់នៅក្នុងវិស័យឧស្សាហកម្មនោះ ហើយបានធ្វើជាភាគីកណ្ដាល រវាងអ្នកទិញខ្សាច់ និងអ្នកបូមខ្សាច់។[២១៦]

ទាំងឃ្លាំងថៃ និងឃ្លាំចិន នៅទល់មុខទន្លេពីក្រុងកោះកុង ស្ថិតនៅលើដីដែលត្រូវបានគេរាយការណ៍ថា ជាដីរបស់លោក លី យ៉ុងផាត់។ មានរបាយការណ៍ផងដែរថា លោកមានផ្ទះវិឡា និងទូកយន្តមួយគ្រឿង នៅឯឃ្លាំងថៃ។[២១៧]

[vii] ឯកឧត្ដម លី យ៉ុងផាត់ មានឈ្មោះ លី ផាត់ ស៊ូផាផា នៃក្នុងលិខិតឆ្លងដែនថៃរបស់លោក។



មានគេរាយការណ៍ថា សមាជិកព្រឹទ្ធសភាពី លី យ៉ុងផាត់ ពីគណបក្ស CPP មានផ្ទះវិឡាមួយខ្នង និងទូកយន្តមួយគ្រឿង នៅឯឃ្លាំងខ្សាច់មួយ ទល់មុខទន្លេពីក្រុងកោះកុង ខេត្តកោះកុង ប្រទេសកម្ពុជា

សមាជិកព្រឹទ្ធសភា លី យ៉ុងផាត់ ត្រូវបានកម្មករនៅឯការដ្ឋានក្រុមហ៊ុន ស៊ីម៉ងត៍ ស-អរុណ ពិពណ៌នាជា ‘អាជ្ញាកណ្ដាល’ សម្រាប់កិច្ចព្រមព្រៀងលក់ដូរខ្សាច់ទាំងអស់ ហើយជាអ្នកទទួលប្រាក់ទាំងអស់ ពីអ្នកទិញបរទេស មកអ្នកបូមនៅក្នុងស្រុក។ កម្មករអះអាងថា នៅពេលណាប៉ូលិស ឬមន្ត្រីផ្សេងទៀតមកដល់ការដ្ឋានរបស់គេ ពួកគេណែនាំឲ្យអ្នកទាំងនោះទៅការិយាល័យរបស់ លី យ៉ុងផាត់។[២១៨]

Global Witness ក៏បានទទួលឯកសារ ដែលបង្ហាញថា ឯកឧត្ដម លី យ៉ុងផាត់ គឺជាម្ចាស់នៃ Ly Yong Phat ឬ LYP Group Company [ក្រុមហ៊ុន លី យ៉ុង ផាត់ ឬក្រុម LYP] ដែលប្រភពពីរូបដ៏មានខ្សែរយៈ បានអះអាងថា ពាក់ព័ន្ធនៅក្នុងការផ្គត់ផ្គង់ខ្សាច់។[២១៩]

Global Witness បានសរសេរសំបុត្រមួយទៅឯកឧត្ដម លី យ៉ុងផាត់ នៅក្នុងខែតុលា ឆ្នាំ ២០០៨ ដើម្បីសុំលោកអធិប្បាយអំពីការអះអាងទាំងនេះ។ នៅពេលបោះពុម្ពរបាយការណ៍នេះ លោកមិនទាន់ឆ្លើយតបទេ។



ទំព័រដកស្រង់ចេញពីអាជ្ញាប័ណ្ណរបស់ LYP គ្រុប ដើម្បីដកស្រង់ខ្សាច់

## ខ្សែរយៈ ចម បូរី

Global Witness បានទទួលព័ត៌មានទាក់ទងនឹងម្ចាស់នៃក្រុមហ៊ុនរ៉ែផ្សេងទៀត ក្រៅពីក្រុមហ៊ុននានាដែលយើងអាចទៅដល់បាន នៅក្នុងឆ្នាំ ២០០៨។ ព័ត៌មានបានបំភ្លឺថា មានករណីផ្សេងទៀតនៃក្រុមហ៊ុនអាជីវកម្មរ៉ែ ដែលជាកម្មសិទ្ធិ ឬដែលត្រូវបានកាន់កាប់ ដោយពួកវរជនគ្រប់គ្រងប្រទេសកម្ពុជា។

ក្រុមហ៊ុន Eight Star Mining [អាជីវកម្មរ៉ែ ផ្កាយប្រាំបី][២២០] Angkor Wat Minerals [ជាតុរ៉ែអង្គរវត្ត][២២១] ហើយនិង Elray Resources[ធនធាន អិលរ៉េ][២២២] គឺជាឧទាហរណ៍នៃហេតុការណ៍នេះ។ នៅក្នុងចំណោមនាយក និងអ្នកកាន់ហ៊ុននៃក្រុមហ៊ុនទាំងបីនេះ មាននាមនៃជនជាតិខ្មែរមួយរូប ឈ្មោះ ចម បូរី។[២២៣]

លោក ចម បូរី គឺជាបងប្អូន ជាមួយរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម របស់ប្រទេសកម្ពុជា ឯកឧត្ដម ចម ប្រសិទ្ធ ហើយជាទីប្រឹក្សាផ្ទាល់ របស់ប្រធានសភាជាតិ សម្ដេច ហេង សំរិន។ Global Witness បានសរសេរសំបុត្រទៅលោក ចម បូរី និង ចម ប្រសិទ្ធ នៅក្នុងខែតុលា ឆ្នាំ ២០០៨ ដើម្បីសុំការអធិប្បាយរបស់លោក។ នៅពេលបោះពុម្ពរបាយការណ៍នេះ លោកទាំងពីររូបមិនបានឆ្លើយតបទេ។

នៅក្នុងខែឧសភា ឆ្នាំ ២០០៨ ក្រុមហ៊ុន ជាតុរ៉ែ អង្គរវត្ត ត្រូវបានទិញដោយក្រុមហ៊ុនមួយ ដែលចុះឈ្មោះនៅក្នុងរដ្ឋណេវ៉ាដា ប្រទេសសហរដ្ឋ ឈ្មោះថា ធនធាន អិលរ៉េ។ ក៏ប៉ុន្តែលោក ចម បូរី នៅតែកាន់ភាគហ៊ុន នៅក្នុងសហគ្រាសនេះនៅឡើយ។ ទាំងក្រុមហ៊ុនជាតុរ៉ែ អង្គរវត្ត និងធនធាន អិលរ៉េ បានអះអាងថា មានសម្បទានបីកន្លែង ដែលអាចមានរ៉ែមាស នៅក្នុងខេត្តព្រះវិហារ និងខេត្តកំពង់ធំ។[២២៤]

គំបន់បណ្ដាញអ៊ិនធឺណិតរបស់ក្រុមហ៊ុន អាជីវកម្មរ៉ែ ផ្កាយប្រាំបី ចែងថា ក្រុមហ៊ុននោះមានសម្បទានរ៉ែមួយចំនួន ដែលអាចមានធនធានរ៉ែច្រើន នៅក្នុងប្រទេសកម្ពុជា និងកន្លែងផ្សេងទៀត ប៉ុន្តែវាមិនផ្ដល់ព័ត៌មានលំអិតអំពីទីតាំងនៃសម្បទានទាំងនេះទេ។[២២៥]

ជនជាតិអូស្ត្រាលីពីររូប ឈ្មោះ Barry Lucas [បា-រី លូកាស] និង Michael Melbourne [ម៉ៃខិល ម៉ិលបូណ] គឺជានាយកនៃក្រុមហ៊ុន ធនធាន អិលរ៉េ និង ជាតុរ៉ែ អង្គរវត្ត។[២២៦] អាជីវកម្មរ៉ែ ផ្កាយប្រាំបី ដាក់ឈ្មោះ ម៉ៃខិល ម៉ិលបូណ ជានាយក។

## តារាងទី ១ | អ្នកសំខាន់នៅក្នុងវិស័យឧស្សាហកម្មរបស់ប្រទេសកម្ពុជា




ជំពូកទី ៣
ប្រេង និង ឧស្ម័ន
global witness

# ជំពូកទី ៣

# ប្រេង និង ឧស្ម័ន

ថ្វីត្បិតតែពួកវរជនប្រទេសកម្ពុជា គឺជាអ្នកដែលនឹងទទួលផលប្រយោជន៍ពីឧស្សាហកម្មរ៉ែភាគច្រើន តាមរយៈការជាម្ចាស់កម្មសិទ្ធិផ្ទាល់ ឬការកាន់កាប់ដែលផ្ដល់ប្រយោជន៍ នៃក្រុមហ៊ុនអាជីវកម្មរ៉ែក៏ដោយ ប៉ុន្តែឧស្សាហកម្មប្រេង និងឧស្ម័នដ៏កំពុងលូតលាស់ របស់ប្រទេសកម្ពុជា ត្រូវបានចាប់ក្ដាប់ដោយមធ្យោបាយផ្សេងទៀត។ នៅក្នុងវិស័យនេះ ការគ្រប់គ្រងកើតមកពីវិសោធនកម្មទៅនឹងច្បាប់ជាតិដែលមិនស្រួវស្រួបនឹងរដ្ឋធម្មនុញ្ញ ដែលវិសោធនកម្មទាំងនេះ បានដាក់ការគ្រប់គ្រងអាជ្ញាធរប្រេងកាតជាតិកម្ពុជា – ហើយនិងធនធាននោះផង – នៅក្នុងដៃនៃអគ្គនាយករដ្ឋមន្ត្រី ហើយនិងឧបនាយករដ្ឋមន្ត្រីរបស់លោក។ ការបង្កើតវិសោធនកម្មទាំងនេះ បានជៀសវាងការត្រួតពិនិត្យដោយសភាជាតិ និងសាធារណជន លើឧស្សាហកម្មនោះ។

លទ្ធផល គឺថា គ្មានតម្លាភាពសោះ នៅក្នុងដំណើរការចែកសម្បទាននៅក្នុងវិស័យឧស្សាហកម្មប្រេង។ ព័ត៌មានបន្តិចបន្តួច ដែលអាចមើលបាន គឺបានលេចចូលក្នុងវិស័យសាធារណៈ មើលទៅដោយអចេតនា មិនមែនដោយមានចេតនានោះទេ។ ក្រុមហ៊ុនខ្លះ ដែលត្រូវបានចែកសម្បទានមួយភាគ ឬសម្បទានទាំងស្រុងណាមួយ មានបទពិសោធន៍តិចតួចណាស់ នៅក្នុងវិស័យប្រេង និងឧស្ម័ន ហើយមានមធ្យោបាយហិរញ្ញវត្ថុដើម្បីធ្វើអាជីវកម្មធនធាននោះ ដ៏គួរឲ្យសង្ស័យ។ នៅក្នុងករណីខ្លះ វាមិនបានបញ្ចេញឲ្យដឹងជាសាធារណៈថាអ្នកណាកាន់កាប់ក្រុមហ៊ុន ឬទទួលផលប្រយោជន៍ពីសកម្មភាពរបស់វានោះទេ។

បូកសរុបទាំងអស់ នេះមានន័យថា ប្រជាជនកម្ពុជា – ដែលជាម្ចាស់រួមនៃធនធាននេះ – គ្មានសំឡេង ឬអំណាចគ្រប់គ្រងឧស្សាហកម្មនេះសោះ។

## ក្របខណ្ឌច្បាប់ និងនីតិវិធី

ច្បាប់ប្រេងកាតរបស់ប្រទេសកម្ពុជា មានភាពច្បាស់លាស់តិចជាងវិស័យអាជីវកម្មរ៉ែទៅទៀត។ ជាផ្លូវការ ឧស្សាហកម្មនេះនៅតែស្ថិតនៅក្រោមច្បាប់ប្រេងកាត ឆ្នាំ ១៩៩១ ដែលត្រូវបានរដ្ឋាភិបាលរដ្ឋកម្ពុជាអនុម័ត មុនអាជ្ញាធរបណ្ដោះអាសន្នសហប្រជាជាតិប្រចាំកម្ពុជា បានចូលមកកាន់កាប់ នៅថ្ងៃទី ៣១ ខែតុលា ឆ្នាំ ១៩៩១ បន្តិច។[ii] នៅក្រោមច្បាប់នេះ ស្ថាប័នរដ្ឋាភិបាលដែលកាន់កាប់ប្រេងកាត គឺជាក្រសួងឧស្សាហកម្ម ដែលក្រោយមកត្រូវបានដាក់ឈ្មោះក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល (MIME)។


អគ្គនាយករដ្ឋមន្ត្រី ហ៊ុន សែន (ខាងស្ដាំ) និងឧបនាយករដ្ឋមន្ត្រី សុខ អាន (ខាងឆ្វេង)។ ជាមួយគ្នា ឯកឧត្តមទាំងពីររូបកាន់កាប់អាជ្ញាធរប្រេងកាតជាតិកម្ពុជា។

---

[ii] មានអ្នកខ្លះអះអាងថា ឯកសារច្បាប់ដែលបានអនុម័តមុនរដ្ឋធម្មនុញ្ញ ឬ UNTAC គឺគ្មានសុពលភាពទេ ប៉ុន្តែតាមការពិត រដ្ឋាភិបាលធ្វើតាមឯកសារច្បាប់ច្រើនបែបយ៉ាង ដែលបានអនុម័តរវាងការធ្លាក់នៃរបបខ្មែរក្រហម ហើយនិងការអនុម័តរដ្ឋធម្មនុញ្ញ នៅក្នុងឆ្នាំ ១៩៩១។

នៅក្នុងលក្ខណៈផ្លូវការ ច្បាប់ប្រេងកាតឆ្នាំ ១៩៩១ ទាមទារឲ្យមានតម្លាភាព និងការត្រួតពិនិត្យមួយកម្រិត ពីរដ្ឋាភិបាល និងសាធារណជន នៅក្នុងការចែកសម្បទានរបស់រដ្ឋ ទៅកាន់ក្រុមហ៊ុនឯកជន។ ច្បាប់នេះតម្រូវឲ្យក្រសួងឧស្សាហកម្ម ចេញសេចក្ដីប្រកាសជាសាធារណៈ អំពីការដេញថ្លៃទិញសម្បទានប្រេង ព្រមទាំងលក្ខខណ្ឌវិនិច្ឆ័យការដេញថ្លៃទាំងនោះ។ ការដេញថ្លៃទាំងនោះ គួរតែដាក់ផ្ញើទៅក្រសួងឧស្សាហកម្ម ហើយក្រសួងត្រូវវាយតម្លៃលើការដេញថ្លៃនានា ដោយសំអាងលើសមត្ថភាពបច្ចេកទេស និងហិរញ្ញវត្ថុ។ បន្ទាប់ពីដំណើរការនេះ ការដេញថ្លៃទាំងឡាយ ត្រូវបញ្ជូន រួមជាមួយអនុសាសន៍ ទៅរដ្ឋាភិបាលកម្ពុជា សម្រាប់ការអនុម័ត។[២២៧] ពេលនោះ បើសិនជារដ្ឋាភិបាលកម្ពុជាសម្រេចចិត្តឲ្យអនុម័តការដេញថ្លៃណាមួយ ក្រសួងឧស្សាហកម្មត្រូវចុះកិច្ចព្រមព្រៀងប្រេងកាត់ ដោយតំណាងឲ្យរដ្ឋាភិបាល។ ច្បាប់នេះក៏មានមាត្រាសម្រាប់ការបង្កើតនូវក្រុមប្រឹក្សាត្រួតត្រាប្រេងកាត ប្រកបដោយសមាជិកអន្តរក្រសួងជាច្រើន។[២២៨]

ក៏ប៉ុន្តែ នៅក្នុងផ្លូវអនុវត្តវិញ លក្ខខណ្ឌនៃច្បាប់នេះ មើលទៅត្រូវបានលុបចោលក្រោយមក ដោយសារការអនុម័ត តាមរយៈរាជក្រឹត្យសម្ងាត់ នូវវិសោធនកម្មបន្ថែម។ វិសោធនកម្មទាំងនេះ បានផ្ទេរអំណាចគ្រប់គ្រងលើធនធានប្រេង ហើយបានផ្លាស់ប្ដូរទាំងស្រុង នូវតម្រូវការតម្លាភាពដែលនៅក្នុងច្បាប់ដើម។

*"អាជ្ញាធរប្រេងកាតជាតិកម្ពុជា ត្រូវជាស្ថាប័នអចិន្ត្រៃយ៍ គ្រប់គ្រងដោយអគ្គនាយករដ្ឋមន្ត្រីផ្ទាល់។"*

សំដីដកស្រង់ពីរាជក្រឹត្យ ស្ដីពីការបង្កើតអាជ្ញាធរប្រេងកាតជាតិកម្ពុជា ថ្ងៃទី ២២ ខែមករា ឆ្នាំ ១៩៩៨។[229]

## ការផ្ទេរអំណាច

ឧទាហរណ៍មួយនៃការផ្ទេរអំណាចនេះ អាចរកឃើញបាននៅក្នុងការបង្កើតអាជ្ញាធរប្រេងកាតជាតិកម្ពុជា (CNPA) ដោយរាជក្រឹត្យនៅថ្ងៃទី ២២ ខែមករា ឆ្នាំ ១៩៩៨។[២៣០] តាមលក្ខខណ្ឌនៃរាជក្រឹត្យនេះ គ្រប់ដំណាក់កាល នៃសកម្មភាពផលិតប្រេងកាត ត្រូវសម្របសម្រួលដោយ CNPA។ មាត្រាទី ៣ នៃរាជក្រឹត្យនេះ ប្រកាសថា CNPA គឺជាស្ថាប័នអចិន្ត្រៃយ៍ ដែលគ្រប់គ្រងដោយអគ្គនាយករដ្ឋមន្ត្រីផ្ទាល់។[២៣១] តាមរបៀបនេះ រាជក្រឹត្យបានផ្ទេរភារកិច្ចលើវិស័យប្រេង និងឧស្ម័នចេញពី MIME ទៅកាន់ស្ថាប័នថ្មី ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់នាយករដ្ឋមន្ត្រី។

Global Witness បានសរសេរសំបុត្រទៅសម្ដេច **ហ៊ុន សែន** នៅក្នុងខែតុលា ឆ្នាំ ២០០៨ ដើម្បីសួរអំពីមូលហេតុនៃការសម្រេចចិត្តនេះ។ នៅពេលបោះពុម្ពរបាយការណ៍នេះ Global Witness មិនទាន់ទទួលការឆ្លើយតបទេ ដូច្នេះគ្មានការអធិប្បាយជាផ្លូវការ អំពីមូលហេតុអ្វី បានជានៅក្នុង ឆ្នាំ ១៩៩៨ សម្ដេច **ហ៊ុន សែន** បានសម្រេចចិត្តផ្ទេរភារកិច្ចលើវិស័យប្រេង ចេញពី MIME ទៅកាន់ CNPA ហើយនិងខ្លួនលោកផ្ទាល់។ ក៏ប៉ុន្តែ Global Witness មានកង្វល់អំពីការប្រើរាជក្រឹត្យ ជាឧបករណ៍ផ្លូវច្បាប់មួយ ដើម្បីជៀសវាងការពិភាក្សាជាសាធារណៈ ហើយនិងនៅក្នុងសភាជាតិ។

នៅក្នុងប្រទេសកម្ពុជា មានវិធីផ្សេងៗ ដែលច្បាប់អាចត្រូវបានបង្កើត ហើយអនុវត្ត។

រដ្ឋធម្មនុញ្ញចែងថា អំណាចបង្កើតច្បាប់ ស្ថិតជាមួយសភាជាតិ ហើយថាអំណាចបង្កើតច្បាប់ មិនអាចផ្ទេរទៅកាន់ស្ថាប័ន ឬបុគ្គលណាផ្សេងទៀតបានទេ។[២៣២]

នៅក្នុងផ្លូវអនុវត្ត មានឯកសារច្បាប់ប្រភេទផ្សេងៗ ដែលត្រូវបានប្រើប្រាស់ ដើម្បីអធិប្បាយបន្ថែម និងផ្ដល់ឧបករណ៍សម្រាប់ការអនុវត្តច្បាប់ ដែលសភាជាតិអនុម័ត។ ឯកសារទាំងនេះ មានរួមទាំងអនុក្រឹត្យ (ដែលអនុម័តដោយក្រុមប្រឹក្សារដ្ឋមន្ត្រី អគ្គនាយករដ្ឋមន្ត្រី និងស្ដេច) និងរាជក្រឹត្យ (ដែលអនុម័តដោយស្ដេច និងអគ្គនាយករដ្ឋមន្ត្រី)។

ធម្មតា នៅពេលបង្កើតស្ថាប័នរដ្ឋ ដែលមានអំណាចដើម្បីចែកទ្រព្យសម្បត្តិរបស់រដ្ឋ ឬធ្វើការសម្រេចចិត្តរបស់រដ្ឋ ដែលមានតម្លៃហិរញ្ញវត្ថុនោះ សភាជាតិអនុម័តច្បាប់មួយ។[២៣៣] ការប្រើអនុក្រឹត្យ ឬរាជក្រឹត្យ ជាធម្មតាត្រូវបានបម្រុងទុកសម្រាប់ការបង្កើតស្ថាប័នដែលមានអំណាចតិចជាង។ នៅក្នុងក្របខណ្ឌនេះ ការប្រើប្រាស់រាជក្រឹត្យ ដើម្បីបង្កើត CNPA – ស្ថាប័នរបស់រដ្ឋ ដែលគ្រប់គ្រងការចែករំលែកសម្បទានប្រេង ដែលអាចមានតម្លៃថ្លៃណាស់ – គឺខុសពីដំណើរការដ៏ប្រក្រតី។[២៣៤]

តាមមតិរបស់អ្នកជំនាញច្បាប់ ដែល Global Witness បានពិគ្រោះជាមួយ ការផ្ទេរអំណាចដ៏ធំធេងបែបនេះ ទៅកាន់ស្ថាប័នថ្មី

ដោយសារតែរាជក្រឹត្យប៉ុណ្ណោះ ដោយគ្មានច្បាប់ចម្លងអនុម័ត ដោយសភាជាតិសិន នោះមិនត្រឹមតែខុសពីដំណើរប្រក្រតីប៉ុណ្ណោះ ប៉ុន្តែវាក៏មិនសូវស្របនឹងរដ្ឋធម្មនុញ្ញផងដែរ។[២៣៥]

ក្រោយពីការបង្កើត CNPA នៅក្នុងខែមករា ឆ្នាំ ១៩៩៨ វិសោធនកម្មទីមួយ នៅក្នុងចំណោមវិសោធនកម្មទាំងពីរប្រការ នៃច្បាប់ឆ្នាំ ១៩៩១ ត្រូវបានអនុម័ត។

វិសោធនកម្មនេះបានយល់ព្រមដើម្បីផ្លាស់ប្តូរដំណើរការ សម្រាប់ការប្រកាសជាសាធារណៈអំពីការដេញថ្លៃ ដោយចែងថា "ក្រសួងឧស្សាហកម្ម អាចបង្កើតទម្រង់ការផ្សេង ដើម្បីចេញការអញ្ជើញឲ្យដេញថ្លៃ ទៅក្រុមហ៊ុន។"[២៣៦] តាមការពិត ឃ្លានេះបានដកចេញ នូវតម្រូវការឲ្យ CNPA បើកទទួលការដេញថ្លៃដ៏ចំហសេរី សម្រាប់ការចែកសម្បទានប្រេងកាត ហើយបានបើកទ្វារសម្រាប់ការចរចាដ៏សម្ងាត់ រវាងពីរភាគីប៉ុណ្ណោះ។

ជារឿងចម្លែកណាស់ វិសោធនកម្មនេះ មានភាពមិនទៀងទាត់មួយចំនួន។ ទីមួយ វាអះអាងថា បានចុះហត្ថលេខាដោយនាយករដ្ឋមន្ត្រីទាំងពីរនាក់របស់ប្រទេសកម្ពុជា នៅពេលនោះ គឺសម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ**[២៣៧] និងសម្តេច **ហ៊ុន សែន**។ ប្រាំមួយខែមុនវិសោធនកម្មនោះត្រូវបានចុះហត្ថលេខា សម្តេច **ហ៊ុន សែន** បានដេញចេញសម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ដោយរដ្ឋប្រហារដ៏ឃោរឃៅ និងប្រកបដោយអំពើហិង្សាមួយ។ Global Witness បានសរសេរសំបុត្រទៅសម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ដើម្បីសួរលោកថា តើលោកបានចុះហត្ថលេខាលើច្បាប់នោះ ដែរឬទេ ប៉ុន្តែមិនបានទទួលការឆ្លើយតបទេ។ ទីពីរ វាហៅក្រសួងឧស្សាហកម្ម ជាស្ថាប័នដ៏មានអំណាចគ្រប់គ្រង ហើយមិននិយាយអំពីតួនាទីនៃ CNPA ដែលទើបតែបង្កើតថ្មីនោះ។ ទោះជាមានទំនាស់ទាំងនេះក្តី ក៏វិសោធនកម្មត្រូវបានអនុវត្ត ហើយតាំងពីពេលនោះមក មិនដែលមានការដេញថ្លៃសេរី សម្រាប់សម្បទានប្រេងរបស់ប្រទេសកម្ពុជាឡើយ។




ប្រេងកាត និងឧស្ម័នរបស់ប្រទេសកម្ពុជា ត្រូវបានផ្ទេរចេញពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ទៅកាន់ CNPA វិញ។

មួយឆ្នាំក្រោយមក នៅក្នុងឆ្នាំ ១៩៩៩ វិសោធនកម្មទីពីរ នៃច្បាប់ប្រេងកាត មើលទៅបានដាក់អំណាចដើម្បីសម្រេចចិត្តអំពីការចែករំលែកសម្បទានប្រេងកាត ទៅក្នុងដៃនៅបុគ្គលតែមួយរូបប៉ុណ្ណោះ គឺលោកឧបនាយករដ្ឋមន្ត្រីរបស់ប្រទេសកម្ពុជា ហើយជាប្រធាននៃ CNPA គឺឯកឧត្តម **សុខ អាន**។[២៣៨]

*"ក្រោយពីការវាយតម្លៃ និងពិនិត្យនូវសំណើ ប្រធាននៃអាជ្ញាធរប្រេងកាតជាតកម្ពុជា អាចធ្វើកិច្ចព្រមព្រៀង រួមទាំង ដោយគ្មានកំណត់ នូវជម្រើសដើម្បីចុះកិច្ចព្រមព្រៀងប្រេងកាត តាមលោកចាត់ទុកថា គួរសមសម្រាប់ការអភិវឌ្ឍន៍ឧស្សាហកម្មធនធានប្រេងកាត នៅក្នុងប្រទេសកម្ពុជា។ … កិច្ចព្រមព្រៀងណាដែលបានប្រតិបត្តិដោយប្រធាននៃអាជ្ញាធរប្រេងកាតជាតិកម្ពុជា ស្របតាមមាត្រា ៥.២ នេះ ត្រូវជាកាតព្វកិច្ចរបស់រដ្ឋាភិបាលដើម្បីប្រតិបត្តិតាម ស្របតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនោះ។"*

សំដីដកស្រង់ពីមាត្រា ៥.២ នៃ 'សេចក្តីសម្រេច ស្តីពីការធ្វើវិសោធនកម្មច្បាប់ប្រេងកាតឆ្នាំ ១៩៩១ នៃរាជរដ្ឋាភិបាលកម្ពុជា លេខ ២៥' ដែលចុះហត្ថលេខា ដោយអគ្គនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅថ្ងៃទី ១៩ ខែមីនា ឆ្នាំ ១៩៩៩។[២៣៩]

លទ្ធផលរួម នៃវិសោធនកម្មទាំងពីរ គឺជាការដកចេញពីច្បាប់ប្រេងកាតឆ្នាំ ១៩៩១ នូវលក្ខខណ្ឌការ ៣រ សម្រាប់ការចែករំលែកសម្បទានប្រេងកាតប្រទេសកម្ពុជា ដោយតម្លាភាព និងយុត្តិធម៌។



## ប្រអប់ទី ៩ | ឯកឧត្តម សុខ អាន

ឯកឧត្តម សុខ អាន គឺជាឧបនាយករដ្ឋមន្ត្រី នៃប្រទេសកម្ពុជា ហើយជាប្រធាននៃអាជ្ញាធរប្រេងកាតជាតិកម្ពុជា (CNPA)។ ដូចជាមិត្តទាំងឡាយរបស់លោក នៅក្នុងគណៈបក្សប្រជាជនកម្ពុជា (CPP) សុខ អាន បានចាប់ផ្តើមអាជីពរបស់ខ្លួន ជាការិយលេខានុការ នៅក្នុងគ្រាកាន់កាប់នៃប្រទេសវៀតណាម នៅក្នុងដើមទសវត្ស ១៩៨០ ហើយបានឡើងតំណែងព្រមជាមួយអគ្គនាយករដ្ឋមន្ត្រី ហ៊ុន សែន។ គាត់ជាអ្នកធ្វើនយោបាយយ៉ាងពូកែ ហើយបានបន្តនៅជិតស្និទ្ធនឹងសម្តេច ហ៊ុន សែន នៅពេល CPP បានពង្រឹងអំណាច ហើយឥឡូវនេះ លោកជាមិត្តដ៏ជិតស្និទ្ធបំផុតមួយរូបរបស់អគ្គនាយករដ្ឋមន្ត្រី។ ពេលថ្មីនេះ ទំនាក់ទំនងរវាងលោកទាំងពីរ ត្រូវបានពង្រឹងថែមទៀត តាមរយៈអាពាហ៍ពិពាហ៍ ដែលត្រូវបានរៀបចំឡើងរវាងកូនប្រុសរបស់ឯកឧត្តម សុខ អាន ឈ្មោះ សុខ ពុទ្ធិវុធ ហើយនិងកូនស្រីរបស់សម្តេច ហ៊ុន សែន ឈ្មោះ ហ៊ុន ម៉ាលី។[២៤០]

Global Witness ធ្លាប់សរសេរអំពីឯកឧត្តម សុខ អាន ក្នុងនាមជាហត្ថលេខីមួយរូប នៃកិច្ចព្រមព្រៀងដំបូងជាច្រើន របស់សម្បទានិកព្រៃឈើ នៅក្នុងប្រទេសកម្ពុជា។[២៤១] កិច្ចព្រមព្រៀងប្រគល់សម្បទានទាំងនេះ គឺជាមូលដ្ឋាននៃការបំផ្លិចបំផ្លាញព្រៃឈើរបស់ប្រទេសកម្ពុជា ដែលបានកើតជាបន្តបន្ទាប់ ដោយបង្ខូចដល់បរិស្ថានប្រទេសកម្ពុជា ហើយផ្តល់ប្រយោជន៍តិចតួច ឲ្យសេដ្ឋកិច្ចកម្ពុជា។

ក្នុងនាមជាអ្នកកាន់អំណាចទីពីរនៃរបបគ្រប់គ្រង ឯកឧត្តម សុខ អាន មានតំណែងសំខាន់មួយចំនួនទៀត នៅក្នុងរដ្ឋាភិបាល។ តាមពិត គាត់មានមុខតំណែងច្រើនណាស់ រហូតដល់មានគេប្រៀបធៀបលោកជាមួយព្រះហិណ្ឌូ មានដៃច្រើន[២៤២] ដោយសារគាត់តែងចូលដៃក្នុងកិច្ចការច្រើនណាស់។ ដូច្នេះ មិនគួរឲ្យភ្ញាក់ផ្អើលសោះ នៅពេល CNPA ត្រូវបានបង្កើតឡើង នៅក្នុងឆ្នាំ ១៩៩៨ សុខ អានត្រូវបានបោះឆ្នោតជ្រើសរើសជាប្រធាន។ តាំងពីពេលនោះមក លោកបានគ្រប់គ្រងលើគ្រប់កិច្ចព្រមព្រៀងជាមួយក្រុមហ៊ុនប្រេងកាត ហើយជាមនុស្សមួយរូបដែលត្រូវទាក់ទងនិយាយជាមួយ សម្រាប់អ្នកដែលចង់វិនិយោគទាំងឡាយ។[២៤៣]




នៅបច្ចុប្បន្ននេះ លោកជាឧត្តមស្នងការគណៈកម្មាធិការកំពូល កែទម្រង់រដ្ឋ[244] ជាប្រធានក្រុមប្រឹក្សាកែទម្រង់រដ្ឋបាល[245] ហើយជាប្រធាននៃអាជ្ញាធរទេសចរណ៍ជាតិ។ (*លោកក៏ជាអនុប្រធាននៃវិជ្ជាស្ថានប្រជាធិបតេយ្យកណ្តាលនិយម* (CDI) *នៃវិជ្ជាស្ថានអាស៊ី-ប៉ាស៊ីហ្វិក ប្រធាននៃក្រុមប្រឹក្សាកែទម្រង់រដ្ឋបាល ប្រធាននៃអាជ្ញាធរអប្សរា ប្រធាននៃអាជ្ញាធរដោះស្រាយទំនាស់ភូមិបាល ប្រធាននៃក្រុមប្រឹក្សាហ្វឹកហ្វឺនកម្ពុជា ប្រធាននៃមហាវិទ្យាល័យភូមិន្ទ ប្រធាននៃក្រុមកាត់ទោសខ្មែរក្រហម សមាជិកនៃក្រុមប្រឹក្សារាជរដ្ឋាភិបាល ហើយប្រធាននៃក្រុមប្រឹក្សាវិនិយោគ នៃសហគ្រាសកៅស៊ូ។*)[246] ឧបនាយករដ្ឋមន្ត្រី សុខ អាន ក៏ឆ្លៀតពេលវេលា ដើម្បីធ្វើជាប្រធានសមាគមកាយរិទ្ធជាតិកម្ពុជា។[247]

## ការគ្រប់គ្រងវិស័យប្រេង និងឧស្ម័នរបស់ប្រទេសកម្ពុជា៖ ករណីច្បាប់កិច្ចព្រមព្រៀង ឬ?

តាំងពីវាជាក់ស្តែងថា ការអភិវឌ្ឍន៍ឧស្សាហកម្មប្រេងមានដំណើរទៅមុខពិត ទាយកបានរស់រាន់ព្យាយាមអភិវឌ្ឍសមត្ថភាពនៃ CNPA ហើយអភិវឌ្ឍរចនាសម្ព័ន្ធច្បាប់ថ្មី ជាមូលដ្ឋានសម្រាប់ឧស្សាហកម្មនោះ។[248] ក៏ប៉ុន្តែ ការប៉ុនប៉ងរបស់ទាយក ដើម្បីបង្កើតច្បាប់ប្រេងកាតព្រាង បានបរាជ័យបីដង ដោយសារ CNPA មិនបានចាប់អារម្មណ៍ទទួលច្បាប់ព្រាងទាំងនោះ។[249] ក្រោយពីការប៉ុនប៉ងទាំងនេះ ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍ នៃប្រទេសន័រវ៉េស្ស (NORAD) បានព្យាយាមជួយ CNPA ដើម្បីអភិវឌ្ឍច្បាប់ប្រេងកាតមួយ ហើយនិងអនុក្រឹត្យដែលពាក់ព័ន្ធ។[250]

នៅពេលធ្វើចប់ហើយ ច្បាប់ប្រេងកាតថ្មីនេះ ត្រូវតែចូលសភា ដើម្បីមានការពិភាក្សា។ អនុក្រឹត្យដែលទាក់ទង ត្រូវបានដាក់ប្រតិទិន ដើម្បីក្រុមប្រឹក្សារដ្ឋមន្ត្រីអនុម័តវា។[២៥១] នៅបច្ចុប្បន្ននេះ កិច្ចការបានឈានចូលដំណាក់កាលសម្របសម្រួលគ្រប់កិច្ចព្រមព្រៀង ច្បាប់ និងអនុក្រឹត្យ ដើម្បីបញ្ជាក់ថា គ្មានទំនាស់រវាងឯកសារទាំងឡាយ។ អ្នកផ្ទៃក្នុងឧស្សាហកម្មមួយរូប បានឲ្យដឹងថា ទីបញ្ចប់ និងការអនុម័តច្បាប់ព្រាងនោះឲ្យក្លាយជាច្បាប់ពេញលក្ខណៈ គឺមើលមិនឃើញសោះ។[២៥២] ទម្រាំដល់ពេលនោះ ក្រុមហ៊ុនណាដែលចង់ធ្វើប្រតិបត្តិការ នៅក្នុងប្លុកប្រេងកាតរបស់ខ្លួន នៅប្រទេសកម្ពុជា នឹងបន្តយោងតាមកិច្ចព្រមព្រៀងឯកជនរបស់ខ្លួន – ហៅថា

កិច្ចព្រមព្រៀងចែកចាយផលិតកម្ម (PSC) – ជាមូលដ្ឋានច្បាប់សម្រាប់ប្រតិបត្តិការរបស់គេ។ 'កិច្ចព្រមព្រៀងប្រេងកាត' កំណត់លក្ខខណ្ឌ នៃ PSC ទាំងឡាយនេះ។[២៥៣]

ទោះបីស្ថានភាពនេះមិនសូវប្លែក នៅក្នុងវិស័យឧស្សាហកម្មប្រេងក៏ដោយ ក៏ការខ្វះច្បាប់សាធារណៈ ដែលគ្រប់គ្រងទង្វើរបស់ក្រុមហ៊ុនប្រេង នៅក្នុងប្រទេសមួយមានបទពិសោធន៍ពុករលួយ និងខ្វះតម្លាភាព នោះគួរឲ្យខ្វល់ខ្វាយមែន។ ប្រភពមួយរូប ដែលជិតស្និទ្ធនឹង CNPA មានប្រសាសន៍ថា "ទោះបីវាមិនមែនជាវិបត្តិធំប៉ុន្មានក៏ដោយ ប៉ុន្តែវាក៏មិនល្អប៉ុន្មានដែរ។ កិច្ចព្រមព្រៀងឯកជន មិនផ្ដល់តម្លាភាពអ្វី ហើយលក្ខខណ្ឌអាចមានភាពខុសគ្នា រវាងក្រុមហ៊ុននានា។"[២៥៤] Global Witness យល់ថា ថ្លៃដែលរដ្ឋាភិបាលកម្ពុជាទារ នៅក្នុង PSC នានា ផ្លាស់ប្ដូរទៅតាមក្រុមហ៊ុនដែលចុះកិច្ចព្រមព្រៀង។ នៅក្នុងកិច្ចព្រមព្រៀងប្រេងកាតព្រាងមួយច្បាប់ជាកិច្ចព្រមព្រៀងគំរូ[iii] មានរាយនូវថ្លៃដូចខាងក្រោមនេះ។

Global Witness មិនបានបញ្ជាក់ថា តើកិច្ចព្រមព្រៀងក្នុងទម្រង់នេះ ត្រូវបានចុះហត្ថលេខាដោយក្រុមហ៊ុនកាន់ PSC ណាមួយ ឬទេ ប៉ុន្តែ យើងយល់ថាច្បាប់ព្រាងនេះ មុខតែជាគំរូ សម្រាប់កិច្ចព្រមព្រៀងពិត។

សំអាងលើកិច្ចព្រមព្រៀងប្រេងកាតនេះ CNPA នឹងទទួល យ៉ាងហោចណាស់ US$៧៤៦.០០០ ពីកិច្ចព្រមព្រៀងចែកចាយផលិតកម្មនីមួយៗ នៅក្នុងឆ្នាំទីមួយនៃកិច្ចព្រមព្រៀង។ បើយើងស្មានថា ថ្លៃទាំងនេះត្រូវបានអនុវត្តដោយទៀងទាត់ និងមិនប្រែប្រួល ទៅលើប្លុកសមុទ្រទាំងប្រាំមួយនោះមានន័យថា CNPA និងរដ្ឋាភិបាលកម្ពុជាបានទទួលជាការស្រេច នូវថ្លៃជិត US$៤,៥ លាន ពីក្រុមហ៊ុនកាន់ PSC។

[iii] ដើម្បីមើលកិច្ចព្រមព្រៀងប្រេងកាតព្រាងនេះទាំងមូល សូមមើល http://www.globalwitness.org/media_library_detail.php/693/en/draft_oil_production_sharing_contract

| តារាងទី ២ ៖ ថ្លៃទារនៅក្នុងកិច្ចព្រមព្រៀងប្រេងកាតព្រាង របស់រដ្ឋាភិបាលកម្ពុជា[២៥៥] | | |
|---|---|---|
| **ថ្លៃ** | **ចំនួនប្រាក់** | **ទីដៅនៃប្រាក់ថ្លៃ** |
| ថ្លៃរដ្ឋបាល | US$២៧២.000 | CNPA |
| ការអប់រំ និងការបណ្ដុះបណ្ដាលបុគ្គលិកជនជាតិខ្មែរ | អប្បបរមា US$១៥0.000 | CNPA |
| សម្រាប់តំបន់ស្វែងរុករក នៅក្នុងដំណាក់កាលទីមួយ នៃរយៈពេលស្វែងរុករក | US$១0 ក្នុងមួយគីឡូម៉ែត្រក្រឡានៃតំបន់ស្វែងរុករក | រដ្ឋាភិបាល |
| សម្រាប់តំបន់ស្វែងរុករក នៅក្នុងដំណាក់កាលទី ២ និងទី ៣ នៃរយៈពេលស្វែងរុករក | US$២0 ក្នុងមួយគីឡូម៉ែត្រក្រឡានៃតំបន់ស្វែងរុករក | រដ្ឋាភិបាល |
| សម្រាប់តំបន់ស្វែងរុករក នៅក្នុងការបន្តពេលណាមួយ នៃរយៈពេលស្វែងរុករក | US$៤0 ក្នុងមួយគីឡូម៉ែត្រក្រឡានៃតំបន់ស្វែងរុករក | រដ្ឋាភិបាល |
| សម្រាប់តំបន់ផលិតកម្ម | US$៥00 ក្នុងមួយគីឡូម៉ែត្រក្រឡានៃតំបន់ផលិតកម្ម | រដ្ឋាភិបាល |
| សម្រាប់ការបន្តពេលនីមួយៗ នៃរយៈពេលស្វែងរុករក | US$ ១.000 | CNPA |
| សម្រាប់លិខិតអនុញ្ញាតផលិតកម្មនីមួយៗ | US$ ១0.000 | CNPA |
| សម្រាប់កំណែណាមួយ នៃលិខិតអនុញ្ញាតផលិតកម្ម | US$ ១.000 | CNPA |
| សម្រាប់ការបន្តលិខិតអនុញ្ញាតផលិតកម្ម នីមួយៗ | US$ ១0.000 | CNPA |
| សម្រាប់ការផ្ទេរសិទ្ធិណាមួយ សម្រាប់ប្រតិបត្តិការប្រេងកាត | US$១៥.000 | CNPA |
| ជំនួយពី CNPA សម្រាប់កិច្ចការវាស់ស្ទង់ដី | ថ្លៃដើម | CNPA |
| ជំនួយពី CNPA សម្រាប់ការរកព្រំដែនតំបន់កិច្ចព្រមព្រៀង | ថ្លៃដើម | CNPA |
| CNPA ត្រូវចាត់អ្នកតំណាងពីរនាក់ (ឬច្រើនជាងពីរនាក់ បើអ្នកចុះកិច្ចព្រមព្រៀងស្នើ) ជាអចិន្ត្រៃយ៍ ដើម្បីជួយអ្នកចុះកិច្ចព្រមព្រៀង។ | US$២៤.000 | CNPA |
| ការបង់ប្រាក់បញ្ជាក់ទឹកចិត្ត | US$៣00.000 | CNPA |

**របនាសម្ព័ន្ធនៃ CNPA៖ ការបាក់បែកផ្ទៃក្នុង...**

*"ពាក្យតម្លាភាព ត្រូវបានកំណត់និយមន័យយ៉ាងខុសគ្នាស្រឡះ ដោយលោកអគ្គនាយក។"*
អ្នកផ្ទៃក្នុងវិស័យឧស្សាហកម្ម និយាយអំពីការខ្វះតម្លាភាព នៅក្នុងអាជ្ញាធរប្រេងកាតជាតិកម្ពុជា។[256]

ដោយជាក់បញ្ហារដ្ឋធម្មនុញ្ញ និងច្បាប់ នៅមួយអន្លើសិន Global Witness បានទទួលដំណឹងពីប្រភពផ្សេងៗ ថាមានការបាក់បែកគ្នាយ៉ាងធ្ងន់ នៅក្នុងថ្នាក់អ្នកដឹកនាំកំពូលនៃ CNPA ដែលនាំឲ្យមានការសង្ស័យ អំពីរបៀបដែលអំណាចត្រូវបានអនុវត្តនៅក្នុងអង្គការនោះ។

ក្រុមប្រឹក្សាគ្រប់គ្រង នៃ CNPA មានប្រធាន គឺលោក **សុខ អាន** អនុប្រធាន គឺលោក **ហូ វិចិត្រ** អគ្គនាយក លោក **តែ ដួងតារា** ហើយនិងក្រុមច្បាប់មួយ។[២៥៧] នាយកនៃអង្គភាពផលិតកម្មចុង គឺជាបុរសមួយរូប ឈ្មោះលោក **មែន ដេន**។[២៥៨] អង្គការនេះ មានបុគ្គលិក ៨0 ទៅ ១00 នាក់។[២៥៩] នៅទីបំផុត បុគ្គលិកនៃ CNPA ទាំងអស់ត្រូវរាយការណ៍ទៅប្រធាន គឺឧបនាយករដ្ឋមន្ត្រី **សុខ អាន** ហើយលោកត្រូវរាយការណ៍ទៅអគ្គនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ផ្ទាល់។

អ្នកកាន់តំណែងខ្ពស់ សុទ្ធតែជាសមាជិកនៃគណបក្សប្រជាជនកម្ពុជា (CPP)។ ក៏ប៉ុន្តែ Global Witness បានទទួលដំណឹងថា ការបាក់បែកនៅក្នុង CPP រវាង សម្ដេច **ហ៊ុន សែន** និងបច្ចុប្បន្នប្រធាននៃព្រឹទ្ធសភា សម្ដេច **ជា ស៊ីម** បានឆ្លងចូល CNPA។ អ្នកដែលស្មោះត្រង់នឹងសម្ដេច **ហ៊ុន សែន** កំពុងតែកាន់កាប់អង្គការនោះ មានន័យថា ចំណែកយ៉ាងធំនៃ CNPA ត្រូវបានកាត់ផ្ដាច់ចេញពីព័ត៌មាន ហើយនិងដំណើរការធ្វើការសម្រេចចិត្ត ដែលធ្វើឲ្យគេដូចជាមនុស្សខ្វិន មិនអាចបំពេញតួនាទីរបស់ខ្លួនបានទេ។[២៦០]

តាមប្រភពមួយចំនួន បានឲ្យដឹងថាលោក **តែ ដួងតារា** ដែលជាអ្នកគាំទ្រសម្ដេច **ហ៊ុន សែន** បានជួលបុគ្គលិករដ្ឋបាល ដែលគ្មានលក្ខណៈសម្បត្តិ ពីខាងក្រៅ CNPA ដើម្បីជួយគាត់ធ្វើសកម្មភាពរបស់ខ្លួន ជំនួសកិច្ចសហការជាមួយបុគ្គលិក CNPA ដែលមានការហ្វឹកហ្វឺន ដែលស្ថិតនៅក្រោមការដឹកនាំនៃលោក **មែន ដែន** ដែលជាអ្នកគាំទ្រសម្ដេច **ជា ស៊ីម**។[២៦១]

ខណៈដែលទាយកបានចាយប្រាក់ទៅលើការហ្វឹកហ្វឺនបណ្ដុះបណ្ដាលសមត្ថភាពរបស់ទាំងបុគ្គលិកផលិតកម្មដើម និងបុគ្គលិកផលិតកម្មចុង នៅក្នុង CNPA អ្នកសង្កេតបានអះអាងថា តាមកាតពិត ការិយាល័យនៃអគ្គនាយក បំពេញតួនាទីខាងផ្នែកផលិតកម្មដើម ហើយថាបុគ្គលិកដ៏មានការហ្វឹកហ្វឺន នៃអង្គភាពផលិតកម្មដើម មិនអាចជួយអ្វីបានទេ។[២៦២]

ទោះបីការបែងចែកអំណាចបែបនេះ កើតមកពីខ្សែស្រឡាយនយោបាយ ឬមកពីបំណងចង់គ្រប់គ្រងលំហូរព័ត៌មានក៏ដោយ – ឬទាំងពីរ– ក៏លទ្ធផលចុងក្រោយ គឺថាបុគ្គលិកដ៏មានចំណេះដឹងសំខាន់ គ្មានអំណាច ដើម្បីធ្វើឲ្យ CNPA ប្រតិបត្តិការ ជាស្ថាប័នដ៏មានប្រសិទ្ធិភាពឡើយ។

**តារាងទី ៣៖ រចនាសម្ព័ន្ធ នៃអាជ្ញាធរប្រេងកាតជាតិកម្ពុជា**

ប្រធាន CNPA **ហូ វិចិត្រ** ដែលគាំទ្រសម្ដេច **ជា ស៊ីម**[263] ទទួលតួនាទីផ្នែកខាងនយោបាយ ដូចជាការសរសេរច្បាប់ ហើយអគ្គនាយកនៃ CNPA លោក **តែ ដួងតារា** ដែលគាំទ្រសម្ដេច **ហ៊ុន សែន** ទទួលបន្ទុកខាងផ្នែកពាណិជ្ជកម្មវិញ។

ឯកសារ 'ការវាយតម្លៃសេចក្ដីត្រូវការខាងការហ្វឹកហ្វឺន' នៃ CNPA ដែលបានលេចចេញមក ដែលធ្វើឡើងដោយក្រុមហ៊ុនប្រទេសន័រវែស្ស ឈ្មោះ Bridge Group [ព្រិជ គ្រូប] ពិពណ៌នាស្ថានភាពដូចតទៅនេះ៖

"អង្គការនេះមិនធ្វើការរួមគ្នា ឆ្ពោះទៅរកគោលដៅរួមមួយទេ ហើយមានការមិនទុកចិត្តគ្នាទៅវិញទៅមក រវាងអ្នកដឹកនាំថ្នាក់កំពូល ហើយនិងអ្នកដឹកនាំអង្គភាពខ្លះ។នេះបានធ្វើឲ្យមានស្ថានភាព ដែលអង្គភាពមិនសូវរួមចំណែកក្នុងកម្មវត្ថុទូទៅ នៃ CNPA ប៉ុន្តែបែរជាបង្កើតជាក្រុមតូចៗដាច់ពីគ្នា ជាមួយផែនការតូចរៀងៗខ្លួន។ ដើម្បីជៀសវាងបញ្ហានេះ លេខាធិការដ្ឋានមួយត្រូវបានបង្កើត ដែលរាយការណ៍ទៅអគ្គនាយកផ្ទាល់ មានបុគ្គលិកដែលលោកទុកចិត្ត ដែលលេខាធិការដ្ឋាននេះចម្លងគុណសម្បត្តិខ្លះៗ ដែលមាននៅក្នុងអង្គភាពស្រាប់។"[២៦៤]

អ្នកផ្ទៃក្នុងខ្លះ បានពិពណ៌នាលទ្ធផលចុងក្រោយ ដោយសំដីមិនសូវសទ្ធា ដោយប្រើពាក្យថា 'វិកល'។[២៦៥]

**ប្រអប់ទី ១០៖ នយោបាយថ្ងៃបើកប្រាក់ខែ**

ប្រសិទ្ធិភាពនៃ CNPA ត្រូវបានបន្ទន់ ដូចជាការងាររាជការភាគច្រើននៅក្នុងប្រទេសកម្ពុជា ដោយប្រាក់ខែតិចរបស់បុគ្គលិក។ បុគ្គលិក CNPA ភាគច្រើនមិនទទួលប្រាក់ខែល្មម សម្រាប់ថ្លៃរស់នៅរបស់ក្រុមគ្រួសារឡើយ។ ប្រាក់ខែធម្មតាសម្រាប់បុគ្គលិកនៃ CNPA គឺ US$៤៥ ក្នុងមួយខែ៖ គឺតែ ២០—២៥ ភាគរយ នៃចំនួនប្រាក់ ដែលត្រូវការដើម្បីរស់នៅ។[២៦៦]

សម្រាប់បុគ្គលិកជាច្រើនអ្នក ដែលបានទទួលការហ្វឹកហ្វឺន នៅក្នុង CNPA នយោបាយកម្មនៃការកិច្ចការងារ រួមជាមួយប្រាក់ខែតិច មានន័យថា ពួកគេត្រូវមានការងារទីពីរដើម្បីរស់នៅ។ អ្នកសង្កេតម្នាក់បានអះអាងថា បុគ្គលិកខ្លះមកធ្វើការតែថ្ងៃបើកប្រាក់ខែប៉ុណ្ណោះ។[២៦៧] ការវាយតម្លៃឯករាជ្យលើសេចក្ដីត្រូវការខាងការហ្វឹកហ្វឺន របស់ ព្រិជ គ្រូប ផ្ដល់ការពន្យល់ដ៏សទ្ធាជាង៖

"នៅថ្ងៃធម្មតា បុគ្គលិកប្រហែល ៣០ នាក់ចូលមកធ្វើការពេលព្រឹក ហើយមានតែ ១០—១២ នាក់ត្រលប់មកវិញ បន្ទាប់ពីអាហារថ្ងៃត្រង់។" "បុគ្គលិកជាច្រើន បានទទួលការហ្វឹកហ្វឺនបន្ថែម...ក៏ប៉ុន្តែពួកគេមិនបានមានឱកាសអនុវត្តចំណេះដឹងដែលគេបានទទួលបាននៅក្នុងការងារប្រចាំថ្ងៃរបស់គេឡើយ ហើយចំណេះនេះមិនបានអភិវឌ្ឍទេ ប៉ុន្តែវាត្រូវបានសឹករលុបបន្តិចម្ដងៗ ជាបន្តបន្ទាប់។ ដូច្នេះ ការហ្វឹកហ្វឺនមួយចំណែកធំ ត្រូវបានខ្ជះខ្ជាយ ហើយនេះជាប្រភពនៃការមួម៉ៅច្រើន ក្នុងចំណោមបុគ្គលិក។"[២៦៨]

ការខ្វះប្រាក់គ្រប់គ្រាន់ សម្រាប់ប្រាក់ខែរបស់បុគ្គលិក CNPA មើលទៅមិនសមស្របនឹងថវិកាសម្រាប់ការបណ្តុះបណ្តាលបុគ្គលិក ដែលត្រូវបានបង់ឲ្យ CNPA រាល់ឆ្នាំ តាមកិច្ចព្រមព្រៀងប្រេងកាតជាគំរូរបស់ CNPA ។ កិច្ចព្រមព្រៀងនេះចែងថា ហត្ថលេខីកិច្ចព្រមព្រៀងប្រេងកាតនីមួយៗ ត្រូវតែបង់ថ្លៃ US$១៥០.០០០ រាល់ឆ្នាំ សម្រាប់ការបណ្តុះបណ្តាល និងអភិវឌ្ឍន៍បុគ្គលិក។ យោងតាមហេតុការណ៍នេះ នៅបច្ចុប្បន្ននេះ CNPA គួរតែទទួលយ៉ាងហោចណាស់ US$៩០០.០០០ រាល់ឆ្នាំ សម្រាប់ការបណ្តុះបណ្តាល និងអភិវឌ្ឍន៍បុគ្គលិក។[២៦៩]

គួរឲ្យសង្ស័យណាស់ ថាតើប្រាក់ដែលក្រុមហ៊ុនវិនិយោគបង់ សម្រាប់ការបណ្តុះបណ្តាលបុគ្គលិក អាចត្រូវបានប្រើសម្រាប់ការបើកប្រាក់ខែ។ ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ការប្រៀបធៀបផលចំណូលនៃ CNPA ជាមួយប្រាក់ខែរបស់បុគ្គលិក ធ្វើឲ្យមានចម្ងល់អំពីប្រាជ្ញា និងហេតុផល នៃការរក្សាប្រាក់ខែបុគ្គលិកទៀបដូច្នោះ ហើយនិងសំណួរថា តើការបង់ថ្លៃទាំងនោះ ត្រូវបានប្រើសម្រាប់អ្វី។

Global Witness បានសរសេរសំបុត្រទៅអគ្គនាយកនៃ CNPA លោក **តែ ដួងតារា** ដើម្បីសួរថា តើថវិកាបណ្តុះបណ្តាល និងអភិវឌ្ឍន៍បុគ្គលិកត្រូវបានប្រើប្រាស់សម្រាប់អ្វីខ្លះ។ នៅពេលបោះពុម្ពរបាយការណ៍នេះ Global Witness មិនបានទទួលការឆ្លើយតបទេ។

**លំហូរព័ត៌មាន ?**

*"បើគោលបំណងរបស់អ្នក គឺមានរដ្ឋាភិបាលដ៏ប្រតិបត្តិយ៉ាងល្អនោះ អ្នកនឹងចង់ចែកចាយព័ត៌មាន។"*[270]

*"ព័ត៌មាន គឺជាអំណាច។"*[271]

សំដីដកស្រង់ពីចម្លើយរបស់អ្នកវិភាគឧស្សាហកម្ម នៅពេលសួរលោកថា តើហេតុអ្វីបានជាគ្មានការចែកចាយព័ត៌មាននៅក្នុងអង្គការ CNPA។

វិកល ឬមិនវិកលក្តី ការកាន់កាប់ព័ត៌មាន និងអំណាចនៅក្នុង CNPA ពិតជាមានប្រសិទ្ធិភាព។ ការបាក់បែកនៅក្នុងអង្គការ មានន័យថា មានតែបុគ្គលមួយចំនួនតិច នៅក្នុងថ្នាក់ខ្ពស់នៃរដ្ឋាភិបាលកម្ពុជា ដែលមានចំណេះដឹង ឬការពាក់ព័ន្ធក្នុងកិច្ចចរចាកិច្ចព្រមព្រៀងដែលចុះជាមួយក្រុមហ៊ុនប្រេងកាត។[២៧២]

Global Witness បានសួរសំណួរជាក់ស្តែង ទៅបុគ្គលមួយចំនួនដែលទាក់ទិនជាមួយ CNPA៖ តើការខ្វះទំនាក់ទំនងផ្ទៃក្នុងនេះ ជាលទ្ធផលនៃការគ្រប់គ្រងដ៏ខ្វះគុណភាព ឬមួយតើវាយុទ្ធសាស្ត្រដោយចេតនា ដើម្បីរក្សាទុកព័ត៌មាន? ចម្លើយ គឺឯកច្ឆន្ទ។

អ្នកដែលត្រូវបានសម្ភាសបានយល់ឃើញថា នេះជាផ្នែកនៃយុទ្ធសាស្ត្រមួយ ដើម្បីបែងចែកស្ថាប័ន ហើយចាប់អំណាចយ៉ាងជាប់ ដើម្បីឲ្យអាចមានការពុករលួយបាន។ ដូចអ្នកផ្ទៃក្នុងឧស្សាហកម្មមួយរូបបាននិយាយ៖

*"ជាមួយស្ថានភាពបែបនេះ វាងាយស្រួលឲ្យមើលឃើញថា ផលចំណូលនឹងត្រូវបានបាត់។"*[២៧៣]

**វគ្គដេញថ្លៃ ហើយនិងការចែកកិច្ចព្រមព្រៀងចែកចាយផលិតកម្ម**

ស្របតាមតម្រូវការនៃច្បាប់ប្រេងកាតឆ្នាំ ១៩៩១ វគ្គដេញថ្លៃដំបូងត្រូវបានប្រកាសនៅក្នុងឆ្នាំ ១៩៩១។ ភាគីដ៏ដេញថ្លៃដោយជោគជ័យសម្រាប់ប្លុកសមុទ្រមានរួមទាំងក្រុមហ៊ុន Enterprise Oil [ប្រេងកាត អិនធឺប្រៃស៍] Campex [ខាមប៊ិច] និង Premier Oil [ប្រេងកាតព្រីមៀរ]។[២៧៤]

ក៏ប៉ុន្តែ នេះជាលើកចុងក្រោយ ដែលមានវគ្គដេញថ្លៃបើកចំហ សម្រាប់សម្បទានប្រេង នៅក្នុងប្រទេសកម្ពុជា។ នៅពេលអាជ្ញាប័ណ្ណស្វែងរុករក សម្រាប់សម្បទានទាំងនោះបានផុតកំណត់ហើយ CNPA បានចាប់ផ្ដើមវគ្គចែកធនធានថ្មីមួយ – លើកនេះនៅក្នុងបន្ទប់បិទទ្វារ ហើយគ្មានដំណើរការដេញថ្លៃដោយតម្លាភាពឡើយ។

នៅក្នុងខែមីនា ឆ្នាំ ២០០២ CNPA បានប្រគល់ប្លុកសមុទ្រ A ទៅក្រុមហ៊ុនសាខាមួយ របស់ក្រុមហ៊ុនប្រេងកាត Chevron [សេវរ៉ន់][iv] មកពីប្រទេសសហរដ្ឋអាមេរិក ហើយនិងដៃគូរបស់ក្រុមហ៊ុននោះ។[២៧៥] តាំងពីពេលនោះមក មើលទៅ CNPA បានចែកប្លុកប្រេងដែលនៅសល់ឲ្យក្រុមហ៊ុនប្រេងកាតដទៃទៀត មានកម្រិតបទពិសោធន៍ខុសៗគ្នា។ ព័ត៌មាននេះមិនបានចូលវិស័យសាធារណៈមកពី CNPA ផ្ទាល់ទេ។ ផ្ទុយទៅវិញ វាបានលេចចេញបន្តិចឯណេះ បន្តិចឯណោះ ពីក្រុមហ៊ុនប្រេងកាត ប្រព័ន្ធផ្សាយព័ត៌មាន ហើយនិងការសម្ដែង power-point [កម្មវិធីផាវ័រ ផ្អយន្ត៍] ដែលត្រូវបានបិទលើអ៊ីនធឺណិត ដោយអង្គការផ្សេងទៀតផ្សេងៗ។[២៧៦]

*"គ្មានសំណួរណាភ្លើជាងសំណួរនេះទេ"*
ការឆ្លើយតបរបស់ឧបនាយករដ្ឋមន្ត្រី សុខ អាន ចំពោះសំណួរអំពីការគ្រប់គ្រងប្រាក់ចំណូលប្រេងកាតនាអនាគត រាយការណ៍ដោយកាសែត *Cambodia Daily* នៅថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ ២០០៧។[២៧៧]

គ្មានការត្រួតត្រាដោយសភាជាតិ ទៅលើការចែកសិទ្ធិស្វែងរុករកប្រេងកាតផងដែរ។ Global Witness បានសម្ភាសប្រភពមួយចំនួនដែលនៅក្នុងសភាជាតិ ហើយដែលជិតស្និទ្ធនឹង CNPA ហើយទាំងអស់គ្នាអះអាងថា គ្មានការត្រួតត្រា ឬសម្របសម្រួលដោយសភាជាតិអំពីការសម្រេចចិត្តទាំងនេះឡើយ។[២៧៨] ប្រភពមួយ បានអះអាងថា ការពិភាក្សាកន្លងមក មានតែសិក្ខាសាលាពីរ សម្រាប់សមាជិកសភារៀបចំឡើងដោយកម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ (UNDP) ប្រចាំប្រទេសកម្ពុជា។[២៧៩]

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MoEF) របស់ប្រទេសកម្ពុជា គឺជាស្ថាប័នដែលត្រូវទទួលភារកិច្ចប្រមូល និងគ្រប់គ្រងផលចំណូលប្រេងកាតណា ដែលអាចរកបាន។ ក្នុងនាមនេះ អ្នកតំណាង MoEF បានចូលរួមសន្និសីទមានប្រធានបទទាក់ទងនឹងប្រេងកាត។[២៨០] ប្រភពមួយចំនួន ដ៏ជិតស្និទ្ធនឹង CNPA បានអះអាងថា មានការទាក់ទងមក CNPA ដោយ MoEFF ដើម្បីបញ្ជាក់ថា ច្បាប់ពន្ធដាររបស់ប្រទេសកម្ពុជា ហើយនិងកិច្ចព្រមព្រៀងប្រេងកាត ដាក់អត្រាពន្ធដារដូចគ្នា។ ក៏ប៉ុន្តែ ប្រភពដដែល បានអះអាងថា នៅក្នុងការអនុវត្តពិតក្រសួងនោះត្រូវបានកាត់ផ្ដាច់ពីទំនាក់ទំនងរបស់ CNPA ស្ដីពីការគ្រប់គ្រងអនាគតផលចំណូល។[២៨១]

**ប្រអប់ទី ១១៖ អ្នកថ្មីចូលប្លុក ឬ?**
CNPA បានតំបន់បណ្ដាញអ៊ិនធឺណិតសាធារណៈជាលើកដំបូង នៅថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៧ នៅឯ http://www.cnpa-cambodia.com។ វាចុះឈ្មោះដោយក្រុមហ៊ុនមួយហៅថា Petroleum Geo Services [សេវាកម្ម ជីយ៉ូ ប្រេងកាត ] (PGS) – គឺជាក្រុមហ៊ុនមួយ ដែលកំពុងធ្វើការស្រាវជ្រាវ 2D ដោយរញ្ជួយផែនដី នៅក្នុងតំបន់ទន្លេសាបរបស់ប្រទេសកម្ពុជា – ហើយមើលទៅ តំបន់បណ្ដាញអ៊ិនធឺណិតនេះ មានគោលបំណងនឹងលើកទឹកចិត្តក្រុមហ៊ុនឯទៀត ដើម្បីដាក់ពាក្យសុំសម្បទានប្រេងកាត នៅក្នុងប្រទេសកម្ពុជា។

[iv] ឈ្មោះថា ក្រុមហ៊ុន Chevron Overseas Petroleum (Cambodia) Ltd. [ប្រេងកាតបរទេស សេវរ៉ន់ (កម្ពុជា) ចំកាត់] ឬ COPCL។







នៅក្នុងខែតុលា ឆ្នាំ ២០០៨ តំបន់បណ្តាញអ៊ិនធឺណិតនេះ មានតែលិបិក្រមសម្រាប់ទំព័របណ្តាញប្រាប់គោលការណ៍ណែនាំសម្រាប់ការដាក់ពាក្យ ប៉ុន្តែឯកសារដែលផ្តល់ព័ត៌មានអំពីរបៀបដើម្បីដាក់ពាក្យ គឺមិនទាន់ផ្តល់ជូននៅឡើយទេ។ ដោយសារប្លុកសមុទ្រទាំងប្រាំមួយ (A-F) របស់ប្រទេសកម្ពុជា ហើយនិងសម្បទានដីគោកមួយចំនួន មើលទៅត្រូវបានចែកស្រាប់ហើយ នៅក្នុងខែឧសភា ឆ្នាំ ២០០៨ នោះ ការចេញមកនៃតំបន់បណ្តាញអ៊ិនធឺណិតនេះ ជាមួយព័ត៌មាននេះ ដូចជាយឺតពេកទៅហើយ។[២៤២]

Global Witness បានទទួលដំណឹងថា CNPA កំពុងតែចែកអាជ្ញាប័ណ្ណចាស់ឡើងវិញ សម្រាប់តំបន់សមុទ្រទាមទារជាន់គ្នា ថៃ-ខ្មែរ (OCA)។[២៨៣] ដោយសាកូគត្តិវិទូអះអាងថា តំបន់ដែលមានលទ្ធភាពផ្តល់ប្រេងច្រើនជាងគេ ស្ថិតនៅលើដីគោក ហើយនៅក្នុង OCA ការចែកសម្បទានទាំងនេះ ត្រូវចាត់ទុកថា ជារឿងសំខាន់ដ៏គួរឲ្យសាធារណជនចាប់អារម្មណ៍ណាស់។ នៅពេលបោះពុម្ពរបាយការណ៍នេះ CNPA និងរដ្ឋាភិបាលកម្ពុជា មិនទាន់ផ្តល់ព័ត៌មានអ្វី អំពីការចែកធនធានទាំងនេះ។




**តើអ្នកណាឈរពីក្រោយឈ្មោះ? ការចែករំលែកសម្បទានប្រេង និងឧស្ម័ន នៅក្នុងប្រទេស កម្ពុជា**

លើកលែងតែក្រុមហ៊ុន សេវរ៉ន់ មួយចេញ រដ្ឋាភិបាលកម្ពុជាមិនបានប្រកាសជាសាធារណៈ នូវឈ្មោះនៃក្រុមហ៊ុនដែលបានទទួលសិទ្ធិស្វែងរុករកប្រេង និងឧស្ម័នឡើយ។ ទោះជាមានការស្ងាត់ស្ងើរយ៉ាងនេះក៏ដោយ ព័ត៌មានអំពីអ្នកណាដែលកាន់សិទ្ធិអ្វីខ្លះ បានលេចចូលក្នុងវិស័យសាធារណៈខ្លះហើយ។[២៨៤]

នៅក្នុងសមុទ្រ មើលទៅប្លុកសម្បទានទាំងប្រាំមួយប្លុក ត្រូវបានលក់ទៅក្រុមហ៊ុនផ្សេងៗ។ ខ្លះមានឈ្មោះល្បី នៅក្នុងវិស័យអាជីវកម្មប្រេង និងឧស្ម័ន ហើយមានបទពិសោធន៍ក្នុងការផ្តល់ប្រេង និងឧស្ម័ន ទៅកាន់ទីផ្សារ។ ខ្លះ មិនសូវមានឈ្មោះទេ ហើយមើលទៅគ្មានបទពិសោធន៍នៅក្នុងវិស័យអាជីវកម្មទេ។ Global Witness បានផ្តោតការស្រាវជ្រាវរបស់យើង ទៅលើក្រុមហ៊ុនទាំងនេះ ដោយមានបំណងផ្តល់ព័ត៌មានបន្ថែមទៀតអំពីវា ទៅសាធារណជនខ្មែរ ហើយដើម្បីស្វែងយល់ថា តើការពាក់ព័ន្ធរបស់ក្រុមហ៊ុនទាំងនេះនៅក្នុងវិស័យឧស្សាហកម្មដ៏កំពុងលូតឡើងនេះ អាចផ្តល់អ្វីខ្លះទៅប្រទេសកម្ពុជាបាន។

ប្លុក A

កិច្ចព្រមព្រៀងចែកចាយផលិតកម្ម (PSC) សម្រាប់ប្លុក A ត្រូវបានប្រគល់ទៅក្រុមហ៊ុនអាម៉េរិកាំង សេវរ៉ន់ នៅក្នុងឆ្នាំ ២០០២។ សកម្មភាពរបស់ សេវរ៉ន់ នៅក្នុងប្លុក A គឺជាសកម្មភាពប្រកបដោយចំណេះបច្ចេកទេសខ្ពស់បំផុត ក្នុងចំណោមក្រុមហ៊ុនប្រេងទាំងអស់ ដែលកំពុងប្រតិបត្តិនៅក្នុងប្រទេសកម្ពុជា។ កម្មវិធីស្វែងរុករក និងវាយតម្លៃមួយ ដោយអណ្តូងប្រេងប្រាំ ត្រូវបានបញ្ចប់នៅក្នុងឆ្នាំ ២០០៦។ ក្រោយមកមានការស្វែងរុករក និងការវាយតម្លៃ តាមរយៈអណ្តូងប្រេងបួនទៀត នៅក្នុងឆ្នាំ ២០០៧។ នៅដើមឆ្នាំ ២០០៨ លទ្ធផលត្រូវបានវិភាគ។ នៅពេលសរសេររបាយការណ៍នេះ CNPA កំពុងរង់ចាំទទួលផែនការអភិវឌ្ឍន៍ប្លុក ពីក្រុមហ៊ុន សេវរ៉ន់។[២៨៥]

តាំងពីពេលនោះ មានក្រុមហ៊ុនពីរទៀត ទទួលចំណែកហ៊ុន នៅក្នុងគម្រោងស្វែងរុករក និងអភិវឌ្ឍន៍នេះ។ ឥឡូវនេះ សេវរ៉ន់កាន់ ៥៥ ភាគរយ ហើយក្រុមហ៊ុនជប៉ុន Mitsui Oil Exploration Co. Ltd [ក្រុមហ៊ុនស្វែងរុករកប្រេង មិតស៊ុយ ចំកាត់] (Moeco)[២៨៦] កាន់ ៣០ ភាគរយ ហើយក្រុមហ៊ុនកូរ៉េខាងត្បូង GS Caltex [GS កាល់តិច][២៨៧] កាន់ ១៥ ភាគរយ។[២៨៨] ក្រុមហ៊ុនទាំងបី មើលទៅ ជាក្រុមហ៊ុនរឹងមាំ ហើយល្បីឈ្មោះ ដែលមានបទពិសោធន៍ប្រកបដោយជោគជ័យ ក្នុងការស្វែងរុករក និងធ្វើអាជីវកម្មលើដំណាក់ប្រេង។

**ប្រអប់ទី ១២៖ ក្រុមហ៊ុន សេវរ៉ន់ – បញ្ហានៃតម្លាភាព**

ក្រុមហ៊ុនប្រេងអន្តរជាតិ សេវរ៉ន់  គឺជាសមាជិកដ៏នាំមុខ នៃគម្រោងជំរុញតម្លាភាពឧស្សាហកម្មដកស្រង់ (EITI) ដែលជាក្រុមសម្ព័ន្ធ នៃរដ្ឋាភិបាល ក្រុមហ៊ុន និងសង្គមស៊ីវិល ដែលគាំទ្រការកែលំអអភិបាលកិច្ច នៅក្នុងប្រទេសមានធនធានច្រើន តាមរយៈការបញ្ជាក់ និងការបោះពុម្ពទាំងស្រុង នូវព័ត៌មានស្តីពីការបង់ប្រាក់របស់ក្រុមហ៊ុន និងផលចំណូលរបស់រដ្ឋាភិបាល មកពីប្រេង ឧស្ម័ន និងអាជីវកម្មរ៉ែ។ ក្រុមហ៊ុននេះ ក៏ជាអ្នកវិនិយោគចម្បង នៅក្នុងសម្បទានសមុទ្រប្លុក A របស់ប្រទេសកម្ពុជា។[២៨៩]

ទោះបីហេតុការណ៍ទាំងពីនេះមិនមែនចាំបាច់មានទំនាស់ក៏ដោយ ក៏ទង្វើរបស់ សេវរ៉ន់ កន្លងមក ធ្វើឲ្យមានសំណួរថា តើសកម្មភាពនៃក្រុមហ៊ុន សមស្របនឹងគោលបំណងនៃ EITI ឬទេ។

អ្នកផ្ទៃក្នុងឧស្សាហកម្មបានអះអាងថា សេវរ៉ន់ បានចុះកិច្ចព្រមព្រៀងជាមួយ CNPA កុំឲ្យបញ្ចេញឲ្យដឹងព័ត៌មានជាសាធារណៈ អំពីសម្បទានរបស់គេទេ។[២៩០] Global Witness កត់សំគាល់ថា នៅក្រោមមាត្រាទី ២៧ នៃ PSC ជាគំរូ ក្រុមហ៊ុនណាដែលចុះកិច្ចព្រមព្រៀង ត្រូវរក្សាទុកគ្រប់ទិន្នន័យ និងព័ត៌មានផ្សេងទៀត ដែលទាក់ទងនឹងប្រតិបត្តិការប្រេងកាត ឬតំបន់កិច្ចព្រមព្រៀង ជារឿងសម្ងាត់។[២៩១]

អ្នកទាំងនោះក៏អះអាងថា សេវរ៉ន់ រួមជាមួយក្រុមហ៊ុនផ្សេងៗ ទៀត ដែលវិនិយោគនៅក្នុងវិស័យប្រេងកាតរបស់ប្រទេសកម្ពុជា បានធ្វើការបង់ប្រាក់ទុកជាមុន – ហៅថាប្រាក់រង្វាន់ចុះហត្ថលេខា – ទៅ CNPA ដើម្បីទទួលសម្បទានរបស់គេ។ តាមប្រភពមួយរូបមានខ្សែរយៈល្អ បានឲ្យដឹងថាក្រុមហ៊ុននោះក៏បង់ប្រាក់ 'ច្រើន' ទៅរដ្ឋាភិបាលកម្ពុជា ជាទ្រង់ទ្រាយពន្ធដារ។[២៩២]

Global Witness បានសរសេរសំបុត្រទៅក្រុមហ៊ុន សេវរ៉ន់ នៅក្នុងខែតុលា ឆ្នាំ ២០០៨ ដើម្បីសុំព័ត៌មានបន្ថែមទៀត អំពីការពាក់ព័ន្ធរបស់គេ នៅក្នុងប្រទេសកម្ពុជា។ សំបុត្រនេះក៏បានស្នើឲ្យក្រុមហ៊ុន សេវរ៉ន់ ប្រាប់ពីចំនួនប្រាក់ ដែលគេបានបង់ឲ្យរដ្ឋាភិបាលកម្ពុជា ជាប្រាក់រង្វាន់ចុះហត្ថលេខា ព្រមទាំងការបង់ប្រាក់ណាផ្សេងទៀត ទៅរដ្ឋាភិបាលកម្ពុជា។ នៅពេលបោះពុម្ពរបាយការណ៍នេះ យើងមិនទាន់ទទួលការឆ្លើយតបទេ។

ទាំងការបង់ប្រាក់រង្វាន់ចុះហត្ថលេខា និងការចុះកិច្ចព្រមព្រៀងរក្សាភាពសម្ងាត់ មិនមែនបំពានលក្ខខណ្ឌនៃសមាជិកភាពរបស់ក្រុមហ៊ុន សេវរ៉ន់ នៅក្នុងក្រុមសម្ព័ន្ធ EITI ទេ។ ទោះជាយ៉ាងណាក៏ដោយ នេះធ្វើឲ្យមានការសង្ស័យ អំពីជម្រៅនៃការប្តេជ្ញារបស់ក្រុមហ៊ុន សេវរ៉ន់ ក្នុងការគាំទ្រតម្លាភាព និងអភិបាលកិច្ចល្អ នៅក្នុងប្រទេសដែលគេធ្វើប្រតិបត្តិការនោះ។

ប្លុក B

សិទ្ធិស្វែងរុករកកំពុងកាន់ដោយក្រុមហ៊ុនថៃ PTTEP International [PTTEP អន្តរជាតិ][២៩៣] នៅក្នុងសហគ្រាសរួម ជាមួយ Singapore Petroleum Company [ក្រុមហ៊ុនប្រេងកាត សិង្ហបុរី] (SPC)[២៩៤] ហើយនិងក្រុមហ៊ុនម៉ាឡេស៊ី Resourceful Petroleum Ltd. [ប្រេងកាត រីសូសហ្វុល ចំកាត់]។ ក្រុមហ៊ុននីមួយៗមានចំណែកហ៊ុនមួយភាគបី។ ក្រុមហ៊ុនអូស្ត្រាលី Cooper Energy [ថាមពល យូព័រ][២៩៥] បានដកថយចេញ នៅក្នុងខែតុលា ឆ្នាំ ២០០៧ ហើយបានលក់ភាគហ៊ុនឲ្យក្រុមហ៊ុនដៃគូរបស់គេ សម្រាប់ថ្លៃ US$១ លាន។[២៩៦]

ទាំង PTTEP អន្តរជាតិ និង SPC មើលទៅ ជាក្រុមហ៊ុនប្រេង និងឧស្ម័នដ៏រឹងមាំនៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍ ដែលមានប្រតិបត្តិការនៅក្នុងប្រទេសមួយចំនួនក្រៅពីកម្ពុជា។[២៩៧] ក្រុមហ៊ុនទីបី ប្រេងកាត រីសូសហ្វុល ចំកាត់ មិនសូវមានឈ្មោះល្បីទេ។ ការស៊ើបអង្កេតរបស់ Global Witness រកឃើញថាក្រុមហ៊ុននេះ ជាកម្មសិទ្ធិរបស់លោកបណ្ឌិត ធិន លិប គីង ដែលជាទីប្រឹក្សាសេដ្ឋកិច្ចផ្ទាល់ របស់អគ្គនាយករដ្ឋមន្ត្រី **ហ៊ុន សែន**។[២៩៨] Global Witness បានសរសេរសំបុត្រទៅ លោកបណ្ឌិត ធិន លិប គីង នៅក្នុងខែតុលា ឆ្នាំ ២០០៨ ហើយបានទទួលចម្លើយមកពីមេធាវីរបស់លោកបណ្ឌិត នៅទីក្រុង ហុងកុង គឺក្រុមហ៊ុន Richards Butler Reed Smith LLP [រីឆាដ បាត់ល័រ រីដ ស្មីធ LLP]។ ពួកគាត់បានសរសេរថា៖

"លោកបណ្ឌិត ធិន ជ្រាបដឹងអំពីកិច្ចការដ៏វិជ្ជមានរបស់អង្គការ Global Witness នៅក្នុងការបំភ្លឺដល់ការទាស់ទែង ទាក់ទងនឹងធនធាន ការពុករលួយ និងការបំពានលើបរិស្ថាន និងសិទ្ធិមនុស្សជុំវិញពិភពលោក។ នេះសុទ្ធជាគោលបំណងដ៏មានតម្លៃ ដែលគួរឲ្យស៊ើបអង្កេត ហើយរាយការណ៍...លោកបណ្ឌិត ធិន បានស្នើឲ្យយើងខ្ញុំជំរាបដល់លោកអ្នកទាំងឡាយថា គាត់ជាអ្នកកាន់ភាគហ៊ុនច្រើនជាងគេ នៃក្រុមហ៊ុនប្រេងកាត រីសូសហ្វុល ចំកាត់។ វាជាព័ត៌មានសាធារណៈ ថា RPL គឺជាសមាជិកនៃសហគមន៍ ដែលបានបង្កើតឡើងដើម្បីស្វែងរុករកប្រេង និងឧស្ម័ន នៅក្នុងសម្បទានសមុទ្រ 'ប្លុក B' របស់ប្រទេសកម្ពុជា។ យើងបានដឹងដែរថា នេះមិនមែនជាសកម្មភាពប្រេង និងឧស្ម័នតែមួយរបស់ក្រុមហ៊ុន RPL ទេ។...RPL ធ្វើអាជីវកម្មប្រេង និងឧស្ម័ននៅកន្លែងផ្សេងក្នុងពិភពលោកផងដែរ។ សមាជិកនៃសហគមន៍ប្លុក Bជាប់ការសន្យា ដើម្បីរក្សាភាពសម្ងាត់។ ទោះជាយ៉ាងណាក៏ដោយ លោកបណ្ឌិត ធិន ជំរាបយើងថា RPL ត្រូវបានអញ្ជើញដើម្បីចូលរួមក្នុងសហគមន៍នេះ ជាក្រុមហ៊ុនវិនិយោគហិរញ្ញវត្ថុ ហើយក្រុមហ៊ុនប្រតិបត្តិគឺជាក្រុមហ៊ុន PTTEP អន្តរជាតិ ចំកាត់ ពីប្រទេសថៃ (PTTEP)។"[២៩៩]

លោកបណ្ឌិត ធិន លិប គីង គឺជាមនុស្សមួយរូបដ៏សំខាន់ នៅក្នុងប្រទេសកម្ពុជា និងពាសពេញភូមិភាគអាស៊ីអាគ្នេយ៍។ លោកត្រូវបានប្រគល់ពានរង្វាន់កិត្តិយសមួយចំនួន សម្រាប់ការបម្រើផ្នែកសេដ្ឋកិច្ច នៅក្នុងប្រទេស ម៉ាឡេស៊ី ហើយលោកជានាយកប្រតិបត្តិចម្បង និងជាអ្នកកាន់ភាគហ៊ុនច្រើនជាងគេ នៃក្រុមហ៊ុន NagaCorp [ណាកា យ័ព] គឺជាក្រុមហ៊ុនដែលជាម្ចាស់នៃកាស៊ីណូតែមួយ នៅទីក្រុងភ្នំពេញ ឈ្មោះ NagaWorld [ណាកា វ៉ូល]។ ណាកា វ៉ូល មានអាជ្ញាប័ណ្ណផ្ដាច់មុខ ពីរដ្ឋាភិបាលកម្ពុជា ដើម្បីប្រតិបត្តិកាស៊ីណូនៅក្នុងទីក្រុងភ្នំពេញ រហូតដល់ឆ្នាំ ២០៣៥។ របាយការណ៍ប្រចាំឆ្នាំ ២០០៧ របស់ក្រុមហ៊ុននេះ អះអាងថា ផលចំណេញបានកើនឡើងជាង ៥០ ភាគរយ ទៅជា US$៥១,៩ លាន នៅក្នុងឆ្នាំហិរញ្ញវត្ថុនោះ។[៣០០]

ក្រុមហ៊ុន ណាកា យ័ព បានចុះបញ្ជីទីផ្សារហ៊ុនហុងកុង តាំងពីខែតុលា ឆ្នាំ ២០០៦ ប៉ុន្តែដំណើរទៅកាន់ទីផ្សារហ៊ុននោះ មានឧបសគ្គ។ ក្រុមហ៊ុននោះ បានព្យាយាមចូលទីផ្សារហ៊ុនសិង្ហបុរី [MAS] នៅក្នុងឆ្នាំ ២០០៣ ប៉ុន្តែពាក្យសុំរបស់គេ ត្រូវបានបដិសេធ ដោយអាជ្ញាធររូបិយវត្ថុសិង្ហបុរី បានថ្លែងនៅពេលនោះថា "យើងខ្ញុំមានយោបល់ថា វាមិនមែនជាប្រយោជន៍ដល់សាធារណជន ដើម្បីចុះបញ្ជីប័ណ្ណប្រកាសហ៊ុនរបស់ក្រុមហ៊ុន ណាកា យ័ពទេ។ MAS មានកង្វល់ថា ប្រតិបត្តិការរបស់ក្រុមហ៊ុន ណាកា យ័ព មិនស្ថិតនៅក្រោមក្របខណ្ឌត្រួតពិនិត្យ និងច្បាប់ដ៏បានអភិវឌ្ឍ និងអនុវត្តពេញលេញ ដើម្បីត្រួតត្រាកាស៊ីណូ ហើយបង្ការសកម្មភាពលាងលុយកខ្វក់ តាមដែលបានអនុសាសដោយក្រុមការងារសម្រាប់សកម្មភាពហិរញ្ញវត្ថុនោះទេ។ ក្រុមហ៊ុន ណាកា យ័ព ក៏មិនមានបទពិសោធន៍ជាក់ស្ដែង ជាមួយការត្រួតពិនិត្យគណនីឯករាជ្យ ដើម្បីបញ្ជាក់ប្រសិទ្ធិភាពនៃការត្រួតពិនិត្យផ្ទៃក្នុង ដើម្បីទប់ស្កាត់លទ្ធភាពនៃសកម្មភាពលាងលុយកខ្វក់ទេ។"[៣០១] ក្រុមហ៊ុននេះបានបែរទៅរកទីផ្សារហ៊ុនហុងកុងវិញ ដែលគេបានចុះបញ្ជីនៅទីនោះ នៅក្នុងឆ្នាំ ២០០៦។[៣០២]

លោកបណ្ឌិត ធិន ក៏ជាប្រធាននៃក្រុមហ៊ុនទេសចរណ៍ និងអចលនទ្រព្យមួយ ដ៏ចុះបញ្ជីនៅប្រទេសម៉ាឡេស៊ី ឈ្មោះថា Karambunai Corp Berhad [ក្រុមហ៊ុន ការាមប៊ូណៃ ប៊ែហាដ] ដែលលោកជាអ្នកកាន់ចំណែកហ៊ុនកាន់កាប់។[៣០៣] ក្រុមហ៊ុននេះ បានទទួលផលចំណេញ ៤៩,២ លាន រីងហ្គីតម៉ាឡេស៊ី នៅក្នុងឆ្នាំ ២០០៧ – គឺប្រហែល US$១៤,៤ លាន។[៣០៤] ត្បូងនៅក្នុងមកុដនៃក្រុមហ៊ុននេះ គឺជា Nexus Resort Karambunai [សណ្ឋាគាររមណីយដ្ឋាន ណិកស៊ុស ការ៉ាមប៊ូណៃ] នៅកោះ ប័រនីយ៉ូ ដែលនៅទីនោះ បន្ទប់មួយ អាចមានថ្លៃដល់ទៅ US$៣៥០ ក្នុងមួយយប់។[៣០៥] រមណីយដ្ឋាននោះ ក៏មានវាលលេងកីឡាកូនហ្គោល ១៨ ប្រហោង ខ្នាតអន្តរជាតិ ដែលនៅទីនោះអ្នកស្រឡាញ់កីឡាកូនហ្គោល អគ្គនាយករដ្ឋមន្ត្រីប្រទេសកម្ពុជា សម្តេច **ហ៊ុន សែន** បានលេងកូនហ្គោលមួយវគ្គ នៅក្នុងខែមិថុនា ឆ្នាំ ២០០០។[៣០៦]

មើលទៅ មួយភាគបីនៃសម្បទានសមុទ្រ ប្លុក B ត្រូវបានកាន់កាប់ដោយក្រុមហ៊ុន មួយ ដែលជាកម្មសិទ្ធិរបស់ទីប្រឹក្សាសេដ្ឋកិច្ចមួយរូប របស់សម្តេច **ហ៊ុន សែន**។

ប្លុក C
តាមការសម្តែងរបស់រដ្ឋាភិបាលកម្ពុជា ដែលឃើញដោយ Global Witness ក្រុមហ៊ុនមួយ ឈ្មោះ Polytec [ផូលីថិច] កាន់សិទ្ធិ ១០០ ភាគរយ ដើម្បីស្វែងរុករកប្រេង នៅក្នុងប្លុក C។[៣០៧] របាយការណ៍សារព័ត៌មានមួយ នៅក្នុងខែឧសភា ឆ្នាំ ២០០៨ បាននិយាយថា ក្រុមហ៊ុននេះមានបំណងចាប់ផ្តើមខួងនៅក្នុងតំបន់នោះ យ៉ាងឆាប់។[៣០៨]

ឯកសារដែលទទួលបានដោយ Global Witness ចង្អុលបង្ហាញថា ក្រុមហ៊ុន ផូលីថិច ដែលកាន់សិទ្ធិសម្រាប់ ប្លុក C គឺជាក្រុមហ៊ុនដដែលនឹង Polytec Asset Holdings Limited [ក្រុមហ៊ុនកាន់ទ្រព្យ ផូលីថិច ចំកាត់] ដែលត្រូវបានរៀបចំជាក្រុមហ៊ុនផ្លូវការ នៅកោះខេម៉ាន់ ហើយមានទីស្នាក់ការនៅឯទីក្រុងហុងកុង។[៣០៩]

ឯកសារដែល Global Witness បានឃើញនោះ បង្ហាញថា Polytec Petroleum Corporation [ក្រុមហ៊ុនប្រេងកាត ផូលីថិច] បានចុះឈ្មោះនៅក្នុងឆ្នាំ ២០០៦ ជាមួយក្រសួងពាណិជ្ជកម្មកម្ពុជា សម្រាប់គោលបំណងស្វែងរុករកប្រេង។ នាយកនៃក្រុមហ៊ុនស្វែងរុករកប្រេងដ៏មានមូលដ្ឋាននៅប្រទេសកម្ពុជានេះ គឺលោក **ថម់មី ឡាំ ជី ផុង** ហើយលោក **អ័រ វ៉េ ស៊ីន**។[៣១០]

តាមគំបន់បណ្តាញអ៊ិនធឺណិតរបស់ក្រុមហ៊ុនកាន់ទ្រព្យ ផូលីថិច ទាំងលោក **ឡាំ ជី ផុង** និង លោក **អ័រ វ៉េ ស៊ីន** មានតំណែងគ្រប់គ្រងថ្នាក់ខ្ពស់ នៅក្នុងក្រុមហ៊ុននៅហុងកុង។ លោក **ឡាំ ជី ផុង** គឺជានាយកប្រតិបត្តិ[៣១១] ហើយលោក **អ័រ វ៉េ ស៊ីន** បានកាន់តំណែងជាប្រធាននៃក្រុមហ៊ុនកាន់ទ្រព្យ ផូលីថិច តាំងពីលោកបានទទួលចំណែកហ៊ុនកាន់កាប់ក្រុមហ៊ុន នៅក្នុងឆ្នាំ ២០០១។ ឥឡូវនេះ លោកកាន់ភាគហ៊ុន ៥៩,៥ ភាគរយរបស់ក្រុមហ៊ុន។[៣១២]

Global Witness បានសរសេរសំបុត្រទៅក្រុមហ៊ុនកាន់ទ្រព្យ ផូលីថិច ចំកាត់ នៅក្នុងខែតុលា ឆ្នាំ ២០០៨ ដើម្បីសួរអំពីលក្ខណៈនៃការពាក់ព័ន្ធ នៅក្នុងប្រទេសកម្ពុជា។ នៅពេលបោះពុម្ពរបាយការណ៍នេះ យើងមិនបានទទួលចម្លើយទេ។

តាមព័ត៌មានរបស់ក្រុមហ៊ុននេះ ក្រុមហ៊ុនកាន់ទ្រព្យ ផូលីថិច មើលទៅមិនមានមុខជំនាញអ្វី នៅក្នុងអាជីវកម្មប្រេង និងឧស្ម័នទេ។ ផ្ទុយទៅវិញ គេនិយាយថា វិស័យជំនួញចម្បងនៃក្រុមហ៊ុន គឺជាអចលនទ្រព្យ ទឹកកក និងផលិតផលកក ហិរញ្ញវត្ថុ និងការវិនិយោគ។ នៅបច្ចុប្បន្ននេះ ក្រុមហ៊ុននោះមានគម្រោងអភិវឌ្ឍន៍អចលនទ្រព្យ និងវិនិយោគមួយចំនួន នៅក្នុងដែនដីដ៏តូច និងមានលុយច្រើន ម៉ាកាវ។[៣១៣] ក្រុមហ៊ុនក៏ជាម្ចាស់កម្មសិទ្ធិ នៃ Hong Kong Ice and Cold Storage Company [ក្រុមហ៊ុនទឹកកក និងការបម្រុងទុកត្រជាក់ ហុងកុង]។[៣១៤] ក្រុមហ៊ុនមិននិយាយអ្វីអំពីប្រទេសកម្ពុជា ឬការស្វែងរុករកប្រេង នៅក្នុងរបាយការណ៍ប្រចាំឆ្នាំចុងក្រោយ របស់ក្រុមហ៊ុនឡើយ។[៣១៥] ក្រុមហ៊ុននោះ បានទទួលផលចំណេញច្រើនគួរសម នៅក្នុងឆ្នាំ ២០០៧ – HK$២២២ លាន ឬ US$២៩ លាន។[៣១៦]

រហូតមកដល់ឆ្នាំ ២០០៤ ក្រុមហ៊ុនកាន់ទ្រព្យ ផូលីចិច ត្រូវបានហៅតាមឈ្មោះ ក្រុមហ៊ុនកាន់ទ្រព្យ គិន ដុន ចំកាត់ ហើយបានពាក់ព័ន្ធនៅក្នុងឧស្សាហកម្មកាត់ដេរ។ ក្រុមហ៊ុននោះមានបញ្ហាហិរញ្ញវត្ថុ រហូតដល់លោក អ៊័រ វ៉េ ស៊ឺន បានទទួលកាន់កាប់។[៣១៧] លោក អ៊័រ ច្បាស់ជាពាណិជ្ជករដ៏មានជោគជ័យច្រើន។ តាមទស្សនាវដ្ដី Forbes លោកគឺជាអ្នកមានលំដាប់ថ្នាក់ទី ២២ នៅក្នុងទីក្រុងហុងកុង ដោយលោកមានទ្រព្យសម្បត្តិផ្ទាល់ខ្លួន US$២,៤ ពាន់លាន។[៣១៨] លោកក៏ជាសមាជិកនៃ សន្និសីទពិគ្រោះនយោបាយប្រជាជនចិន (CPPCC) ដែលជាស្ថាប័ននយោបាយដ៏សំខាន់ ដែលផ្ដល់ដំបូន្មានដល់រដ្ឋាភិបាលចិន អំពីគោលនយោបាយជាតិ។[៣១៩]

ជាការសង្ខេប សម្បទានសមុទ្រ ប្លុក C របស់ប្រទេសកម្ពុជា មើលទៅ ត្រូវបានកាន់កាប់ដោយក្រុមហ៊ុនមួយ ដែលគ្មានបទពិសោធន៍កន្លងមក ជាមួយការស្វែងរុករកប្រេង និងឧស្ម័ន ហើយដែលមិនបញ្ចេញឲ្យដឹងអំពីការវិនិយោគនៅក្នុងប្រទេសកម្ពុជា នៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់វាទេ។ ចំពោះ Global Witnessវាមិនច្បាស់លាស់សោះ ថាហេតុអ្វីបានជាក្រុមហ៊ុននោះត្រូវបានប្រគល់សម្បទាន ឬថា តើក្រុមហ៊ុននោះនឹងផ្ដល់មុខជំនាញអ្វីនោះឡើយ។

ប្លុក D

សិទ្ធិស្វែងរុករកប្រេងនៅក្នុងប្លុក D នៃប្រទេសកម្ពុជា ប្រហែលជាសម្បទានដ៏ខ្វះតម្លាភាពបំផុត។ មានសេចក្ដីរាយការណ៍ នៅក្នុងឯកសាររដ្ឋាភិបាល ហើយនិងប្រព័ន្ធផ្សព្វផ្សាយខ្មែរ ថាប្លុកជាកម្មសិទ្ធិ ១០០ ភាគរយ របស់ក្រុមហ៊ុនចុះឈ្មោះនៅសិង្ហបុរី ឈ្មោះ China Petrotech [ឆាយណា ប៉េត្រូតិក][៣២០] ដែលជាអតីតក្រុមហ៊ុនកម្មវិធីកុំព្យូទ័រ ដែលមានមុខជំនាញបង្កើតកម្មវិធីស្វែងរុករកប្រេង សម្រាប់អតិថិជន មានរួមទាំងក្រុមហ៊ុនប្រេងកាតរដ្ឋធំៗ របស់ប្រទេសចិន។[៣២១] ក៏ប៉ុន្តែនៅពេលដែល Global Witness ពិនិត្យភស្តុតាង មើលទៅមានក្រុមឯទៀតៗពាក់ព័ន្ធផងដែរ។ មើលទៅ ឆាយណា ប៉េត្រូតិក មិនមែនជាក្រុមហ៊ុនប្រតិបត្តិការក្នុង ប្លុក D តែមួយប៉ុណ្ណោះទេ គឺវាបានទិញផ្នែកនៃក្រុមហ៊ុនមួយ ដែលកាន់សិទ្ធិប្រតិបត្តិការ នៅក្នុងប្លុកនោះវិញ។ ឆាយណា ប៉េត្រូតិក បានផ្លាស់ប្ដូរឈ្មោះ ទៅជា Mirach Energy [ថាមពល មីរ៉ាច] នៅក្នុងឆ្នាំ ២០០៨។

តាមតំបន់បណ្ដាញអ៊ិនធឺណិតរបស់ក្រុមហ៊ុន ឆាយណា ប៉េត្រូតិក/ថាមពល មីរ៉ាច បានឲ្យដឹងថា PSC សម្រាប់ប្លុក D របស់ប្រទេសកម្ពុជា ត្រូវបានប្រគល់ទៅក្រុមហ៊ុនមួយដ៏ចុះឈ្មោះក្នុងប្រទេសកម្ពុជា ឈ្មោះថា China Zhen Rong Cambodia Energy [ថាមពល ឆាយណា ចេន រ៉ុង] (CZRCE)[៣២២] នៅក្នុងខែមេសា ឆ្នាំ ២០០៦។ តាមលក្ខខណ្ឌនៃ PSC ក្រុមហ៊ុន CZRCE មានសិទ្ធិស្វែងរុករកប្រេងផ្ដាច់មុខ នៅក្នុងប្លុក D សម្រាប់រយៈពេលប្រាំពីរឆ្នាំ ហើយសិទ្ធិផលិតប្រេង សម្រាប់រយៈពេល ៣០ ឆ្នាំ។[៣២៣] នេះមានន័យថា តាមច្បាប់ សិទ្ធិដើម្បីស្វែងរុករកប្រេងនៅក្នុងប្លុក D ស្ថិតនៅក្នុងដៃរបស់ CZRCE មិនមែន ឆាយណា ប៉េត្រូតិក/ថាមពល មីរ៉ាចទេ។

នៅក្នុងខែមេសា ឆ្នាំ ២០០៦ ឆាយណា ប៉េត្រូតិក/ថាមពល មីរ៉ាច បានប្រកាសថា វាបានចុះកិច្ចព្រមព្រៀងសេវាកម្មវាលប្រេងកាតបរទេសមួយ ជាមួយក្រុមហ៊ុន CZRCE។ តាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងសេវាកម្មនេះ ឆាយណា ប៉េត្រូតិក/ថាមពល មីរ៉ាច ត្រូវផ្ដល់សេវាកម្មប្រឹក្សាផ្នែកបច្ចេកទេស និងគ្រប់គ្រងគម្រោង សម្រាប់ប្រតិបត្តិការអភិវឌ្ឍន៍ និងផលិតប្រេង នៃគម្រោងប្រេងកាតសមុទ្ររបស់ CZRCE នៅក្នុងប្រទេសកម្ពុជា។[៣២៤] បីខែក្រោយមក នៅថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ២០០៦ ឆាយណា ប៉េត្រូតិក/ថាមពល មីរ៉ាច បានទិញភាគហ៊ុន ៤៨ ភាគរយ នៃCZRCE ដែលធ្វើឲ្យគេជាអ្នកកាន់ចំណែកហ៊ុនច្រើនជាងគេនៅក្នុងក្រុមហ៊ុននោះ។[៣២៥] គេបានបង់ប្រាក់ US$៥,៨ លាន សម្រាប់ចំណែកហ៊ុននេះ។ តាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនោះ នៅពេលការទិញនោះជាការស្រេច ឆាយណា ប៉េត្រូតិក/ថាមពល មីរ៉ាច ក្លាយជាក្រុមហ៊ុនប្រតិបត្តិផ្ដាច់មុខ នៃប្លុក D។[៣២៦]

ការទិញ CZRCE ដោយ ឆាយណា ប៉េត្រូតិក/ថាមពល មីរ៉ាច បានធ្វើឲ្យទីផ្សារហ៊ុនសិង្ហបុរីមានសំណួរ ហើយគេបានសុំឲ្យឆាយណា ប៉េត្រូតិក/ថាមពល មីរ៉ាច បញ្ជាក់ប្រាប់ថា CZRCE ធ្វើអ្វីខ្លះ ហើយមានតម្លៃអ្វី។[៣២៧] ក្រុមហ៊ុនបានឆ្លើយតបថា CZRCE "ត្រូវបានរៀបចំនៅក្នុងប្រទេសកម្ពុជា ដើម្បីកាន់កិច្ចព្រមព្រៀងចែកចាយផលិតកម្មវាលប្រេង និងឧស្ម័ន ហៅថា PSC ប្លុក D ដែលបានប្រគល់ដោយ

អាជ្ញាធរប្រេងកាតជាតិកម្ពុជា" ហើយបានពោលបន្ថែមថា "តម្លៃទ្រព្យសកម្មសុទ្ធ នៃ CZRCE នៅថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០០៦ គឺជា US$៥.០០០។"[៣២៨] និយាយម្យ៉ាងទៀត CNPA បានចុះហត្ថលេខា PSC មួយ ជាមួយក្រុមហ៊ុនដែលគ្មានបទពិសោធន៍ជាក់ស្ដែង ក្នុងការស្វែងរុករកប្រេង ឬឧស្ម័នទេ ហើយ – ជាមួយតម្លៃទ្រព្យសកម្មសុទ្ធតែ US$៥.០០០ ប៉ុណ្ណោះ – គ្មានសមត្ថភាពហិរញ្ញវត្ថុច្បាស់ ដើម្បីស្វែងរុករក ឬធ្វើអាជីវកម្មប្រេង ឬឧស្ម័នឡើយ។

ដោយសារក្រុមហ៊ុន CZRCE មិនមានឈ្មោះល្បីទេ Global Witness បានព្យាយាមស្វែងរកព័ត៌មានបន្ថែម អំពីក្រុមហ៊ុន និងម្ចាស់កម្មសិទ្ធិរបស់វា។ ឯកសារចុះឈ្មោះក្រុមហ៊ុន ដែល Global Witness ទទួលបាន បង្ហាញថា CZRCE ត្រូវបានចុះឈ្មោះ ជាមួយនឹងក្រសួងពាណិជ្ជកម្ម នៅថ្ងៃទី ៧ ខែមេសា ឆ្នាំ ២០០៦ ដោយមាននាយកឈ្មោះលោក ស៊ុង សោ ហ៊ុយ។[៣២៩]

នៅជិតទីបញ្ចប់នៃឆ្នាំ ២០០៨ អ្នកស៊ើបអង្កេត Global Witness បានទៅដល់អាសយដ្ឋាននៅក្នុងទីក្រុងភ្នំពេញ ដែល CZRCE បានចុះឈ្មោះនោះ។ នៅឯអាសយដ្ឋាននោះ គ្មានក្រុមហ៊ុនណាមានឈ្មោះនោះឡើយ។

Global Witness ក៏បានស្រាវជ្រាវអំពីកំណត់ហេតុកម្មសិទ្ធិរបស់ CZRCE។ ឆាយណា ប៉េត្រូតិក/ថាមពល មីរ៉ាច បានឲ្យដឹងថា នៅក្នុងខែកក្កដា ឆ្នាំ ២០០៦ វាបានទិញចំណែកហ៊ុន ៤៨ ភាគរយ នៃ CZRCE ពីក្រុមហ៊ុនចុះឈ្មោះនៅ ប្រទេសកម្ពុជា ឈ្មោះថា Power Unicorn Investments Limited [ការវិនិយោគ ផៅវ័រ យូនីឃាន់ ចំកាត់]។[៣៣០] ការលក់ចំណែកហ៊ុននេះ បានបន្ថយកម្មសិទ្ធិចំណែកហ៊ុនរបស់ ផៅវ័រ យូនីឃាន់ នៅក្នុងក្រុមហ៊ុន CZRCE ទៅជា ២៧ ភាគរយ។[៣៣១] ការស៊ើបសួរដោយ Global Witness មិនបានផ្ដល់ព័ត៌មានបន្ថែម អំពីសកម្មភាពនៃក្រុមហ៊ុនការវិនិយោគ ផៅវ័រ យូនីឃាន់ ឬម្ចាស់ទទួលប្រយោជន៍របស់វាឡើយ។

សេចក្ដីប្រកាសសារព័ត៌មាន ដោយឆាយណា ប៉េត្រូតិក អះអាងថា ក្រោយពីការទិញចំណែកហ៊ុន ៤៨ ភាគរយនៅក្នុង CZRCE ដោយឆាយណា ប៉េត្រូតិកនៅក្នុងខែកក្កដា ឆ្នាំ ២០០៦ ក្រុមហ៊ុនមួយឈ្មោះថា China Finance Fund [មូលនិធិហិរញ្ញវត្ថុចិន][៣៣២] កាន់ ៥ ភាគរយ នៃ CZRCE ហើយក្រុមហ៊ុនមួយទៀត ឈ្មោះ Guangdong Zhen Rong Energy Company Limited [ក្រុមហ៊ុន ថាមពល ក្វាំងដុង ចេន រ៉ុង ចំកាត់] កាន់ ២០ ភាគរយ។[៣៣៣] មូលនិធិហិរញ្ញវត្ថុចិន គឺជាក្រុមហ៊ុនចុះឈ្មោះនៅហុងកុង ដោយមាននាយកមួយរូបឈ្មោះលោក លុត ទិម ឆេង ដែលផ្ដល់សេវាកម្មហិរញ្ញវត្ថុ ទៅអតិថិជនចិនអនាមិក។[៣៣៤] ថាមពល ក្វាំងដុង ចេន រ៉ុង គឺជាក្រុមហ៊ុនសាខានៃក្រុមហ៊ុន Zhuhai Zhen Rong Limited Company [ជូហៃ ចេន រ៉ុង ចំកាត់] ដែលជាផ្នែកមួយនៅ Zhen Rong Group [ក្រុម ចេន រ៉ុង]។ ក្រុម ចេន រ៉ុង ត្រូវបានគេរាយការណ៍ថាស្ថិតក្នុងចំណោមក្រុមហ៊ុនរបស់រដ្ឋចិនដ៏ធំជាងគេទាំងប្រាំក្រុមហ៊ុន ដែលមានអាជ្ញាប័ណ្ណនាំចូលប្រេងកាតឆៅ។[៣៣៥]

នៅក្នុងខែមេសា ឆ្នាំ ២០០៧ CZRCE បានផ្លាស់ប្ដូរឈ្មោះទៅជា China Petrotech Holdings Limited (Cambodia) Co [ក្រុមហ៊ុនកាន់ទ្រព្យ ឆាយណា ប៉េត្រូតិក ចំកាត់ (កម្ពុជា)] – ឬ CPHL កម្ពុជា។[៣៣៦]

ក្រោយពីការខំស្វែងរុករកប្រេង នៅក្នុងឆ្នាំ ២០០៧ ឆាយណា ប៉េត្រូតិក បានប្រកាសថា ប្លុក D អាចផ្ទុកប្រេងដែលអាចដកស្រង់បានចំនួន ២២,៦ លានធុង ឬ ឧស្ម័នចំនួន ៤៩៦,២ ពាន់លានហ្វីតគីប។[៣៣៧] ទោះជាបានអះអាងបែបនេះក៏ដោយ ក៏ក្រុមហ៊ុននេះមានសំណាងមិនសូវល្អ ក្នុងរយៈពេលពីរបីឆ្នាំកន្លងមកនេះ។ នាយកបីរូបបានលាលែងតំណែង រវាងខែមីនា ឆ្នាំ ២០០៧ និង ខែកុម្ភៈ ឆ្នាំ ២០០៨។[៣៣៨] ភាគហ៊ុននៃក្រុមហ៊ុន បានបាត់តម្លៃ ៩០ ភាគរយ នៃតម្លៃដើម តាំងពីខែកញ្ញា ឆ្នាំ ២០០៧។[៣៣៩] នៅក្នុងខែមេសា ឆ្នាំ ២០០៧ ក្រុមហ៊ុនត្រួតពិនិត្យបញ្ជីឯករាជ្យKPMG[៣៤០] បានប្រកាសថា វាមិនអាចផ្ដល់មតិអំពីគណនីរបស់ក្រុមហ៊ុននោះបានទេ ដោយសារវារកកស្ដុតាងអំពីសេវាកម្ម និងអតិថិជនមួយចំនួន ដែលបានរាយជាក់ក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមិនឃើញទេ។ សេចក្ដីថ្លែងរបស់ KPMG បានអះអាងថាវា "មិនអាចទទួលភស្ដុតាងពិនិត្យគ្រប់គ្រាន់ ដើម្បីជាមូលដ្ឋាននៃការផ្ដល់មតិពិនិត្យគណនីបានទេ។"[៣៤១] KPMG បានដកថយចេញ នៅជិតទីបញ្ចប់នៃឆ្នាំ ២០០៧ ហើយក្រុមហ៊ុន LTC and Associates [LTC និងសហការី] បានទទួលការងារជាបន្តពីគេ។[៣៤២]

ដូច្នេះ សិទ្ធិសម្រាប់ប្លុក D ស្ថិតក្នុងដៃនៃក្រុមហ៊ុនសេវាកម្មកម្មវិធីកុំព្យូទ័ររកប្រេងពីសិង្ហបុរីមួយ ហើយនិងក្រុមហ៊ុនអាថ៌កំបាំងមួយ ចុះឈ្មោះក្នុងប្រទេសកម្ពុជា ដែលរៀបចំឡើងដើម្បីកាន់សម្បទាន ហើយដែលមួយភាគនៃក្រុមហ៊ុននោះ កាន់ដោយក្រុមហ៊ុនអាថ៌កំបាំងមួយទៀត ក្រុមហ៊ុនវិនិយោគចិនមួយ ហើយនិងក្រុមហ៊ុនរដ្ឋចិននាំចូលប្រេងកាតឆៅមួយ។

Global Witness បានសរសេរសំបុត្រទៅក្រុមហ៊ុនទាំងអស់នេះ នៅក្នុងខែតុលា ឆ្នាំ ២០០៨ ដើម្បីសុំឲ្យគេផ្តល់ការអធិប្បាយ ប៉ុន្តែនៅពេលបោះពុម្ពរបាយការណ៍នេះ យើងមិនបានទទួលការឆ្លើយតបអ្វីទេ។

ប្លុក E

នៅក្នុងឆ្នាំ ២០០៦ ក្រុមហ៊ុនប្រេងឥណ្ឌូណេស៊ី PT Medco Energi Internasional [ថាមពល PT ម៉ិដកូ អន្តរជាតិ] (ម៉ិដកូ) បានទទួលចំណែក ៩០ ភាគរយនៅក្នុងប្លុក E ហើយក្រុមហ៊ុន JHL Petroleum [ប្រេងកាត JHL][៣៤៣] បានទទួល ១០ ភាគរយ។[៣៤៤] នៅក្នុងឆ្នាំ ២០០៧ ម៉ិដកូ បានលក់ ៣១ ភាគរយ នៃចំណែកវា ទៅក្រុមហ៊ុនមួយ ឈ្មោះ Kuwait Energy [ថាមពល គូវ៉ែត]។[៣៤៥] ក្រោយមកទៀត នៅក្នុងឆ្នាំដដែលនោះ ក្រុមហ៊ុនស៊ុយអែត Lundin Petroleum [ប្រេងកាត លូនឌិន][៣៤៦] បានទិញចំណែក ៣៤ ភាគរយ នៃប្លុកនោះ ពីក្រុមទាំងបី – គឺ ម៉ិដកូ ប្រេងកាតJHL និងថាមពល គូវ៉ែត។

ដូច្នេះ សព្វថ្ងៃនេះ សម្បទាន ប្លុក E របស់ប្រទេសកម្ពុជា ត្រូវបានចែកគ្នា ដូចតទៅនេះ៖

| | |
|---|---|
| ម៉ិដកូ (ក្រុមហ៊ុនកាន់ PSC) | - ៤១,៣ ភាគរយ |
| ថាមពល គូវ៉ែត | - ២០,៦ ភាគរយ |
| ប្រេងកាត JHL | - ៤,១ ភាគរយ |
| ប្រេងកាត លូនឌិន | - ៣៤ ភាគរយ |

Global Witness បានសរសេរសំបុត្រទៅក្រុមហ៊ុនទាំងបួន នៅក្នុងខែតុលា ឆ្នាំ ២០០៨ ដើម្បីសួរអំពីលក្ខណៈនៃការពាក់ព័ន្ធរបស់វា នៅក្នុងប្លុក E។ មានតែក្រុមហ៊ុន លូនឌិនតែមួយ ដែលបានឆ្លើយតប។ ក្រុមហ៊ុននោះបានណែនាំ Global Witness ឲ្យមើលតំបន់បណ្តាញអ៊ិនធឺណិតរបស់គេ ដើម្បីរកព័ត៌មានបន្ថែម ហើយបានថ្លែងថា៖

"តាមបានថ្លែងនៅក្នុងសេចក្តីប្រកាសសារព័ត៌មានរបស់យើង ចុះថ្ងៃទី ២៩ ខែតុលា ឆ្នាំ ២០០៧ ដែលមាននៅក្នុងតំបន់បណ្តាញអ៊ិនធឺណិតរបស់យើង ប្រេងកាត លូនឌិន បានទិញចំណែកមិនប្រតិបត្តិ ៣៤ រយ នៅក្នុងសម្បទានសមុទ្រកម្ពុជា ប្លុក E ពីក្រុមហ៊ុនប្រេងកាតអន្តរជាតិ ម៉ិដកូ ចំកាត់ ថាមពល គូវ៉ែត និង ប្រេងកាត JHL។"

"ក្រោយពីការទិញចំណែកសម្បទាននោះ ក្រុមហ៊ុនប្រេងកាត លូនឌិន បានចូលរួមជាភាគីក្នុងកិច្ចព្រមព្រៀងប្រេងកាត សម្រាប់ប្លុក E ជាមួយក្រុមហ៊ុន ម៉ិដកូ KEC [ថាមពលគូវ៉ែត] និងប្រេងកាត JHL ព្រមទាំងអាជ្ញាធរប្រេងកាតជាតិកម្ពុជា។ ម៉ិដកូ គឺជា 'ក្រុមហ៊ុនប្រតិបត្តិ' នៃសម្បទាន ប្លុក E..."

"នៅពេលក្រុមហ៊ុន ប្រេងកាត លូនឌិន ត្រូវបានបង្កើតឡើង យើងបានអនុម័តគោលការណ៍ណែនាំសកម្មភាព ហើយបានបង្កើតក្របខណ្ឌសម្រាប់ការទទួលខុសត្រូវរបស់ក្រុមហ៊ុន សម្រាប់បញ្ហាអភិសមាចារ ដែលអាចលេចឡើង នៅក្នុងការអនុវត្តសកម្មភាពរបស់យើង។" គេបានបន្ថែមថា "ទោះបីប្រេងកាត លូនឌិន មិនបានរួមចំណែកជាផ្លូវការ នៅក្នុងគម្រោងជំរុញតម្លាភាពឧស្សាហកម្មដកស្រង់ (EITI) ក៏ដោយ ក៏យើងគាំទ្រគោលការណ៍តម្លាភាព ដែល EITI លើកស្ទួយ។"[៣៤៧]

ក៏ប៉ុន្តែ ក្រុមហ៊ុន លូនឌិន មិនបានឆ្លើយតបនឹងសំណើរបស់ Global Witness ដើម្បីប្រាប់ចំនួនទឹកប្រាក់ ឬប្រាក់រង្វាន់ចុះហត្ថលេខា ដែលបានបង់ទៅរដ្ឋាភិបាលកម្ពុជាឡើយ។

មិុដកូ លូនឌិន និង ថាមពល គូវ៉ែត សុទ្ធតែជាក្រុមហ៊ុនប្រេងកាតដ៏ល្បីឈ្មោះ ប៉ុន្តែ យើងមិនបានដឹងច្រើនប៉ុន្មានអំពីក្រុមហ៊ុនប្រេងកាត JHL ទេ។ ការស៊ើបអង្កេតបន្ថែមដោយអ្នកស៊ើបអង្កេត Global Witness បានរកឃើញព័ត៌មានដែលបានដាក់នឹងទីផ្សារហ៊ុនហ្សាការតា នៅខែតុលា ឆ្នាំ ២០០៦ ដោយ មិុដកូ ដែលបានថ្លែងថា៖

"ក្រុមហ៊ុនប្រេងកាត JHL (JHL) ពីប្រទេសបាហាម៉ា គឺជាក្រុមហ៊ុនប្រេង និងឧស្ម័ន ដែលជាកម្មសិទ្ធិរបស់ក្រុមហ៊ុនមួយចំនួន ដែលប្រតិបត្តិក្នុងប្រទេសឥណ្ឌូណេស៊ី ហើយដែលបានចូលរួមក្នុងសំណើប្រេង និងឧស្ម័នអន្តរជាតិមួយចំនួន ដែលមានរួមទាំងសំណើទិញសម្បទាន ប្លុក L (សមុទ្រ និងដីគោក) ហើយនិង ប្លុក M (ដីគោក) នៃប្រទេសប្រ៊ុយណេ។"[៣៤៨]

Global Witness ក៏បានទទួលសំណៅឯកសារចុះឈ្មោះក្រុមហ៊ុន ដែលបញ្ជាក់ពីប័ណ្ណរៀបចំក្រុមហ៊ុន JHL នៅក្នុងប្រទេស បាហាម៉ា នៅថ្ងៃទី ២២ ខែមករា ឆ្នាំ ២០០៤។ ក៏ប៉ុន្តែ Global Witness រកមិនឃើញទេ នូវព័ត៌មានលំអិតបន្ថែម ស្តីពី តើក្រុមហ៊ុនអ្វីខ្លះ ដែលជាម្ចាស់ JHL។[៣៤៩]

ដូចជាក្រុមហ៊ុន CZRCE នៅក្នុង ប្លុក D ក្រុមហ៊ុន JHL មើលទៅមិនមានបទពិសោធន៍កន្លងមក ក្នុងការគ្រប់គ្រងសម្បទានប្រេងឡើយ។ ដូច្នេះ ហេតុផលនៃការចែកចំណែកសម្បទាន ទៅក្រុមហ៊ុននេះ គឺមិនច្បាស់លាស់។

## ប្លុក F

មានព័ត៌មានតិចណាស់ អំពីការគ្រប់គ្រងសម្បទានសមុទ្រ ប្លុក F របស់ប្រទេសកម្ពុជាទេ។ ក៏ប៉ុន្តែ ឯកសាររដ្ឋាភិបាល និងរបាយការណ៍កាសែត[350] ផ្តល់ព័ត៌មានថា ប្រហែលក្រុមហ៊ុនដែលកាន់សិទ្ធិនេះ គឺជាក្រុមហ៊ុនប្រេងរបស់រដ្ឋចិន ឈ្មោះ Chinese National Offshore Oil Corp [ក្រុមហ៊ុនប្រេងសមុទ្រជាតិចិន] (CNOOC)។[351] ទីភ្នាក់ងារព័ត៌មានចិន ស៊ីនហួ អះអាងថា CNOOC បានចុះកិច្ចព្រមព្រៀងសម្រាប់ ប្លុក F នៅក្នុងខែឧសភា ឆ្នាំ ២០០៧ ហើយបានសម្តែងចំណាប់អារម្មណ៍លើការចុះកិច្ចព្រមព្រៀងមួយទៀត សម្រាប់សម្បទានដីគោក ប្លុក XIII។ ក៏ប៉ុន្តែ ការអះអាងនេះ មិនទាន់បានបញ្ជាក់ទេ។[352]

Global Witness បានសរសេរសំបុត្រទៅ CNOOC នៅក្នុងខែតុលា ឆ្នាំ ២០០៨ ដើម្បីស្នើឲ្យគេបញ្ជាក់ថា តើព័ត៌មានដែលបានរាយការណ៍នោះពិត ឬមិនពិតទេ។ នៅពេលបោះពុម្ពរបាយការណ៍នេះ CNOOC មិនបានឆ្លើយតបទេ។

## ប្លុក XII

ក្រុមហ៊ុនឥណ្ឌូណេស៊ី មិុដកូ គឺជាក្រុមហ៊ុនកាន់សិទ្ធិភាគច្រើន សម្រាប់ការស្វែងរុករកប្រេង នៅក្នុងប្លុក XII។ ប្លុកនេះ កំពុងត្រូវបានស្ទង់ដោយក្រុមហ៊ុនន័រវែស្ស ឈ្មោះ PGS ដែលត្រូវបានគេជឿ ថាជាក្រុមហ៊ុនទទួលម៉ៅការបន្តរបស់ មិុដកូ។[៣៥៣]

ភាគីដែលវិនិយោគទុនសម្រាប់ការស្វែងរុករកក្នុងប្លុក XII គឺ មិុដកូ ដែលកាន់ ៥២,៥ ភាគរយ CNPA ដែលកាន់ ៤០ ភាគរយ ហើយនិង ប្រេងកាត JHL ដែលកាន់ ៧,៥ ភាគរយ។[៣៥៤] (សម្រាប់ព័ត៌មានលំអិតបន្ថែមអំពីក្រុមហ៊ុន ប្រេងកាត JHL សូមមើលផ្នែកមុន មានចំណងជើង ប្លុក E)។ កិច្ចព្រមព្រៀងបីឆ្នាំនេះ – ជាមួយលទ្ធភាពបន្តកិច្ចព្រមព្រៀង – ត្រូវបានចុះនៅថ្ងៃទី ២៨ ខែកញ្ញា ឆ្នាំ ២០០៧។[៣៥៥]

## ប្លុក X និង XV

ក្រុមហ៊ុន ATI Petroleum [ប្រេងកាត ATI] (ATIP)[356] គឺជាក្រុមហ៊ុនស្វែងរុករកប្រេងកាត។ តាមតំបន់បណ្តាញអ៊ិនធឺណិតរបស់វា បានឲ្យដឹងថាវាកំពុងប្រតិបត្តិការនៅក្នុងប្រទេស កូតឌីវ័រ វៀតណាម និងទុយនីស៊ី។[៣៥៧] ក្រុមហ៊ុននេះក៏អះអាងថា បានយល់ព្រមគ្នា ជាមួយរដ្ឋាភិបាលកម្ពុជា ដើម្បីស្វែងរុករកប្រេងដីគោក នៅក្នុងប្លុក X និង XV ដែលមានទីតាំងនៅតាមមាត់សមុទ្រកម្ពុជា ហើយនិងផ្នែកខាង

ឡៀសាននៃបឹងទន្លេសាប។ គំបន់បណ្ដាញអ៊ិនធឺណិតនៃក្រុមហ៊ុននេះ ថ្លែងថា កិច្ចព្រមព្រៀងនេះនឹង "ជួយសង់ផ្លូវ មន្ទីរពេទ្យ និង សាលារៀន ហើយលើកស្ទួយកម្រិតជីវភាពនៃប្រជាជនកម្ពុជា។" [៣៥៨]

ក៏ប៉ុន្តែ នៅពេលនេះវាមិនទាន់ច្បាស់លាស់ថា តើ ATIP បានទទួលសិទ្ធិជាផ្លូវការ ដើម្បីស្វែងរុករកប្រេង និងឧស្ម័ន នៅក្នុងប្លុកទាំងនេះ ឬទេ។ ទោះជាយ៉ាងណាក៏ដោយ ព័ត៌មានអំពីក្រុមហ៊ុននោះ ហើយនិងសកម្មភាពដែលអាចនឹងកើតមានឡើង មិនដែលផ្ដល់ឲ្យសាធារណជនខ្មែរដឹងឡើយ។

**ប្លុកផ្សេងៗទៀត**

ក្រុមហ៊ុនមួយទៀត ដែលមើលទៅ បានទាមទារធនធានដីគោកនៅក្នុងប្រទេសកម្ពុជា គឺជា Guangdong Chenguan Enterprise Investment Group [ក្រុមសហគ្រាសវិនិយោគ ក្វាំងដុង ឆិនក្វាន់]– គឺជាក្រុមហ៊ុនឯកជន ពីខេត្តក្វាំងដុង ប្រទេសចិន។ របាយការណ៍ព័ត៌មានវិស័យឧស្សាហកម្ម បានឲ្យដឹងថា ក្វាំងដុង ឆិនក្វាន់ បានចុះកិច្ចព្រមព្រៀង ដើម្បីស្វែងរុករកប្រេង និង ឧស្ម័ន នៅក្នុងប្លុកដីគោកបួនកន្លែង។ Global Witness មិនទាន់បញ្ជាក់បានទេ ថាតើនេះជាការពិត ហើយបើពិតមែន តើប្លុកនៅកន្លែងណាខ្លះ។ របាយការណ៍ព័ត៌មាននោះបានឲ្យដឹងថា ក្រុមហ៊ុនអះអាងថា ប្លុកនីមួយៗ មានតម្លៃ US$១០ លាន ហើយវានឹងពិចារណាធ្វើកិច្ចសហការ ជាមួយក្រុមហ៊ុនប្រេង និងឧស្ម័នរបស់រដ្ឋចិន ដើម្បីស្វែងរុករកនៅក្នុងប្លុកទាំងនោះ។ របាយការណ៍ដដែលអះអាងថា ប្រធានក្រុមហ៊ុន លោក ចាំង កូហ៊ុយ[៣៥៩] ក៏ជាប្រធាននៃគណៈកម្មការវិនិយោគសហគ្រាសចិន-កម្ពុជា។[៣៦០]

ម្ដងទៀត វាមិនច្បាស់ថា ក្រុមហ៊ុនអភិវឌ្ឍន៍អចលនទ្រព្យ អាចផ្ដល់សមត្ថភាពស្វែងរុករកប្រេង និងឧស្ម័នអ្វី ក្នុងការអភិវឌ្ឍន៍សម្បទានដីគោកបានឡើយ។

**ប្រាក់រង្វាន់ចុះហត្ថលេខាក្នុងប្រទេសកម្ពុជា** – អ្នកណាចុះហត្ថលេខា អ្នកនោះទទួលប្រាក់រង្វាន់

*"អ្នកណាចុះហត្ថលេខា អ្នកនោះទទួលប្រាក់រង្វាន់។"*

ការអធិប្បាយអំពីលក្ខណៈ នៃប្រាក់រង្វាន់ចុះហត្ថលេខាក្នុងប្រទេសកម្ពុជា ដោយប្រភពមួយរូប ដែលជិតស្និទ្ធនឹងប្រតិបត្តិការរបស់អាជ្ញាធរប្រេងកាតជាតិកម្ពុជា។[៣៦១]

ប្រាក់រង្វាន់ចុះហត្ថលេខា គឺជាការបង់ប្រាក់ទុកជាមុន តែមួយដង ដែលបង់ដោយក្រុមហ៊ុនប្រេង ទៅរដ្ឋាភិបាលមួយ ដើម្បីទទួលសិទ្ធិស្វែងរុករក ឬធ្វើអាជីវកម្មប្រេង ហើយបានក្លាយជារឿងធម្មតា នៅក្នុងវិស័យឧស្សាហកម្មនេះ នៅផ្នែកជាច្រើននៃពិភពលោក។ ចំនួននៃប្រាក់រង្វាន់អាចមានតម្លៃថ្លៃមែនទែន សំអាងលើចំណាប់អារម្មណ៍នៃក្រុមហ៊ុននានា នៅក្នុងតំបន់សម្បទាន។ ឧទាហរណ៍ ក្រុមហ៊ុន BP បានបង់ប្រាក់រង្វាន់ចុះហត្ថលេខា ទៅរដ្ឋាភិបាលអង់ហ្គោឡា ជាចំនួនUS$១១១.៦៨៩.០០០ ដើម្បីទទួលសិទ្ធិលើសម្បទានប្រេងកាត ប្លុក ៣១ នៅក្នុងឆ្នាំ ១៩៩៩។[៣៦២]

ប្រភពក្រុមហ៊ុនប្រេង និងរដ្ឋាភិបាល បានទទួលស្គាល់ជាទូទៅ ថាប្រាក់រង្វាន់ចុះហត្ថលេខា ត្រូវបានបង់ឲ្យCNPA។[៣៦៣] ឯកសាររដ្ឋាភិបាលបញ្ជាក់ថា រង្វាន់ចុះហត្ថលេខាត្រូវបានទាមទារជាធម្មតា ហើយថាវា 'អាចចរចាបាន'។[៣៦៤] ទោះបីចំនួនប្រាក់ គឺតិច បើប្រៀបធៀបនឹងប្រទេសអង់ហ្គោឡានោះក៏ដោយ ប៉ុន្តែសម្រាប់ប្រទេសកម្ពុជា ចំនួនប្រាក់នោះ នៅតែមានតម្លៃថ្លៃ។ ក៏ប៉ុន្តែ ដូចជាព័ត៌មានអំពីការបែករំលែកសម្បទានដែរ ព័ត៌មានអំពីការបង់ប្រាក់រង្វាន់ចុះហត្ថលេខា គឺកម្រមានណាស់។

ក្រុមហ៊ុនមួយ ដែលមានតម្លាភាព នៅក្នុងទំនាក់ទំនងជាមួយ CNPA គឺជាក្រុមហ៊ុនប្រេងឥណ្ឌូណេស៊ី ថាមពល PT មីដកូ អន្តរជាតិ (មីដកូ) ដែលនាបច្ចុប្បន្ននេះកាន់ ៤១,៣ ភាគរយ នៃសម្បទានសមុទ្រប្លុក E របស់ប្រទេសកម្ពុជា ហើយនិង ៥២,៥ ភាគរយ នៃសម្បទានដីគោក ប្លុក XII របស់ប្រទេសកម្ពុជា។[៣៦៥]

នៅថ្ងៃទី ១ ខែតុលា ឆ្នាំ ២០០៦ ម៉ិដកូ បានប្រកាសនៅក្នុងតំបន់បណ្តាញអ៊ិនធឺណិតរបស់វា ថាវាបានទទួលសិទ្ធិស្វែងរុករក នៅក្នុង ប្លុក E នៅក្នុងសមុទ្រកម្ពុជា។ នៅក្នុងសេចក្តីថ្លែងដដែលនោះ ម៉ិដកូ បានថ្លែងថា គេបានបង់ប្រាក់ US$៤,៥ លាន ជា 'មូលនិធិគម្រោងអភិវឌ្ឍន៍សង្គម' ទៅព្រះរាជាណាចក្រកម្ពុជា។[366]

នៅថ្ងៃទី ២៨ ខែកញ្ញា ឆ្នាំ ២០០៧ ម៉ិដកូ បានប្រកាសម្តងទៀត ថាវាបានទទួលសម្បទានមួយពី CNPA – គឺប្លុក XII ជាតំបន់ដីគោក ជាប់នឹងបឹងទន្លេសាប។[៣៦៧] តាមរបាយការណ៍ប្រចាំឆ្នាំរបស់ ម៉ិដកូ ប្រាក់រង្វាន់ចុះហត្ថលេខា ដែលបានបង់សម្រាប់សម្បទាននេះ គឺ US$៣ លាន។[៣៦៨]

Global Witness បានឆែកឆេរបញ្ជាក់ការបង់ប្រាក់នេះ ដោយឯកសារ 'Tableau des Opérations Financières de l'Etat' (TOFE) របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលផ្តល់ព័ត៌មានអំពីប្រាក់ចំណូលប្រចាំឆ្នាំ នៃរដ្ឋកម្ពុជា។[៣៦៩] លទ្ធផលគឺគួរឲ្យបារម្ភមែន។ នៅក្នុងឆ្នាំ ២០០៦ ក្រសួងនេះបានអះអាងថា ទទួលផលចំណូលមិនមែនពន្ធដារ US$១៩.៣០០ ពីធនធានប្រេង និងឧស្ម័ន។ នៅក្នុងឆ្នាំ ២០០៧ ឯកសារនេះចែងថា រដ្ឋទទួល US$២២.០០០។ នៅក្នុងគ្រាដដែលនេះ ម៉ិដកូ អះអាងថា វាបានបង់ប្រាក់ US$៧,៥ លាន ជាថ្លៃផ្សេងៗ និងប្រាក់រង្វាន់ ទៅរដ្ឋាភិបាលកម្ពុជា។[៣៧០] បើប្រាក់នេះមាននៅកន្លែងផ្សេង នៅក្នុងតារាង TOFE នោះវាមិនច្បាស់ថាកន្លែងណាទេ។ នេះធ្វើឲ្យមានសំណួរថា តើការបង់ប្រាក់របស់ ម៉ិដកូ បានទៅណា។ Global Witness បានសរសេរសំបុត្រទៅ ម៉ិដកូ នៅក្នុងខែតុលា ឆ្នាំ ២០០៨ ដើម្បីស្នើសុំឲ្យក្រុមហ៊ុនបញ្ជាក់ថា បានបង់ប្រាក់ទៅអ្នកណា។ នៅពេលបោះពុម្ពរបាយការណ៍នេះក្រុមហ៊ុនមិនបានឆ្លើយតបទេ។

មានសេចក្តីរាយការណ៍អះអាងថា ក្រុមហ៊ុនដទៃទៀតត្រូវបានស្នើ ដើម្បីបង់ប្រាក់ក្រៅច្បាប់ ដើម្បីទទួលសិទ្ធិស្វែងរុករកនៅក្នុងសម្បទាន។ នៅក្នុងខែតុលា ឆ្នាំ ២០០៥ ក្រុមហ៊ុន Indocan Resources Inc.[ធនធាន ឥណ្ឌូកាន] នៅទីក្រុង វ៉ាន់គូវ័រ ប្រទេសកាណាដា បានប្រកាសថា វាបានដាក់ពាក្យជាមួយរដ្ឋាភិបាលកម្ពុជា សុំសិទ្ធិស្វែងរុករក នៅក្នុងតំបន់ដីគោក និងសមុទ្រ។[៣៧១] ក្រុមហ៊ុននោះ មិនដែលបញ្ចប់ដំណើរការដាក់ពាក្យសុំស្វែងរុករកទេ ហើយនៅពេលកាសែត *Bangkok Post* បានសម្ភាសប្រធានក្រុមហ៊ុន Jeffrey Bruhjell [ចេហ្វ្រី ប្រូចិល] មួយឆ្នាំក្រោយ លោកមានប្រសាសន៍ថា ឥណ្ឌូកាន បានប៉ុនប៉ងទទួលអាជ្ញាប័ណ្ណពីរ ប៉ុន្តែត្រូវបានប្រាប់ថា អ្នកមានតំណែងខ្ពស់ នៅក្នុងរដ្ឋាភិបាលកម្ពុជាទាមទារ "ប្រាក់ចំនួនច្រើនណាស់ ជាប្រាក់សំណូក។" គាត់បានបន្ថែមពាក្យថា ក្រុមហ៊ុនលោក "ត្រូវបានស្នើឲ្យបង់ប្រាក់ចំនួនច្រើនណាស់ សម្រាប់អាជ្ញាប័ណ្ណដែលមិនដែលឃើញឡើយ។"[៣៧២]

Global Witness បានសរសេរសំបុត្រទៅគ្រប់ក្រុមហ៊ុន ដែលត្រូវបានជឿថា ទទួលប្លុកសម្បទានស្វែងរុករក នៅក្នុងប្រទេសកម្ពុជា ដើម្បីសួរថា តើពួកគេមានបង់ប្រាក់រង្វាន់ចុះហត្ថលេខាឬទេ ហើយបើមាន តើបង់ច្រើនប៉ុណ្ណា ហើយបង់ទៅអ្នកណា? នៅពេលបោះពុម្ពរបាយការណ៍នេះ មិនមានក្រុមហ៊ុនណាឆ្លើយតបទេ។

## ការស្វែងរុករកនៅលើដីគោក នៅក្នុងខេត្តបាត់ដំបង និងពោធិ៍សាត់

ចំណាប់អារម្មណ៍ភាគច្រើន លើការស្វែងរុករកប្រេង និងឧស្ម័ន នៅក្នុងប្រទេសកម្ពុជា គឺផ្តោតលើប្លុកសមុទ្រ ប៉ុន្តែការស្វែងរុករកលើដីគោក ក៏បានចាប់ផ្តើមជុំវិញអាងទន្លេសាប – គឺជាតំបន់យ៉ាងធំធេងជុំវិញបឹងទន្លេសាប ដែលជាផ្នែកមួយនៃប្លុកដីគោកប្រាំពីរកន្លែង គឺលេខ XI ទៅ XVII។[៣៧៣] ការស្ទង់ដីនៅក្នុងឆ្នាំ ១៩៩៦ ដោយ Japanese National Oil Corporation [ក្រុមហ៊ុនប្រេងកាតជាតិជប៉ុន] បង្ហាញតំបន់ដែលអាចមានប្រេង និងឧស្ម័ន នៅខាងត្បូង និងខាងលិច នៃបឹងទន្លេសាប ប៉ុន្តែត្រូវមានតេសត៍បន្ថែមទៀត ដើម្បីកំណត់ថាតើមានអ្វីខ្លះនៅពីក្រោមបឹងធំ និងវាលស្រែរបស់ប្រទេសកម្ពុជា។[៣៧៤]

បឹងទន្លេសាប គឺជាលក្ខណៈធម្មជាតិដ៏សំខាន់បំផុតមួយ របស់ប្រទេសកម្ពុជា បើនិយាយអំពីសេវាបរិស្ថាន និងជីវភាព ដែលបឹងនេះផ្តល់។ បឹងនេះគឺជាបឹងទឹកសាបដ៏ធំជាងគេ នៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍ ហើយត្រូវបានញែកចេញជាបរិវេណជីវមណ្ឌលមួយ ដោយ UNESCO[៣៧៥] ហើយត្រូវបានលើកឈ្មោះ សម្រាប់ស្ថានភាពជាបេតិកភណ្ឌពិភពលោក។[៣៧៦]

ទោះបីតំបន់នេះត្រូវបានការពារ ដោយរាជក្រឹត្យស្ដីពីការបង្កើត និងការគ្រប់គ្រងឋបនីយជីវមណ្ឌលបឹងទន្លេសាបក៏ដោយ[៣៧៧] ប៉ុន្តែតំបន់ដ៏សំខាន់ខាងលក្ខណៈជីវៈចំរុះនេះ ត្រូវបានគំរាមកំហែងដោយកត្តាបង្កឡើងដោយមនុស្ស ជាច្រើនកត្តា។ បញ្ហាប្រជាជនរស់នៅច្រើនពេក គឺជាបញ្ហាធ្ងន់ ដោយប្រជាជនប្រមាណ ១,២ លាននាក់ រស់នៅលើដីទំនាបទឹកជន់[៣៧៨] ហើយមានអត្រាភាពក្រីក្រខ្ពស់បំផុត នៅក្នុងប្រទេសកម្ពុជា តាមព័ត៌មានរបស់អង្គការAsian Development Bank [ធនាគារអភិវឌ្ឍន៍អាស៊ី]។[៣៧៩] ការចុះដុនដាបនៃប្រព័ន្ធបរិស្ថាននៃទន្លេសាប ចាប់ផ្ដើមជាក់ស្ដែងហើយ៖ គុណភាពដី និងទឹកបានចុះ ហើយមានការភ័យខ្លាចថា ចំនួនត្រីនៅក្នុងបឹងកំពុងចុះដែរ។[៣៨០] លទ្ធផលនៃការចុះដុនដាបនេះ អាចបង្កើតបញ្ហាសន្តិសុខអាហារពាសពេញប្រទេសកម្ពុជា ដោយសារត្រីចំនួន ២៣០.០០០ តោន ដែលនេសាទបានពីបឹងទន្លេសាបរាល់ឆ្នាំ ផ្ដល់ប្រមាណជា ៤០ – ៧០ ភាគរយ នៃជាតិប្រូតេអ៊ីនដែលប្រជារាស្ត្របរិភោគក្នុងមួយឆ្នាំ ហើយជាប្រភពនៃអាហារ និងជីវភាពដ៏ចាំបាច់ សម្រាប់ប្រជារាស្ត្រកម្ពុជា ប្រមាណពីរលាននាក់។[៣៨១]

ទោះជាមានកង្វល់អំពីហេតុប៉ះពាល់ដល់បរិស្ថានក៏ដោយ ក៏រដ្ឋាភិបាលកម្ពុជាបានចាប់ផ្ដើមចែកអាជ្ញាប័ណ្ណស្វែងរុករកប្រេង នៅក្នុងអាងទន្លេសាប។

នៅក្នុងដើមឆ្នាំ ២០០៨ ក្រុមហ៊ុនន័រវ៉េស្ស សេវាកម្មប្រេងកាត ជីយ៉ូ (PGS) បានធ្វើតេសត៍ស្ទង់ 2D នៅតាមផ្លូវថ្នល់ នៅក្នុងខេត្តបាត់ដំបង និងពោធិ៍សាត់។ PGS បានធ្វើការក្នុងនាមជាក្រុមហ៊ុនទទួលម៉ៅការបន្តពីក្រុមហ៊ុនឥណ្ឌូណេស៊ី ថាមពល PT មិដកូ អន្តរជាតិ (មិដកូ) ដែល ដូចបានពន្យល់ខាងលើ គឺជាក្រុមហ៊ុនកាន់ចំណែកសិទ្ធិស្វែងរុករកច្រើនជាងគេ សម្រាប់ប្លុក XII។

តាមព័ត៌មានដែល Global Witness ទទួលបាន ការស្ទង់ដីនៅក្នុងខេត្តបាត់ដំបង និងពោធិ៍សាត់ បានធ្វើឡើងនៅក្នុងស្រុកបាណន់ សង្កែ មោងឫស្សី គាស់ក្រឡ ហើយនិងនឹងឃុំពីរ នៅក្នុងស្រុកស្វាយដូនកែវ។[៣៨២] ក៏ប៉ុន្តែតេសត៍រញ្ជួយផែនដី អាចពង្រីកវិស័យធំហួសពីនេះទៅទៀត។ ការស្ទង់ដីភាគច្រើន បានកើតឡើយឆ្ងាយផុតពីបឹងទន្លេសាប – ដែលស្ថិតចម្ងាយ ៤០ គ.ម. ពីផ្លូវជាតិលេខ ៥ – ប៉ុន្តែមន្ត្រីក្រុមហ៊ុន PGS មួយរូប បានមានប្រសាសន៍ថា "បឹងក៏គួរឲ្យចាប់អារម្មណ៍ដែរ។"[៣៨៣]
តេសត៍ស្ទង់ដី មានពាក់ព័ន្ធនូវខ្សែភ្លើងប្រវែង ៥ គ.ម. ដែលសន្ទឹងទៅតាមដងផ្លូវជាតិលេខ ៥ ហើយនិងផ្លូវតូចជាង ដែលបែកចេញពីផ្លូវជាតិ។ ប្រដាប់ស្ដាប់ដ៏តូច ត្រូវបានស៊កចូលក្នុងដី តាមចន្លោះ ១០—២០ ម៉ែត្រ។ នៅពេលខ្សែ និងប្រដាប់ស្ដាប់ត្រូវបានរៀបអស់ហើយ 'ប្រដាប់គោះ' មួយដែលជាប់គូថឡានដឹកទំនិញតូចមួយគ្រឿង បានបើកបរទៅមុខយ៉ាងយឺត ហើយឈប់នៅគ្រប់ប្រដាប់ស្ដាប់ ដើម្បីគោះដីដោយដុំដែកដ៏ធំ រាងក្រឡា។[384] វិធីដ៏មានហេតុប៉ះពាល់តិចនេះ ផ្ដល់ទិន្នន័យ ដែលប្រាប់ថា តើមានដំណាក់ប្រេងកាតនៅក្រោមដី ឬទេ។

ទោះបីមិនដែលមានការប្រកាសលទ្ធផលផ្លូវការក៏ដោយ មានការរំភើបចិត្តក្នុងចំណោមអ្នកស្រុក ដោយគិតថា ការរកឃើញប្រេងកាតយ៉ាងច្រើន ជិតកើតឡើងនៅតំបន់នោះ។ មេឃុំមួយរូប នៅក្នុងខេត្តពោធិ៍សាត់ ដែលបានកំដរក្រុមអន្តរជាតិ ដែលធ្វើតេសត៍ស្ទង់ដី ត្រូវបានអ្នកតំណាងក្រុមហ៊ុនមួយរូបប្រាប់ថា នឹងមានការវិនិយោគ US$១ ពាន់លាន នៅក្នុងតំបន់នោះ រួមទាំងផ្លូវថ្មី។[៣៨៥] មន្ត្រីនៅក្នុងតំបន់ដែលបាននិយាយជាមួយ Global Witness បានស្វាគមន៍ចំពោះការរកឃើញប្រេងកាត ដោយគិតថា វានឹងធ្វើឲ្យប្រេងសាំងថោកជាង ហើយផ្ដល់ការងារសម្រាប់ប្រជាជន។

ទោះបីរដ្ឋាភិបាលពាក់ព័ន្ធក្នុងការសម្រួលដល់សកម្មភាពស្វែងរុករក នៅកម្រិតជាតិ ខេត្ត ស្រុក និងឃុំក៏ដោយ មើលទៅមានការពិគ្រោះតិចណាស់ ជាមួយសហគមន៍។ អ្នកស្រុកខ្លះបារម្ភថា ការខួងអាចបង្កការរញ្ជួយផែនដី ហើយបានមកតវ៉ានឹងមេឃុំ។ ពួកគេត្រូវបានលួងលោមប្រាប់ថា ធាតុរាវណាដែលយកចេញពីក្នុងផែនដី នឹងត្រូវបានប្ដូរដោយទឹក ហើយថានឹងគ្មានហេតុប៉ះពាល់ដល់បរិស្ថានទេ។

ដំណាក់កាលនៃការធ្វើតេសត៍បន្ទាប់មកទៀត មានរួមការខួងចូលក្នុងដី ហើយមន្ត្រីរដ្ឋាភិបាលកម្ពុជាបានផ្ដល់ការអនុញ្ញាតឲ្យ PGS បន្តការស្ទង់របស់គេ ចូលក្នុងវាលស្រែ នៅពេលដូវច្រូតកាត់ចប់ហើយ នៅក្នុងចុងឆ្នាំ ២០០៨។[386] នៅពាក់កណ្ដាលឆ្នាំ ២០០៨ មិនដែល

មានការពិគ្រោះជាមួយអ្នកក្នុងសហគមន៍ អំពីហេតុការណ៍នេះទេ ប៉ុន្តែមេឃុំមួយរូប បានគិតថា នឹងមានវេទិកាសាធារណៈនៅពេលណាមួយ ក្នុងពេលអនាគត។

ដោយសារប្រព័ន្ធបរិស្ថានខ្វះស្ថិរភាព ការបង្កើតហេដ្ឋារចនាសម្ព័ន្ធដ៏ស្មុគស្មាញ ដែលត្រូវការដើម្បីដកយក និងដឹកជញ្ជូនប្រេង និងឧស្ម័ន អាចបង្កគ្រោះថ្នាក់យ៉ាងធ្ងន់ ដល់អាងទន្លេសាប។ ក៏ប៉ុន្តែ ទោះជាក្រុមការពារបរិស្ថានមានការខ្វល់ខ្វាយក៏ដោយ ក៏រដ្ឋាភិបាលមើលទៅស្ទាក់ស្ទើរក្នុងការយកចិត្តទុកដាក់នឹងហេតុប៉ះពាល់ដល់បរិស្ថាន។[៣៨៧] មន្ត្រីទទួលបន្ទុកផ្នែកជំណាក់ប្រេងទន្លេសាប បានអះអាងថា រដ្ឋាភិបាល "នឹងបញ្ជាក់ថា គ្មានការបំពុលទេ" នៅក្នុងដំណើរការស្វែងរុករក។[៣៨៨]

Global Witness បារម្ភថា CNPA មិនមានសមត្ថភាព ឬបទពិសោធន៍ល្មម ដើម្បីបញ្ជាក់ថា ការស្វែងរុករក និងការធ្វើអាជីវកម្មលើធនធានប្រេង ឬឧស្ម័ន នៅក្នុងអាងទន្លេសាបនៅពេលអនាគត ប្រកបដោយសុវត្ថិភាព និងប្រសិទ្ធិភាពនោះទេ។ នៅក្នុងប្រទេសដទៃទៀត ដូចជាប្រទេសនីហ្សេរីយ៉ា លទ្ធផលនៃការគ្រប់គ្រងដោយអសមត្ថភាព បាននាំឲ្យមានវិបត្តិធំ ដល់បរិស្ថាន។ ដោយសារអភិបាលកិច្ចលើឧស្សាហកម្មប្រេងរបស់ប្រទេសកម្ពុជា មានភាពទន់ខ្សោយកន្លងមកហើយ បញ្ហានៃកិច្ចការពារបរិស្ថាន នៅក្នុងតំបន់ដែលសំខាន់សម្រាប់សុខភាពប្រទេសជាតិកម្ពុជាទាំងមូលបែបនេះ គឺត្រូវតែដោះស្រាយជាបន្ទាន់។

ដូច្នេះ ជាការសង្ខេប ការលក់សម្បទានប្រេង និងឧស្ម័នប្រទេសកម្ពុជា កំពុងឈានទៅមុខពេញទំហឹង ដោយគ្រប់សម្បទានសមុទ្រទាំងអស់ ហើយនិងសម្បទានដីគោកមួយចំនួន ត្រូវបានចែកឲ្យក្រុមហ៊ុនស្រេចហើយ។ កង្វល់របស់ Global Witness គឺថា នៅក្នុងប្រទេសមួយដ៏ល្បីឈ្មោះ ដោយសារការពុករលួយ មានព័ត៌មានតិចពេក អំពីអ្នកណាដែលជាម្ចាស់ទទួលប្រយោជន៍នៃក្រុមហ៊ុនខ្លះ ហើយចំពោះក្រុមហ៊ុនមួយចំនួន វាមិនច្បាស់សោះថា តើក្រុមហ៊ុនផ្ដល់មុខជំនាញ ឬសមត្ថភាពអ្វីខ្លះ ដើម្បីជួយអភិវឌ្ឍន៍ឧស្សាហកម្មប្រេង និងឧស្ម័នរបស់ប្រទេសកម្ពុជា ដ៏នៅតែក្មេងខ្ចី។ ដូចជាវិស័យអាជីវកម្មរ៉ែដែរ មានគ្រោះថ្នាក់ត្រង់ថា ការខ្វះខាតព័ត៌មានមូលដ្ឋានបែបនេះ ធ្វើឲ្យធនធានសំខាន់របស់ប្រទេសជាតិស្ថិតរងគ្រោះថ្នាក់នៃការចាប់យកដោយបុគ្គល សម្រាប់ប្រយោជន៍ផ្ទាល់ខ្លួន ជំនួសប្រយោជន៍ជាតិ។

## ជំពូកទី ៤៖ ទាយករបស់ប្រទេសកម្ពុជា – តើគេធ្វើការដើម្បីអ្នកណា?

*"អភិបាលកិច្ចល្អគឺជាការចាំបាច់ សម្រាប់ការអភិវឌ្ឍន៍ដ៏ស្វ័យទ្រទ្រង់។ គោលនយោបាយរឹងមាំ ស្ថាប័នប្រជាធិបតេយ្យដ៏រឹងមាំ ដែលឆ្លើយតបនឹងសេចក្ដីត្រូវការនៃប្រជាជន ហើយនិងហេដ្ឋារចនាសម្ព័ន្ធដ៏ល្អឡើង គឺជាមូលដ្ឋាននៃការលូតលាស់សេដ្ឋកិច្ចបន្តបន្ទាប់ ការកម្ចាត់ចោលភាពក្រីក្រ ហើយនិងការបង្កើតការងារ...ការប្រឆាំងអំពើពុករលួយ នៅក្នុងគ្រប់ថ្នាក់កម្រិត គឺជាសកម្មភាពមានអាទិភាព។ ការពុករលួយគឺជាឧបសគ្គដ៏ធំណាស់ នៅក្នុងការប្រើប្រាស់ និងចែករំលែកធនធានដោយប្រសិទ្ធិភាព ហើយវាបង្វែរធនធានចេញពីសកម្មភាពដែលចាំបាច់ សម្រាប់ការកម្ចាត់ចោលភាពក្រីក្រ និងការអភិវឌ្ឍន៍សេដ្ឋកិច្ច ដោយស្វ័យទ្រទ្រង់។"*

សំដីដកស្រង់ពីការស្រុះសម្រួលមតិគ្នានៅទីក្រុងម៉ុនតេរេ នៅក្នុងសន្និសីទអន្តរជាតិ ស្ដីពីការផ្ដល់ធនធានហិរញ្ញវត្ថុសម្រាប់ការអភិវឌ្ឍន៍ ខែមីនា ឆ្នាំ ២០០២។[៣៨៩]

*"រួមជាមួយនឹងការផ្ដល់ជំនួយ មានភារកិច្ចដើម្បីបញ្ជាក់ថា ជំនួយនោះជួយដល់ប្រជាជន។... វាមិនគ្រប់គ្រាន់ទេ ដែលពឹងផ្អែកលើជំនួយបច្ចេកទេស ឬការអភិវឌ្ឍន៍សមត្ថភាព ឬដែលដៅបញ្ជាក់ការគោរពតាមសន្ធិសញ្ញា និងពិធីការសិទ្ធិមនុស្ស (ទោះជាវាសំខាន់ប៉ុណ្ណាក៏ដោយ)។ ច្បាប់ថ្មី ឬស្ថាប័នបង្កើតថ្មី ក៏មិនមែនជាដំណោះស្រាយដ៏សាកលនោះទេ ពីព្រោះរដ្ឋាភិបាលធ្វើព្រងើយកន្តើយនឹងច្បាប់ ឬ ដោយការប្រើច្បាប់ខុសឆ្គង បែរវាទៅបម្រើប្រយោជន៍នៃបក្សខ្លួនឯងវិញ។"*

សំដីដកស្រង់ពីសេចក្ដីថ្លែង ឆ្នាំ ២០០៦ ទៅកាន់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ដោយអ្នកតំណាងពិសេសរបស់អគ្គលេខាធិការសម្រាប់សិទ្ធិមនុស្សប្រចាំប្រទេសកម្ពុជា លោក យ៉ាស ហ្គាយ។[៣៩០]

របៀបដែលជំនួយអភិវឌ្ឍន៍អន្តរជាតិត្រូវបានផ្តល់ឲ្យ កំពុងតែផ្លាស់ប្តូរ។ ឥឡូវនេះ មានការស្របមតិគ្នាជាទូទៅ នៅថ្នាក់អន្តរជាតិ ថា អភិបាលកិច្ចល្អ គឺជាការចាំបាច់ សម្រាប់ការអភិវឌ្ឍន៍ដ៏ស្ថិតទ្រទ្រង់ ហើយថាការប្រឆាំងអំពើពុករលួយ នៅគ្រប់ថ្នាក់កម្រិតទាំងអស់ គឺជាកិច្ចការត្រូវមានអាទិភាព ដើម្បីបង្កើនប្រសិទ្ធិភាពនៃជំនួយ។ ដោយសារទីភ្នាក់ងារជំនួយភាគច្រើន ទាំងរបស់រដ្ឋាភិបាល និងពហុភាគីផង ឥឡូវនេះអះអាងថា ការបន្ថយភាពក្រីក្រ និងភាពមិនស្មើគ្នា គឺជាខ្លឹមសារនៃគោលបំណងរបស់ខ្លួននោះ បញ្ហានៃអភិបាលកិច្ច និងអំពើពុករលួយ គួរគប្បីជាមូលដ្ឋាននៃការអនុវត្ត និងការចែកចាយ នូវជំនួយអភិវឌ្ឍន៍។[៣៩១]

ក៏ប៉ុន្តែ សហគមន៍ទាយកនៅក្នុងប្រទេសកម្ពុជា មើលទៅ មិនបានត្រៀមខ្លួន ឬក៏មានការស្ទាក់ស្ទើរ ដើម្បីអនុវត្តគោលនយោបាយនេះ។ ផ្ទុយទៅវិញ មានការដាច់គ្នា រវាងការប្តេជ្ញាដែលបានធ្វើឡើងនៅថ្នាក់អន្តរជាតិ និងសកម្មភាពរបស់ទាយករបស់ប្រទេសកម្ពុជា នៅថ្នាក់ជាតិ។ សហគមន៍ទាយករបស់ប្រទេសកម្ពុជាបរាជ័យជាទៀងទាត់ ក្នុងការឲ្យរដ្ឋាភិបាលទទួលខុសត្រូវ ចំពោះការបំពានយ៉ាងជាក់ស្តែង នូវការសន្យារបស់ខ្លួន ដើម្បីការពារសិទ្ធិមនុស្សរបស់ប្រជាជនកម្ពុជា ប្រឆាំងអំពើពុករលួយ ហើយធ្វើឲ្យប្រាកដថា ដីធ្លី និងធនធានធម្មជាតិ ត្រូវបានការពារ។

*"នៅក្នុងក្របខណ្ឌនៃកិច្ចប្រឹងប្រែងសាងសង់ជាតិឡើងវិញ ជំនួយសេដ្ឋកិច្ចគួរតែផ្តល់ប្រយោជន៍ដល់គ្រប់ផ្នែកនៃសង្គមកម្ពុជា ជាពិសេស អ្នកដែលខ្វះធនធាន ហើយជួយដល់គ្រប់ថ្នាក់កម្រិតនៃសង្គម។"*

### ចំណុចទី ៤ នៃសេចក្តីប្រកាស ស្តីពីដំណើរការសម្បទា និងការសាងសង់ឡើងវិញប្រទេសកម្ពុជា របស់អង្គការសហប្រជាជាតិ ថ្ងៃទី ២៣ ខែតុលា ឆ្នាំ ១៩៩១។[392]

ដោយបានសន្យាឲ្យឧបត្ថម្ភដំណើរការសម្បទាប្រទេសកម្ពុជាក្រោយពីសង្គ្រាម ទាយកអន្តរជាតិរបស់ប្រទេសនោះ បានផ្តល់ប្រមាណ ៥០ ភាគរយនៃថវិកាប្រចាំឆ្នាំរបស់រដ្ឋាភិបាល អស់ជាងមួយទសវត្សហើយ។ ជំនួយនេះបានឈានដល់កំពូលនៅក្នុងឆ្នាំ ២០០៨ ដោយមានការសន្យាផ្តល់ជំនួយជិត ប៤$១៣ន់លាន។[៣៩៣] ប្រាក់នេះ ពិតជាបានជួយច្រើន ក្នុងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធរបស់ប្រទេសឡើងវិញ ហើយផ្តល់សេវាកម្មចាំបាច់ ប៉ុន្តែប្រសិទ្ធិភាពរបស់វាមានកម្រិត ដោយសារអភិបាលកិច្ចមិនល្អ និងការពុករលួយ។

## *"ការកែទម្រង់ មិនមែនជាពាក្យដ៏រាក់ទ្បើយ។"*

សំដីដកស្រង់ពីសន្ទរកថារបស់សម្តេច ហ៊ុន សែន ទៅកាន់ទាយកអន្តរជាតិរបស់ប្រទេសកម្ពុជា នៅក្នុងឆ្នាំ ២០០៤ ២០០៥ និង ២០០៧។[៣៩៤]

នៅក្នុងទសវត្ស ១៩៩០ ការបែរមុខចេញពីអភិបាលកិច្ចមិនល្អ និងអំពើពុករលួយ ត្រូវបានទាយកដោះសារ ដោយសារមានសេចក្តីត្រូវការដើម្បីបញ្ជាក់ឲ្យមាន 'ស្ថិរភាព'។ ស្ថិរភាពជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ច ហើយពហុភាគនិយមនឹងកើតមកជាបន្តបន្ទាប់។[៣៩៥] រយៈពេលដប់ប្រាំមួយឆ្នាំកន្លងមកនេះ បានបង្ហាញកំហុសនៃការគិតបែបនេះ។ រាល់ពេលដែលសហគមន៍ទាយកអាក់ខានក្នុងការសួរសំណួរដ៏ពិបាក និងប្រព្រឹត្តដោយសមហេតុសមផល ចំពោះការបរាជ័យរបស់របបគ្រប់គ្រង ក្នុងការគោរពពាក្យសន្យារបស់ខ្លួន និងអភិបាលកិច្ចល្អនោះ អ្នកដែលត្រូវទទួលខុសត្រូវ បានបង្កើនអំណាចនយោបាយ ទ្រព្យសម្បត្តិផ្ទាល់ខ្លួន ហើយនិងសេរីភាពពីការទទួលទោសពៃរ៍។ លទ្ធផលចុងក្រោយ គឺថាប្រជាជនខ្មែរធម្មតា មានការលំបាកកាន់តែច្រើន ក្នុងការទាមទារឲ្យរដ្ឋាភិបាលទទួលខុសត្រូវ ហើយផលប្រយោជន៍នៃការអភិវឌ្ឍន៍ប្រទេសកម្ពុជា នៅតែស្ថិតក្នុងដៃនៃមនុស្សតែបន្តិចបន្តួចប៉ុណ្ណោះ។

**ប្រអប់ទី ១៣៖ បាត់ខ្លួន – ច្បាប់ប្រឆាំងអំពើពុករលួយរបស់ប្រទេសកម្ពុជា**

ឧទាហរណ៍ដ៏ជាក់ស្តែងមួយ នៃអសមត្ថភាពរបស់ទាយក ដើម្បីដោះស្រាយបញ្ហានៃការមិនព្រមស្តាប់របស់រដ្ឋាភិបាល គឺជាច្បាប់ប្រឆាំងអំពើពុករលួយ ដែលត្រូវបានរង់ចាំយ៉ាងយូរអង្វែង។ ច្បាប់នេះត្រូវបានព្រាងឡើងនៅក្នុងឆ្នាំ ១៩៩៤ ហើយត្រូវបានផ្តោកជាគោលដៅរវាងទាយក និងរដ្ឋាភិបាល នៅក្នុងឆ្នាំ ២០០២[៣៩៦] ហើយរដ្ឋាភិបាលបានជោគជ័យ ក្នុងការអាក់ខានអនុម័តច្បាប់នេះរាល់ឆ្នាំ អស់រយៈពេល ១៤ ឆ្នាំកន្លងមកនេះ ហើយចោតការយឺតយ៉ាវ ក្នុងការបង្កើតច្បាប់ព្រហ្មទណ្ឌដ៏ទាន់សម័យ ជាមូលហេតុ។[៣៩៧] ទោះជាមានអាក់ខានរៀង

រាល់ឆ្នាំ ក្នុងការឈានទៅមុខជាមួយច្បាប់នេះក៏ដោយ ទាយករបស់ប្រទេសកម្ពុជា នៅតែបន្តផ្ដល់ប្រាក់ ដោយមិនព្រមទាមទារឲ្យការអនុម័តច្បាប់នេះ ជាលក្ខខណ្ឌផ្ដាច់ការ សម្រាប់ការចែកថវិកា ក្រៅពីជំនួយមនុស្សធម៌នោះឡើយ។

នៅក្នុងខែសីហា ឆ្នាំ ២០០៨ អ្នកតំណាងរដ្ឋាភិបាល ឯកឧត្ដម **ខៀវ កញ្ញារិទ្ធ** បានប្រកាសថា ការតែងច្បាប់ព្រាងប្រឆាំងអំពើពុករលួយដែលរង់ចាំយ៉ាងយូរអង្វែងហើយ ត្រូវបានបញ្ចប់ ហើយនឹងត្រូវបានប្រគល់ទៅសភាជាតិ នៅក្នុងរយៈពេលប៉ុន្មានខែខាងមុខ – ប៉ុន្តែលុះត្រាតែច្បាប់ព្រហ្មទណ្ឌត្រូវបានអនុម័តសិន។ ច្បាប់ព្រហ្មទណ្ឌព្រាងនេះ កំពុងត្រូវបានពិនិត្យដោយក្រុមប្រឹក្សារដ្ឋមន្ត្រី។ ក៏ប៉ុន្តែ នៅក្នុងខែកញ្ញា ឆ្នាំ ២០០៨ មានតែ ៤០ មាត្រា ក្នុងចំណោម ៧០០ មាត្រា ត្រូវបានពិនិត្យដោយក្រុមប្រឹក្សា។[៣៩៨] ទោះជារដ្ឋាភិបាលបានធ្វើការសន្យាជាច្រើន នៅក្នុងរយៈពេលដប់បួនឆ្នាំនេះក៏ដោយ ក៏ការអនុម័តច្បាប់ប្រឆាំងអំពើពុករលួយ នៅតែឆ្ងាយណាស់ទៅមុខ។

**អនុម័ត ឬមិនអនុម័ត? គម្រោងជំរុញតម្លាភាពឧស្សាហកម្មដកស្រង់ (EITI)**[v]

កង្វះខាត នូវការតបតរួមគ្នាដោយទាយក ដើម្បីដោះស្រាយការពុករលួយថ្នាក់ខ្ពស់ តាមរយៈលក្ខខណ្ឌនៃការបរិច្ចាគប្រាក់របស់ទាយកនោះអាចមើលឃើញជាក់ស្ដែង នៅក្នុងរបៀបដែលទាយកប្រឈមមុខនឹងអភិបាលកិច្ចទៅលើឧស្សាហកម្មដកស្រង់របស់ប្រទេសកម្ពុជា។ នៅក្នុងខែមិថុនា ឆ្នាំ ២០០៧ Global Witness បានធ្វើការប្រជុំជាមួយសមាជិកនៃសហគមន៍ទាយក ដែលក្នុងការប្រជុំនោះ យើងត្រូវបានប្រាប់ថា ការអនុម័ត EITI ដោយរដ្ឋាភិបាល គឺជាគោលដៅដ៏ផ្ដាច់ការ ដើម្បីទទួលជំនួយថវិកាផ្ទាល់។[៣៩៩] នៅក្នុងខែវិច្ឆិកា ឆ្នាំ ២០០៧ Global Witness បានចូលរួមការប្រជុំមួយ ដែលក្នុងនោះ ទាយកដដែលបានទទួលសារភាពថា តម្រូវការដើម្បីអនុម័តEITI ត្រូវបានបន្ធូរទៅជា 'ការយល់ព្រម ដើម្បីគិតពិចារណាអំពីការអនុម័ត EITI' វិញ។[៤០០] នៅក្នុងខែតុលា ឆ្នាំ ២០០៨ មានសេចក្ដីប្រកាសថា រដ្ឋាភិបាលបានសម្រេចមិនឲ្យរួមចំណែកក្នុងគ្រោង EITI ទេ។[៤០១] Global Witness បានលើកបញ្ហានេះឡើង ពិភាក្សាជាមួយសមាជិកនៃសហគមន៍ទាយក ហើយត្រូវបានប្រាប់ថា រដ្ឋាភិបាលកំពុងធ្វើការឆ្ពោះទៅរកគោលការណ៍ហិរញ្ញវត្ថុទូទៅនៃគម្រោងនោះ ប៉ុន្តែការប្រើពាក្យEITI អាចនាំឲ្យមានទំនាស់នយោបាយ ហើយពួកគេខ្លាចថា ការគាប់សង្កត់រដ្ឋាភិបាលខ្លាំងពេក អំពីរឿងនោះ នឹងធ្វើឲ្យគេដើរចេញពីតុ។[៤០២]

---

[v] គម្រោងជំរុញតម្លាភាពឧស្សាហកម្មដកស្រង់ (EITI) ជាក្រុមសម្ព័ន្ធ ប្រកបដោយរដ្ឋាភិបាល ក្រុមហ៊ុន ក្រុមសង្គមស៊ីវិល អ្នកវិនិយោគ និងអង្គការអន្តរជាតិ។ គម្រោងនេះគាំទ្រការកែលំអអភិបាលកិច្ច នៅក្នុងប្រទេសមានធនធានច្រើន តាមរយៈការបញ្ជាក់ និងការបោះពុម្ពទាំងស្រុង នូវព័ត៌មានស្ដីពីការបង់ប្រាក់របស់ក្រុមហ៊ុន និងផលចំណូលរបស់រដ្ឋាភិបាល មកពីប្រេង ឧស្ម័ន និងអាជីវកម្មរ៉ែ។ ព័ត៌មានអំពីគម្រោងជំរុញតម្លាភាពឧស្សាហកម្មដកស្រង់ មានផ្ដល់ជូននៅឯ៖ www.eitransparency.org។

## តារាងទី ៤ ៖ របៀបដើម្បីចែកប្រាក់ ដោយនៅតែគ្មានអានុភាព

| ឆ្នាំ | ការកែទម្រង់ដែលបានយល់ព្រម | ការឈានទៅរកគោលដៅកែទម្រង់ | ការអធិប្បាយរបស់ទាយក | ការអធិប្បាយរបស់ NGO | ការអធិប្បាយរបស់ប្រព័ន្ធផ្សព្វផ្សាយ | ការអធិប្បាយរបស់រដ្ឋាភិបាលកម្ពុជា | ជំនួយដែលបានស្នើសុំដោយរដ្ឋាភិបាល | ជំនួយដែលបានផ្ដល់ឲ្យដោយទាយក[403] |
|---|---|---|---|---|---|---|---|---|
| '០២ | បានដាក់ក្នុងឆ្នាំ ២០០១[404]<br>- អនុម័តច្បាប់ប្រឆាំងអំពើពុករលួយ<br>- អនុម័តច្បាប់ព្រៃឈើ និងបង្កើយកិច្ចចរចាជាមួយសម្បទានិក<br>- អនុម័តច្បាប់ភូមិបាល | - ច្បាប់ប្រឆាំងអំពើពុករលួយ មិនបានអនុម័តទេ។[405]<br>- ការមិនដាក់ទោសពៃរ៍បន្តបន្ទាប់ នៅថ្នាក់ខ្ពស់។[406]<br>- ការគ្រប់គ្រងធនធានព្រៃឈើ/ធម្មជាតិ ដ៏ច្របូកច្របល់។[407] | អង់គ្លេស – "ការចម្រើនគួរឲ្យខកចិត្ត ជាទូទៅ លើចំណុចសកម្មភាព ដែលបានយល់ព្រម នៅក្នុង [ការប្រជុំ] ឆ្នាំ ២០០១។ មិនត្រូវបន្តការបង្កើនជំនួយទាយកជាស្វ័យប្រវត្តិទេ។ ត្រូវបញ្ជាក់ថារដ្ឋាភិបាលធ្វើតាមកាតព្វកិច្ចរបស់ខ្លួន។ [...] នៅតែរង់ចាំការអនុម័តច្បាប់ប្រឆាំងអំពើពុករលួយ។"[408] | វេទិកា NGO – "ការចម្រើនឡើងផ្នែកគោលនយោបាយ មិនបានក្លាយជាការចម្រើនលទ្ធផលឡើយ [...] ការពុករលួយ និងការមិនដាក់ទោសពៃរ៍ នៅតែមានជាទូទៅ។"[409] | - "[អ្នកវិភាគ] បានព្រមាន [ថា] ដំណើរយឺត នៃការកែទម្រង់ ការពុករលួយទូទៅ ហើយការខកខានកាត់ទោសអ្នកដឹកនាំខ្មែរក្រហម សាកល្បងការអត់ធ្មត់នៃទាយក ហើយអាចមានលទ្ធផលដាក់លក្ខខណ្ឌលើការផ្ដល់ជំនួយ ជាលើកដំបូង។"[410] | ហ៊ុន សែន–"រាជរដ្ឋាភិបាលប្ដេជ្ញាឲ្យបង្កើតច្បាប់ព្រាងនៃច្បាប់ប្រឆាំងអំពើពុករលួយ មុនទីបញ្ចប់នៃខែមិថុនា ឆ្នាំ ២០០៣។" [411] | US$៤៨៥ លាន | US$៥៣០,៩ លាន |
| '០៣ | គ្មានការប្រជុំ | | | | | | | US$៥៣៩.៥ លាន |
| '០៤ | បានដាក់នៅក្នុងឆ្នាំ ២០០២[412]<br>**ការប្រឆាំងអំពើពុករលួយ**<br>- 'ករណីនៃការពុករលួយ ត្រូវស៊ើបអង្កេត ហើយផ្ដន្ទា នៅក្រោមក្របខណ្ឌច្បាប់បច្ចុប្បន្ន។' ថ្ងៃកំណត់៖ ភ្លាម<br>- 'ច្បាប់ប្រឆាំងអំពើពុករលួយ ដាក់ជាមួយសភាជាតិ' ពេលកំណត់៖ ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០០៣។<br>**សម្បទាន**<br>- 'ការបញ្ចេញព័ត៌មានជាសាធារណៈ និងឱកាសសម្រាប់អ្នកជំនាញឯករាជ្យអធិប្បាយអំពីគោលនយោបាយគ្រប់គ្រងព្រៃឈើដោយស្វ័យទ្រទ្រង់ និងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម មុនបញ្ចប់ការពិនិត្យរបស់រដ្ឋាភិបាល។'<br>**ការបញ្ចេញព័ត៌មាន**<br>- 'លក្ខខណ្ឌកិច្ចព្រមព្រៀងរដ្ឋាភិបាល មានតម្លាភាពថែមឡើង។' ពេលកំណត់៖ ភ្លាម | - ច្បាប់ប្រឆាំងអំពើពុករលួយ មិនបានអនុម័តទេ។[413]<br>- សកម្មភាពតិចណាស់ អំពីការពុករលួយ។[414]<br>- ការព្យួរទុកសម្បទានព្រៃឈើ ប៉ុន្តែការកាប់ឈើខុសច្បាប់បន្ត។[415]<br>- ការអនុវត្តយ៉ាងអន់ចំពោះគោលនយោបាយ និងច្បាប់ដែលមានស្រាប់។[416] | ធនាគារពិភពលោក – "អំពើពុករលួយមានទូទៅ [...] ចំនួននៃប្រាក់ជំនួយទោភាគី និងពហុភាគី ត្រូវតែអាស្រ័យលក្ខខណ្ឌនៃកិច្ចការកែទម្រង់គ្រប់គ្រាន់របស់កម្ពុជា។"[417] | វេទិកា NGO "NGO គិតថា ផែនការ គោលនយោបាយ និងយុទ្ធសាស្ត្រចេះតែកើនឡើង។ បញ្ហានៅពេលនេះ គឺត្រូវបញ្ជាក់ថាផែនការទាំងនេះត្រូវបានអនុវត្ត [...] តើទាយកមានទំនុកចិត្តប៉ុណ្ណា ថាប្រាក់ត្រូវបានប្រើដោយប្រសិទ្ធិភាព ហើយមានហេតុប៉ះពាល់ដ៏វិជ្ជមាន លើការកែលំអជីវភាព ជំនួសការប្រើសម្រាប់ជំនួយបច្ចេកទេសដ៏មិនចាំបាច់ ការជំរុញអំពើពុករលួយ ហើយពង្រីកចន្លោះវិសមភាពស្គម?"[418] | - "ទោះបីរដ្ឋាភិបាលអាក់ខានបំពេញគោលដៅដែលដាក់ពីមុនក៏ដោយ ទាយកអន្តរជាតិសន្យាផ្ដល់ប្រាក់ US$៥០៤ លាន ទៅកម្ពុជាឆ្នាំក្រោយ ប៉ុន្តែព្រមានថា ជំនួយនាអនាគតត្រូវអាស្រ័យលើការផ្លាស់ប្ដូរពិតនៅក្នុងឆ្នាំ ២០០៥ [...] 'នេះជាការខ្ជប់សារឡើងវិញ នូវប្រព័ន្ធចាស់ ដែលមិនបានកើតផលពីមុន,' ប្រសាសន៍នៃអ្នកការទូតប្រចាំភ្នំពេញ ដែលចូលរួមក្នុងការប្រជុំ CG។"[419] | សុខ អាន – "ច្បាប់ [ប្រឆាំងអំពើពុករលួយ] នឹងដាក់ទៅសភាជាតិ និងព្រឹទ្ធសភា យ៉ាងបន្ទាន់។"[420]<br>ហ៊ុន សែន – 'ការកែទម្រង់ មិនមែនជាពាក្យដ៏រាក់ឡើយ។" [421] | US$៥០០ លាន[422] | US$៥៥៥,៤ លាន |
| '០៥ | គ្មានការប្រជុំ | | | | | | | US$៦១០ លាន |

# ប្រទេសជាតិលក់ – របៀបដែលពួកវរជនកម្ពុជា បានចាប់ក្ដាប់ឧស្សាហកម្មដកស្រង់ធនធានរបស់ប្រទេស

| ឆ្នាំ | ការកែទម្រង់ដែលបានយល់ព្រម | ការឈានទៅរកគោលដៅកែទម្រង់ | ការអធិប្បាយរបស់ទាយក | ការអធិប្បាយរបស់ NGO | ការអធិប្បាយរបស់ប្រព័ន្ធផ្សព្វផ្សាយ | ការអធិប្បាយរបស់រដ្ឋាភិបាលកម្ពុជា | ជំនួយដែលបានស្នើសុំដោយរដ្ឋាភិបាល | ជំនួយដែលបានផ្ដល់ឲ្យដោយទាយក[403] |
|---|---|---|---|---|---|---|---|---|
| '០៦ | បានដាក់នៅក្នុងឆ្នាំ ២០០៤[423]<br>**ការប្រឆាំងអំពើពុករលួយ**<br>- ៉ករណីនៃអំពើពុករលួយ ត្រូវយកទៅតុលាការ ដើម្បីស៊ើបអង្កេត និងធ្វើសវនាការ។៉<br>- ៉ច្បាប់ប្រឆាំងអំពើពុករលួយព្រាងបច្ចុប្បន្ន ត្រូវសម្របតាមក្បួនប្រតិបត្តិអន្តរជាតិដ៏ល្អបំផុត។៉<br>**សម្បទាន**<br>- ៉អនុវត្តមាត្រាទី ១៨ នៃច្បាប់ភូមិបាល ដែលថា ការលក់ដូរដីឯកជន លើដីរដ្ឋជាការខុសច្បាប់។៉<br>- ៉បង្កើនតម្លាភាពនៃការគ្រប់គ្រងធនធានធម្មជាតិដោយរដ្ឋ តាមរយៈការបញ្ចេញឲ្យដឹងជាសាធារណៈភ្លាម អំពីកិច្ចព្រមព្រៀងដែលមានស្រាប់ ហើយនិងស្ថានភាពស្របច្បាប់ (ថ្លៃឈ្នួល និងលក្ខខណ្ឌសំខាន់ឯទៀត) នៃកិច្ចព្រមព្រៀងសម្បទានដីសេដ្ឋកិច្ច សម្បទានរ៉ែ សម្បទាននេសាទត្រី និងការបញ្ចេញព័ត៌មានជាបន្ត អំពីស្ថានភាពនៃការពិនិត្យសម្បទានព្រៃឈើ។៉<br>- ៉RGC ត្រូវប្រាប់ទីតាំង ស្ថានភាពស្របច្បាប់ ហើយនិងដំណើរការសម្រាប់ការផ្ដាច់ នៃសម្បទានរ៉ែ ឃោជភូមិភាគ សម្បទានដីសេដ្ឋកិច្ច និងការរៀបចំអភិវឌ្ឍន៍ណាផ្សេងទៀត នៅក្នុងដីព្រៃឈើ ឬនៅក្នុងតំបន់ការពារ ហើយដែលមិនស្របនឹងច្បាប់ដែលគ្រប់គ្រងតំបន់ទាំងនោះ។៉<br>**ការបញ្ចេញព័ត៌មាន**<br>- ៉មន្ត្រីសាធារណៈត្រូវផ្លាស់ប្ដូរការអនុវត្តបច្ចុប្បន្ន ដោយបង្ហាញចិត្តត្រៀមជាស្រេច ដើម្បីចែកព័ត៌មានជាមួយសាធារណជនទូទៅ។៉ | - ច្បាប់ប្រឆាំងអំពើពុករលួយ មិនបានអនុម័តទេ។[424]<br>- ការបញ្ចេញព័ត៌មានខ្លះ អំពីសម្បទាន ប៉ុន្តែខ្វះព័ត៌មានលំអិត។[425]<br>- ការកាប់ឈើខុសច្បាប់ និងការចាប់យកដីខុសច្បាប់ បានបន្ត។[426] | អាល្លីម៉ង់ – "បញ្ហាដែលមិនទាន់ដោះស្រាយ នៃការចាប់យកដីធ្លី និងបរិកប្បដី គឺគួរឲ្យខ្វល់ខ្វាយណាស់ [...] យើងសង្ឃឹមថា ព័ត៌មានដែលបានផ្ដល់អំពីសម្បទានដីសេដ្ឋកិច្ច នឹងត្រូវបានតាមដានយ៉ាងលឿន ដោយការបញ្ចេញព័ត៌មានកាន់តែពេញលេញ។"[427] | សំបុត្ររបស់ NGO ទៅកាន់អ្នកចូលរួមការប្រជុំ CG – "មានការកើនឡើងនៃការប្រើធនធានធម្មជាតិ និងទ្រព្យសាធារណៈខុសឆ្គង ដោយគ្រួសារវរជន និងក្រុមហ៊ុនបក្សពួកនិយម។"[428] | - "សំណើ គឺសម្រាប់ US$៥១៣ លាន ប៉ុន្តែប្រាក់សន្យាផ្ដល់ គឺ US$៦០១ លាន" ប្រសាសន៍នៃរដ្ឋមន្ត្រីហិរញ្ញវត្ថុ គាត ឈន់។[429] [...] "ទាយកបានសរសើរសមិទ្ធផលនៅក្រោមអគ្គនាយករដ្ឋមន្ត្រី ហ៊ុន សែន។"[430] | ហ៊ុន សែន – "ច្បាប់ព្រាង នៃច្បាប់ប្រឆាំងអំពើពុករលួយ [...] កំពុងនៅក្នុងដំណាក់កាលចុងក្រោយនៃការពិចារណា នៅក្នុងរដ្ឋាភិបាល មុនវាចូលសភាជាតិ។"<br>- "ការកែទម្រង់មិនមែនជាពាក្យដ៏រាក់ឡើយ។"[431] | US$៥១៣ លាន | US$៧១៣, ២ លាន |

# ប្រទេសជាតិលក់ – របៀបដែលពួកវរជនកម្ពុជា បានចាប់ក្ដាប់ឧស្សាហកម្មដកស្រង់ធនធានរបស់ប្រទេស

| **ឆ្នាំ** | **ការកែទម្រង់ដែលបានយល់ព្រម** | **ការឈានទៅរក គោលដៅកែទម្រង់** | **ការអធិប្បាយរបស់ទាយក** | **ការអធិប្បាយរបស់ NGO** | **ការអធិប្បាយរបស់ប្រព័ន្ធផ្សព្វផ្សាយ** | **ការអធិប្បាយរបស់ រដ្ឋាភិបាលកម្ពុជា** | **ជំនួយដែលបាន ស្នើសុំដោយ រដ្ឋាភិបាល** | **ជំនួយដែល បានផ្ដល់ឲ្យ ដោយ ទាយក[403]** |
|---|---|---|---|---|---|---|---|---|
| '០៧ | បានដាក់នៅក្នុងឆ្នាំ ២០០៦[432]<br>**ការប្រឆាំងអំពើពុករលួយ**<br>- 'បង្កើយ ហើយអនុម័តច្បាប់ប្រឆាំងអំពើពុករលួយ សំអាងលើការអនុវត្តជាក្បួនប្រតិបត្តិអន្តរជាតិដ៏ល្អបំផុត។' ពេលកំណត់៖ ចុងខែមិថុនា ឆ្នាំ ២០០៦។<br>**សម្បទាន**<br>- 'បញ្ចេញព័ត៌មានជាទៀងទាត់ អំពីសម្បទានដីសេដ្ឋកិច្ច'។<br>- '[បញ្ចេញ] ព័ត៌មានគ្រប់វិស័យ អំពីសកម្មភាពនៃទីភ្នាក់ងាររដ្ឋាភិបាល រួមទាំងព័ត៌មានអំពីសម្បទានរ៉ែ និងឃោជកភូមិភាគ ក៏ដូចជាទាយក និង NGO ដោយបិទប្រកាសជាទៀងទាត់ លើគំបន់បណ្ដាញអ៊ិនធឺណិតនៃក្រុមការងារបច្ចេកទេស-ព្រៃឈើ និងបរិស្ថាន។' ពេលកំណត់៖ ចុងត្រីមាសទី ៤ ឆ្នាំ ២០០៦<br>- 'ពង្រឹងការអនុវត្តនៃច្បាប់ព្រៃឈើ ជាពិសេសការប្រឆាំងការកាប់រុករាន និងកាប់ព្រៃឈើ'<br>**ការបញ្ចេញព័ត៌មាន**<br>- 'បង្កើតក្របខណ្ឌគោលនយោបាយច្បាស់លាស់ អំពីការផ្ដល់ព័ត៌មាន'។ ពេលកំណត់៖ ខែធ្នូ ឆ្នាំ ២០០៦ | - ច្បាប់ប្រឆាំងអំពើពុករលួយ មិនបានអនុម័តទេ។[433]<br>- តម្លាភាពតិច ក្នុងការប្រគល់កិច្ចព្រមព្រៀង ELC។[434]<br>- ការគ្រប់គ្រងធនធានធម្មជាតិយ៉ាងអន់។[435] | អ្នកតំណាងធនាគារពិភពលោក – "យើងខ្វល់ខ្វាយណាស់ ថា លក្ខខណ្ឌនៃការដេញថ្លៃដោយតម្លាភាពលើកិច្ចព្រមព្រៀង ELC ត្រូវបានជៀសវាង។"[436] | ប្រធាននៃអង្គការសិទ្ធិមនុស្សខ្មែរ លីកាដូ – "ការប្រជុំនេះ បានក្លាយជាទម្លាប់។ យើងដឹងថា គ្មានអ្វីផ្លាស់ប្ដូរទេ។ រដ្ឋាភិបាលនឹងធ្វើការសន្យា – ការសន្យាដូចឆ្នាំមុនបេះបិត – ហើយក្រោយពីការប្រជុំចប់ហើយ អ្វីៗនៅតែដដែលជាបន្ត។"[437] | - "ខ្ញុំបារម្ភថា ប្រហែលពេលវេលាដើម្បីតឹងរឹងជាមួយរដ្ឋាភិបាលបានកន្លងហួសហើយ។" ប្រសាសន៍របស់ប្រភពមួយរូប មានបទពិសោធន៍ច្រើនជាមួយការប្រជុំរវាងទាយក និងរដ្ឋាភិបាល ដែលអ្នកនេះស្នើសុំឲ្យនៅអនាមិក។ "ខ្ញុំបារម្ភថា សហគមន៍ទាយកបានខកខានឱកាសរបស់គេហើយ។[...] មួយឆ្នាំទៀតហើយ ហើយច្បាប់ប្រឆាំងអំពើពុករលួយ នៅតែជាទម្រង់ព្រាង ការកែទម្រង់តុលាការឈានទៅមុខតាមល្បឿនយឺតយ៉ាវ ហើយការគ្រប់គ្រងធនធានធម្មជាតិដោយរដ្ឋាភិបាលត្រូវបានរិះគន់ពីគ្រប់ទិសទី។"[438] | ហ៊ុន សែន – "រាជរដ្ឋាភិបាលប្ដេជ្ញាដោយមិនស្ទាក់ស្ទើរ ដើម្បីប្រឆាំងអំពើពុករលួយ ដោយអនុវត្តកិច្ចការដាក់ស្ដែងជាច្រើន ដើម្បីសម្រេចកម្មវត្ថុ រួមទាំងការព្រាងច្បាប់ប្រឆាំងអំពើពុករលួយនេះឯង។"<br>- "ការកែទម្រង់ មិនមែនជាពាក្យដ៏រាក់ឡើយ។" [439] | US$៦៨៩ លាន[440] | US$៧៩០,៤ លាន |

## ការស្មុគស្មាញនៃភាពជាដៃគូ

អស់ច្រើនឆ្នាំនេះ ទាយករបស់ប្រទេសកម្ពុជា បានលើកការដោះសារជាច្រើនប្រការ អំពីការដែលខ្លួនមិនបានទាមទារជាដាច់ខាត ថា រដ្ឋាភិបាលអនុវត្តការកែទម្រង់ ដែលសមស្របនឹងប្រយោជន៍នៃប្រជាជនកម្ពុជាទេ។ ពេលថ្មីនេះ គេបានលើកហេតុផលថា ការតាំងគោលជំហរខ្លាំងជាងនេះ នឹងរុញប្រទេសកម្ពុជា កាន់តែជ្រៅទៅក្នុងហោប៉ៅរបស់ទាយកធំជាងគេរបស់គេ – គឺប្រទេសចិន។ ក៏ប៉ុន្តែការដែលទាយកបស្ចិមប្រទេសប៉ុនលើកមកប្រើការដោះសារនេះ គឺព្រងើយនឹងហេតុការណ៍ថា ប្រទេសចិន ទោះបីមានចិត្តទូលាយប៉ុណ្ណាក៏ដោយ មិនអាចផ្ដល់ឲ្យរដ្ឋាភិបាលកម្ពុជាភ នូវភាពគួរឲ្យគោរព នៅលើឆាកអន្តរជាតិ ដែលគេស្វែងរកនោះបានទេ។ តាមការពិត 'កត្តាប្រទេសចិន' បានក្លាយជាពាក្យនិយាយកាត់ ដើម្បីជៀសវាងការលើកមកនិយាយអំពីកត្តានយោបាយ និងកត្តាការិយាធិបតេយ្យមួយចំនួន ដែលទទួលអាទិភាពជាជាងសេចក្ដីត្រូវការដើម្បីកែលំអអភិបាលកិច្ច។

សេចក្ដីពិត គឺថា នៅពេលដែលភាពខ្លោចផ្សារ នៃរបបខ្មែរក្រហមចាប់ផ្ដើមរលុបចេញបន្តិចម្ដងៗ ពីគំនិតនៃពួកជើងសារអំណាច ប្រទេសកម្ពុជារអិលចុះកាន់តែទៀប នៅក្នុងតារាងវិបត្តិពិភពលោក។ អ្នកការទូតដែលត្រូវបានបញ្ជូនទៅភ្នំពេញ ដឹងថា គេនឹងមិនទទួលអំណរគុណពីមេរបស់ខ្លួនទេ បើគេធ្វើឲ្យឃ្លីឃ្លោងដល់ទូកនៃការទូត ហើយទាមទារពេលវេលានៃមេរបស់ខ្លួន នៅទីស្នាក់ការឯណោះ។ ម្យ៉ាងទៀត ប្រទេសកម្ពុជាមិនមែនជាប្រទេសមានអាទិភាពច្រើនជាងគេទេ សម្រាប់អ្នកការទូតជាច្រើននាក់ ដែលទទួលបន្ទុលលើអាស៊ីអាគ្នេយ៍ទាំងមូល – គឺជាតំបន់មានរដ្ឋដ៏មានសេចក្ដីត្រូវការជាច្រើន។ ប្រទេសកម្ពុជា ហើយនិងការវេទនាទុក្ខនៃប្រជាជនកម្ពុជា ជារឿយៗត្រូវបានដាក់យ៉ាងទៀប នៅក្នុងបញ្ជីកិច្ចការដែលមានអាទិភាព គឺស្ថិតពីក្រោមអំពើឃោរឃៅនៃរដ្ឋាភិបាលយោធារបស់ប្រទេសភូមា ហើយនិងគ្រោះធម្មជាតិដែលបានវាយលុកលើប្រទេសឥណ្ឌូណេស៊ី។

## សេចក្ដីសន្និដ្ឋាន

ដល់សព្វថ្ងៃនេះ ការពិភាក្សាជាច្រើន អំពីឧស្សាហកម្មដកស្រង់របស់ប្រទេសកម្ពុជា ដែលកំពុងតែលូតឡើង បានយកចិត្តទុកដាក់លើចំនួនប្រាក់ ដែលរដ្ឋនិងទទួល ដោយសារសកម្មភាពទាំងនេះ ហើយលើរបៀបដែលប្រាក់ទាំងអស់នេះ អាចជួយលើកប្រជាជនជំនាន់នេះឲ្យផុតពីភាពក្រីក្រ។ ក៏ប៉ុន្តែគំនិតទាំងនេះ អាស្រ័យលើការសន្និដ្ឋានដ៏ខុស ថាផលចំណូលដែលកើតមកពីអាជីវកម្មរ៉ែ ប្រេង និងឧស្ម័ន និងក្លាយទៅជាប្រាក់សម្រាប់ការអភិវឌ្ឍន៍ ជាស្វ័យប្រវត្តិ។ ការពិសោធន៍របស់ Global Witness ជាមួយការគ្រប់គ្រងធនធានធម្មជាតិ នៅក្នុងប្រទេសកម្ពុជា ហើយនៅកន្លែងផ្សេង បង្ហាញរូបភាពដ៏ខុសគ្នា។ នៅក្នុងប្រទេសមានធនធានធម្មជាតិដ៏សម្បូរជាច្រើន ដែល Global Witness ធ្លាប់ស្រាវជ្រាវ ការធ្វើអាជីវកម្មលើធនធានបានធ្វើឲ្យមានភាពក្រីក្រកាន់តែច្រើន មិនមែនកាន់តែតិចនោះឡើយ។ នៅក្នុងករណីទាំងអស់នេះ របៀបដែលសម្បទានត្រូវបានចែករំលែក ហើយរបៀបដែលសិទ្ធិប្រើធនធានត្រូវបានប្រគល់ នោះកំណត់និន្នាការនៃការគ្រប់គ្រងធនធាននោះឯង នាពេលអនាគត។

បទពិសោធន៍កន្លងមក ជាមួយវិស័យព្រៃឈើរបស់ប្រទេសកម្ពុជា មិនមែនជាបទពិសោធន៍ដ៏លើកទឹកចិត្តឡើយ។ ព្រៃឈើរបស់ប្រទេសជាតិ – ដែលធនាគារពិភពលោកធ្លាប់ហៅថា "ធនធានធម្មជាតិដ៏សំខាន់បំផុតសម្រាប់ដំណើរការអភិវឌ្ឍន៍" – ត្រូវបានបង្ខូចជាបន្តបន្ទាប់អស់មួយទសវត្សកន្លងមកនេះហើយ។ មានផលចំណូលតិចណាស់ មកពីការកាប់ឈើនេះ ចូលទៅក្នុងហិបរបស់រដ្ឋ។ ផ្ទុយទៅវិញ វាបានបង្កើនទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់ពួកវរជនដែលគ្រប់គ្រងប្រទេស ដែលបានលួចប្លន់ ហើយកាប់ព្រៃឈើ ដោយគ្មានការដាក់ទោសពៃរ៍សោះ។

វាមិនត្រូវការអ្នកជំនាញខាងអភិបាលកិច្ចឡើយ ដើម្បីយល់ឃើញថា សញ្ញាដំបូងនៃការគ្រប់គ្រងធនធានរ៉ែ និងប្រេងរបស់ប្រទេសកម្ពុជា គឺគួរបារម្ភយ៉ាងខ្លាំង។ រដ្ឋាភិបាលខ្វះឧបករណ៍ត្រឹមត្រូវ ដើម្បីដាក់កម្រិតលើការស្វែងរុករក និងការធ្វើអាជីវកម្មធនធាន ហើយក្នុងករណីខ្លះរដ្ឋាភិបាលបានធ្វើវិទ្ធង្សនាដោយចេតនា លើឧបករណ៍ដែលមានជាស្រេច។ ពួកជើងសារអំណាចដ៏ធំខ្ពស់ ដែលគ្រប់គ្រងរដ្ឋ បានលក់សម្បទានដ៏ធំ តាមរបៀបដែលខ្វះតម្លាភាព ហើយគួរឲ្យសង្ស័យខ្លាំងណាស់។ ភាពស្របច្បាប់ និងសមត្ថភាពនៃក្រុមហ៊ុនខ្លះ ដែលបាន

ទិញសម្បទានទាំងនេះ គឺមិនច្បាស់លាស់ឡើយ។ ទន្ទឹមនឹងពេលនេះ គ្រោះថ្នាក់ដល់បរិស្ថាន និងប្រជាជនដែលរស់នៅលើទឹកដី គឺធំណាស់។ គ្រប់លក្ខណៈ នៃរបៀបដែលសិទ្ធិប្រើធនធានទាំងនេះត្រូវបានចែករំលែក និងគ្រប់គ្រងពេលកន្លងមក គឺបង្ហាញឲ្យឃើញការពង្រឹងគំរូកន្លងមក នៃការធ្វើអាជីវកម្ម ដែលមានបំណងផ្ដល់ផលចំណេញទៅមន្ត្រី និងក្រុមហ៊ុន ជំនួសការបន្ថយភាពក្រីក្រនៃប្រជាជន។

ទោះជាយ៉ាងណាក៏ដោយ ស្ថានភាពមិនគួរឲ្យអស់សង្ឃឹមទេ។ ការដកស្រង់ធនធានទាំងនេះមិនទាន់ចាប់ផ្ដើមយ៉ាងពេញលេញទេ ហើយរហូតដល់ពេលនោះ មានឱកាសដ៏ខ្លីស្ដើងមួយ ដើម្បីកែតម្រូវបញ្ហានេះ។ ជំហានទីមួយ គឺត្រូវតែមានការព្យួរទុកបណ្ដោះអាសន្ន លើការប្រគល់សម្បទានថ្មី ការពិនិត្យគ្រប់សម្បទានដែលមានជាស្រេច ហើយនិងតម្លាភាពទាំងស្រុង ក្នុងការចែកចាយ និងការគ្រប់គ្រង នូវធនធានសាធារណៈទាំងនេះ។ ក៏ប៉ុន្តែការជួសជុលបច្ចេកាធិបតេយ្យ គ្រាន់តែជាដំណោះស្រាយមួយភាគប៉ុណ្ណោះ។ បញ្ហាដ៏ធំជាងគេ គឺជាការបង្កើតឆន្ទៈនយោបាយ ក្នុងចំណោមទាយកអន្តរជាតិរបស់ប្រទេសកម្ពុជា ដើម្បីប្រឈមមុខនឹងអ្នកដែលមានឫសយ៉ាងជ្រៅ ដែលកំពុងទទួលប្រយោជន៍ផ្ទាល់ខ្លួន ដោយសារស្ថានភាពបច្ចុប្បន្ន – គឺជាឆន្ទៈនយោបាយដែលបានខ្វះខាតយ៉ាងខ្លាំងកន្លងមក។

ការបរាជ័យដ៏ទៀងទាត់ ដោយទាយករបស់ប្រទេសកម្ពុជា ក្នុងការទាមទារការកែទម្រង់ខាងផ្នែកអភិបាលកិច្ច ជាលក្ខខណ្ឌដើម្បីទទួលការចែកប្រាក់ជំនួយ គ្រាន់តែបានពង្រឹងដល់ដំណើរការនៃការចាប់លួចធនធានរដ្ឋប៉ុណ្ណោះ។ ការខ្វះតម្លាភាពចំពោះព័ត៌មាន ដូចជាអ្នកណាជាម្ចាស់ក្រុមហ៊ុនទទួលភារកិច្ចដើម្បីគ្រប់គ្រងធនធានសាធារណៈ ហើយនិងទីដៅនៃការបង់ប្រាក់សម្រាប់សម្បទានទាំងនោះជាដើម គឺមានគោលបំណងតែមួយៈ ដើម្បីការពារ និងចាក់ឫសឲ្យកាន់តែជ្រៅ នៃអ្នកដែលទទួលប្រយោជន៍ពីការប្រតិបត្តិជាបន្តបន្ទាប់ទៀត នៃរដ្ឋស្រមោលរបស់ប្រទេសកម្ពុជា។

វាមិនទាន់ហួសពេលទេ ដើម្បីទាយកអន្តរជាតិរបស់ប្រទេសកម្ពុជា ផ្លាស់ប្ដូរលក្ខខណ្ឌនៃការចរចាជាមួយប្រទេសកម្ពុជាទេ ប៉ុន្តែវានឹងត្រូវការការផ្លាស់ប្ដូរគំនិតយ៉ាងធំ ដើម្បីមើលហួសពីសំដីដ៏អនាម័យ អំពីអភិបាលកិច្ចល្អ។ ខ្លឹមសារនៃការផ្លាស់ប្ដូរនេះ ត្រូវតែជាការទទួលស្គាល់ថា ការដកហូតធនធានរបស់ប្រទេសជាតិ សម្រាប់ប្រយោជន៍ផ្ទាល់ខ្លួន គឺជាការបំពានយ៉ាងធ្ងន់ធ្ងរ នូវសិទ្ធិខាងផ្នែកសង្គម និងខាងផ្នែកសេដ្ឋកិច្ច នៃប្រជាជនរបស់ប្រទេសជាតិ។

នេះគឺជាពេលវេលាដើម្បីសម្រេចចិត្ត ថាតើប្រជាជនកម្ពុជាអាចរួមចំណែកនៅក្នុងទ្រព្យធនធានធម្មជាតិរបស់ប្រទេសជាតិខ្លួនឯង ឬតើពួកវរជនចោរាធិបតេយ្យ នឹងរក្សាទុកសម្រាប់ខ្លួនឯងម្ដងទៀត នូវផលប្រយោជន៍នៃការលក់ប្រទេសជាតិ ឬទេ។ អក្សរកាត់

| | | |
|---|---|---|
| ADB | - | ធនាគារអភិវឌ្ឍន៍អាស៊ី |
| BPAMP | - | គម្រោងគ្រប់គ្រងជីវៈចំរុះ និងតំបន់ការពារធម្មជាតិ |
| CDC | - | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| CDCF | - | វេទិកាកិច្ចសហការអភិវឌ្ឍន៍កម្ពុជា |
| CG | - | ក្រុមពិគ្រោះ |
| CNPA | - | អាជ្ញាធរប្រេងកាតជាតិកម្ពុជា |
| CPP | - | គណបក្សប្រជាជនកម្ពុជា |
| EITI | - | គម្រោងជំរុញតម្លាភាពឧស្សាហកម្មដកស្រង់ |
| ELC | - | សម្បទានដីសេដ្ឋកិច្ច |
| ESIA | - | ដំណើរការវាយតម្លៃហេតុប៉ះពាល់សេដ្ឋកិច្ច និងសង្គម |
| FA | - | រដ្ឋបាលព្រៃឈើ |
| ហ.ត. | - | ហិកតារ |
| IMF | - | មូលនិធិរូបិយវត្ថុអន្តរជាតិ |

| | | |
|---|---|---|
| គ.ម. | - | គីឡូម៉ែត្រ |
| MAFF | - | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MIME | - | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល |
| MoE | - | ក្រសួងបរិស្ថាន |
| MoEF | - | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MP | - | កងអាវុធហត្ថ |
| NGO | - | អង្គការក្រៅរដ្ឋាភិបាល |
| NORAD | - | ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍ នៃប្រទេសន័រវ៉េស្ស |
| PSC | - | កិច្ចព្រមព្រៀងចែកចាយផលិតកម្ម |
| RCAF | - | កងយោធពលខេមរភូមិន្ទ |
| RGC | - | រាជរដ្ឋាភិបាលកម្ពុជា |
| SEZ | - | តំបន់សេដ្ឋកិច្ចពិសេស |
| SRP | - | គណបក្ស សម រង្ស៊ី |
| UN | - | អង្គការសហប្រជាជាតិ |
| UNDP | - | កម្មវិធីអភិវឌ្ឍន៍នៃអង្គការសហប្រជាជាតិ |
| UNOHCHR | - | ការិយាល័យអង្គការសហប្រជាជាតិ នៃអគ្គស្នងការសម្រាប់សិទ្ធិមនុស្ស |

---

[1] William Reno, 'Clandestine Economies, Violence and States in Africa,' Journal of International Affairs, លេខ ៥៣, ឆ្នាំ ២០០០។

[2] ដើម្បីជ្រាបដឹងបន្ថែមអំពី របៀបដែលធនធានប្រេង ឧស្ម័ន និងរ៉ែរបស់ប្រទេសកម្ពុជា អាចត្រូវបានខ្ជះខ្ជាយបាន សូមអានរបាយការណ៍កន្លងមក ស្តីពីការកាប់ព្រៃឈើខុសច្បាប់ នៅឯ www.globalwitness.org។

[3] Global Witness បានសរសេរសំបុត្រមួយទៅលោកឧត្តមសេនីយ៍ អ៊ុក កោសា នៅក្នុងខែវិច្ឆិកា ឆ្នាំ ២០០៨ ដើម្បីសុំការអធិប្បាយរបស់លោក អំពីរឿងរ៉ាវនៅក្នុងរបាយការណ៍នេះ ដែលពាក់ព័ន្ធ ឬទាក់ទងនឹងលោក។ នៅពេលបោះពុម្ពរបាយការណ៍នេះ Global Witness មិនបានទទួលចម្លើយទេ។

[4] Global Witness បានសរសេរសំបុត្រមួយទៅ លោក ចម បូរី នៅក្នុងខែតុលា ឆ្នាំ ២០០៨ ដើម្បីសុំការអធិប្បាយរបស់លោក អំពីរឿងរ៉ាវនៅក្នុងរបាយការណ៍នេះ ដែលពាក់ព័ន្ធ ឬទាក់ទងនឹងលោក។ នៅពេលបោះពុម្ពរបាយការណ៍នេះ Global Witness មិនបានទទួលចម្លើយទេ។

[5] Global Witness បានសរសេរសំបុត្រមួយទៅលោក ចម ប្រសិទ្ធ នៅក្នុងខែតុលា ឆ្នាំ ២០០៨ ដើម្បីសុំការអធិប្បាយរបស់លោក អំពីរឿងរ៉ាវនៅក្នុងរបាយការណ៍នេះ ដែលពាក់ព័ន្ធ ឬទាក់ទងនឹងលោក។ នៅពេលបោះពុម្ពរបាយការណ៍នេះ Global Witness មិនបានទទួលចម្លើយទេ។

[6] Global Witness បានសរសេរសំបុត្រមួយទៅលោក ឌី ចូច នៅក្នុងខែវិច្ឆិកា ឆ្នាំ ២០០៨ ដើម្បីសុំការអធិប្បាយរបស់លោក អំពីរឿងរ៉ាវនៅក្នុងរបាយការណ៍នេះ ដែលពាក់ព័ន្ធ ឬទាក់ទងនឹងលោក។ នៅពេលបោះពុម្ពរបាយការណ៍នេះ Global Witness មិនបានទទួលចម្លើយទេ។

[7] Global Witness បានសរសេរសំបុត្រមួយទៅឧត្តមសេនីយ៍ មាស សុភា នៅក្នុងខែតុលា ឆ្នាំ ២០០៨ ដើម្បីសុំការអធិប្បាយរបស់លោក អំពីរឿងរ៉ាវនៅក្នុងរបាយការណ៍នេះ ដែលពាក់ព័ន្ធ ឬទាក់ទងនឹងលោក។ នៅពេលបោះពុម្ពរបាយការណ៍នេះ Global Witness មិនបានទទួលចម្លើយទេ។

[8] Global Witness បានសរសេរសំបុត្រមួយទៅឯកឧត្តម លី យ៉ុងផាត់ នៅក្នុងខែវិច្ឆិកា ឆ្នាំ ២០០៨ ដើម្បីសុំការអធិប្បាយរបស់លោក អំពីរឿងរ៉ាវនៅក្នុងរបាយការណ៍នេះ ដែលពាក់ព័ន្ធ ឬទាក់ទងនឹងលោក។ នៅពេលបោះពុម្ពរបាយការណ៍នេះ Global Witness មិនបានទទួលចម្លើយទេ។

[9] Global Witness បានសរសេរសំបុត្រមួយទៅឯកឧត្តម ឱម យ៉ិនទៀង នៅក្នុងខែតុលា ឆ្នាំ ២០០៨ ដើម្បីសុំការអធិប្បាយរបស់លោក អំពីរឿងរ៉ាវនៅក្នុងរបាយការណ៍នេះ ដែលពាក់ព័ន្ធ ឬទាក់ទងនឹងលោក។ នៅពេលបោះពុម្ពរបាយការណ៍នេះ Global Witness មិនបានទទួលចម្លើយទេ។

[10] Global Witness បានសរសេរសំបុត្រមួយទៅឯកឧត្តម ឡៅ ម៉េងឃីន នៅក្នុងខែវិច្ឆិកា ឆ្នាំ ២០០៨ ដើម្បីសុំការអធិប្បាយរបស់លោក អំពីរឿងរ៉ាវនៅក្នុងរបាយការណ៍នេះ ដែលពាក់ព័ន្ធ ឬទាក់ទងនឹងលោក។ នៅពេលបោះពុម្ពរបាយការណ៍នេះ Global Witness មិនបានទទួលចម្លើយទេ។

[11] Global Witness បានសរសេរសំបុត្រមួយទៅឧត្តមសេនីយ៍ ប៉ុល សារឿន នៅក្នុងខែតុលា ឆ្នាំ ២០០៨ ដើម្បីសុំការអធិប្បាយរបស់លោក អំពីរឿងរ៉ាវនៅក្នុងរបាយការណ៍នេះ ដែលពាក់ព័ន្ធ ឬទាក់ទងនឹងលោក។ នៅពេលបោះពុម្ពរបាយការណ៍នេះ Global Witness មិនបានទទួលចម្លើយទេ។

[12] Global Witness បានសរសេរសំបុត្រមួយទៅ ក្រុម ទ្រី ភាព នៅក្នុងខែវិច្ឆិកា ឆ្នាំ ២០០៨ ដើម្បីសុំការអធិប្បាយរបស់ក្រុមហ៊ុន អំពីរឿងរ៉ាវនៅក្នុងរបាយការណ៍នេះ ដែលពាក់ព័ន្ធ ឬទាក់ទងនឹងក្រុមហ៊ុននោះ។ នៅពេលបោះពុម្ពរបាយការណ៍នេះ Global Witness មិនបានទទួលចម្លើយទេ។

[13] Global Witness បានសរសេរសំបុត្រមួយទៅអគ្គនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅក្នុងខែតុលា ឆ្នាំ ២០០៨ ដើម្បីសុំការអធិប្បាយរបស់សម្តេច អំពីរឿងរ៉ាវនៅក្នុងរបាយការណ៍នេះ ដែលពាក់ព័ន្ធ ឬទាក់ទងនឹងសម្តេច។ នៅពេលបោះពុម្ពរបាយការណ៍នេះ Global Witness មិនបានទទួលចម្លើយទេ។

[14] Global Witness បានសរសេរសំបុត្រមួយទៅសម្តេច ជា ស៊ីម នៅក្នុងខែវិច្ឆិកា ឆ្នាំ ២០០៨ ដើម្បីសុំការអធិប្បាយរបស់សម្តេច អំពីរឿងរ៉ាវនៅក្នុងរបាយការណ៍នេះ ដែលពាក់ព័ន្ធ ឬទាក់ទងនឹងសម្តេច។ នៅពេលបោះពុម្ពរបាយការណ៍នេះ Global Witness មិនបានទទួលចម្លើយទេ។

[15] Global Witness បានសរសេរសំបុត្រពីរ ទៅលោក តែ ដួងតារា នៅក្នុងខែតុលា ឆ្នាំ ២០០៨ ដើម្បីសុំការអធិប្បាយរបស់លោក អំពីរឿងរ៉ាវនៅក្នុងរបាយការណ៍នេះ ដែលពាក់ព័ន្ធ ឬទាក់ទងនឹងលោក។ នៅពេលបោះពុម្ពរបាយការណ៍នេះ Global Witness មិនបានទទួលចម្លើយទេ។

[16] Global Witness បានសរសេរសំបុត្រមួយទៅ លោកបណ្ឌិត ធិន លិប គឹង នៅក្នុងខែតុលា ឆ្នាំ ២០០៨ ដើម្បីសុំការអធិប្បាយរបស់លោកបណ្ឌិត អំពីរឿងរ៉ាវនៅក្នុងរបាយការណ៍នេះ ដែលពាក់ព័ន្ធ ឬទាក់ទងនឹងលោកបណ្ឌិត ហើយបានទទួលចម្លើយ។ ដើម្បីមើលព័ត៌មានថែមអំពីចម្លើយនេះ សូមមើលទំព័រ ##។

